

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក
# ឆដ្ឋភាគ
# ២៥



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## MAJJHIMANIKĀYA

## MAJJHIMAPAṆṆĀSAKA

## CHAṬṬHABHĀGA

## 25

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះគឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្ល** ក្នុងពាក្យនេះ ព្យញ្ជនៈ ល គឺជាជើងរបស់ព្យញ្ជនៈ ម ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សង្កឹកាច្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## មជ្ឈិមនិកាយ   មជ្ឈិមបណ្ណាសកៈ

## ឆដ្ឋភាគ

## ២៥

## ព.ស. ២៥០៤

# ព្រាហ្មណវគ្គោ

## បឋមំ ព្រហ្មាយុសុត្តំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វិទេហេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ តេន ខោ បន សមយេន ព្រហ្មាយុ ព្រាហ្មណោ មិថិលាយំ បដិវសតិ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ វីសវស្សសតិកោ ជាតិយា តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាស-បញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហា-បុរិសលក្ខណេសុ អនវយោ ។ អស្សោសិ ខោ ព្រហ្មាយុ ព្រាហ្មណោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ វិទេហេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិ-សទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ

# ព្រាហ្មណវគ្គ

## ព្រហ្មាយុសូត្រ ទី ១

[១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនវិទេហៈ ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូប ។ សម័យនោះឯង ព្រហ្មាយុព្រាហ្មណ៍នៅអាស្រ័យ ក្នុងនគរមិថិលា ជាមនុស្សជរា ព្រឹទ្ធា ចាស់កន្លងកាលវែងឆ្ងាយ មកដល់បច្ឆិមវ័យហើយ មានអាយុ ១២០ ឆ្នាំ អំពីកំណើត ជាអ្នកចេះចប់នូវត្រៃវេទ ព្រមទាំងគម្ពីរឈ្មោះនិឃណ្ដុ និងគម្ពីរឈ្មោះកេដុភៈ ព្រមទាំងអក្ខរប្បភេទ មានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥ ជាអ្នកដឹងនូវបទនៃវេទ ជាអ្នកដឹងនូវវេយ្យាករណ៍ ជាអ្នកមិនទើសទាល់ក្នុងគម្ពីរលោកាយតៈ និងគម្ពីរមហាបុរិសលក្ខណៈ ។ ព្រហ្មាយុព្រាហ្មណ៍ បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ឥឡូវស្តេចមកកាន់ចារិកក្នុងដែនវិទេហៈ ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូប ឯកិត្តិសព្ទល្អនៃព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយសុសសាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង

វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា[១] សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

[២] តេន ខោ បន សមយេន ព្រហ្មាយុស្ស ព្រាហ្មណស្ស ឧត្តរោ នាម មាណវោ អន្តេវាសី ហោតិ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ ។

១ ម. ភគវាតិ ។

ដោយប្រពៃ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាសាស្តានៃទេវតានិងមនុស្ស ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់ត្រៃភពទៀតហើយ ព្រះមានព្រះភាគអង្គនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមរបស់ព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះមានព្រះភាគអង្គនោះ ទ្រង់សំដែងធម៌ មានលំអខាងដើម មានលំអកណ្តាល មានលំអខាងចុង បរិបូណ៌ដោយអត្ថ បរិបូណ៌ដោយព្យញ្ជនៈ ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ក៏ការបានចួបព្រះអរហន្តដែលមានសភាពដូច្នោះ ជាការប្រពៃពេកណាស់ ។

[២] សម័យនោះឯង ព្រហ្មាយុព្រាហ្មណ៍ មានកូនសិស្សម្នាក់ឈ្មោះឧត្តរមាណព ជាអ្នកចេះចប់នូវត្រៃវេទ ព្រមទាំងគម្ពីរឈ្មោះនិឃណ្ឌុ និងគម្ពីរឈ្មោះកេដុភៈ ព្រមទាំងអក្ខរប្បភេទ មានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥ ជាអ្នកដឹងនូវបទនៃវេទ ជាអ្នកដឹងនូវវេយ្យាករណ៍ ជាអ្នកមិនទើសទាល់ក្នុងគម្ពីរលោកាយតៈ និងគម្ពីរមហាបុរិសលក្ខណៈ ។

៣

## ព្រាហ្មណវគ្គស្ស ព្រហ្មាយុសុត្តេ ឧត្តរាមន្តនំ

អថខោ ព្រហ្មាយុ ព្រាហ្មណោ ឧត្តរំ មាណវំ អាមន្តេសិ អយំ តាត ឧត្តរ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ វិទេហេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុ-សតេហិ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ឯហិ ត្វំ តាត ឧត្តរ យេន សមណោ គោតមោ តេនុបសង្កម ឧបសង្កមិត្វា សមណំ គោតមំ ជានាហិ យទិ វា តំ ភវន្តំ គោតមំ តថា សន្តំយេវ សទ្ទោ អព្ភុគ្គតោ យទិ វា នោ តថា យទិ វា សោ ភវំ គោតមោ តាទិសោ យទិ វា ន តាទិសោ តយា មយំ តំ ភវន្តំ គោតមំ ទេសិស្សាមាតិ[១] ។ យថាកថំ បនាហំ ភោ ភវន្តំ តំ គោតមំ ជានិស្សាមិ

១ ឱ. ម. វេទិស្សាមាតិ ។

គ្រានោះ ព្រហ្មាយុព្រាហ្មណ៍ ហៅឧត្តរមាណពមកថា នែបាឧត្តរៈ ព្រះសមណគោតមនេះ ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ឥឡូវស្តេចមកកាន់ចារិក ក្នុងដែនវិទេហៈ ជាមួយនឹងភិក្ខុសង្ឃច្រើន គឺភិក្ខុប្រមាណ ៥០០ រូប ឯកិត្តិសព្ទល្អ នៃព្រះសមណគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយ សុសសាយទៅ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ។ បេ ។ ក៏ការបានចួបប្រទះនូវព្រះអរហន្ត មានសភាពដូច្នោះ ជាការប្រពៃពេកណាស់ នែបាឧត្តរៈ អ្នកចូរមក ចូរអ្នកចូលទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរដឹងនូវព្រះសមណគោតមថា កិត្តិសព្ទនៃព្រះសមណគោតម ដ៏ចម្រើននោះ ខ្ចរ-ខ្ចាយសុសសាយទៅ មានដោយប្រការដូច្នោះមែនឬ ឬថាមិនមែនដោយប្រការដូច្នោះទេ មួយទៀត ព្រះគោតមដ៏ចម្រើននោះ ជាបុគ្គលប្រាកដដូច្នោះមែនឬ ឬថាមិនមែនជាបុគ្គលប្រាកដដូច្នោះទេ យើងនឹងប្រើអ្នក ឲ្យទៅមើលព្រះគោតមដ៏ចម្រើននោះ ។ ឧត្តរមាណពពោលថា បពិត្រលោកដ៏ចម្រើន ចុះធ្វើម្តេចខ្ញុំនឹងស្គាល់នូវព្រះគោតមដ៏ចម្រើននោះថា

យទិ វា តំ ភវន្តំ គោតមំ តថា សន្តំយេវ សទ្ទោ អព្ភុគ្គតោ យទិ វា នោ តថា យទិ វា សោ ភវំ គោតមោ តាទិសោ យទិ វា ន តាទិសោតិ ។ អាគតានិ ខោ តាត ឧត្តរ អម្ហាកំ មន្តេសុ ទ្វត្តឹស មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហា-បុរិសស្ស ទ្វេវ[១] គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្ត រតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន[២] អភិវិជិយ អជ្ឈាវសតិ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ

---

១ ម. ទ្វេយេវ ។ ២ ម. ឯត្ថន្តរេ សមេនាតិ ទិស្សតិ ។

កិត្តិសព្ទនៃព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយសុសសាយទៅ មានដោយប្រការដូច្នោះមែនឬ ឬថាមិនមែនដោយប្រការដូច្នោះទេ មួយទៀត ព្រះគោតមដ៏ចម្រើននោះ ជាបុគ្គលប្រាកដដូច្នោះឬ ឬថាមិនមែនជាបុគ្គលប្រាកដដូច្នោះទេ ។ ព្រហ្មាយុព្រាហ្មណ៍ពោលថា នែបាឧត្តរៈ មហាបុរសប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ដែលមានមក ក្នុងមន្តវេទរបស់យើង រមែងមានតែគតិ ២ យ៉ាងប៉ុណ្ណោះ មិនមែនខុសអំពីគតិ ២ យ៉ាងនោះទេ គឺថាបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិជាធម្មរាជប្រកបដោយធម៌ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត ឈ្នះអស់សត្រូវទាំងខាងក្នុង ខាងក្រៅ[១] ដល់នូវការមាំមួនក្នុងជនបទ ប្រកបដោយកែវទាំង ៧ ប្រការ ឯកែវទាំង ៧ ប្រការនេះរបស់ស្តេចចក្រពត្តិនោះគឺ ចក្រកែវ ១ ដំរីកែវ ១ សេះកែវ ១ មណិកែវ ១ ស្រីកែវ ១ គហបតីកែវ ១ បរិនាយកកែវ ១ ជាគម្រប់ ៧ មួយទៀត ព្រះរាជានោះមានព្រះរាជបុត្រច្រើនជាងពាន់ ជាអ្នកក្លៀវក្លា មានសភាពអង់អាចអាចញាំញីនូវសេនានៃស្តេចដទៃបាន ព្រះរាជានោះមានជ័យជម្នះ នៅគ្រប់គ្រងផែនដីនេះមានសាគរជាទីបំផុត ប្រកបដោយធម៌ មិនមានគ្រឿងវាយដំ មិនមានគ្រឿងកាប់ចាក់ បើចេញចាកផ្ទះចូលទៅកាន់ផ្នួសវិញ

១ សត្រូវខាងក្នុងមានសេចក្តីក្រោធជាដើម សត្រូវខាងក្រៅមានស្តេចដទៃជាដើម ។

អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ អហំ ខោ បន តាត ឧត្តរ មន្តានំ កត្តា[១] ត្វំ មន្តានំ បដិគ្គហេតាតិ ។

[៣] ឯវំ ភោតិ ខោ ឧត្តរោ មាណវោ ព្រហ្មាយុស្ស ព្រាហ្មណស្ស បដិស្សុត្វា ឧដ្ឋាយា-សនា ព្រហ្មាយុំ ព្រាហ្មណំ អភិវាទេត្វា បទក្ខិណំ កត្វា វិទេហេសុ យេន ភគវា តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកញ្ចរមានោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧត្តរោ មាណវោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ សមន្នេសិ ។ អទ្ទសា ខោ ឧត្តរោ មាណវោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ

១ ឱ. ម. ទាតា ។

នឹងបានជាអរហន្តសម្មាសម្ពុទ្ធ បានបើកនូវដំបូល[១] គឺកិលេស ក្នុងលោកហើយ នែបាឧត្តរៈ ចំណែកខាងខ្ញុំជាអ្នកតាក់តែងមន្ត អ្នកឯងជាអ្នកទទួលយកមន្តទៅ (សម្រាប់ផ្ទៀបមើល) ។

[៣] ឧត្តរមាណព ទទួលស្តាប់ពាក្យរបស់ព្រហ្មាយុព្រាហ្មណ៍ថា បាទ លោកដ៏ចម្រើន ហើយក្រោកចាកអាសនៈ សំពះព្រហ្មាយុព្រាហ្មណ៍ ធ្វើប្រទក្សិណហើយចេញទៅកាន់ចារិក សំដៅទៅត្រង់ទីដែលព្រះមានព្រះភាគគង់នៅ ក្នុងដែនវិទេហៈ ក៏ត្រេចទៅកាន់ចារិក ដោយលំដាប់ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ ឧត្តរមាណព លុះអង្គុយក្នុងទីសមគួររួចហើយ ក៏ពិនិត្យមើលនូវមហាបុរិសលក្ខណៈទាំង ៣២ ក្នុងព្រះកាយនៃព្រះមានព្រះភាគ ។ លុះឧត្តរមាណព បានឃើញមហាបុរិសលក្ខណៈទាំង ៣២ ក្នុងព្រះកាយនៃព្រះមានព្រះភាគដោយច្រើន វៀរលែងតែមហាបុរិសលក្ខណៈ ២ ប្រការ

---

១ រាគៈ ១ ទោសៈ ១ មោហៈ ១ មានះ ១ ទិដ្ឋិ ១ អវិជ្ជា ១ ទុច្ចរិត ១ ធម៌ទាំង ៧ ប្រការនេះ ទុកដូចជាដំបូលជាគ្រឿងបិទបាំងសត្វ មិនឲ្យឃើញព្រះនិព្វាន ។

កង្ខតិ វិចិកិច្ឆតិ ជាធិមុច្ចតិ ន សំបសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហុតជិវ្ហតាយ ច ។

[៤] អថខោ ភគវតោ ឯតទហោសិ បស្សតិ ខោ មេ អយំ ឧត្តរោ មាណវោ ទ្វត្តឹស មហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ ជាធិមុច្ចតិ ន សំបសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហុតជិវ្ហតាយ ចាតិ ។ អថខោ ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ យថា អទ្ទស ឧត្តរោ មាណវោ ភគវតោ កោសោហិតំ វត្ថគុយ្ហំ ។ អថខោ ភគវា ជិវ្ហំ និន្នាមេត្វា ឧភោបិ កណ្ណសោតានិ អនុមសិ បដិមសិ ឧភោបិ នាសិកសោតានិ អនុមសិ បដិមសិ កេវលកប្បំ[១] នលាដមណ្ឌលំ ជិវ្ហាយ ឆាទេសិ[២] ។

---

១ ឱ. កេវលកម្បិ ។ ២ ឱ. បច្ឆាទេសីតិ ទិស្សតិ ។

ក៏សង្ស័យ ងឿងឆ្ងល់ មិនចូលចិត្ត មិនជ្រះស្រឡះ ក្នុងមហាបុរិសលក្ខណៈទាំង ២ ប្រការនោះ គឺអវយវៈដែលត្រូវលាក់ក្នុងសំពត់ បិតនៅក្នុងស្រោម ១ ព្រះជិវ្ហាដ៏ល្មម ១ ។

[៤] គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះដូច្នេះថា ឧត្តរមាណពនេះ បានឃើញនូវមហាបុរិសលក្ខណៈទាំង ៣២ របស់តថាគតដោយច្រើន វៀរលែងតែមហាបុរិសលក្ខណៈ ២ ប្រការ ក៏សង្ស័យ ងឿងឆ្ងល់ មិនចូលចិត្ត មិនជ្រះស្រឡះ ក្នុងមហាបុរិសលក្ខណៈទាំង ២ ប្រការនោះ គឺអវយវៈដែលត្រូវលាក់ក្នុងសំពត់ បិតនៅក្នុងស្រោម ១ ព្រះជិវ្ហាដ៏ល្មម ១ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់តាក់តែងនូវឥទ្ធាភិសង្ខារ ឲ្យឧត្តរមាណពបានឃើញអវយវៈ របស់ព្រះអង្គ ដែលត្រូវលាក់ក្នុងសំពត់ បិតនៅក្នុងស្រោម ។ តមកទៀត ព្រះមានព្រះភាគទ្រង់លៀននូវព្រះជិវ្ហា ប៉ះពាល់ដល់រន្ធព្រះកាណ៌ទាំង ២ ផង ប៉ះពាល់ដល់រន្ធព្រះនាសិកទាំង ២ ផង ហើយទ្រង់យកព្រះជិវ្ហា បាំងមណ្ឌលនៃព្រះនលាដទាំងអស់ ។

ព្រាហ្មណវគ្គស្ស ព្រហ្មាយុសុត្តេ ភគវន្តានុពន្ធនំ

[៤] អថខោ ឧត្តរស្ស មាណវស្ស ឯតទហោសិ សមន្នាគតោ ខោ សមណោ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ យន្នូនាហំ សមណំ គោតមំ អនុពន្ធេយ្យំ ឥរិយាបថមស្ស បស្សេយ្យន្តិ ។ អថខោ ឧត្តរោ មាណវោ សត្ត មាសានិ ភគវន្តំ អនុពន្ធិ ឆាយាវ អនុចាយិនី ។ អថខោ ឧត្តរោ មាណវោ សត្តន្នំ មាសានំ អច្ចយេន វិទេហេសុ យេន មិថិលា តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន មិថិលា យេន ព្រហ្មាយុ ព្រាហ្មណោ តេនុបសង្កមិ ឧបសង្កមិត្វា ព្រហ្មាយុំ ព្រាហ្មណំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ឧត្តរំ មាណវំ ព្រហ្មាយុ ព្រាហ្មណោ ឯតទវោច កច្ចិ តាត ឧត្តរ តំ ភវន្តំ គោតមំ តថា សន្តំយេវ សទ្ទោ អព្ភុគ្គតោ នោ អញ្ញថា កច្ចិ បន សោ ភវំ គោតមោ តាទិសោ នោ អញ្ញាទិសោតិ ។

ព្រាហ្មណវគ្គ ព្រហ្មាយុសូត្រ អំពីការដើរជាប់តាមព្រះមានព្រះភាគ

[៥] គ្រានោះ ឧត្តរមាណព មានសេចក្តីត្រិះរិះដូច្នេះថា សមណគោតម ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ពិត បើដូច្នោះ មានតែអាត្មាអញដើរតាម នូវព្រះសមណគោតម នឹងបានឃើញឥរិយាបថរបស់ព្រះអង្គ ។ ឯឧត្តរមាណពក៏ជាប់តាមព្រះមានព្រះភាគ អស់ ៧ ខែ ប្រៀបដូចជាស្រមោលជាប់តាមរូប ។ លុះកន្លងខែ ៧ ទៅហើយ ទើបឧត្តរមាណពចេញទៅកាន់ចារិក សំដៅទៅត្រង់នគរមិថិលាក្នុងដែននៃពួកអ្នកវិទេហៈ ក៏ត្រេចទៅកាន់ចារិកដោយលំដាប់ ហើយចូលទៅរកព្រហ្មាយុព្រាហ្មណ៍ ឯនគរមិថិលា លុះចូលទៅដល់ហើយ ក៏សំពះព្រហ្មាយុព្រាហ្មណ៍ រួចអង្គុយក្នុងទីសមគួរ ។ លុះឧត្តរមាណពអង្គុយក្នុងទីសមគួរហើយ ព្រហ្មាយុព្រាហ្មណ៍ សួរដូច្នេះថា នែបាឧត្តរៈ ឯកិត្តិសព្ទ នៃព្រះគោតមដ៏ចម្រើននោះ ឮខ្ចរខ្ចាយសុសសាយទៅ មានប្រការដូច្នោះ មិនខុសពិតមែនឬ មួយទៀត ព្រះគោតមដ៏ចម្រើននោះ ជាបុគ្គលប្រាកដដូច្នោះ មិនមែនជាបុគ្គលប្រាកដ ដោយប្រការដទៃពិតមែនឬ ។

[៦] យថា[១] សន្តំយេវ ភោ តំ ភវន្តំ គោតមំ តថា[១] សទ្ទោ អព្ភុគ្គតោ នោ អញ្ញថា តាទិសោ ច ខោ សោ ភវំ គោតមោ នោ អញ្ញាទិសោ សមន្នាគតោ ច ភោ សោ ភវំ គោតមោ ទ្វត្តឹស-មហាបុរិសលក្ខណេហិ សុប្បតិដ្ឋិតចាទោ ខោ បន សោ ភវំ គោតមោ ឥទម្បិ តស្ស ភោតោ គោត-មស្ស មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ហេដ្ឋា ខោ បន តស្ស ភោតោ គោតមស្ស ចាទ-តលេសុ ចក្កានិ ជាតានិ សហស្សារានិ សនេ-មិកានិ សនាភិកានិ សព្វាការបរិបូរានិ ។ អា-យតបណ្ហិ ខោ បន សោ ភវំ គោតមោ ទី-ឃង្គុលី ខោ បន សោ ភវំ គោតមោ មុទុតលុ-ណហត្ថចាទោ ខោ បន សោ ភវំ គោតមោ ជាលហត្ថចាទោ ខោ បន សោ ភវំ គោតមោ ឧស្សង្ខចាទោ ខោ បន សោ ភវំ គោតមោ ឯណិជង្ឃោ ខោ បន សោ ភវំ គោតមោ

១ ឱ. ម. តថា ។ ២ ម. តថាសទ្ទោ ន ទិស្សតិ ។

[៦] ឧត្តរមាណពតបថា បពិត្រលោកដ៏ចម្រើន កិត្តិសព្ទនៃព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយសុសសាយទៅមានប្រការដូច្នោះ មិនខុសទេ មួយទៀត ព្រះគោតមដ៏ចម្រើននោះ ជាបុគ្គលប្រាកដដូច្នោះពិត មិនមែនជាបុគ្គលប្រាកដដោយប្រការដទៃទេ បពិត្រលោកដ៏ចម្រើន ឯព្រះគោតមដ៏ចម្រើននោះឯង ប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ គឺព្រះគោតមដ៏ចម្រើននោះ មានព្រះបាទាប្រតិស្ឋានលើផែនដីស៊ប់ល្អ នេះជាមហាបុរិសលក្ខណៈនៃមហាបុរសរបស់ព្រះគោតមដ៏ចម្រើននោះ ១ ព្រះគោតមដ៏ចម្រើននោះ មានកង់ចក្រកើតនៅត្រង់ផ្ទៃនៃព្រះបាទខាងក្រោម មានកាំ ១.០០០ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ ដ៏បរិបូណ៌ដោយអាការទាំងពួង ១ ។ ព្រះគោតមដ៏ចម្រើននោះ មានព្រះបណ្ហិ (កែងជើង) វែង ១ ព្រះគោតមដ៏ចម្រើននោះ មានម្រាមព្រះហស្ត និងម្រាមព្រះបាទវែង ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះហស្តនិងព្រះបាទទន់ខ្ចី ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះហស្តនិងព្រះបាទដូចជាសំណាញ់ ១ ព្រះគោតមដ៏ចម្រើននោះ មានកព្រះបាទដូចជាអណ្តែតឡើង ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះជង្ឃាដូចជាស្មងនៃសត្វទ្រាយ ១ ព្រះគោតមដ៏ចម្រើននោះ

ឋិតកោ ខោ បន សោ ភវំ គោតមោ អនោនមន្តោ ឧភោហិ បាណិតលេហិ ជន្នុកានិ បរិមសតិ បរិមជ្ជតិ កោសោហិតវត្ថគុយ្ហោ ខោ បន សោ ភវំ គោតមោ សុវណ្ណវណ្ណោ ខោ បន សោ ភវំ គោតមោ កាញ្ចនសន្និភត្តចោ សុខុមច្ឆវី ខោ បន សោ ភវំ គោតមោ សុខុមត្តា ឆវិយា រជោជល្លំ កាយេន ឧបលិម្បតិ ឯកេកលោមោ ខោ បន សោ ភវំ គោតមោ ឯកេកានិ លោមានិ លោមកូបេសុ ជា-តានិ ឧទ្ធគ្គលោមោ ខោ បន សោ ភវំ គោតមោ ឧទ្ធគ្គានិ លោមានិ ជាតានិ នីលានិ អញ្ជនវណ្ណានិ កុណ្ឌលាវដ្ដានិ បទក្ខិណាវដ្ដកជាតានិ ព្រហ្មុជុគត្តោ ខោ បន សោ ភវំ គោតមោ សត្តុស្សទោ ខោ បន សោ ភវំ គោតមោ[១] សីហបុព្វឌ្ឍកាយោ ខោ បន សោ ភវំ គោតមោ ចិតន្តរំសោ ខោ បន

១ ឱ. សត្តុស្សទោ បន សោ ភវំ គោតមោតិ ន ទិស្សន្តិ ។

បើទ្រង់ឈរជាប្រក្រតី មិនបានឱនចុះ ហើយយកផ្ទៃព្រះហស្តទាំងពីរ ស្ទាបពាល់នូវព្រះជានុបាន ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះអវយវៈដែលត្រូវលាក់ក្នុងសំពត់បិតនៅក្នុងស្រោម ១ ព្រះគោតមដ៏ចម្រើននោះ មានសម្បុរព្រះកាយល្អដូចជាសម្បុរនៃមាស មានព្រះតចៈភ្លឺ ប្រហែលដោយមាស ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះឆវីល្អិតម៉ត់ ព្រោះព្រះឆវីល្អិតម៉ត់ (នោះ) ទើបធូលីនិងក្អែលមិនបានជិតជាប់ព្រះកាយឡើយ ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះរោមតែមួយ ៗ គឺព្រះរោមទាំងឡាយតែមួយសរសៃ ៗ ដុះឡើងក្នុងរណ្ដៅនៃរោមទាំងឡាយ ១ ព្រះគោតមដ៏ចម្រើននោះ មានចុងព្រះរោមកួចឡើងលើ គឺព្រះរោមទាំងឡាយមានចុងងើង មានពណ៌ខៀវដូចជាពណ៌នៃផ្កាអញ្ជ័ន វិលទៅខាងស្ដាំដូចជាវង្វង់នៃកុណ្ឌល ១ ព្រះគោតមដ៏ចម្រើននោះ មានជង្គព្រះអង្គត្រង់ដូចជាកាយមហាព្រហ្ម ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះមំសៈដ៏ពេញកំពុងល្អ ក្នុងសរីរៈប្រទេស ៧ អន្លើ (ត្រង់ខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទាទាំងពីរ ចង្កួយស្មាទាំងពីរ និងព្រះសុរង) ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះកាយដូចជាកាយពាក់កណ្ដាលខាងមុខ នៃសត្វសីហៈ ១ ព្រះគោតមដ៏ចម្រើននោះ មានចន្លោះព្រះអង្សា[១]ពេញស្មើល្អ ១

---

១ អដ្ឋកថា ថា សាច់ជាចន្លោះនៃស្លាបប្រជៀវទាំងពីរ ។

សោ ភវំ គោតមោ និគ្រោធបរិមណ្ឌលោ ខោ បន សោ ភវំ គោតមោ យាវតក្វស្ស កាយោ តាវត-ក្វស្ស ព្យាមោ យាវតក្វស្ស ព្យាមោ តាវតក្វស្ស កាយោ ។ សមវដ្ដក្ខន្ធោ ខោ បន សោ ភវំ គោតមោ រសគ្គសគ្គី[១] ខោ បន សោ ភវំ គោត-មោ សីហហនុ ខោ បន សោ ភវំ គោតមោ ចត្តាឡីសទន្តោ ខោ បន សោ ភវំ គោតមោ សម-ទន្តោ ខោ បន សោ ភវំ គោតមោ អវិរឡទន្តោ[២] ខោ បន សោ ភវំ គោតមោ សុសុក្កទាឋោ ខោ បន សោ ភវំ គោតមោ បហុតជិវ្ហោ ខោ បន សោ ភវំ គោតមោ ព្រហ្មស្សរោ ខោ បន សោ ភវំ គោតមោ ករវិកភាណី អភិនីលនេត្តោ ខោ បន សោ ភវំ គោតមោ គោបខុមោ ខោ បន សោ ភវំ គោតមោ ឧណ្ណា ខោ បនស្ស ភោតោ គោតមស្ស ភមុកន្តរេ ជាតា

---
១ ឱ. ម. រសគ្គសគ្គី ។ ២ ឱ. អវិវរទន្តោ ។

ព្រះគោតមដ៏ចម្រើននោះ មានបរិមណ្ឌលនៃព្រះកាយស្មើគ្នា ដូចជាបរិ-មណ្ឌលនៃដើមជ្រៃ គឺព្រះកាយរបស់ព្រះអង្គប្រវែងប៉ុន្មាន ព្យាមរបស់ព្រះអង្គប្រវែងប៉ុណ្ណោះដែរ ព្យាមរបស់ព្រះអង្គប្រវែងប៉ុន្មាន កាយរបស់ព្រះអង្គក៏ប្រវែងប៉ុណ្ណោះដែរ ១ ។ ព្រះគោតមដ៏ចម្រើននោះ មានព្រះសុរង់មូលស្មើ ១ ព្រះគោតមដ៏ចម្រើននោះ មានសរសៃល្អសម្រាប់នាំនូវរស ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះហនុ (ចង្កា) ដូចជាចង្កានៃសត្វសីហៈ ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះទន្ត ៤០ គត់ ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះទន្តត្រឹមស្មើ ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះទន្តមិនរង្មើល ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះចង្កូមសស្អាត ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះជិវ្ហាដ៏ល្មម ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះសូរស័ព្ទ ដូចជាសំឡេងនៃព្រហ្ម មានព្រះវាចាពីរោះដូចជាសំឡេងនៃសត្វករវិក ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះនេត្រខ្មៅយង់ ១ ព្រះគោតមដ៏ចម្រើននោះ មានរោមព្រះនេត្រដូចជារោមភ្នែកនៃកូនគោ ១ ព្រះឧណ្ណាលោមរបស់ព្រះគោតមដ៏ចម្រើននោះ ដុះក្នុងចន្លោះនៃ

ឱទាតា មុទុ តលសន្និភា ឧណ្ហិសសីសោ ខោ បន សោ ភវំ គោតមោ ឥទម្បិ តស្ស ភោតោ គោតមស្ស មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។ ឥមេហិ ខោ សោ ភោ ភវំ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ សមន្នាគតោ ។ គច្ឆន្តោ ខោ បន សោ ភវំ គោតមោ ទក្ខិណេន[១] បាទេន បឋមំ បក្កមតិ សោ នាតិទូរេ បាទំ ឧទ្ធរតិ នាច្ចាសន្នេ បាទំ និក្ខិបតិ សោ នាតិសីឃំ គច្ឆតិ នាតិសណិកំ គច្ឆតិ ន ច អទ្ធុវេន អទ្ធុវំ[២] សង្ឃដ្ដេន្តោ គច្ឆតិ ន ច គោប្ផកេន គោប្ផកំ សង្ឃដ្ដេន្តោ គច្ឆតិ សោ គច្ឆន្តោ ន សត្ថឹ ឧន្នាមេតិ ន សត្ថឹ ឱនាមេតិ ន សត្ថឹ សន្នាមេតិ ន សត្ថឹ វិនាមេតិ គច្ឆតោ ខោ បន តស្ស[៣] ភោតោ គោតមស្ស អារទ្ធកាយោ វ ឥញ្ជតិ ន ច កាយពលេន គច្ឆតិ អវលោកេន្តោ[៤] ខោ បន សោ ភវំ គោតមោ សព្វកាយេនេវ អវលោកេតិ

១ ឱ. ទក្ខិណេនេវ ។ ២ ឱ. ម. អន្ទុវេន អន្ទុវំ ។ ៣ ឱ. បនស្ស ។ ៤ ម. អបលោកេន្តោ ។

ព្រះភមូ (ចិញ្ចើម) មានពណ៌សទន់ល្វន់ដូចជាសំឡី ១ ព្រះគោតមដ៏ចម្រើននោះ មានព្រះឧណ្ហិសៈ (ថ្ងាសឬក្បាំង) និងព្រះសិរ្សដ៏បរិបូណ៌ នេះជាមហាបុរិសលក្ខណៈនៃមហាបុរសរបស់ព្រះគោតមដ៏ចម្រើននោះ ១ ។ បពិត្រលោកដ៏ចម្រើន ព្រះគោតមដ៏ចម្រើននោះ ប្រកបដោយមហាបុរិស-លក្ខណៈ ទាំង ៣២ នេះឯង ។ ព្រះគោតមដ៏ចម្រើននោះ កាលដែលទ្រង់ពុទ្ធដំណើរទៅ រមែងទ្រង់ឈានព្រះបាទខាងស្តាំទៅជាមុន ព្រះអង្គលើកជំហានព្រះបាទមិនឆ្ងាយពេក ដាក់ព្រះបាទមិនជិតពេក ព្រះអង្គទ្រង់ពុទ្ធដំណើរទៅ មិនរហ័សពេក ទ្រង់ពុទ្ធដំណើរទៅ មិនយឺតពេក ទ្រង់ពុទ្ធដំណើរទៅ មិនទង្គិចព្រះជានុដោយព្រះជានុ ទ្រង់ពុទ្ធដំណើរទៅ មិនទង្គិចព្រះគោប្ផកៈ (ភ្នែកគោរ) ដោយព្រះគោប្ផកៈ ព្រះគោតមនោះ កាលដែលទ្រង់ពុទ្ធដំណើរទៅ មិនលើកព្រះឩរុ (ភ្លៅ) ទៅខាងមុខ មិនសណ្ដូកព្រះឩរុមកខាងក្រោយ មិនធ្វើព្រះឩរុឲ្យជាប់រឹងស្ដូក មិនកែក្រាយព្រះឩរុ ព្រះគោតមដ៏ចម្រើននោះ កាលដែលទ្រង់ពុទ្ធដំណើរទៅ មានព្រះកាយខាងលើរឹងប៉ឹងមិនបានកម្រើក មិនទ្រង់ពុទ្ធដំណើរទៅដោយកម្លាំងព្រះកាយឡើយ ព្រះគោតមដ៏ចម្រើននោះ កាលដែលទតព្រះនេត្រក្រឡេកមើល រមែងក្រឡេកមើលទៅ ដោយទាំងកាយ

សោ ន ឧច្ចំ ឧល្លោកេតិ ន អធោ ឱលោកេតិ ន[១] វិក្ខេបមានោ គច្ឆតិ យុគ្គមត្តញ្ច បេក្ខតិ តតោ ចស្ស ឧត្តរឹ អនាវដំ ញាណទស្សនំ ភវតិ ។ សោ អន្តរឃរំ បវិដ្ឋោ ន កាយំ ឧន្នាមេតិ ន កាយំ ឱនាមេតិ ន កាយំ សន្នាមេតិ ន កាយំ វិនាមេតិ ។ សោ នាតិទូរេ នាច្ចាសន្នេ អាសនស្ស បរិវត្តតិ ន ច បាណិនា អាលម្ពិត្វា អាសនេ និសី-ទតិ ន ច អាសនស្មឹ[២] កាយំ បក្ខិបតិ ។ សោ អន្តរឃរេ និសិន្នោ សមានោ ន ហត្ថកុក្កុច្ចំ អាបជ្ជតិ ន បាទកុក្កុច្ចំ អាបជ្ជតិ ន ច អទ្ទុ-វេន អទ្ទុវំ អារោបេត្វា និសីទតិ ន គោប្ផកេន គោប្ផកំ អារោបេត្វា និសីទតិ ន ច បាណិនា ហនុកំ ឧបនេត្វា[៣] និសីទតិ ។ សោ អន្តរឃរេ និសិន្នោ[៤] សមានោ ន ឆម្ភតិ ន កម្បតិ ន វេធតិ ន បរិតស្សតិ សោ អច្ឆម្ភី អកម្បី អវេធី

១ ឱ. ន ច ។ ២ ម. អាសនេ តស្មឹ ។ ៣ ឱ. ឧប្បាទិយិត្វា ។ ៤ ឱ. និសិន្នោ ។

ព្រះអង្គមិនបានងើយទតទៅខាងលើ មិនបានឈ្ងោកទតទៅខាងក្រោម ទ្រង់ពុទ្ធដំណើរទៅមិនក្រឡេកទតទិសផ្សេង ៗ ទ្រង់ក្រឡេកទតទៅតែប្រមាណមួយជួរនឹម[១] ប៉ុន្តែឯញាណទស្សនៈដែលមិនមានអ្វីរាំងរារបស់ព្រះគោតមនោះ រមែងមានលើសលុបជាងមួយជួរនឹមនោះឯង ។ ព្រះគោតមនោះ កាលដែលចូលទៅកាន់ចន្លោះផ្ទះ មិនដកព្រះកាយឡើងលើ មិនបន្ទន់ព្រះកាយចុះក្រោម មិនទប់ទល់ព្រះកាយឲ្យរឹង មិនគ្រលែងព្រះកាយ ។ ព្រះគោតមនោះ ទ្រង់បែរព្រះកាយមិនឆ្ងាយពេក មិនជិតពេកអំពីអាសនៈ ទ្រង់គង់លើអាសនៈ មិនយកបាតព្រះហស្តច្រត់អាសនៈ មិនផ្អែកព្រះកាយទៅលើអាសនៈ ។ ព្រះគោតមនោះ កាលដែលទ្រង់គង់ក្នុងចន្លោះផ្ទះ មិនរពឹសព្រះហស្ត មិនរពឹសព្រះបាទា មិនគង់លើកព្រះជានុតម្រួតលើព្រះជានុ មិនគង់លើកព្រះគោប្ផកៈតម្រួតលើព្រះគោប្ផកៈ មិនគង់យកបាតព្រះហស្តទល់ព្រះហនុកៈ ។ ព្រះគោតមនោះ កាលដែលទ្រង់គង់ក្នុងចន្លោះផ្ទះ តែងមិនរំភើប មិនញាប់ញ័រ មិនរន្ធត់ មិនតក់ស្លុត ព្រះអង្គជាបុគ្គលមិនរំភើបផង មិនញាប់ញ័រផង មិនរន្ធត់ផង

១ មួយជួរនឹមនោះ ប្រមាណ ៩ ចំអាម (អដ្ឋកថា) ។

១៣



អបរិតស្សី វិគតលោមហំសោ វិវេការត្តោ[១] ច ។ សោ ភវំ គោតមោ អន្តរឃរេ និសិន្នោ ហោតិ សោ បតោទកំ បដិគ្គណ្ហន្តោ ន បត្តំ ឧន្នាមេតិ ន បត្តំ ឱនាមេតិ ន បត្តំ សន្នាមេតិ ន បត្តំ វិនាមេតិ សោ បត្តោទកំ បដិគ្គណ្ហាតិ នាតិថោកំ នាតិពហុំ ។ សោ ន ខលុខលុការកំ[២] បត្តំ ធោវតិ ន សំបរិវត្តកំ បត្តំ ធោវតិ ន បត្តំ ភូមិយំ និក្ខិបិត្វា ហត្ថេ ធោវតិ ។ ហត្ថេសុ ធោតេសុ បត្តោ ធោតោ ហោតិ បត្តេ ធោតេ ហត្ថា ធោតា ហោន្តិ ។ សោ បត្តោទកំ ឆឌ្ឌេតិ នាតិទូរេ នាច្ចាសន្នេ ន ច វិច្ឆឌ្ឌិយមានោ ។ សោ ឱទនំ បដិគ្គណ្ហន្តោ ន បត្តំ ឧន្នាមេតិ ន បត្តំ ឱនាមេតិ ន បត្តំ សន្នាមេតិ ន បត្តំ វិនាមេតិ ។ សោ ឱទនំ បដិគ្គណ្ហាតិ នាតិថោកំ នាតិពហុំ ។ ព្យញ្ជនំ បន[៣] សោ ភវំ គោតមោ

---

១ ម. វិវេការធោ ។ ២ ឱ. ខុលុខុលុការកំ ។ ៣ ឱ. ខោ បន ។

មិនតក់ស្លុតផង ប្រាសចាកសេចក្តីព្រឺរោមផង មានព្រះហឫទ័យបែរទៅរកសេចក្តីស្ងាត់ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់គង់ក្នុងចន្លោះផ្ទះ កាលដែលទ្រង់ទទួលទឹកលាងបាត្រ មិនលើកបាត្រឡើង ឲ្យខ្ពស់ពេក មិនដាក់បាត្រឲ្យទាបពេក មិនទប់ទល់បាត្រឲ្យរឹង មិនគ្រលែងបាត្រ ព្រះអង្គទ្រង់ទទួលទឹកលាងបាត្រ មិនឲ្យតិចពេក មិនឲ្យច្រើនពេក ។ ព្រះអង្គលាងបាត្រមិនធ្វើឲ្យឮសូរខ្ទូកខ្ទូក ទ្រង់លាងបាត្រមិនបង្វិលបាត្រឲ្យវិលជុំវិញ មិនដាក់បាត្រលើផែនដី ហើយលាងព្រះហស្តឡើយ ។ កាលដែលព្រះអង្គលាងព្រះហស្តហើយស្រេច បាត្រក៏លាងហើយស្រេចដែរ ឬកាលដែលលាងបាត្រហើយស្រេច ព្រះហស្តក៏លាងហើយស្រេចដែរ ។ ព្រះអង្គទ្រង់ចាក់ទឹកលាងបាត្រ ក្នុងទីមិនឆ្ងាយពេក មិនជិតពេក ទ្រង់មិនបាចសាចផ្តេសផ្តាស ។ កាលដែលព្រះអង្គទ្រង់ទទួលបាយ មិនលើកបាត្រឡើងឲ្យខ្ពស់ពេក មិនដាក់បាត្រឲ្យទាបពេក មិនទប់ទល់បាត្រឲ្យរឹង មិនគ្រលែងបាត្រ ។ ព្រះអង្គទ្រង់ទទួលបាយ មិនឲ្យតិចពេក មិនឲ្យច្រើនពេក ។ មួយទៀត ព្រះគោតមដ៏ចម្រើននោះ

បដិគ្គណ្ហាតិ ព្យញ្ជនមត្តាយ អាហារេតិ ន ច ព្យញ្ជនេន អាលោបំ អតិនាមេតិ(១) ទ្វត្តិក្ខត្តុំ ខោ(២) ភវំ គោតមោ មុខេ អាលោបំ សំបរិវត្តេត្វា អជ្ឈោហរតិ ។ ន ចស្ស កាចិ ឱទនមិញ្ជា អសំភិន្នា កាយំ បវិសតិ ។ ន ចស្ស កាចិ ឱទនមិញ្ជា មុខេ អវសិដ្ឋា ហោតិ ។ អឌ្ឍាយ(៣) អាលោបំ ឧបនាមេតិ ។ រសប្បដិសំវេទី ខោ បន សោ ភវំ គោតមោ អាហារំ អាហារេតិ នោ ច រសរាគប្បដិសំវេទី ។ អដ្ឋង្គសមន្នាគតំ ខោ បន សោ ភវំ គោតមោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ

---

១ ឱ. អតិមញ្ញមេតិ ។ ២ ឱ. ខោ បន សោ ។ ៣ ឱ. អថាបរំ ។ ម. អទ្ធាយំ ។

ទ្រង់ទទួលម្ហូបហើយទ្រង់សោយកត្តដោយល្មមប្រមាណដល់ម្ហូប[១] មិនសោយម្ហូបឲ្យលើសលុបពំនូតកត្ត ឬមិនសោយកត្ត ឲ្យលើសលុបម្ហូបឡើយ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់គ្រលៀវពំនូតកត្តក្នុងព្រះឱស្ឋកំណាត់ត្រឹមពីរបីដង ហើយទ្រង់លេបទៅ ។ ឯសាច់កត្តបន្តិចបន្តួចដែលមិនទាន់ល្អិត ក៏មិនចូលទៅកាន់ព្រះកាយរបស់ព្រះអង្គឡើយ ។ លុះតែមិនសល់សាច់កត្តបន្តិចបន្តួច នៅក្នុងព្រះឱស្ឋព្រះអង្គ ។ ទើបព្រះអង្គបង្អោនទូវពំនូតកត្តដទៃទៀតឲ្យចូលទៅ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់សោយអាហារ ទ្រង់ធ្វាញ់ពិសាតែរសអាហារប៉ុណ្ណោះ មិនបានធ្វាញ់ពិសា ព្រោះតម្រេកក្នុងរសអាហារឡើយ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់សោយអាហារប្រកបដោយអង្គ ៨ គឺទ្រង់សោយដើម្បីនឹងលេងក៏ទេ ដើម្បីនឹងឲ្យកើតសេចក្តីស្រវឹងក៏ទេ ដើម្បីនឹងប្រដាប់រាងកាយក៏ទេ ដើម្បីនឹងស្អិតស្អាងរាងកាយក៏ទេ ដើម្បីនឹងឲ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារ្យ ទ្រង់ពិចារណាថា អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានចេញផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឲ្យកើតឡើងបានផង

១ បរិភោគអាហារឲ្យមានបាយជាភាគទី ៤ គឺចំនួនម្ហូប ៣ ភាគ បាយ ១ ភាគ ជាភាគទី ៤ នេះជាកំណត់យ៉ាងច្រើនបំផុត ។ (អដ្ឋកថា) ។

១៤

## ព្រាហ្មណវគ្គស្ស  ព្រហ្មាយុសុត្តេ  មហាបុរិសលក្ខណានិ

យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ សោ កុត្តាវី បត្តោទកំ បដិគ្គណ្ហន្តោ ន បត្តំ ឧន្នាមេតិ ន បត្តំ ឱនាមេតិ ន បត្តំ សន្នាមេតិ ន បត្តំ វិនាមេតិ ។ សោ បត្តោទកំ បដិគ្គណ្ហាតិ នាតិថោកំ នាតិពហុំ ។ សោ ន ខលុខលុការកំ បត្តំ ធោវតិ ន សំបរិវត្តកំ បត្តំ ធោវតិ ន បត្តំ ភូមិយំ និក្ខិបិត្វា ហត្ថេ ធោវតិ ហត្ថេសុ ធោតេសុ បត្តោ ធោតោ ហោតិ បត្តេ ធោតេ ហត្ថា ធោតា ហោន្តិ ។ សោ បត្តោទកំ ឆឌ្ឌេតិ នាតិទូរេ នាច្ចាសន្នេ ន ច វិច្ឆឌ្ឌយមានោ ។ សោ កុត្តាវី ន បត្តំ ភូមិយំ និក្ខិបតិ នាតិទូរេ នាច្ចាសន្នេ ន ច អនត្ថិកោ បត្តេន ហោតិ ន ច អតិវេលានុរក្ខី បត្តស្មឹ ។ សោ កុត្តាវី មុហុត្តំ តុណ្ហី និសីទតិ ។ ន ច អនុមោទនស្ស កាលមតិនាមេតិ ។

កិរិយាប្រព្រឹត្តទៅ (នៃឥរិយាបថទាំង ៤) ក្តី សេចក្តីមិនមានទោស (មានមិនប្រអូសកាយ មិនប្រអូសចិត្តជាដើម) ក្តី កិរិយានៅសប្បាយក្តី នឹងមានដល់អាត្មាអញ ។ លុះព្រះអង្គសោយរួចហើយ កាលដែលទ្រង់ទទួលទឹកលាងបាត្រ មិនលើកបាត្រឡើងឲ្យខ្ពស់ពេក មិនដាក់បាត្រឲ្យទាបពេក មិនទប់ទល់បាត្រឲ្យរឹង មិនបានគ្រលែងបាត្រ ។ ព្រះអង្គទ្រង់ទទួលទឹកលាងបាត្រមិនឲ្យតិចពេក មិនឲ្យច្រើនពេក ។ ព្រះអង្គលាងបាត្រ មិនធ្វើឲ្យឮសូរខ្ជុកខ្ជូក ទ្រង់លាងបាត្រមិនបង្វិលបាត្រឲ្យវិលជុំវិញ មិនដាក់បាត្រលើផែនដីហើយលាងព្រះហស្តឡើយ ។ កាលដែលលាងព្រះហស្តហើយស្រេច បាត្រក៏លាងហើយស្រេច កាលដែលលាងបាត្រហើយស្រេច ព្រះហស្តក៏លាងហើយស្រេចដែរ ។ ព្រះអង្គទ្រង់ចាក់ទឹកលាងបាត្រក្នុងទីមិនឆ្ងាយពេក មិនជិតពេក ទ្រង់មិនបាចសាចផ្តេសផ្តាសឡើយ ។ លុះព្រះអង្គសោយរួចហើយ មិនដាក់បាត្រលើផែនដី ទ្រង់ទុកបាត្រក្នុងទីមិនឆ្ងាយពេក មិនជិតពេក ព្រះអង្គមិនមែនជាមិនត្រូវការដោយបាត្រទេ ទាំងទ្រង់រក្សាបាត្រមិនឲ្យហួសវេលា ។ លុះព្រះអង្គសោយរួចហើយ ទ្រង់គង់ស្ងៀមមួយស្របក់ ។ ព្រះអង្គមិនញុំាងកាលនៃមនុស្ស អ្នកត្រូវការដោយអនុមោទនាឲ្យកន្លងហួសទៅឡើយ ។

សោ កុត្តាវី អនុមោទតិ ន តំ ភត្តំ គរហតិ ន អញ្ញំ ភត្តំ បដិកង្ខតិ ។ អញ្ញទត្ថុំ ធម្មិយា កថាយ តំ បរិសំ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ សោ តំ បរិសំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កមតិ ។ សោ នាតិសីឃំ គច្ឆតិ នាតិសណិកំ គច្ឆតិ ន ច មុញ្ចិតុកាមោ គច្ឆតិ ។ ន ច តស្ស ភោតោ គោតមស្ស កាយេ ចីវរំ អច្ចុ-កដ្ឋំ ហោតិ ន ច អច្ចោកដ្ឋំ ន ច កាយស្មឹ អល្លីនំ ន ច កាយស្មា[១] អបកដ្ឋំ ។ ន ច[២] ភោតោ គោតមស្ស កាយស្មឹ[៣] វាតោ ចីវរំ អសំវហតិ[៤] ។ ន ច តស្ស ភោតោ គោតមស្ស កាយេ រជោ-ជល្លំ លិម្បតិ ។ សោ អារាមគតោ និសីទតិ បញ្ញត្តេ អាសនេ និសជ្ជ ចានេ បក្ខាលេតិ ។

---

១ ឱ. កាយស្មឹ ។ ២ ឱ. ម. ច តស្ស ។ ៣ ឱ. កាយម្ហា ។ ៤ ឱ. អបវហតិ ។

លុះព្រះអង្គសោយរួចហើយ ទ្រង់អនុមោទនា មិនតិះដៀលភត្តនោះ មិនប្រាថ្នានូវភត្តដទៃទៀតឡើយ ។ ព្រះអង្គទ្រង់ញុំាងបរិស័ទនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដោយពិត ។ លុះព្រះអង្គទ្រង់ញុំាងបរិស័ទនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកអំពីអាសនៈចេញទៅ ។ ព្រះអង្គទ្រង់ស្តេចទៅ មិនបានលឿនពេក មិនបានយឺតពេក ទ្រង់ស្តេចទៅមិនប្រាថ្នានឹងឃ្លាតឆ្ងាយអំពីបរិស័ទឡើយ ។ ចីវរក្នុងកាយ របស់ព្រះគោតមដ៏ចម្រើននោះ មិនឡើងលើពេក មិនចុះក្រោមពេក[១] មិនទទឹកស្អិតជាប់នៅក្នុងកាយដោយញើសក្អែល ទាំងមិនរបូតចាកកាយឡើយ ។ ខ្យល់[២] ក៏មិនបក់សើយចីវរអំពីកាយរបស់ព្រះគោតមដ៏ចម្រើន ។ ធូលីនិងក្អែលក៏មិនជិតជាប់នៅ ក្នុងកាយរបស់ព្រះគោតមដ៏ចម្រើននោះ ។ ព្រះគោតមនោះ ស្តេចទៅកាន់អារាម ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ លុះគង់រួចហើយ ទ្រង់លាងព្រះបាទ ។

---

១ ភិក្ខុដែលឃ្លុំចីវរឲ្យឡើងលើដរាបដល់ទល់នឹងឆ្អឹងចង្កា ហៅថា ឡើងលើពេក ។ ភិក្ខុដែលឃ្លុំចីវរឲ្យចុះក្រោមដរាបដល់កជើង ហៅថា ចុះក្រោមពេក ។ ២ ទុកជាខ្យល់កំបុតត្បូងក៏មិនអាចបក់ឲ្យកម្រើកបានដែរ ។ អដ្ឋកថា ។

១៧



ន ច សោ ភវំ គោតមោ បាទមណ្ឌនានុយោគមនុយុត្តោ វិហរតិ ។ សោ បាទេ បក្ខាលេត្វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ នេវ អត្តព្យាពាធាយ ចេតេតិ ន បរព្យាពាធាយ ចេតេតិ ន ឧភយព្យាពាធាយ ចេតេតិ ។ អត្តហិតំ បរហិតំ ឧភយហិតំ សព្វលោកហិតមេវ សោ ភវំ គោតមោ ចិន្តេន្តោ និសិន្នោ ហោតិ ។ សោ អារាមគតោ បរិសតិ ធម្មំ ទេសេតិ ន តំ បរិសំ ឧស្សាទេតិ ន តំ បរិសំ អប្បសាទេតិ អញ្ញទត្ថុំ ធម្មិយា កថាយ តំ បរិសំ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ អដ្ឋង្គសមន្នាគតោ ខោ បនស្ស ភោតោ គោតមស្ស មុខតោ ឃោសោ និច្ឆរតិ វិស្សដ្ឋោ ច វិញ្ញេយ្យោ ច មញ្ជុ ច សវនីយោ ច វិន្ទុ[១] ច អវិសារី ច គម្ភីរោ ច

១ ឱ. ម. ពិន្ទុ ។

ព្រះគោតមដ៏ចម្រើននោះ ទ្រង់មិនបានខ្វល់ខ្វាយ ក្នុងការប្រកបគ្រឿងប្រដាប់ព្រះបាទទេ ។ លុះព្រះអង្គទ្រង់លាងព្រះបាទរួចហើយ ក៏គង់ផ្គត់ព្រះភ្នែនតម្កល់កាយឲ្យត្រង់ ផ្ចង់ស្មារតីឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ ព្រះអង្គមិនទ្រង់ព្រះតម្រិះដើម្បីបៀតបៀនខ្លួនឯង មិនទ្រង់ព្រះតម្រិះដើម្បីបៀតបៀនអ្នកដទៃ មិនទ្រង់ព្រះតម្រិះ ដើម្បីបៀតបៀនទាំងពីរខាង ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់គង់ត្រិះរិះតែអំពីប្រយោជន៍ នៃសត្វលោកទាំងអស់ គឺប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ ឬប្រយោជន៍ទាំងពីរខាង ។ ព្រះអង្គស្តេចទៅកាន់អារាម ទ្រង់សំដែងធម៌ក្នុងកណ្តាលបរិស័ទ មិនបានលើកបញ្ជោរបរិស័ទនោះ មិនបានតិះដៀលបរិស័ទនោះ ទ្រង់ញុំាងបរិស័ទនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហានឲ្យរីករាយ ដោយធម្មីកថាតាមពិត ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់មានព្រះសូរសេង[១] ប្រកបដោយអង្គ ៨ លាន់ចេញអំពីព្រះឱស្ឋ គឺព្រះសូរសេងជ្រះស្រឡះ ១ ញុំាងបុគ្គលឲ្យដឹងសេចក្តីច្បាស់ ១ ទន់ពីរោះ ១ គួរស្តាប់ ១ ណែន ១ មិនរាត់រាយគឺព្រះសូរសេងមូល ១ ក្រអួន ១

១ សូរសេង គឺសូរសំឡេង សៀមយកទៅប្រើក្លាយជា សូរសៀង ។

និដ្ឋានី ច ។ យថា បរិសំ ខោ បន សោ ភវំ គោតមោ សាវកេ វិញ្ញាបេតិ ន ច តស្ស ពហិទ្ធា បរិសាយ ឃោសោ និច្ឆរតិ ។ តេ តេន ភោតា គោតមេន ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ឧដ្ឋាយាសនា បក្កមន្តិ អវលោកយមានាយេវ អវិជហន្តាភាវេន[១] អទ្ទសាម ខោ មយំ ភោ តំ ភវន្តំ គោតមំ គច្ឆន្តំ អទ្ទសាម ឋិតំ អទ្ទសាម អន្តរឃរំ បវិសន្តំ អទ្ទសាម អន្តរឃរេ និសិន្នំ តុណ្ហីភូតំ អទ្ទសាម អន្តរឃរេ ភុញ្ជន្តំ អទ្ទសាម ភុត្តាវឹ និសិន្នំ តុណ្ហីភូតំ អទ្ទសាម ភុត្តាវឹ អនុមោទន្តំ អទ្ទសាម អារាមំ អាគច្ឆន្តំ អទ្ទសាម អារាមគតំ និសិន្នំ តុណ្ហីភូតំ អទ្ទសាម

១ ឱ. អវិជហន្តាភាវេន ។ ម. អវិជហិតត្តា ។

កង់រំពង់ ១ ។ ព្រះគោតមដ៏ចម្រើននោះ ទ្រង់ញុាំងបរិស័ទឲ្យដឹងច្បាស់ ដោយព្រះសូរសេង យ៉ាងណា ព្រះសូរសេងរបស់ព្រះគោតមនោះ ក៏មិនផ្សាយចេញទៅខាងក្រៅអំពីបរិស័ទ យ៉ាងនោះ ។ ឯពួកបរិស័ទទាំងនោះ លុះព្រះគោតមដ៏ចម្រើននោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ រមិលមើលមិនបានលះបង់ (នូវសេចក្ដីសរសើរអំពីធម្មកថា) ហើយចៀសចេញទៅដោយពាក្យថា ម្នាលគ្នាយើង យើងបានឃើញព្រះគោតមដ៏ចម្រើននោះ កំពុងស្ដេចទៅ យើងបានឃើញព្រះគោតមទ្រង់ឈរ យើងបានឃើញព្រះគោតមទ្រង់ចូលទៅកាន់ចន្លោះផ្ទះ យើងបានឃើញព្រះគោតមគង់ស្ងៀម ក្នុងចន្លោះផ្ទះ យើងបានឃើញព្រះគោតមកំពុងសោយក្នុងចន្លោះផ្ទះ យើងបានឃើញព្រះគោតម សោយរួចហើយទ្រង់គង់ស្ងៀម យើងបានឃើញព្រះគោតមសោយរួចហើយទ្រង់អនុមោទនា យើងបានឃើញព្រះគោតមស្ដេចមកកាន់អារាម យើងបានឃើញព្រះគោតមស្ដេចទៅកាន់អារាមគង់ស្ងៀម យើងបានឃើញ

អារាមគតំ បវិសតិ ធម្មំ ទេសេន្តំ ឯទិសោ ច ឯទិសោ ច សោ ភវំ គោតមោ តតោ ច ភិយ្យោតិ ។

[៧] ឯវំ វុត្តេ ព្រហ្មាយុ ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ អប្បេវ នាម មយំ កទាចិ ករហចិ តេន ភោតា គោតមេន សទ្ធឹ សមាគច្ឆេយ្យាម អប្បេវ នាម សិយា កោចិទេវ កថាសល្លាបោតិ ។

[៨] អថខោ ភគវា វិទេហេសុ អនុបុព្វេន ចារិកញ្ចរមានោ យេន មិថិលា តទវសរិ ។ តត្រ សុទំ ភគវា មិថិលាយំ វិហរតិ មឃទេវម្ពវនេ(១) ។ អស្សោសុំ ខោ មិថិលេយ្យកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ

១ ឱ. មខាទេវម្ពវនេ ។

ព្រះគោតមស្តេចទៅកាន់អារាម ទ្រង់សំដែងធម៌ ក្នុងកណ្តាលបរិស័ទ ព្រះគោតមដ៏ចម្រើននោះ ប្រាកដដូច្នេះផង ប្រាកដដូច្នេះផង ក្រៃលែងជាងនោះទៅទៀតផង ។

[៧] កាលបើឧត្តរមាណព ពោលយ៉ាងនេះហើយ ព្រហ្មាយុព្រាហ្មណ៍ ក៏ក្រោកអំពីអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះត្រង់ទីដែលព្រះមានព្រះភាគគង់ បន្លឺនូវឧទានវាចា អស់វារៈ ៣ ដងថា សូមថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ... សូមថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ធ្វើដូចម្តេចហ្ន៎ យើងគប្បីបានចួបនឹងព្រះគោតមដ៏ចម្រើននោះ ក្នុងកាលរឿយ ៗ ធ្វើដូចម្តេចហ្ន៎ គប្បីមានកថាសល្លាបៈណាមួយ ។

[៨] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិកក្នុងដែនវិទេហៈ តាមលំដាប់ ក៏បានដល់នគរមិថិលា ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងមឃទេវម្ពវ័ន (ព្រៃស្វាយរបស់ព្រះរាជាព្រះនាមមឃទេវៈ) ជិតក្រុងមិថិលានោះ ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងមិថិលា បានឮដំណឹងថា ព្រះសមណគោតម

២០



សក្យបុត្តោ សក្យកុលា បព្វជិតោ វិទេហេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ មិថិលំ អនុប្បត្តោ មិថិលាយំ វិហរតិ មឃទេវម្ពវនេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

ជាសក្យបុត្រចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវស្ដេចមកកាន់ចារិក ក្នុងដែនវិទេហ: ជាមួយនឹងភិក្ខុសង្ឃច្រើន ប្រមាណ ៥០០ រូប មកដល់ក្រុងមិថិលា ទ្រង់គង់នៅក្នុងមឃទេវម្ពវ័ន ជិតក្រុងមិថិលា ឯកិត្តិសព្ទល្អនៃព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយសុសសាយទៅ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណ: ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាសាស្ដានៃទេវតានិងមនុស្ស ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងត្រឡប់មកកាន់ត្រៃភពទៀតហើយ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយព្រះអង្គឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេសហើយប្រកាស ព្រះអង្គទ្រង់សំដែង នូវធម៌មានលំអខាងដើម មានលំអកណ្ដាល មានលំអខាងចុង បរិបូណ៌ដោយអត្ថ បរិបូណ៌ដោយព្យញ្ជន: ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ក៏ការបានចួបនឹងព្រះអរហន្តមានសភាពដូច្នោះ ជាការប្រពៃពេកណាស់ ។

អថខោ មិថិលេយ្យកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។

[៩] អស្សោសិ ខោ ព្រហ្មាយុ ព្រាហ្មណោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ[១] មិថិលាយំ វិហរតិ មឃទេវម្ពវនេតិ ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ សម្ពហុលេហិ មាណវកេហិ សទ្ធឹ យេន មឃទេវម្ពវនំ តេនុបសង្កមិ ។ អថខោ ព្រហ្មាយុនោ ព្រាហ្មណស្ស

១ ឱ. ម. ឯត្ថន្តរេ មិថិលំ អនុប្បត្តោតិ ទិស្សតិ ។

គ្រានោះពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងក្រុងមិថិលា ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ពួកខ្លះ ប្រណម្យអញ្ជលីទៅរកព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះ ប្រកាសនាមនិងគោត្រ ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះស្ងៀម ហើយអង្គុយក្នុងទីសមគួរ ។

[៩] ព្រហ្មាយុព្រាហ្មណ៍ បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ឥឡូវគង់នៅក្នុងមឃទេវម្ពវ័ន ជិតក្រុងមិថិលា ។ ទើបព្រហ្មាយុព្រាហ្មណ៍ចូលទៅកាន់មឃទេវម្ពវ័ន ជាមួយនឹងពួកមាណពជាច្រើន ។ ព្រហ្មាយុព្រាហ្មណ៍

អវិទូរេ អម្ពវនស្ស ឯតទហោសិ ន ខោ មេតំ បតិរូបំ យោហំ បុព្វេ អប្បដិសំវិទិតោ សមណំ គោតមំ ទស្សនាយ ឧបសង្កមេយ្យន្តិ ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ អញ្ញតរំ មាណវកំ អាមន្តេសិ ឯហិ ត្វំ មាណវក យេន សមណោ គោតមោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន សមណំ គោតមំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ ព្រហ្មាយុ ភោ គោតម ព្រាហ្មណោ ភវន្តំ គោតមំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ ព្រហ្មាយុ ភោ គោតម ព្រាហ្មណោ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ វីសវស្ស-សតិកោ ជាតិយា តិណ្ណំ វេទានំ បារគូ សនិ-ឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ

លុះដល់ទីជិតអម្ពវ័ន ក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញដែលមិនបានថ្វាយដំណឹងជាមុន ហើយចូលទៅ ដើម្បីចួបព្រះសមណគោតម អំពើនេះមិនសមគួរដល់អាត្មាអញឡើយ ។ លំដាប់នោះ ព្រហ្មាយុព្រាហ្មណ៍ ហៅមាណពម្នាក់មកថា នែមាណព អ្នកចូរមក អ្នកចូលទៅគាល់ព្រះសមណគោតម លុះចូលទៅដល់ហើយ ចូរសួរព្រះសមណគោតម អំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័ស កម្លាំងកាយនិងការនៅសប្បាយគ្រប់ឥរិយាបថ តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មាយុព្រាហ្មណ៍ សួរមកព្រះគោតមដ៏ចម្រើន អំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយគ្រប់ឥរិយាបថ ដូច្នេះ រួចហើយអ្នកចូរក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មាយុព្រាហ្មណ៍ជាមនុស្សជរា ព្រឹទ្ធា ចាស់ កន្លងកាលវែងឆ្ងាយ មកដល់បច្ឆិមវ័យហើយ មានអាយុ ១២០ ឆ្នាំ អំពីកំណើត ជាអ្នកចេះចប់នូវត្រៃវេទ ព្រមទាំងគម្ពីរឈ្មោះនិឃណ្ឌុ និងគម្ពីរឈ្មោះកេដុភៈ ព្រមទាំងអក្ខរប្បភេទ មានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥

បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខ-ណេសុ អនវយោ យាវតា ភោ ព្រាហ្មណគហបតិកា មិថិលាយំ បដិវសន្តិ ព្រហ្មាយុ តេសំ ព្រាហ្មណោ អគ្គមក្ខាយតិ យទិទំ ភោគេហិ ព្រហ្មាយុ តេសំ ព្រាហ្មណោ អគ្គមក្ខាយតិ យទិទំ មន្តេហិ ព្រហ្មាយុ តេសំ ព្រាហ្មណោ អគ្គមក្ខាយតិ យទិទំ អាយុនា ចេវ យសសា ច សោ ភោតោ គោតមស្ស ទស្សនកាមោតិ ។

[១០] ឯវំ ភោតិ ខោ សោ មាណវកោ ព្រហ្មាយុស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ[១] មាណវកោ ភគវន្តំ ឯតទវោច ព្រហ្មាយុ ភោ គោតម ព្រាហ្មណោ ភវន្តំ គោតមំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ព្រហ្មាយុ ភោ គោតម ព្រាហ្មណោ ជិណ្ណោ

១ ឱ. ម. ខោ សោតិ ទិស្សតិ ។

ជាអ្នកចេះនូវបទនៃវេទ ជាអ្នកចេះនូវវេយ្យាករណ៍ ជាអ្នកមិនទើសទាល់ក្នុងគម្ពីរលោកាយតៈនិងគម្ពីរមហាបុរិសលក្ខណៈ ពួកព្រាហ្មណ៍និងគហបតីដ៏ចម្រើនទាំងអម្បាលម៉ាន តែងនៅអាស្រ័យក្នុងក្រុងមិថិលា ឯព្រហ្មាយុព្រាហ្មណ៍ ប្រាកដជាប្រសើរ ដោយភោគសម្ប័ទជាងព្រាហ្មណ៍ និងគហបតីទាំងអម្បាលនោះ ព្រហ្មាយុព្រាហ្មណ៍ ប្រាកដជាប្រសើរ ដោយមន្តវិជ្ជាជាងព្រាហ្មណ៍និងគហបតីទាំងអម្បាលនោះ ព្រហ្មាយុព្រាហ្មណ៍ ប្រាកដជាប្រសើរ ដោយអាយុផង ដោយយសផង ជាងព្រាហ្មណ៍និងគហបតីទាំងអម្បាលនោះ ឥឡូវគាត់ចង់ចួបនឹងព្រះគោតមដ៏ចម្រើន ។

[១០] មាណពនោះ ទទួលពាក្យរបស់ព្រហ្មាយុព្រាហ្មណ៍ថា បាទ លោកដ៏ចម្រើន ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។ លុះមាណពឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មាយុព្រាហ្មណ៍ទូលសួរព្រះគោតមដ៏ចម្រើន អំពីសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើង ដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយគ្រប់ឥរិយាបថ បពិត្រព្រះគោតមដ៏ចម្រើន ព្រហ្មាយុព្រាហ្មណ៍ ជាមនុស្សជរា

វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ វីសវស្សសតិកោ ជាតិយា តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ យាវតា ភោ ព្រាហ្មណាគហបតិកា មិថិលាយំ បដិវសន្តិ ព្រហ្មាយុ តេសំ ព្រាហ្មណោ អគ្គមក្ខាយតិ យទិទំ ភោគេហិ ព្រហ្មាយុ តេសំ ព្រាហ្មណោ អគ្គមក្ខាយតិ យទិទំ មន្តេហិ ព្រហ្មាយុ តេសំ ព្រាហ្មណោ អគ្គមក្ខាយតិ យទិទំ អាយុនា ចេវ យសសា ច សោ ភោតោ គោតមស្ស ទស្សនកាមោតិ ។ យស្សទានិ មាណវ[១] ព្រហ្មាយុ ព្រាហ្មណោ កាលំ មញ្ញតីតិ ។ អថខោ សោ មាណវកោ យេន ព្រហ្មាយុ ព្រាហ្មណោ តេនុបសង្កមិ ឧបសង្កមិត្វា ព្រហ្មាយុំ ព្រាហ្មណំ ឯតទវោច កតាវកាសោ ខោ ភវំ[២] សមណេន គោតមេន យស្សទានិ ភវំ កាលំ មញ្ញតីតិ[៣] ។

---

១ ឱ. មាណវក ។ ២ ម. ខោម្ហិ ភវតាតិ ទិស្សតិ ។ ៣ ឱ. មញ្ញសីតិ ។

ព្រឹទ្ធា ចាស់ កន្លងកាលវែងឆ្ងាយ មកដល់បច្ឆិមវ័យហើយ មានអាយុ ១២០ ឆ្នាំ អំពីកំណើត ជាអ្នកចេះចប់នូវត្រៃវេទ ព្រមទាំងគម្ពីរឈ្មោះ និឃណ្ឌុ និងគម្ពីរឈ្មោះកេដុភៈ ព្រមទាំងអក្ខរប្បភេទ មានគម្ពីរឈ្មោះ ឥតិហាសៈជាគម្រប់ ៥ ជាអ្នកដឹងនូវបទនៃវេទ ជាអ្នកចេះនូវវេយ្យាករណ៍ ជាអ្នកមិនទើសទាល់ ក្នុងគម្ពីរលោកាយតៈ និងគម្ពីរមហាបុរិសលក្ខណៈ ពួកព្រាហ្មណ៍និងគហបតីដ៏ចម្រើនទាំងអម្បាលម៉ាន តែងនៅអាស្រ័យក្នុងក្រុងមិថិលា ឯព្រហ្មាយុព្រាហ្មណ៍ ប្រាកដជាប្រសើរ ដោយភោគសម្ប័ទជាងព្រាហ្មណ៍និងគហបតីទាំងអម្បាលនោះ ព្រហ្មាយុព្រាហ្មណ៍ ប្រាកដជាប្រសើរ ដោយមន្តវិជ្ជា ជាងព្រាហ្មណ៍និងគហបតីទាំងអម្បាលនោះ ព្រហ្មាយុព្រាហ្មណ៍ ប្រាកដជាប្រសើរ ដោយអាយុផង ដោយយសផង ជាងព្រាហ្មណ៍និងគហបតីទាំងអម្បាលនោះ ឥឡូវគាត់ចង់ចួបនឹងព្រះគោតមដ៏ចម្រើន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមាណព ព្រហ្មាយុព្រាហ្មណ៍ ចូរសំគាល់នូវកាលគួរនឹងមកឥឡូវនេះចុះ ។ ទើបមាណពនោះ ចូលទៅរកព្រហ្មាយុព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រហ្មាយុព្រាហ្មណ៍ដូច្នេះថា ព្រះសមណគោតម បានបើកឱកាសដល់អ្នកដ៏ចម្រើនហើយ អ្នកដ៏ចម្រើន ចូរសំគាល់នូវកាលគួរនឹងទៅ ឥឡូវនេះចុះ ។

[១១] អថខោ ព្រហ្មាយុ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ។ អទ្ទសា ខោ សា បរិសា ព្រហ្មាយុំ ព្រាហ្មណំ ទូរតោ វ អាគច្ឆន្តំ ទិស្វា[១] ឱរមត្ត[២] ឱកាសមកាសិ យថាតំ ញាតស្ស យសស្សិនោ ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ តំ បរិសំ ឯតទវោច អលំ ភោ[៣] និសីទថ តុម្ហេ សកេ អាសនេ ឥធាហំ សមណស្ស គោតមស្ស សន្តិកេ និសីទិស្សាមីតិ ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ព្រហ្មាយុ ព្រាហ្មណោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ សម្មន្នេសិ ។ អទ្ទសា ខោ ព្រហ្មាយុ ព្រាហ្មណោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សំបសីទតិ កោសោហិតេ ច វត្ថគុយ្ហេ

១ ឱ. ម. ទិស្វាន ។ ២ ម. ឱរមតិ ។ ៣ ម. ខោ ភោ ។

[១១] គ្រានោះ ព្រហ្មាយុព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ ។ ឯបរិស័ទនោះ បានឃើញព្រហ្មាយុព្រាហ្មណ៍ ដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ថយចេញ បើកឱកាសឲ្យ ដូចជាបុគ្គលបើកឱកាសដល់បុគ្គល ដែលមានកេរ្តិ៍ឈ្មោះមានយស ។ លំដាប់នោះ ព្រហ្មាយុព្រាហ្មណ៍ ពោលនឹងបរិស័ទនោះដូច្នេះថា នៃអ្នកទាំងឡាយដ៏ចម្រើន ណ្ហើយចូរអ្នកទាំងឡាយអង្គុយលើអាសនៈជារបស់ខ្លួនចុះ ខ្ញុំនឹងអង្គុយក្នុងទីជិតព្រះសមណគោតមក្នុងទីនេះ ។ ទើបព្រហ្មាយុព្រាហ្មណ៍ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រហ្មាយុព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ពិនិត្យមើលនូវមហាបុរិសលក្ខណៈទាំង ៣២ ក្នុងព្រះកាយ នៃព្រះមានព្រះភាគ ។ ព្រហ្មាយុព្រាហ្មណ៍ក៏បានឃើញ នូវមហាបុរិសលក្ខណៈទាំង ៣២ ក្នុងព្រះកាយនៃព្រះមានព្រះភាគដោយច្រើន វៀរលែងតែមហាបុរិសលក្ខណៈ ២ ប្រការ ក៏សង្ស័យងឿងឆ្ងល់ មិនចូលចិត្ត មិនជ្រះស្រឡះក្នុងមហាបុរិសលក្ខណៈ ទាំង ២ ប្រការនោះ គឺអវយវៈដែលត្រូវលាក់ក្នុងសំពត់ ឋិតនៅក្នុងស្រោម ១

បហុតជិវ្ហតាយ ច[១] ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ ភគវន្តំ គាថាហិ អជ្ឈភាសិ

យេ មេ ទ្វត្តឹសាតិ សុតា
មហាបុរិសលក្ខណា
ទុវេ[២] តេសំ ន បស្សាមិ
ភោតោ កាយស្មិំ គោតម
កច្ចិ កោសោហិតំ ភោតោ
វត្ថគុយ្ហំ នរុត្តម
នារីសមានសវ្ហយា[៣]
កច្ចិ ជិវ្ហា នរស្សិកា
កិច្ចិ បហុតជិវ្ហាសិ
យថាតំ ជានិយាមសេ[៤]
និន្នាមយេតំ តនុកំ[៥]
កង្ខំ វិនយ នោ ឥសេ

---

១ ម. ចាតីតិ ទិស្សតិ ។ ២ ម. ទ្វេ ។ ៣ ម. នារីសមានសវ្ហយាតិ ទិស្សតិ ។ ៤ ម. ជានិស្សាមសេ ។ ៥ ម. បហុតំ ។

ព្រះជិវ្ហាដ៏ល្មម ១[១] ។ លំដាប់នោះ ព្រហ្មាយុព្រាហ្មណ៍ ពោលសរសើរព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា

មហាបុរិសលក្ខណៈទាំងឡាយណា ដែលខ្ញុំបានចេះដឹងមក ថាមាន ៣២ ប្រការ បពិត្រព្រះគោតម បណ្តាមហាបុរិស-លក្ខណៈទាំងនោះ ខ្ញុំមិនឃើញនូវលក្ខណៈ ២ ប្រការក្នុងព្រះកាយនៃព្រះអង្គ បពិត្រព្រះអង្គទ្រង់ខ្ពង់ខ្ពស់ជាងជន អវយវៈដែលត្រូវលាក់ក្នុងសំពត់ ឋិតនៅក្នុងស្រោម ដ៏ប្រាកដស្មើដោយភេទស្ត្រីរបស់ព្រះអង្គមានដែរឬ ព្រះជិវ្ហាមិនខ្លីរបស់ព្រះអង្គមានឬទេ យើងខ្ញុំបានដឹងមកយ៉ាងណា ព្រះអង្គជាបុគ្គលមានព្រះជិវ្ហាដ៏ល្មម (យ៉ាងនោះ) ដែរឬ សូមព្រះអង្គលៀននូវព្រះជិវ្ហានុ៎ះ បន្តិចមកមើល បពិត្រព្រះអង្គទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ សូមព្រះអង្គបន្ទោបង់នូវសេចក្តីសង្ស័យដល់

១ គឺអណ្តាតដែលទន់វែង ។

និជ្ជជម្មហិតត្ថាយ
សម្បរាយ សុខាយ ច
កតាវកាសា បុច្ឆាម
យំកិញ្ចិ អភិបត្ថិតន្តិ ។

[១២] អថខោ ភគវតោ ឯតទហោសិ បស្សតិ ខោ មេ អយំ ព្រហ្មាយុ ព្រាហ្មណោ ទ្វត្តឹស មហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សំបសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហុតជិវ្ហតាយ ចាតិ ។ អថខោ ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ យថា អទ្ទស ព្រហ្មាយុ ព្រាហ្មណោ ភគវតោ កោសោហិតំ វត្ថគុយ្ហំ ។ អថខោ ភគវា ជិវ្ហំ និន្នាមេត្វា ឧភោបិ កណ្ណសោតានិ អនុមសិ បដិមសិ ឧភោបិ នាសិកសោតានិ អនុមសិ បដិមសិ កេវលកប្បំ[១] នលាដមណ្ឌលំ ជិវ្ហាយ ឆាទេសិ[២] ។

---

១ ឱ. កេវលកម្បិ ។ ២ ឱ. បច្ឆាទេសីតិ ទិស្សតិ ។ ម. ឆាទេតិ ។

យើងខ្ញុំ បើព្រះអង្គបើកឱកាសឲ្យហើយ យើងខ្ញុំសូមសួរនូវប្រស្នាណានីមួយ ដែលយើងខ្ញុំត្រូវការ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្ដីសុខក្នុងលោកខាងមុខផង ។

[១២] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះដូច្នេះថា ព្រហ្មាយុព្រាហ្មណ៍នោះ បានឃើញនូវមហាបុរិសលក្ខណៈទាំង ៣២ ប្រការ របស់តថាគតដោយច្រើន វៀរតែមហាបុរិសលក្ខណៈ ២ ប្រការ ក៏សង្ស័យ ងឿងឆ្ងល់ មិនចូលចិត្ត មិនជ្រះស្រឡះ ក្នុងមហាបុរិសលក្ខណៈទាំង ២ ប្រការនោះ គឺអវយវៈដែលត្រូវលាក់ក្នុងសំពត់ ឋិតនៅក្នុងស្រោម ១ អណ្ដាតដ៏ល្មម ១ ។ ទើបព្រះមានព្រះភាគ ទ្រង់តាក់តែងនូវឥទ្ធាភិសង្ខារ ឲ្យព្រហ្មាយុព្រាហ្មណ៍ បានឃើញនូវអវយវៈដែលត្រូវលាក់ក្នុងសំពត់ ឋិតនៅក្នុងស្រោម របស់ព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់លៀននូវព្រះជិវ្ហា ប៉ះពាល់ដល់រន្ធព្រះកាណ៌ទាំងពីរផង ប៉ះពាល់ដល់រន្ធព្រះនាសិកទាំងពីរផង ហើយទ្រង់យកព្រះជិវ្ហាបាំងនូវមណ្ឌលនៃព្រះនលាដ (ថ្ងាស) ទាំងអស់ ។

អថខោ ភគវា ព្រហ្មាយុំ ព្រាហ្មណំ គាថាហិ អជ្ឈភាសិ

យេ តេ ទ្វត្តឹសាតិ សុតា
មហាបុរិសលក្ខណា
សព្វេ តេ មម កាយស្មឹ
មា តេ (១) កង្ខាហុ ព្រាហ្មណា
អភិញ្ញេយ្យំ អភិញ្ញាតំ
ភាវេតព្វញ្ច ភាវិតំ
បហាតព្វំ បហីនំ មេ
តស្មា ពុទ្ធោស្មិ ព្រាហ្មណា
ទិដ្ឋធម្មហិតត្ថាយ
សម្បរាយ សុខាយ ច
កតាវកាសោ បុច្ឆស្សុ
យំកិញ្ចិ អភិបត្ថិតន្តិ ។

[១៣] អថខោ ព្រហ្មាយុស្ស ព្រាហ្មណស្ស ឯតទហោសិ កតាវកាសោ ខោម្ហិ សមណេន គោតមេន កឹ នុ ខោ អហំ

១ ម. វោ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រហ្មាយុព្រាហ្មណ៍ ដោយគាថាទាំងឡាយថា

មហាបុរិសលក្ខណៈទាំងឡាយណា ដែលអ្នកបានចេះដឹងមកថា មាន ៣២ ប្រការ មហាបុរិសលក្ខណៈទាំងអស់នោះ មានក្នុងកាយនៃតថាគត ម្នាលព្រាហ្មណ៍ អ្នកកុំមានសេចក្តីសង្ស័យឡើយ ធម្មជាតដែលគួរដឹងច្បាស់ តថាគតបានដឹងច្បាស់ហើយ ធម្មជាតដែលគួរចម្រើន តថាគតបានចម្រើនហើយ ធម្មជាតដែលគួរលះបង់ តថាគតក៏បានលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគតឈ្មោះថា ព្រះពុទ្ធ តថាគតបើកឱកាសឲ្យអ្នកហើយ អ្នកចូរសួរនូវប្រស្នាណានីមួយ ដែលអ្នកត្រូវការចុះ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងលោកខាងមុខផង ។

[១៣] លំដាប់នោះ ព្រហ្មាយុព្រាហ្មណ៍ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ ព្រះសមណគោតមបានបើកឱកាសឲ្យហើយ អាត្មាអញ

២៩

ព្រាហ្មណវគ្គស្ស ព្រហ្មាយុសុត្តេ ភគវន្តំ បញ្ហាបុច្ឆនំ

សមណំ គោតមំ បុច្ឆេយ្យំ ទិដ្ឋធម្មិកំ វា អត្ថំ សម្បរាយិកំ វាតិ ។ អថខោ ព្រហ្មាយុស្ស ព្រាហ្មណស្ស ឯតទហោសិ កុសលោ ខោ អហំ ទិដ្ឋធម្មិកានំ អត្ថានំ អញ្ញេបិ មំ ទិដ្ឋធម្មិកំ អត្ថំ បុច្ឆន្តិ យន្នូនាហំ សមណំ គោតមំ សម្បរាយិកមេវ អត្ថំ បុច្ឆេយ្យន្តិ ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ ភគវន្តំ គាថាហិ អជ្ឈភាសិ

កថំ ខោ ព្រាហ្មណោ ហោតិ
កថំ ភវតិ វេទគូ
តេវិជ្ជោ ភោ កថំ ហោតិ
សោត្ថិយោ កិន្តិ វុច្ចតិ
អរហំ ភោ កថំ ហោតិ
កថំ ភវតិ កេវលី
មុនិ ច ភោ កថំ ហោតិ
ពុទ្ធោ កិន្តិ បវុច្ចតីតិ ។

គប្បីសួរព្រះសមណគោតមអំពីប្រយោជន៍ក្នុងបច្ចុប្បន្ន ឬប្រយោជន៍ក្នុងលោកខាងមុខ ។ ទើបព្រហ្មាយុព្រាហ្មណ៍ មានសេចក្ដីត្រិះរិះដូច្នេះទៀតថា អាត្មាអញជាបុគ្គលឈ្លាសវៃ ក្នុងប្រយោជន៍បច្ចុប្បន្ន ឯជនទាំងឡាយដទៃទៀត តែងសួរអាត្មាអញ អំពីប្រយោជន៍បច្ចុប្បន្នដែរ បើដូច្នោះ គួរតែអាត្មាអញសួរព្រះសមណគោតម អំពីប្រយោជន៍ក្នុងបរលោកវិញចុះ ។ ទើបព្រហ្មាយុព្រាហ្មណ៍ ពោលសួរព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា

បុគ្គលដូចម្ដេច ហៅថា ព្រាហ្មណ៍ បុគ្គលដូចម្ដេច ហៅថា អ្នកចេះចប់នូវត្រៃវេទ បុគ្គលដូចម្ដេច ហៅថា អ្នកមានត្រៃវិជ្ជា បុគ្គលដូចម្ដេច ហៅថា អ្នកមានសួស្តី បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដូចម្ដេច ហៅថា ព្រះអរហន្ត បុគ្គលដូចម្ដេច ហៅថា អ្នកបរិបូណ៌ដោយគុណទាំងអស់ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត បុគ្គលដូចម្ដេច ហៅថា មុនិ បុគ្គលដូចម្ដេច ដែលហៅថា ព្រះពុទ្ធ ។

[១៤] អថខោ ភគវា ព្រហ្មាយុំ ព្រាហ្មណំ គាថាហិ បច្ចភាសិ

បុព្វេនិវាសំ យោ វេទិ
សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ
អភិញ្ញាវោសិតោ មុនិ
ចិត្តំ វិសុទ្ធំ ជានាតិ
មុត្តំ រាគេហិ សព្វសោ
បហីនជាតិមរណោ
ព្រហ្មចរិយស្ស កេវលី
បារគូ សព្វធម្មានំ
ពុទ្ធោ តាទិ បវុច្ចតីតិ ។

[១៥] ឯវំ វុត្តេ ព្រហ្មាយុ ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវតោ បាទានិ មុខេន ច បរិចុម្ពតិ បាណីហិ[១] បរិសម្ពាហតិ នាមញ្ច សាវេតិ ព្រហ្មាយ្វាហំ[២] ភោ គោតម ព្រាហ្មណោ

១ ឱ. ម. ឯត្ថន្តរេ ចសទ្ទោ ទិស្សតិ ។ ២ ម. ព្រហ្មាយុហំ ។

[១៤] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបនឹងព្រហ្មាយុព្រាហ្មណ៍វិញ ដោយគាថាទាំងឡាយថា

បុគ្គលណា ដឹងនូវខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅ ក្នុងកាលមុន ឃើញច្បាស់នូវឋានសួគ៌និងអបាយ មួយទៀត បុគ្គលណា ដល់នូវកិរិយាអស់ទៅនៃជាតិ ដល់នូវទីបំផុតដោយអភិញ្ញា ជាអ្នកប្រាជ្ញដឹងច្បាស់នូវចិត្តដ៏បរិសុទ្ធ ជាចិត្តរួចស្រឡះហើយចាករាគៈ ដោយអាការៈទាំងពួង ជាអ្នកមានជាតិនិងមរណៈលះបង់ហើយ ជាអ្នកប្រកបដោយមគ្គព្រហ្មចរិយៈទាំងអស់ ជាអ្នកចេះចប់ នូវធម៌ទាំងអស់ បុគ្គលប្រាកដដូច្នោះ តថាគតហៅថា ព្រះពុទ្ធ ។

[១៥] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រហ្មាយុព្រាហ្មណ៍ ក៏ក្រោកអំពីអាសនៈ ធ្វើនូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ក្រាបទៀបព្រះបាទានៃព្រះមានព្រះភាគដោយក្បាល ជប់ព្រះបាទានៃព្រះមានព្រះភាគដោយមាត់ផង ច្របាច់ដោយដៃផង បន្លឺឈ្មោះរបស់ខ្លួនថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះថា ព្រហ្មាយុ-

ព្រហ្មាយ្វាហំ ភោ គោតម ព្រាហ្មណោតិ ។ អថខោ សា បរិសា អច្ឆរិយព្ភុតជាតា[១] អហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សមណស្ស មហិទ្ធិកតា មហានុភាវតា យត្រ ហិ នាមាយំ ព្រហ្មាយុ ព្រាហ្មណោ ញាតោ យសស្សី ឯវរូបំ បរមំ និបច្ចការំ ករិស្សតីតិ ។ អថខោ ភគវា ព្រហ្មាយុំ ព្រាហ្មណំ ឯតទវោច អលំ ព្រាហ្មណ ឧដ្ឋហ[២] និសីទ ត្វំ សកេ អាសនេ យតោ តេ មយិ ចិត្តំ បសន្នន្តិ ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ ឧដ្ឋហិត្វា សកេ អាសនេ និសីទិ ។

[១៦] អថខោ ភគវា ព្រហ្មាយុស្ស ព្រាហ្មណស្ស អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ ព្រហ្មាយុំ ព្រាហ្មណំ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ

---

១ ឱ. ម. អច្ឆរិយព្ភុតចិត្តជាតាតិ ទិស្សតិ ។ ២ ម. ឧដ្ឋាហិ ។

ព្រាហ្មណ៍ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គ ឈ្មោះព្រហ្មាយុព្រាហ្មណ៍ ។ គ្រានោះ បរិស័ទនោះ ក៏មានសេចក្ដីស្ងើច និងសេចក្ដីស្ញប់ស្ញែងថា អើ អស្ចារ្យណាស់ហ្ន៎ អើ ចំឡែកណាស់ហ្ន៎ សមណៈពេញជាមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថាព្រហ្មាយុព្រាហ្មណ៍នេះជាអ្នកមានកេរ្តិ៍ឈ្មោះ មានយស ហើយមានសេចក្ដីគោរពដ៏ក្រៃលែងមានសភាពដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រហ្មាយុព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ ល្មមហើយ អ្នកចូរក្រោកឡើង ចូរអង្គុយលើអាសនៈរបស់ខ្លួនចុះ ព្រោះចិត្តរបស់អ្នកជ្រះថ្លានឹងតថាគតហើយ ។ សម័យនោះ ព្រហ្មាយុព្រាហ្មណ៍ ក្រោកឡើងអង្គុយលើអាសនៈរបស់ខ្លួន ។

[១៦] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថាដល់ព្រហ្មាយុព្រាហ្មណ៍ គឺ ទ្រង់ប្រកាសនូវទានកថា សីលកថា សគ្គកថា និងទោសរបស់កាម ជាទោសដ៏លាមក សៅហ្មង និងអានិសង្ស ក្នុងការចេញចាកកាម ។ ព្រះមានព្រះភាគទ្រង់ជ្រាបថាព្រហ្មាយុព្រាហ្មណ៍ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តអណ្ដែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ

អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ព្រហ្មាយុស្ស ព្រាហ្មណស្ស តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។

[១៧] អថខោ ព្រហ្មាយុ ព្រាហ្មណោ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ

ទ្រង់ត្រាស់ នូវធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺទុក្ខ ១ សមុទ័យ ១ និរោធ ១ មគ្គ ១ ក្នុងកាលនោះ ។ សំពត់ស្អាត ប្រាសចាកវត្ថុមានពណ៌ខ្មៅ គួរទទួលនូវគ្រឿងជ្រលក់ដោយល្អបាន យ៉ាងណាមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់ព្រហ្មាយុព្រាហ្មណ៍ លើអាសនៈនោះឯងថា ធម្មជាតណានីមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា ក៏យ៉ាងនោះដែរ ។

[១៧] គ្រានោះ ព្រហ្មាយុព្រាហ្មណ៍ បានឃើញចតុស្សច្ចធម៌ហើយ បានដល់ចតុស្សច្ចធម៌ហើយ បានដឹងចតុស្សច្ចធម៌ហើយ បានចុះចិត្តស៊ប់កាន់ចតុស្សច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចបុគ្គលផ្ងារឡើងនូវរបស់ដែលផ្កាប់ទុក ឬបើកឡើងនូវរបស់ដែលបិទបាំងទុក ពុំនោះដូចគេប្រាប់ផ្លូវដល់មនុស្សអ្នកវង្វេងផ្លូវ ពុំនោះសោត ដូចគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សអ្នកមានភ្នែក រមែងមើលឃើញនូវរូប

ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតំ អធិវាសេតុ ច មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេតិ ភគវា តុណ្ហីភាវេន ។

[១៨] អថខោ ព្រហ្មាយុ ព្រាហ្មណោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ព្រហ្មាយុស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ

ទាំងឡាយ ព្រះធម៌ដែលព្រះគោតមដ៏ចម្រើន បានសំដែងហើយដោយអនេកបរិយាយក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះតទៅ មួយទៀត សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃ ទទួលនូវភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលដោយតុណ្ហីភាព ។

[១៨] គ្រានោះ ព្រហ្មាយុព្រាហ្មណ៍ ដឹងថាព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយចេញទៅ ។ លុះរាត្រីនោះកន្លងទៅ ព្រហ្មាយុ-ព្រាហ្មណ៍ ឲ្យតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ក្នុងផ្ទះរបស់ខ្លួនរួចហើយ ឲ្យមនុស្សទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលគួរហើយ ភត្តសម្រេចហើយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់ដោយបាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយស្ដេចចូលទៅកាន់ផ្ទះរបស់ព្រហ្មាយុព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេរៀបចំថ្វាយ

សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ ព្រហ្មាយុ ព្រាហ្មណោ សត្តាហំ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ ភគវា តស្ស សត្តាហស្ស អច្ចយេន វិទេហេសុ ចារិកំ បក្កាមិ ។

[១៩] អថខោ ព្រហ្មាយុ ព្រាហ្មណោ អចិរប្បក្កន្តស្ស ភគវតោ កាលមកាសិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ[១] តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ព្រហ្មាយុ ភន្តេ ព្រាហ្មណោ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។

[២០] បណ្ឌិតោ ភិក្ខវេ ព្រហ្មាយុ ព្រាហ្មណោ បច្ចបាទិ ធម្មំ សានុធម្មំ នេវ មំ[២] ធម្មាធិករណំ វិហេសេសិ ព្រហ្មាយុ[៣] ព្រាហ្មណោ

១ ឱ. ខោសទ្ទោ នត្ថិ ។ ២ ឱ. ធម្មស្សានុធម្មំ ន វ មន្តិ ទិស្សតិ ។ ម. ធម្ម... ន ច មន្តិ ទិស្សតិ ។ ៣ ឱ. ម. ឯត្ថន្តរេ ភិក្ខវេតិ ទិស្សតិ ។

ជាមួយនឹងភិក្ខុសង្ឃ ។ គ្រានោះ ព្រហ្មាយុព្រាហ្មណ៍ បានញុំាង ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែភិក្ខុសង្ឃហាមឃាត់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃនៃខ្លួនអស់ ៧ ថ្ងៃ ។ លុះថ្ងៃ ៧ កន្លងទៅហើយ ទើបព្រះមានព្រះភាគ ក៏ស្តេចចេញទៅកាន់ចារិក ក្នុងដែនវិទេហៈ ។

[១៩] គ្រានោះ កាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចេញទៅមិនយូរប៉ុន្មាន ព្រហ្មាយុព្រាហ្មណ៍ ក៏ធ្វើមរណកាល ។ លំដាប់នោះ ពួកភិក្ខុជាច្រើន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រហ្មាយុ-ព្រាហ្មណ៍ ធ្វើមរណកាលហើយ គតិរបស់គាត់ដូចម្តេច បរលោកដូចម្តេច ។

[២០] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រហ្មាយុ-ព្រាហ្មណ៍ជាបណ្ឌិត បាននូវធម៌[១] ព្រមទាំងអនុធម៌[២] ហើយមិនបានញុំាងតថាគតឲ្យលំបាក ព្រោះធម៌ជាហេតុ ព្រហ្មាយុព្រាហ្មណ៍

---

១ បានដល់អរហត្តមគ្គ ។ ២ បានដល់មគ្គទាំង ៣ ខាងក្រោម ។

៣៤



បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកាតិ ។ ឯវមាហ ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ព្រហ្មាយុសុត្តំ បឋមំ និដ្ឋិតំ ។

ជាឧបបាតិកៈកំណើត ព្រោះអស់ទៅនៃសញ្ញោជនៈ ជាចំណែកខាងក្រោមទាំង ៥ ហើយបរិនិព្វានក្នុងលោកនោះ មានសភាពជាអ្នកមិនត្រឡប់ចាកលោកនោះ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអរ រីករាយហើយ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

ចប់ ព្រហ្មាយុសូត្រ ទី ១ ។

# ទុតិយំ សេលសុត្តំ

[២១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អង្គុត្តរាបេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេ-ន សទ្ធឹ អឌ្ឍតេលសេហិ ភិក្ខុសតេហិ យេន អាបណំ នាម អង្គុត្តរាបានំ និគមោ តទវសរិ ។ អស្សោសិ ខោ កេណិយោ ជដិលោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ អង្គុត្តរាបេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេលសេហិ ភិក្ខុសតេហិ អាបណំ អនុប្បត្តោ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិស-ទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ

# សេលសូត្រ ទី ២

[២១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់ស្តេចទៅកាន់ចារិក ក្នុងអង្គុត្តរាបជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួនភិក្ខុ ១.២៥០ រូប ទ្រង់ស្តេចទៅដល់អាបណនិគមនៃអង្គុត្តរាបជនបទ ។ កេណិយជដិល បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ឥឡូវទ្រង់ស្តេចមកកាន់ចារិកក្នុងអង្គុត្តរាបជនបទ មួយអន្លើដោយភិក្ខុសង្ឃច្រើន ចំនួនភិក្ខុ ១.២៥០ រូប ទ្រង់ស្តេចមកដល់អាបណនិគមហើយ កិត្តិស័ព្ទល្អនៃព្រះគោតមដ៏ចម្រើននោះ សុសសាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងដោយប្រពៃ ចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ទូន្មាននូវបុរស ដែលគួរទូន្មានបាន ទ្រង់ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹង នូវអរិយសច្ចធម៌ ទ្រង់លែងវិលមកកាន់ភពថ្មីទៀត ព្រះសមណគោតមអង្គនោះ

ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសាន-កល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

[២២] អថខោ កេណិយោ ជដិលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កេណិយំ ជដិលំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ កេណិយោ ជដិលោ ភគវតា ធម្មិយា កថាយ សន្ទស្សិ-តោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ

ទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមចំពោះព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ព្រះអង្គសំដែងធម៌ មានលំអបទដើម មានលំអបទកណ្ដាល មានលំអបទចុង ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ទ្រង់ប្រកាសព្រហ្មចរិយៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ការបានឃើញព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក ។

[២២] គ្រានោះ កេណិយជដិល ចូលទៅគាល់ព្រះមានបុណ្យ លុះចូលទៅដល់ហើយ ក៏និយាយពាក្យរាក់ទាក់ សំណេះសំណាលមួយអន្លើដោយព្រះមានបុណ្យ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ អង្គុយក្នុងទីសមគួរ ។ ព្រះមានព្រះភាគទ្រង់សំដែងពន្យល់កេណិយជដិលដែលអង្គុយក្នុងទីសមគួរ ឲ្យយល់ (ប្រយោជន៍ក្នុងបច្ចុប្បន្ននិងបរលោក) ឲ្យជឿជាក់ (ក្នុងកុសលធម៌) ឲ្យសង្វាត (ធ្វើការកុសល) ឲ្យរីករាយ (ដោយគុណដែលមានក្នុងខ្លួន) ដោយធម្មីកថា ។ លុះព្រះមានព្រះភាគ ទ្រង់ពន្យល់កេណិយជដិល ឲ្យយល់ ឲ្យជឿជាក់ ឲ្យសង្វាត ឲ្យរីករាយដោយធម្មីកថាហើយ កេណិយជដិល

ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ ឯវំ វុត្តេ ភគវា កេណិយំ ជដិលំ ឯតទវោច មហា ខោ កេណិយ ភិក្ខុសង្ឃោ អឌ្ឍតេលសានិ ភិក្ខុសតានិ ត្វញ្ច ព្រាហ្មណេសុ អភិប្បសន្នោតិ ។ ទុតិយម្បិ ខោ កេណិយោ ជដិលោ ភគវន្តំ ឯតទវោច កិញ្ចាបិ ភោ[១] គោតម មហាភិក្ខុសង្ឃោ អឌ្ឍតេលសានិ ភិក្ខុសតានិ អហញ្ច ព្រាហ្មណេសុ អភិប្បសន្នោ អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ ទុតិយម្បិ ខោ ភគវា កេណិយំ ជដិលំ ឯតទវោច មហា ខោ កេណិយ ភិក្ខុសង្ឃោ អឌ្ឍតេលសានិ ភិក្ខុសតានិ ត្វញ្ច ព្រាហ្មណេសុ អភិប្បសន្នោតិ ។ តតិយម្បិ ខោ កេណិយោ ជដិលោ ភគវន្តំ ឯតទវោច កិញ្ចាបិ ភោ គោតម មហាភិក្ខុសង្ឃោ អឌ្ឍតេលសានិ ភិក្ខុសតានិ អហញ្ច ព្រាហ្មណេសុ អភិប្បសន្នោ

១ ម. ខោ ភោ ។

ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា សូមព្រះគោតម ដ៏ចម្រើន ទទួលភត្តាហាររបស់ខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុសង្ឃ ក្នុងថ្ងៃស្អែក ។ កាលបើកេណិយជដិលក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានឹងកេណិយជដិលដូច្នេះថា ម្នាលកេណិយៈ ភិក្ខុសង្ឃមានច្រើន ចំនួនភិក្ខុ ១.២៥០ រូប ចំណែកអ្នកក៏ធ្លាប់មានសេចក្ដីជ្រះថ្លា ចំពោះពួកព្រាហ្មណ៍ទៅហើយ ។ កេណិយជដិលក្រាបបង្គំទូលព្រះមានព្រះភាគ ជាគម្រប់ពីរដង ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភិក្ខុសង្ឃមានច្រើន ចំនួនភិក្ខុ ១.២៥០ រូប ចំណែកខ្លួនខ្ញុំព្រះអង្គធ្លាប់មានសេចក្ដីជ្រះថ្លាចំពោះពួកព្រាហ្មណ៍ ក៏មែនពិតហើយ តែបើទុកជាដូច្នោះ ក៏សូមព្រះគោតមដ៏ចម្រើន ទទួលភត្តាហាររបស់ខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុសង្ឃក្នុងថ្ងៃស្អែកឲ្យទាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងកេណិយជដិល ជាគម្រប់ពីរដងដូច្នេះថា ម្នាលកេណិយៈ ភិក្ខុសង្ឃមានច្រើន ចំនួនភិក្ខុ ១.២៥០ រូប ចំណែកអ្នកក៏ធ្លាប់មានសេចក្ដីជ្រះថ្លា ចំពោះពួកព្រាហ្មណ៍ទៅហើយ ។ កេណិយជដិល ក្រាបបង្គំទូលព្រះមានបុណ្យ ជាគម្រប់បីដង ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ភិក្ខុ-សង្ឃមានច្រើន ចំនួនភិក្ខុ ១.២៥០ រូប ចំណែកខ្ញុំព្រះអង្គធ្លាប់មានសេចក្ដីជ្រះថ្លា ចំពោះពួកព្រាហ្មណ៍ ក៏ពិតមែនហើយ តែបើទុកជាដូច្នោះ

៣៩

ព្រាហ្មណវគ្គស្ស សេលសុត្តេ ភគវតោ អធិវាសនា

អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេតិ ភគវា តុណ្ហីភាវេន ។ អថខោ កេណិយោ ជដិលោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា យេន សកោ អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា មិត្តាមច្ចេ ញាតិសាលោ-ហិតេ អាមន្តេសិ សុណន្តុ មេ ភោន្តោ មិត្តាមច្ចា ញាតិសាលោហិតា សមណោ គោតមោ និមន្តិតោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេន យេន មេ កាយវេយ្យាវត្តិកំ ករេយ្យាថាតិ ។ ឯវំ ភោតិ ខោ កេណិយស្ស ជដិលស្ស មិត្តាមច្ចា ញាតិសាលោហិ-តា កេណិយស្ស ជដិលស្ស បដិស្សុត្វា អប្បេកច្ចេ ឧទ្ធនានិ ខនន្តិ អប្បេកច្ចេ កដ្ឋានិ ផាលេន្តិ អប្បេ-កច្ចេ ភាជនានិ ធោវន្តិ អប្បេកច្ចេ ឧទកមណិកំ បតិដ្ឋាបេន្តិ អប្បេកច្ចេ អាសនានិ បញ្ញាបេន្តិ ។ កេណិយោបិ ជដិលោ សាមញ្ញេវ[១] មណ្ឌលមាឡំ បដិយាទេតិ ។

---

១ ម. សាមំយេវ ។

ក៏សូមព្រះគោតមដ៏ចម្រើន ទទួលភត្តាហាររបស់ខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុសង្ឃក្នុងថ្ងៃស្អែកឲ្យទាន ។ ព្រះមានបុណ្យទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ កេណិយជដិលដឹងថា ព្រះមានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកអំពីអាសនៈ ចូលទៅកាន់អាស្រមរបស់ខ្លួន លុះចូលទៅដល់ហើយ ហៅពួកមិត្រអាមាត្យនិងញាតិសាលោហិត (មកនិយាយថា) សូមមិត្រអាមាត្យនិងញាតិសាលោហិតដ៏ចម្រើនទាំងឡាយស្តាប់ (ពាក្យខ្ញុំ) ដ្បិតខ្ញុំបាននិមន្តព្រះសមណគោតមមកទទួលភត្ត ក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ ចូរអ្នកទាំងឡាយខ្វល់ខ្វាយបម្រើដោយកាយ តាមយើង ។ ពួកមិត្រអាមាត្យនិងញាតិសាលោហិត របស់កេណិយជដិលទទួលស្តាប់ពាក្យកេណិយជដិលថា បាទ លោកដ៏ចម្រើន ហើយពួកខ្លះជីកគុកធ្វើចង្ក្រាន ពួកខ្លះពុះឧស ពួកខ្លះលាងភាជន៍ ពួកខ្លះតម្កល់ក្អមទឹក ពួកខ្លះក្រាលអាសនៈ ។ ឯកេណិយជដិលចាត់ចែងបារាំ មានសណ្ឋានមូល[១] ដោយខ្លួនឯង ។

---

១ អដ្ឋកថា ថា មណ្ឌប (បារាំ) ប្រក់សំពត់ ។

[២៣] តេន ខោ បន សមយេន សេលោ ព្រាហ្មណោ អាបណេ បដិវសតិ តិណ្ណំ វេទានំ ចារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ តីណិ មាណវកសតានិ មន្តេ វាចេតិ ។ តេន ខោ បន សមយេន កេណិយោ ជដិលោ សេលេ ព្រាហ្មណេ អភិប្បសន្នោ ហោតិ ។ អថខោ សេលោ ព្រាហ្មណោ តីហិ មាណវកសតេហិ បរិវុតោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន កេណិយស្ស ជដិលស្ស អស្សមោ តេនុបសង្កមិ ។ អទ្ទសា ខោ សេលោ ព្រាហ្មណោ កេណិយស្មឹ ជដិលេ[១] អប្បេកច្ចេ ឧទ្ធនានិ ខណន្តេ អប្បេកច្ចេ កដ្ឋានិ ផាលេន្តេ អប្បេកច្ចេ ភាជនានិ ធោវន្តេ អប្បេកច្ចេ ឧទកមណិកំ បតិដ្ឋាបេន្តេ អប្បេកច្ចេ អាសនានិ បញ្ញាបេន្តេ

១ ម. កេណិយស្ស ជដិលស្ស អស្សមេតិ ទិស្សតិ ។

[២៣] សម័យនោះឯង សេលព្រាហ្មណ៍ អាស្រ័យនៅក្នុង អាបណនិគម ជាអ្នកចេះចប់ត្រៃវេទ គឺឥរុវេទ យជុវេទ និងសាមវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ គម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខា និងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគម្រប់ប្រាំ ជាអ្នករៀនទូវបទនិង វេយ្យាករណ៍ ជាអ្នកមិនអួនថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ តែងបង្រៀនទូវមន្តទាំងឡាយ ដល់ពួកមាណពជំទង់ ៗ ចំនួន ៣០០ នាក់ ។ សម័យនោះ កេណិយជដិល ជាអ្នកជ្រះថ្លាចំពោះសេលព្រាហ្មណ៍ ។ គ្រានោះ សេលព្រាហ្មណ៍ មានពួកមាណពជំទង់ ៗ ចំនួន ៣០០ នាក់ហែហម ដើរត្រាច់ចុះឡើងដើម្បីសម្រួលស្មង ហើយក៏ចូលទៅអាស្រមរបស់កេណិយជដិល ។ សេលព្រាហ្មណ៍បានឃើញមនុស្សពួកខ្លះ កំពុងជីកគុកធ្វើចង្ក្រាន ពួកខ្លះកំពុងពុះឧស ពួកខ្លះកំពុងលាងភាជន៍ ពួកខ្លះកំពុងតម្កល់ក្អមទឹក ពួកខ្លះកំពុងក្រាលអាសនៈ ជិតអាស្រមរបស់កេណិយជដិល

កេណិយំ ជដិលំ សាមញ្ញេវ មណ្ឌលមាឡំ បដិយាទេន្តំ ទិស្វាន កេណិយំ ជដិលំ ឯតទវោច កឹ នុ ភោតោ កេណិយស្ស អាវាហោ វា ភវិស្សតិ វិវាហោ វា ភវិស្សតិ មហាយញ្ញោ វា បច្ចុបដ្ឋិតោ រាជា[១] មាគធោ សេនិយោ ពិម្ពិសារោ និមន្តិតោ ស្វាតនាយ សទ្ធឹ ពលកាយេនាតិ ។ ន មេ ភោ សេល[២] អាវាហោ វា ភវិស្សតិ នបិ វិវាហោ វា ភវិស្សតិ នបិ រាជា មាគធោ សេនិយោ ពិម្ពិសារោ និមន្តិតោ ស្វាតនាយ សទ្ធឹ ពលកាយេន អបិច ខោ មេ មហាយញ្ញោ បច្ចុបដ្ឋិតោ អត្ថិ[៣] សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ អង្គុត្តរាបេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេ-លសេហិ ភិក្ខុសតេហិ អាបណំ អនុប្បត្តោ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្ម-

១ ម. រាជា វា ។ ២ ម. សេលាតិ ន ទិស្សតិ ។ ៣ ម. អត្ថិ ភោ ។

បានឃើញកេណិយជដិលកំពុងចាត់ចែងបារាំមានសណ្ឋានមូលដោយខ្លួនឯង លុះឃើញហើយ ក៏សួរកេណិយជដិលដូច្នេះថា លោកកេណិយ-ជដិលដ៏ចម្រើន មានអាពាហ៍ពិពាហ៍ ឬតាំងមហាយ័ញ្ញ ឬអញ្ជើញព្រះបាទមាគធសេនិយពិម្ពិសារ ព្រមទាំងពួកពល ដើម្បីជប់លៀងក្នុងថ្ងៃស្អែកឬអ្វីហ្ន៎ ។ កេណិយជដិលនិយាយថា បពិត្រលោកសេលៈដ៏ចម្រើន ខ្ញុំមិនមានអាពាហ៍ពិពាហ៍ មិនអញ្ជើញព្រះបាទមាគធសេនិយពិម្ពិសារ ព្រមទាំងពួកពលដើម្បីជប់លៀងក្នុងថ្ងៃស្អែកទេ ខ្ញុំតាំងមហាយ័ញ្ញទេតើ ដ្បិតព្រះសមណគោតម ជាសក្យបុត្រចេញចាកសក្យត្រកូលទ្រង់ព្រះផ្នួស ហើយទ្រង់ត្រាច់មកកាន់ចារិក ក្នុងអង្គុត្តរាបជនបទ មួយអន្លើដោយភិក្ខុ-សង្ឃជាច្រើន ចំនួនភិក្ខុ ១.២៥០ រូប ឥឡូវទ្រង់ស្តេចមកដល់អាបណ-និគមហើយ កិត្តិសព្ទល្អនៃព្រះគោតមដ៏ចម្រើននោះ ខ្ចរខ្ចាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ទ្រង់ទូន្មាននូវបុរសដែលគួរ

សារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ សោ មេ និមន្តិតោ ស្វាតនាយ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ ពុទ្ធោតិ ភោ កេណិយ វទេសីតិ ។ ពុទ្ធោតិ ភោ សេល វទាមីតិ ។ ពុទ្ធោតិ ភោ កេណិយ វទេសីតិ ។ ពុទ្ធោតិ ភោ សេល វទាមីតិ ។ អថខោ សេលស្ស ព្រាហ្មណស្ស ឯតទហោសិ ឃោសោបិ ខោ ឯសោ ទុល្លភោ លោកស្មឹ យទិទំ ពុទ្ធោតិ អាគតានិ ខោ បនម្ហាកំ មន្តេសុ ទ្វត្តឹស មហាបុរិ-សលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេវ គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្ត រតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ

ទូន្មានបាន ទ្រង់ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ចធម៌ ទ្រង់លែងវិលមកកាន់ភពថ្មីទៀត ខ្ញុំបាននិមន្តព្រះសមណគោតមអង្គនោះ មួយអន្លើដោយភិក្ខុសង្ឃ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ សេលព្រាហ្មណ៍សួរថា ម្នាលកេណិយៈដ៏ចម្រើន អ្នកនិយាយថាព្រះពុទ្ធឬ ។ កេណិយជដិលឆ្លើយថា បពិត្រលោកសេលៈដ៏ចម្រើន ខ្ញុំនិយាយថាព្រះពុទ្ធ ។ សេលព្រាហ្មណ៍សួរថា ម្នាលកេណិយៈដ៏ចម្រើន អ្នកនិយាយថា ព្រះពុទ្ធឬ ។ កេណិយជដិលឆ្លើយថា បពិត្រលោកសេលៈដ៏ចម្រើន ខ្ញុំនិយាយថា ព្រះពុទ្ធ ។ លំដាប់នោះ សេលព្រាហ្មណ៍ មានសេចក្តីត្រិះរិះដូច្នេះថា សូរសព្ទបែបនេះ រកបានដោយកម្រក្នុងលោក ពាក្យថា ព្រះពុទ្ធដូច្នេះ មានមកក្នុងមន្តរបស់យើងថា មហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ តែងមានគតិ ២ យ៉ាងជាប្រាកដ មិនមែនដទៃឡើយ គឺថា បើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ ជាធម្មិកធម្មរាជ គ្រប់គ្រងផែនដី ដែលមានសមុទ្រទាំង ៤ ជាព្រំប្រទល់ ជាស្តេចឈ្នះសង្គ្រាម ដល់នូវសេចក្តីមាំមួនក្នុងជនបទ ប្រកបដោយរ័តន៍ទាំង ៧ ប្រការ មហាបុរសនោះ រមែងមានរ័តន៍ទាំង ៧ ប្រការនេះ គឺចក្ករ័តន៍

ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បថវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសតិ សចេ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដច្ឆទោ កហំ បន ភោ កេណិយ ឯតរហិ សោ ភវំ គោតមោ វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។

[២៤] ឯវំ វុត្តេ កេណិយោ ជដិលោ ទក្ខិណំ ពាហំ បគ្គហេត្វា សេលំ ព្រាហ្មណំ ឯតទវោច យេនេសា ភោ សេល នីលវនរាជីតិ ។ អថខោ សេលោ ព្រាហ្មណោ តីហិ មាណវកសតេហិ សទ្ធឹ យេន ភគវា តេនុបសង្កមិ ។ អថខោ សេលោ

ហត្ថិរ័តន៍ អស្សរ័តន៍ មណិរ័តន៍ ឥត្ថីរ័តន៍ គហបតិរ័តន៍ និងបរិណាយក-រ័តន៍ ជាគម្រប់ ៧ មួយទៀត មហាបុរសនោះ មានរាជបុត្រច្រើនជាងពាន់ជាបុត្រដ៏ក្លៀវក្លា មានសភាពជាអ្នកប្រកបដោយព្យាយាម អាចញាំញីនូវសេនារបស់ស្តេចដទៃបាន មហាបុរសនោះ គ្រួតគ្រានូវផែនដីនេះ ដែលមានសាគរជាទីបំផុត ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាឡើយ បើមហាបុរសនោះចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូលគឺកិលេសបើកហើយ ម្នាលកេណិយៈដ៏ចម្រើន ចុះឥឡូវនេះ ព្រះគោតមដ៏ចម្រើនជាអរហន្តសម្មាសម្ពុទ្ធនោះ នៅឯណា ។

[២៤] កាលបើសេលព្រាហ្មណ៍ និយាយយ៉ាងនេះហើយ កេ-ណិយជដិលលើកដៃខាងស្តាំឡើង និយាយប្រាប់សេលព្រាហ្មណ៍ដូច្នេះថា បពិត្រលោកសេលៈដ៏ចម្រើន ព្រះអង្គគង់នៅឯជួរព្រៃ មានពណ៌ខៀវ ៗ ឯណោះ ។ លំដាប់នោះ សេលព្រាហ្មណ៍ចូលទៅគាល់ព្រះមានបុណ្យ ជាមួយនឹងពួកមាណពជំទង់ ៣០០ នាក់ ។ ទើបសេល-

ព្រាហ្មណោ តេ មាណវកេ អាមន្តេសិ អប្បសទ្ទា ភោន្តោ អាគច្ឆន្តុ បទេ បទំ និក្ខិបន្តា ទុរា សទា ហិ តេ ភវន្តោ សីហាវ ឯកចរា យទា ចាហំ ភោតា សមណេន គោតមេន សទ្ធឹ មន្តេយ្យំ មា មេ ភោ- ន្តោ[១] អន្តរន្តរា កថំ ឱបាតេថ កថាបរិយោសា- នំ ច[២] មេ ភវន្តោ អាគមេន្តូតិ ។ អថខោ សេលោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្ក- មិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯក- មន្តំ និសិន្នោ ខោ សេលោ ព្រាហ្មណោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ សម្មន្នេសិ ។ អទ្ទសា ខោ សេលោ ព្រាហ្មណោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សំបសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហុតជិវ្ហតាយ ច ។

១ ម. ភោន្តោបិ ។ ២ ម. ចសទ្ទោ នត្ថិ ។

ព្រាហ្មណ៍ហាមប្រាមពួកមាណពទាំងនោះថា ចូរអ្នកដ៏ចម្រើនទាំងឡាយ មានសំឡេងតិច ៗ ដើរមក ចូរអ្នកដ៏ចម្រើនទាំងឡាយ ថ្នមជើងរាល់ ៗ ជំហានតាំងពីចម្ងាយបណ្តើរ ៗ ទៅ ចូរអ្នកដ៏ចម្រើនទាំងនោះ ធ្វើដូចជាសីហៈត្រេចទៅតែម្នាក់ឯង កាលណាបើខ្ញុំត្រូវប្រឹក្សាមួយអន្លើដោយព្រះសមណគោតមដ៏ចម្រើន អ្នកដ៏ចម្រើនទាំងឡាយ កុំធ្វើពាក្យរបស់ខ្ញុំឲ្យដាច់ក្នុងចន្លោះ ៗ ឡើយ ចូរអ្នកដ៏ចម្រើនទាំងឡាយ បង្អង់ចាំខ្ញុំនិយាយចប់សិន ។ លំដាប់នោះ សេលព្រាហ្មណ៍ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏និយាយពាក្យរាក់ទាក់សំណេះសំណាលមួយអន្លើដោយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសេលព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ពិចារណាមើលនូវមហាបុរិសលក្ខណៈទាំង ៣២ ក្នុងព្រះកាយរបស់ព្រះដ៏មានបុណ្យ ។ សេលព្រាហ្មណ៍ បានឃើញមហាបុរិសលក្ខណៈទាំង ៣២ ក្នុងព្រះកាយរបស់ព្រះមានបុណ្យដោយច្រើន លើកលែងតែមហាបុរិសលក្ខណៈ ២ ប្រការចេញ ក៏មានសេចក្តីសង្ស័យ ងឿងឆ្ងល់ មិនអស់ចិត្ត មិនជ្រះថ្លាស៊ប់ ក្នុងមហាបុរិសលក្ខណៈទាំង ២ ប្រការ (នោះ) គឺអវយវៈដែលត្រូវលាក់ក្នុងសំពត់ បិតនៅក្នុងស្រោម ១ ព្រះជិវ្ហាដ៏ល្មម ១ ។

ព្រាហ្មណវគ្គស្ស សេលសុត្តេ ភគវតោ បរិវិតក្កនំ

[២៥] អថខោ ភគវតោ ឯតទហោសិ បស្សតិ ខោ មេ អយំ សេលោ ព្រាហ្មណោ ទ្វត្តឹស មហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សំបសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហុតជិវ្ហតាយ ចាតិ ។ អថខោ ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ យថា អទ្ទស សេលោ ព្រាហ្មណោ ភគវតោ កោសោហិតំ វត្ថគុយ្ហំ ។ អថខោ ភគវា ជិវ្ហំ និន្នាមេត្វា ឧភោបិ កណ្ណសោតានិ អនុមសិ បដិមសិ ឧភោបិ នាសិកសោតានិ អនុមសិ បដិមសិ កេវលកប្បំ នលាដមណ្ឌលំ ជិវ្ហាយ ឆាទេសិ ។

[២៦] អថខោ សេលស្ស ព្រាហ្មណស្ស ឯតទហោសិ សមន្នាគតោ ខោ សមណោ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ បរិបុណ្ណេហិ នោ អបរិបុណ្ណេហិ នោ ច ខោ នំ ជានាមិ ពុទ្ធោ វា នោ វា

[២៥] គ្រានោះ ព្រះមានបុណ្យ មានសេចក្ដីត្រិះរិះ ដូច្នេះថា សេលព្រាហ្មណ៍នេះឃើញមហាបុរិសលក្ខណៈទាំង ៣២ ប្រការ របស់តថាគត ដោយច្រើន លើកលែងតែមហាបុរិសលក្ខណៈ ២ ប្រការប៉ុណ្ណោះ ក៏មានសេចក្ដីសង្ស័យ ងឿងឆ្ងល់ មិនអស់ចិត្ត មិនជ្រះថ្លាស៊ប់ ក្នុងមហាបុរិសលក្ខណៈទាំង ២ ប្រការ គឺអវយវៈដែលត្រូវលាក់ក្នុងសំពត់ ឋិតនៅក្នុងស្រោម ១ ជិវ្ហាដ៏ល្មម ១ ។ ទើបព្រះមានបុណ្យសំដែងនូវឥទ្ធានុភាពមានសភាពដូច្នោះ ឲ្យសេលព្រាហ្មណ៍បានឃើញអវយវៈដែលត្រូវលាក់ ក្នុងសំពត់ដែលឋិតនៅក្នុងស្រោមរបស់ព្រះអង្គ ។ លំដាប់ពីនោះមក ព្រះមានព្រះភាគទ្រង់លៀនព្រះជិវ្ហា ឲ្យទៅជដុសនឹងរន្ធព្រះកាណ៌ទាំងពីរផង ឲ្យទៅជដុសនឹងរន្ធព្រះនាសិកទាំងពីរផង មិនតែប៉ុណ្ណោះ ទ្រង់បញ្ចេញព្រះជិវ្ហាទៅបាំងមណ្ឌលនៃព្រះនលាដទាំងអស់ផង ។

[២៦] គ្រានោះ សេលព្រាហ្មណ៍មានសេចក្ដីត្រិះរិះដូច្នេះថា ព្រះសមណគោតម ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ប្រការ ពេញលេញ ឥតខ្វះខាតមែនហើយ តែអាត្មាអញមិនទាន់ស្គាល់ព្រះសមណគោតមនោះ ថាជាព្រះពុទ្ធ ឬមិនមែនជាព្រះពុទ្ធនៅ

សុតំ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ[១] មហល្លកានំ អាចរិយប្បាចរិយានំ ភាសមានានំ យេ តេ ភវន្តិ អរហន្តោ សម្មាសម្ពុទ្ធា តេ សកេ វណ្ណេ ភញ្ញមានេ អត្តានំ ចាតុករោន្តីតិ[២] យន្នូនាហំ សមណំ គោតមំ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវេយ្យន្តិ ។ អថខោ សេលោ ព្រាហ្មណោ ភគវន្តំ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវិ

បរិបុណ្ណកាយោ សុរុចី
សុជាតោ ចារុទស្សនោ
សុវណ្ណវណ្ណោសិ ភគវា
សុសុក្កទាឋោ សវីរិយវា[៣]
នរស្ស ហិ សុជាតស្ស
យេ ភវន្តិ វិសុញ្ជនា[៤]
សព្វេ តេ តវ កាយស្មឹ
មហាបុរិសលក្ខណា
បសន្ននេត្តោ សុមុខោ

១ ម. ខោ បន ។ ២ ម. តិសទ្ទោ នត្ថិ ។ ៣ ម. វីរិយវា ។ ៤ ម. វិយញ្ជនា ។

ឡើយទេ អាត្មាអញគ្រាន់តែបានឮពាក្យនុ៎ះ អំពីសំណាក់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ ចាស់ទុំ ជាអាចារ្យប្រធានលើអាចារ្យ និយាយថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណាមានក្នុងលោក កាលបើមានគេសរសើរគុណរបស់ព្រះអង្គ ព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ រមែងធ្វើនូវខ្លួន (របស់ព្រះអង្គ) ឲ្យជាក់ច្បាស់ បើដូច្នោះ គួរតែអាត្មាអញសរសើរព្រះសមណគោតម ដោយគាថាទាំងឡាយដ៏សមគួរក្នុងទីចំពោះព្រះភក្ត្រព្រះអង្គ ។ លំដាប់នោះ សេលព្រាហ្មណ៍និយាយសរសើរដោយគាថាទាំងឡាយដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគថា

បពិត្រព្រះមានបុណ្យ ព្រះអង្គមានព្រះកាយពេញលេញ
មានព្រះសរីរៈល្អ មានកំពស់និងទំហំសមសួន អ្នកផងមើល
មិនចេះឆ្អែតឆ្អន់ មានសម្បុរដូចមាស មានព្រះទាឋាស្អាត
ទ្រង់ប្រកបដោយសេចក្តីព្យាយាម មហាបុរិសលក្ខណៈ
ទាំងឡាយ ដែលមានដល់ជនអ្នកមានកំណើតល្អយ៉ាងណា
មហាបុរិសលក្ខណៈទាំងអស់នោះ ក៏មានក្នុងព្រះកាយរបស់
ព្រះអង្គយ៉ាងនោះដែរ ព្រះអង្គមានព្រះនេត្រថ្លា មានព្រះភក្ត្រ

៤៧

ព្រាហ្មណវគ្គស្ស សេលសុត្តេ ភគវន្តាភិត្ថុតិ

ព្រហ្មា ឧជុ បតាបវា
មជ្ឈេ សមណសង្ឃស្ស
អាទិច្ចោវ វិរោចសិ
កល្យាណទស្សនោ ភិក្ខុ
កញ្ចនសន្និភត្តចោ
កឹ តេ សមណភាវេន
ឯវំ ឧត្តមវណ្ណិនោ
រាជា អរហសិ ភវិតុំ
ចក្កវត្តិ រថេសភោ
ចាតុរន្តោ វិជិតាវី
ជម្ពុសណ្ឌស្ស[១] ឥស្សរោ
ខត្តិយា ភោជរាជានោ[២]
អនុយុត្តា ភវន្តុ តេ
រាជាភិរាជា មនុជិន្ទោ
រជ្ជំ ការេហិ គោតម[៣]
រាជាហមស្មិ សេលាតិ (ភគវា)
ធម្មរាជា អនុត្តរោ

---

១ ម. ជម្ពុមណ្ឌស្ស ។ ២ ម. ភោគិរាជានោ ។ ៣ ម. ការេថ គោតមំ ។

ស្រស់បស់ មានព្រះអង្គាវយវៈត្រង់ដូចជាអង្គព្រហ្ម មានព្រះរស្មី មានព្រះញាណដ៏ល្អ ទ្រង់ខ្វាចក័យក្នុងសង្សារវដ្ដ ទ្រង់មានព្រះតចៈភ្លឺដូចមាស រុងរឿងកណ្ដាលពពួកសមណៈ ដូចជាព្រះអាទិត្យ ព្រះអង្គមានពន្លឺដ៏ថ្លៃថ្លាយ៉ាងនេះ ត្រូវការអ្វីដោយសមណភាព គួរណាស់តែសោយរាជ្យជាស្ដេចចក្រពត្តិ (ទូន្មានប្រជាជន ឲ្យត្រឹមត្រូវតាមធម៌) ដូចជាសារថីដ៏ឧត្ដម ទ្រង់គ្រប់គ្រងផែនដីរហូតដល់សមុទ្រទាំង ៤ ជាទីបំផុត ជាស្ដេចឈ្នះសង្គ្រាម ជាឥស្សរៈនៃជម្ពូទ្វីប ពួកខត្តិយជាតិដែលសោយរាជ្យ ដោយភោគសម្បទ ចូលមកជាក្សត្រិយ៍ចំណុះព្រះអង្គ បពិត្រព្រះគោតម សូមព្រះអង្គសោយរាជសម្បត្តិ ជាព្រះរាជាធិរាជដ៏ធំជាងមនុស្ស (ព្រះមានព្រះភាគ) ត្រាស់ថា ម្នាលសេលព្រាហ្មណ៍ តថាគតជាស្ដេចព្រោះធម៌ ប្រសើរដោយគុណឥតបុគ្គលណាស្មើ

ធម្មេន ចក្កំ វត្តេមិ

ចក្កំ អប្បដិវត្តិយំ

សម្ពុទ្ធោ បដិជានាសិ (ឥតិ សេលោ ព្រាហ្មណោ)

ធម្មរាជា អនុត្តរោ

ធម្មេន ចក្កំ វត្តេមិ

ឥតិ ភាសសិ គោតម

កោ នុ សេនាបតិ ភោតោ

សាវកោ សត្ថុ ឧន្វយោ

កោ តេមំ អនុវត្តេតិ

ធម្មចក្កំ បវត្តិតំ

មយា បវត្តិតំ ចក្កំ (សេលាតិ ភគវា)

ធម្មចក្កំ អនុត្តរំ

សារីបុត្តោ អនុវត្តេតិ

អនុជាតោ តថាគតំ

អភិញ្ញេយ្យំ អភិញ្ញាតំ

ញ៉ាំងចក្រជាចក្រដែលបុគ្គលដទៃឲ្យប្រព្រឹត្តទៅមិនកើត ឲ្យប្រព្រឹត្តទៅតាមធម៌បាន (សេលព្រាហ្មណ៍ក្រាបបង្គំទូលថា បើដូច្នោះ) ព្រះអង្គជាព្រះសម្ពុទ្ធ បានត្រាស់ដឹងហើយតើ (ព្រះអង្គត្រាស់ថា) តថាគតជាស្តេចព្រោះធម៌ហើយ ប្រសើរដោយគុណ ឥតបុគ្គលណាស្មើ ញ៉ាំងចក្រឲ្យប្រព្រឹត្តទៅតាមធម៌បាន សេលព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតម សូមព្រះអង្គប្រាប់ខ្ញុំ ចុះលោកណាជាសេនាបតីជាសាវ័ករបស់ព្រះសាស្តា ចុះលោកណាញ៉ាំងធម្មចក្រដែលព្រះអង្គឲ្យប្រព្រឹត្តទៅហើយនេះ ឲ្យប្រព្រឹត្តទៅបាន (ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសេលព្រាហ្មណ៍) ធម្មចក្រណា ដែលតថាគតឲ្យប្រព្រឹត្តទៅ សារីបុត្តជាអនុជាតក៏ញ៉ាំងធម្មចក្រនោះ ឲ្យប្រព្រឹត្តទៅ ទុក្ខសច្ច និងនិរោធសច្ច ដែលតថាគតត្រូវដឹងច្បាស់ ក៏តថាគតបានដឹង

៤៩

ព្រាហ្មណវគ្គស្ស សេលសុត្តេ ភគវន្តាភិត្ថុតិ

ភាវេតព្វញ្ច ភាវិតំ
បហាតព្វំ បហីនំ មេ
តស្មា ពុទ្ធោស្មិ ព្រាហ្មណ
វិនយស្សុ មយិ កង្ខំ
អធិមុច្ចស្សុ ព្រាហ្មណ
ទុល្លភំ ទស្សនំ ហោតិ
សម្ពុទ្ធានំ អភិណ្ហសោ
យេសំ វេ ទុល្លភោ លោកេ
បាតុភាវោ អភិណ្ហសោ
សោហំ ព្រាហ្មណ សម្ពុទ្ធោ
សល្លកត្តោ អនុត្តរោ
ព្រហ្មភូតោ អតិតុលោ
មារសេនប្បមទ្ទនោ
សព្វាមិត្តេ វសីកត្វា
មោទាមិ អកុតោភយោ
ឥមំ ភោន្តោ និសាមេថ
យថា ភាសតិ ចក្ខុមា

ច្បាស់ហើយ មគ្គសច្ចដែលតថាគតត្រូវអប់រំ ក៏តថាគតបានអប់រំហើយ សមុទយសច្ច ដែលតថាគតត្រូវលះបង់ ក៏តថាគត បានលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ បានជាតថាគតឈ្មោះថាព្រះពុទ្ធ ម្នាលព្រាហ្មណ៍ អ្នកចូរនាំបង់ ជម្រះបង់ នូវសេចក្តីសង្ស័យក្នុងតថាគតចេញ ការចួបប្រទះនឹងព្រះសម្ពុទ្ធទាំងឡាយរឿយ ៗ គេមិនងាយនឹងបានទេ ការកើតប្រាកដឡើងក្នុងលោករឿយ ៗ នៃព្រះសម្ពុទ្ធទាំងឡាយ ក៏គេមិនងាយនឹងបានដែរ ម្នាលព្រាហ្មណ៍ តថាគតហ្នឹងឯងជាព្រះពុទ្ធ ជាពេទ្យវះ មិនមានពេទ្យដទៃប្រសើរជាងឡើយ មានសភាពជាអ្នកប្រសើរ កន្ទេងបង់នូវសេចក្តីប្រៀបផ្ទឹម ជាអ្នកញាំញីនូវមារ និងសេនារបស់មារ ធ្វើពួកសត្រូវទាំងអស់ ឲ្យលុះក្នុងអំណាចបាន ឥតមានភ័យអំពីអ្វី រមែងរីករាយ ទើបសេលព្រាហ្មណ៍និយាយនឹងពួកមាណពទាំងនោះថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ចូរអ្នកទាំងឡាយស្តាប់ នូវព្រះពុទ្ធដីកានេះចុះ ព្រះមានចក្ខុ ជា

៤០



សល្លកត្តោ មហាវីរោ
សីហោវ នទតី វនេ
ព្រហ្មភូតំ អតិតុលំ
មារសេនប្បមទ្ទនំ
កោ ទិស្វា នប្បសីទេយ្យ
អបិ កណ្ហាភិជាតិកោ
យោ មំ ឥច្ឆតិ អន្វេតុ
យោ ច និច្ឆតិ គច្ឆតុ
ឥធាហំ បព្វជិស្សាមិ
វរប្បញ្ញស្ស សន្តិកេ
ឯវញ្ចេ រុច្ចតិ ភោតោ
សម្មាសម្ពុទ្ធសាសនំ
មយំបិ បព្វជិស្សាម
វរប្បញ្ញស្ស សន្តិកេ
ព្រាហ្មណា តិសតា ឥមេ

ពេទ្យវះ (ដ៏ប្រសើរ) មានព្យាយាមធំ ទ្រង់មានព្រះពុទ្ធ-ដីកាមកទាំងប៉ុន្មាន ដូចជាសីហៈបន្លឺក្នុងព្រៃ នរណាបានឃើញព្រះសាស្តា មានសភាពជាបុគ្គលប្រសើរ កន្ទង់បង់នូវសេចក្តីប្រៀបផ្ទឹម ជាអ្នកញាំញីនូវមារនិងសេនានៃមារហើយ (ដូចម្តេចឡើយ) នឹងអត់ទ្រាំមិនជ្រះថ្លាបាន សូម្បីជនអ្នកកើតក្នុងត្រកូលដ៏ថោកទាប (ក៏គង់ជ្រះថ្លានឹងព្រះអង្គដែរ) អ្នកណាចូលចិត្តតាមខ្ញុំ អ្នកនោះចូរមក អ្នកណាមិនចូលចិត្តទេ អ្នកនោះចូរទៅចុះ ខ្ញុំនឹងបួសក្នុងសំណាក់នៃព្រះសម្ពុទ្ធ ព្រះអង្គមានប្រាជ្ញាដ៏ប្រសើរ ក្នុងទីនេះហើយ ពួកមាណពទាំងអស់ ក៏និយាយនឹងសេលព្រាហ្មណ៍ថា បើលោកដ៏ចម្រើន ពេញចិត្តនឹងសាសនា របស់ព្រះសម្មា-សម្ពុទ្ធយ៉ាងនេះ យើងទាំងឡាយក៏នឹងបួសក្នុងសំណាក់ព្រះសម្ពុទ្ធ ទ្រង់មានប្រាជ្ញាដ៏ប្រសើរដែរ (សេលព្រាហ្មណ៍ក្រាបបង្គំទូលថា) ព្រាហ្មណ៍ទាំង ៣០០ នាក់នេះ លើក

យាចន្តិ បញ្ជលីកតា
ព្រហ្មចរិយំ ចរិស្សាម
ភគវា តវ សន្តិកេ
ស្វាក្ខាតំ ព្រហ្មចរិយំ (សេលាតិ ភគវា)
សន្ទិដ្ឋិកមកាលិកំ
យត្ថ អមោឃា បព្វជ្ជា
អប្បមត្តស្ស សិក្ខតោតិ ។
អលត្ថ ខោ សេលោ ព្រាហ្មណោ
សបរិសោ ភគវតោ សន្តិកេ
បព្វជ្ជំ អលត្ថ ឧបសម្បទំ ។

[២៧] អថខោ កេណិយោ ជដិលោ តស្សា រត្តិយា អច្ចយេន សកេ អស្សមេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចី-វរមាទាយ យេន កេណិយស្ស ជដិលស្ស អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ

កំបង់អញ្ជលីសូមផ្នួស បពិត្រព្រះមានបុណ្យ យើងទាំង-ឡាយនឹងប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់ព្រះអង្គ (ព្រះមានព្រះភាគត្រាស់ថា ម្នាលសេលព្រាហ្មណ៍) ព្រហ្មចរិយៈដែលតថាគតសំដែង ដោយប្រពៃហើយ ជាព្រហ្មចរិយៈដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ឲ្យផលមិនរង់ចាំកាល បព្វជ្ជារបស់បុគ្គលអ្នកមិនប្រហែសធ្វេស ជាអ្នកសិក្សា ជាបព្វជ្ជាមិនសោះសូន្យទេ ។ សេលព្រាហ្មណ៍ ព្រមទាំងបរិស័ទ ក៏បានបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។

[២៧] លុះកន្លងរាត្រីនោះហើយ លំដាប់នោះ កេណិយជដិលក៏ញុំាងពួកមនុស្សឲ្យចាត់ចែងខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ក្នុងអាស្រមរបស់ខ្លួន ហើយឲ្យមនុស្សទៅក្រាបបង្គំទូលភត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលវេលាដល់ហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានបុណ្យទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ស្ដេចចូលទៅឯអាស្រម របស់កេណិយជដិល លុះទ្រង់ចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ

សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ កេណិយោ ជដិលោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ កេណិយោ ជដិលោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។

[២៨] ឯកមន្តំ និសិន្នំ ខោ កេណិយំ ជដិលំ ភគវា ឥមាហិ គាថាហិ អនុមោទិ

អគ្គិហុត្តមុខា យញ្ញា
សាវិត្តិ ឆន្ទសោ មុខំ
រាជា មុខំ មនុស្សានំ
នទីនំ សាគរោ មុខំ
នក្ខត្តានំ មុខំ ចន្ទោ
អាទិច្ចោ តបតំ មុខំ
បុញ្ញមាកង្ខមានានំ
សង្ឃោ វេ យជតំ មុខន្តិ ។

មួយអន្លើដោយភិក្ខុសង្ឃ ។ លំដាប់នោះ កេណិយជដិលអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារ ដ៏ប្រសើរដោយដៃខ្លួនឯង ។ កេណិយជដិល បានដឹងថា ព្រះមានព្រះភាគទ្រង់សោយឆ្អែត លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈមួយយ៉ាងទាប អង្គុយក្នុងទីសមគួរ ។

[២៨] លុះកេណិយជដិល អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់អនុមោទនា ដោយគាថាទាំងនេះថា

យ័ញ្ញទាំងឡាយ មានការបូជាភ្លើងជាប្រធាន គម្ពីរសាវិត្តិ-
សាស្ត្រ ជាប្រធាននៃឆន្ទសាស្ត្រ ព្រះរាជាជាប្រធាននៃពួក
មនុស្ស សាគរជាប្រធាននៃពួកនទី ព្រះចន្ទ្រជាប្រធាននៃ
ពួកផ្កាយ ព្រះអាទិត្យជាប្រធាននៃពួកកម្តៅ ព្រះសង្ឃក៏ជា
ប្រធាននៃមនុស្សទាំងឡាយអ្នកចង់បានបុណ្យ កាលបូជា ។

ព្រាហ្មណវគ្គស្ស សេលសុត្តេ ភគវន្តូបសង្កមនំ

អថខោ ភគវា កេណិយំ ជដិលំ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ អាយស្មា សេលោ សបរិសោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា សេលោ សបរិសោ អរហតំ អហោសិ ។

[២៩] អថខោ អាយស្មា សេលោ សបរិសោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកំសំ ចីវរំ កត្វា

លុះព្រះមានព្រះភាគ ទ្រង់ញ៉ាំងកេណិយជដិល ឲ្យរីករាយតាម ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកអំពីអាសនៈចេញទៅ ។ លំដាប់ នោះ សេលភិក្ខុមានអាយុ ព្រមទាំងបរិស័ទ ចៀសចេញអំពីពួក ជាអ្នកមិនមានសេចក្ដីប្រហែសធ្វេស មានសេចក្ដីព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សម្រាន្តនៅដោយឥរិយាបថទាំង ៤ កុលបុត្រដែលចេញចាកផ្ទះទៅបួសក្នុងផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរ-ធម៌ណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាធម៌ទីបំផុតនៃមគ្គព្រហ្មចរិយៈ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ហើយក៏ដឹងថា ជាតិរបស់អញ អស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចក៏អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ សេលភិក្ខុមានអាយុ ព្រមទាំងបរិស័ទ ក៏ជាព្រះអរហន្តនឹងគេដែរ ។

[២៩] គ្រានោះ សេលភិក្ខុមានអាយុ ព្រមទាំងបរិស័ទ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ធ្វើចីពរឆៀងស្មា

៥៤



យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ គាថាហិ អជ្ឈភាសិ

យន្តំ សរណមាគម្ហ[១]

ឥតោ អដ្ឋមិ ចក្ខុម

សត្តរត្តេន ភគវា

ទន្តម្ហា តវ សាសនេ

តុវំ ពុទ្ធោ តុវំ សត្ថា

តុវំ មារាភិភូ មុនិ

តុវំ អនុសយេ ឆេត្វា

តិណ្ណោ តារេសិមំ បជំ

ឧបធី តេ សមតិក្កន្តា

---

១ ម. សរណមាគម្ម ។

ម្នាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ពោលគាថាទាំងឡាយ ចំពោះព្រះមានព្រះភាគថា

បពិត្រព្រះអង្គទ្រង់មានបញ្ញាចក្ខុ យើងខ្ញុំទាំងឡាយ បាន ដល់នូវទីពឹង រាប់មកដល់ថ្ងៃនេះ គម្រប់ជា ៨ ថ្ងៃហើយ បពិត្រព្រះមានបុណ្យ យើងខ្ញុំទាំងឡាយ បានទូន្មានខ្លួន តាមព្រះសាសនារបស់ព្រះអង្គ អស់ ៧ រាត្រីហើយ ព្រះ អង្គជាព្រះពុទ្ធ ព្រះអង្គជាបរមសាស្ដា ព្រះអង្គជាអ្នកប្រាជ្ញ គ្របសង្កត់នូវមារ ព្រះអង្គជាអ្នកឈ្វាសវៃ ក្នុងអនុសយធម៌ ទ្រង់ឆ្លង (ចាកសង្សារវដ្ដ) បានដោយព្រះអង្គឯង ហើយ ទ្រង់ចម្លងពពួកសត្វនេះឲ្យឆ្លងបានផង ព្រះអង្គកន្លងផុតឧបធិ

៥៥

ព្រាហ្មណវគ្គស្ស សេលសុត្តេ ភគវន្តប្បសំសា

អាសវា តេ បទាលិតា

សីហោវ អនុបាទានោ

បហីនភយភេរវោ

ភិក្ខវោ តិសតា ឥមេ

តិដ្ឋន្តិ បញ្ជលីកតា

បាទេ វីរ បសារេហិ

នាគា វន្ទន្តុ សត្ថុនោតិ ។

សេលសុត្តំ ទុតិយំ និដ្ឋិតំ ។

ព្រាហ្មណវគ្គ សេលសូត្រ ការពោលសរសើរព្រះមានព្រះភាគ

*ព្រះអង្គទម្លាយ នូវអាសវៈទាំងឡាយ ព្រះអង្គមិនមានឧបាទាន ទ្រង់លះបង់នូវភ័យដែលគួរខ្លាចទាំងអស់ ដូចសីហៈ ភិក្ខុទាំង ៣០០ រូបនេះ ឈរប្រណម្យអញ្ជលី បពិត្រព្រះអង្គអ្នកមានព្យាយាម សូមព្រះអង្គលាព្រះបាទទាំងគូ ពួកនាគគឺភិក្ខុ សូមក្រាបថ្វាយបង្គំចំពោះព្រះអង្គជាបរមសាស្តា ។*

ចប់ សេលសូត្រ ទី ២ ។

# តតិយំ អស្សលាយនសុត្តំ

[៣០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន នានាវេរជ្ជកានំ ព្រាហ្មណានំ បញ្ចមត្តានិ ព្រាហ្មណសតានិ សាវត្ថិយំ បដិវសន្តិ កេនចិទេវ ករណីយេន ។ អថខោ តេសំ ព្រាហ្មណានំ ឯតទហោសិ អយំ ខោ សមណោ គោតមោ ចាតុវណ្ណឹ សុទ្ធឹ បញ្ញាបេតិ កោ នុ ខោ បហោតិ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុន្តិ ។ តេន ខោ បន សមយេន អស្សលាយនោ នាម មាណវោ សាវត្ថិយំ បដិវសតិ ទហរោ វុត្តសិរោ សោឡសវស្សុទ្ទេសិកោ ជាតិយា តិណ្ណំ វេទានំ បារគូ សនិឃណ្ដុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ ។ អថខោ តេសំ ព្រាហ្មណានំ ឯតទហោសិ

# អស្សលាយនសូត្រ ទី ៣

[៣០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង បណ្តាពួកព្រាហ្មណ៍អ្នកមកពីដែនផ្សេង ៗ មានពួកព្រាហ្មណ៍ចំនួន ៥០០ នាក់ នៅអាស្រ័យក្នុងក្រុងសាវត្ថី ដោយកិច្ចការនីមួយ ។ ព្រាហ្មណ៍ទាំងនោះមានសេចក្តីត្រិះរិះថា ព្រះសមណ-គោតមនេះ តែងបញ្ញត្តនូវសេចក្តីបរិសុទ្ធ ចំពោះវណ្ណៈទាំង ៤ ឱ្យ នរណាហ្ន៎ ទើបសមនឹងពិគ្រោះពាក្យនេះ មួយអន្លើដោយព្រះសមណ-គោតមបាន ។ សម័យនោះឯង មាណពឈ្មោះអស្សលាយនៈ នៅអាស្រ័យ ក្នុងក្រុងសាវត្ថី ជាមនុស្សក្មេង មានក្បាលកោរ មានអាយុ ១៦ ឆ្នាំ អំពីកំណើត បានដល់នូវត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ គម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទគឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នករៀននូវបទនិងវេយ្យាករណ៍ ជាអ្នកមិនឱនថយគឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណ-ព្យាករណសាស្ត្រ ។ ព្រាហ្មណ៍ទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា

អយំ ខោ អស្សលាយនោ មាណវោ សាវត្ថិយំ បដិវសតិ ឧហពោ ។ បេ ។ អលំវយោ សោ ខោ បហោតិ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុន្តិ ។

[៣១] អថខោ តេ ព្រាហ្មណា យេន អស្សលាយនោ មាណវោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អស្សលាយនំ មាណវំ ឯតទវោចុំ អយំ ភោ អស្សលាយន សមណោ គោតមោ ចាតុវណ្ណឹ សុទ្ធឹ បញ្ញាបេតិ ឯតុ ឯវំ អស្សលាយន[១] សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតូតិ[២] ។ ឯវំ វុត្តេ អស្សលាយនោ មាណវោ តេ ព្រាហ្មណេ ឯតទវោច សមណោ ខលុ ភោ គោតមោ ធម្មវាទី ធម្មវាទិនោ ច បន ទុប្បដិមន្តិយា ភវន្តិ នាហំ សក្កោមិ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុន្តិ ។ ទុតិយម្បិ ខោ តេ[៣] ព្រាហ្មណា អស្សលាយនំ មាណវំ ឯតទវោចុំ

---

១ ឱ. ម. អស្សលាយនោ ។ ២ ឱ. ម. បដិមន្តេតុន្តិ ។ ៣ ឱ. តេតិ បទំ ន ទិស្សតិ ។

អស្សលាយនមាណពនេះ នៅអាស្រ័យក្នុងក្រុងសាវត្ថី ជាមនុស្សក្មេង ។ បេ ។ ជាអ្នកមិនឱនថយគឺស្ទាត់ជំនាញ មានតែមាណពនោះ ទើបសមនឹងពិគ្រោះពាក្យនោះ មួយអន្លើដោយព្រះសមណគោតមបាន ។

[៣១] គ្រានោះ ព្រាហ្មណ៍ទាំងនោះ នាំគ្នាចូលទៅរកអស្សលាយនមាណព លុះចូលទៅដល់ហើយ និយាយនឹងអស្សលាយនមាណពដូច្នេះថា ម្នាលអស្សលាយនៈដ៏ចម្រើន ព្រះសមណគោតមនេះ តែងបញ្ញត្តនូវសេចក្តីបរិសុទ្ធ ចំពោះវណ្ណៈទាំង ៤ ម្នាលអស្សលាយនៈ ចូរអ្នកដ៏ចម្រើនមក ចូរអ្នកដ៏ចម្រើនពិគ្រោះពាក្យនោះ មួយអន្លើដោយព្រះសមណគោតម ។ កាលបើព្រាហ្មណ៍ទាំងនោះ និយាយយ៉ាងនេះហើយ អស្សលាយនមាណព ក៏និយាយនឹងព្រាហ្មណ៍ទាំងនោះដូច្នេះថា ម្នាលអ្នកដ៏ចម្រើន ឮថាព្រះសមណគោតម ជាធម្មវាទី ទុកជាពួកបុគ្គលជាធម្មវាទីផងគ្នា ក៏រមែងពិគ្រោះបានដោយលំបាក ខ្ញុំមិនអាចពិគ្រោះពាក្យនោះ មួយអន្លើដោយព្រះសមណគោតមឡើយ ។ ព្រាហ្មណ៍ទាំងនោះ និយាយនឹងអស្សលាយនមាណព ជាគម្រប់ពីរដងដូច្នេះថា

អយំ ភោ អស្សលាយន សមណោ គោតមោ ចាតុវណ្ណឹ សុទ្ធឹ បញ្ញាបេតិ ឯតុ ភវំ អស្សលាយន[១] សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតូតិ[២] ។ ទុតិយម្បិ ខោ អស្សលាយនោ មាណវោ តេ ព្រាហ្មណេ ឯតទវោច សមណោ ខលុ ភោ គោតមោ ធម្មវាទី ធម្មវាទិនោ ច បន ទុប្បដិមន្តិយា ភវន្តិ នាហំ សក្កោមិ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុន្តិ ។ តតិយម្បិ ខោ តេ ព្រាហ្មណា អស្សលាយនំ មាណវំ ឯតទវោចុំ អយំ ភោ អស្សលាយន សមណោ គោតមោ ចាតុវណ្ណឹ សុទ្ធឹ បញ្ញាបេតិ ឯតុ ភវំ អស្សលាយន[៣] សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុ[៤] ចរិតំ ខោ បន ភោតា អស្សលាយនេន បរិព្វាជកំ មា ភវំ អស្សលាយនោ អយុទ្ធបរាជិតំ បរាជយីតិ ។ ឯវំ វុត្តេ អស្សលាយនោ មាណវោ

---

១ ឱ. ម. អស្សលាយនោ ។ ២ ឱ. ម. បដិមន្តេតុ ។ ឱ. ម. ចរិតំ ខោ បន ភោតា អស្សលាយនេន បរិព្វាជកន្តិ អតិរេកបាឋា ទិស្សន្តិ ។ ៣ ម. អស្សលាយនោ ។ ៤ ឱ. ម. បដិមន្តេតុំ ។

ម្នាលអស្សលាយនៈដ៏ចម្រើន ព្រះសមណគោតមនេះ តែងបញ្ញត្តនូវសេចក្តីបរិសុទ្ធចំពោះវណ្ណៈទាំង ៤ ម្នាលអស្សលាយនៈ ចូរអ្នកដ៏ចម្រើនមក ចូរអ្នកដ៏ចម្រើនទៅពិគ្រោះពាក្យនោះ មួយអន្លើដោយព្រះសមណ-គោតម ។ អស្សលាយនមាណព និយាយនឹងព្រាហ្មណ៍ទាំងនោះជាគម្រប់ពីរដងដូច្នេះថា ម្នាលអ្នកដ៏ចម្រើន ឮថាព្រះសមណគោតម ជាធម្ម-វាទី ទុកជាពួកបុគ្គលជាធម្មវាទីផងគ្នា ក៏ពិគ្រោះបានដោយលំបាក ខ្ញុំមិនអាចពិគ្រោះពាក្យនោះ មួយអន្លើដោយព្រះសមណគោតមឡើយ ។ ព្រាហ្មណ៍ទាំងនោះនិយាយនឹងអស្សលាយនមាណពជាគម្រប់ ៣ ដងដូច្នេះថា ម្នាលអស្សលាយនៈដ៏ចម្រើន ព្រះសមណគោតមនេះតែងបញ្ញត្តនូវសេចក្តីបរិសុទ្ធចំពោះវណ្ណៈទាំង ៤ ម្នាលអស្សលាយនៈ ចូរអ្នកដ៏ចម្រើនមក ចូរអ្នកដ៏ចម្រើនពិគ្រោះពាក្យនោះ មួយអន្លើដោយព្រះសមណគោ-តម ដ្បិតអស្សលាយនៈដ៏ចម្រើន ធ្លាប់ប្រព្រឹត្តនឹងបរិព្វាជកមកដែរហើយ សូមអស្សលាយនៈដ៏ចម្រើន ច្បាំងឲ្យឈ្នះ កុំឲ្យចាញ់ឡើយ ។ កាលបើព្រាហ្មណ៍ទាំងនោះ និយាយយ៉ាងនេះហើយ អស្សលាយនមាណព

៤៩



តេ ព្រាហ្មណេ ឯតទវោច អទ្ធា ខោ អហំ ភន្តេ ន លភាមិ សមណោ ខលុ ភោ គោតមោ ធម្មវាទី ធម្មវាទិនោ ច បន ទុប្បដិមន្តិយា ភវន្តិ នាហំ សក្កោមិ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុំ អបិចាហំ ភវតំ(១) វចនេន គមិស្សាមីតិ ។

[៣២] អថខោ អស្សលាយនោ មាណវោ មហតា(២) ព្រាហ្មណគណេន សទ្ធឹ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អស្សលាយនោ មាណវោ ភគវន្តំ ឯតទវោច ព្រាហ្មណា ភោ គោតម ឯវមាហំសុ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា វ ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា

ឱ. ម. ភវន្តានំ ។ ២ ម. មហតិយា ។

និយាយនឹងព្រាហ្មណ៍ទាំងនោះ ដូច្នេះថា បពិត្រអ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំ (ទៅពិគ្រោះ) មិនបានដោយដាច់ខាត ម្នាលអ្នកដ៏ចម្រើន ព្រោះថា ព្រះសមណគោតម ជាធម្មវាទី ទុកជាពួកបុគ្គល ជាធម្មវាទីផងគ្នា ក៏ពិគ្រោះបាន ដោយលំបាក ខ្ញុំមិនហ៊ានពិគ្រោះពាក្យនោះ មួយអន្លើដោយព្រះសមណគោតមទេ ខ្ញុំគ្រាន់តែទៅតាមពាក្យរបស់អ្នកដ៏ចម្រើនទាំងឡាយប៉ុណ្ណោះ ។

[៣២] លំដាប់នោះ អស្សលាយនមាណព ចូលទៅរកព្រះមានព្រះភាគ ជាមួយនឹងពួកព្រាហ្មណ៍ជាច្រើននាក់ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់សំណេះសំណាល មួយអន្លើដោយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះអស្សលាយនមាណពអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍តែងនិយាយយ៉ាងនេះថា មានតែពួកព្រាហ្មណ៍ទេ ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ពួកព្រាហ្មណ៍ទើបជាវណ្ណៈស វណ្ណៈឯទៀតជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍ទើបបរិសុទ្ធ មិនមែនពួកព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រជាឱរស កើតមកអំពីព្រះឱស្ឋព្រះព្រហ្ម

ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ឥធ ករំ គោតមោ កិមាហាតិ ។

[៣៣] និស្សន្តេ[១] ខោ បន អស្សលាយន ព្រាហ្មណានំ ព្រាហ្មណិយោ ឧតុនិយោបិ គព្ភិនិយោបិ វិជាយមានាបិ បាយមានាបិ តេ ច ព្រាហ្មណា យោនិជា វ សមានា ឯវមាហំសុ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា វ ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្ម-ទាយាទាតិ ។ កិញ្ចាបិ ករំ គោតមោ ឯវមាហ អថ-ខ្វត្ថ[២] ព្រាហ្មណា ឯវមេតំ មញ្ញន្តិ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។

[៣៤] តំ កឹ មញ្ញសិ អស្សលាយន សុតន្តេ យោនកកម្ពោជេសុ[៣] អញ្ញេសុ ច បច្ចន្តិមេសុ ជនបទេសុ ទ្វេវ វណ្ណា អយ្យោ ចេវ

---

១ ឱ. ម. ទិស្សន្តិ ។ ២ ឱ. អថខោ ។ ៣ ឱ. ម. យោនកម្ពោជេសុ ។

មានព្រះព្រហ្ម ជាអ្នកបង្កើត មានព្រះព្រហ្ម ជាអ្នកនិម្មិត ជាញាតិនឹងព្រះព្រហ្ម ត្រង់នេះ តើព្រះគោតមដ៏ចម្រើនសំដែងដូចម្ដេច ។

[៣៣] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអស្សលាយនៈ នាងព្រាហ្មណីទាំងឡាយរបស់ពួកព្រាហ្មណ៍ ជាស្ត្រីមានរដូវ មានគភ៌ សម្រាលកូននិងបំបៅកូន (អ្នករាល់គ្នា) ក៏ឃើញដែរ តែព្រាហ្មណ៍ដែលប្រាកដជាកើតអំពីយោនីទាំងនោះ ត្រឡប់ជានិយាយថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ពួកព្រាហ្មណ៍ទើបជាវណ្ណៈស វណ្ណៈឯទៀតជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍ទើបបរិសុទ្ធ មិនមែនពួកព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្តជាឱរស កើតមកអំពីព្រះឱស្ឋនៃព្រហ្ម មានព្រហ្ម ជាអ្នកបង្កើត មានព្រហ្ម ជាអ្នកនិម្មិត ជាញាតិនឹងព្រហ្ម យ៉ាងនេះទៅវិញ ។ អស្សលាយនមាណព ក្រាបបង្គំទូលថា ព្រះគោតមដ៏ចម្រើនត្រាស់យ៉ាងនេះ ក៏សមដែរហើយ តែថា ពួកព្រាហ្មណ៍ តែងយល់សេចក្ដីនុ៎ះ ក្នុងរឿងនុ៎ះ យ៉ាងនេះថា ពួកព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរ ។ បេ ។ ជាញាតិនឹងព្រះព្រហ្ម ។

[៣៤] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្ដីនោះដូចម្ដេច ក្រែងអ្នកធ្លាប់បានឮថា ក្នុងយោនករដ្ឋនិងកម្ពោជរដ្ឋទាំងឡាយ និងបច្ចន្តិមជនបទទាំងឡាយឯទៀត មានវណ្ណៈ ២ គឺម្ចាស់ ១

ទាសោ ច អយ្យោ ហុត្វា ទាសោ ហោតិ ទាសោ ហុត្វា អយ្យោ ហោតីតិ ។ ឯវំ ភោ សុតំ[១] មេ យោនកកម្ពោជេសុ អញ្ញេសុ ច បច្ចន្តិមេសុ ជនបទេសុ ទ្វេវ វណ្ណា អយ្យោ ចេវ ទាសោ ច អយ្យោ ហុត្វា ទាសោ ហោតិ ទាសោ ហុត្វា អយ្យោ ហោតីតិ ។ ឯត្ថ អស្សលាយន ព្រាហ្មណានំ កឹ ពលំ កោ អស្សាសោ យទេត្ថ ព្រាហ្មណា ឯវ-មាហំសុ ព្រាហ្មណា សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ កិញ្ចាបិ ភវំ គោតមោ ឯវមាហ អថខ្វេត្ថ ព្រាហ្មណា ឯវមេតំ មញ្ញន្តិ ព្រាហ្មណាវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។

[៣៨] តំ កឹ មញ្ញសិ អស្សលាយន ខត្តិយោវ នុ ខោ បាណាតិបាតី អទិន្នាទាយី កាមេសុមិច្ឆា-ចារី មុសាវាទី បិសុណាវាចោ ផរុសាវាចោ សម្ផប្បលាបី

១ ម. សុតំ តំ ។

ខ្ញុំ ១ ម្ចាស់ត្រឡប់ទៅជាខ្ញុំ ខ្ញុំត្រឡប់ទៅជាម្ចាស់វិញ មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់បានឮមកថា ក្នុងយោនករដ្ឋនិងកម្ពោជរដ្ឋទាំងឡាយ និងបច្ចន្តិមជនបទទាំងឡាយឯទៀត មានវណ្ណៈ ២ គឺ ម្ចាស់ ១ ខ្ញុំ ១ ម្ចាស់ត្រឡប់ទៅជាខ្ញុំ ខ្ញុំត្រឡប់ទៅជាម្ចាស់វិញ ដូច្នេះដែរ ។ ម្នាលអស្សលាយនៈ បណ្តាវណ្ណៈទាំង ២ នុ៎ះ ពួកព្រាហ្មណ៍មានកម្លាំងដូចម្តេច មានទីពឹងពំនាក់ដូចម្តេច បានជាពួកព្រាហ្មណ៍ ហ៊ាននិយាយយ៉ាងនេះ ក្នុងរឿងនុ៎ះថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រហ្មដូច្នោះ ។ ព្រះគោតមដ៏ចម្រើន ត្រាស់យ៉ាងនេះ ក៏សមដែរ តែថាពួកព្រាហ្មណ៍ នៅតែយល់សេចក្តីនុ៎ះ ក្នុងរឿងនុ៎ះយ៉ាងនេះថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រះព្រហ្មដែល ។

[៣៥] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះ ដូចម្តេច (បើ) ក្សត្រិយ៍ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យឥត

អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋី កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នោ ព្រាហ្មណោ វេស្សោ វ នុ ខោ... សុទ្ទោ វ[១] នុ ខោ បាណាតិបាតី អទិន្នាទាយី កាមេសុមិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋី កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នោ ព្រាហ្មណោតិ ។ នោ ហិទំ ភោ គោតម ខត្តិយោបិ ហិ ភោ គោតម បាណាតិបាតី អទិន្នាទាយី កាមេសុមិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋី កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ព្រាហ្មណោបិ ហិ ភោ គោតម... វេស្សោបិ

---

១ ឱ. ច ។

ប្រយោជន៍ មានចិត្តរំពៃចង់បានទ្រព្យគេ មានចិត្តគុំគួន មានគំនិតយល់ខុស លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ឯព្រាហ្មណ៍មិនទៅកើតទេឬ (បើ) វេស្សៈ... សុទ្ទៈ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យឥតប្រយោជន៍ មានចិត្តរំពៃចង់បានទ្រព្យគេ មានចិត្តគុំគួន មានគំនិតយល់ខុស លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ឯព្រាហ្មណ៍ (បើទុកជាសម្លាប់សត្វជាដើម) មិនទៅកើត (ក្នុងអបាយ) ទេឬ ។ អស្សលាយនមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន មិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន (បើ) ក្សត្រិយ៍ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យឥតប្រយោជន៍ មានចិត្តរំពៃចង់បានទ្រព្យគេ មានចិត្តគុំគួន មានគំនិតយល់ខុស លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកដែរ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្តី... បពិត្រព្រះគោតមដ៏ចម្រើន វេស្សៈក្តី . . .

ព្រាហ្មណវគ្គស្ស អស្សលាយនសុត្តេ អកុសលកម្មបថា

ហិ ភោ គោតម... សុត្វាបិ ហិ ភោ គោតម... សព្វេបិ ហិ ភោ គោតម ចត្តារោ វណ្ណា បាណាតិបាតិនោ អទិន្នាទាយិនោ កាមេសុមិច្ឆាចារិនោ មុសាវាទិនោ បិសុណាវាចា ផរុសវាចា សម្ផប្បលាបិនោ អភិជ្ឈាលូ ព្យាបន្នចិត្តា មិច្ឆាទិដ្ឋី[១] កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យុំ ។ ឯត្ថ អស្សលាយន ព្រាហ្មណានំ កឹ ពលំ កោ អស្សាសោ យទេត្ថ ព្រាហ្មណា ឯវមាហំសុ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ កិញ្ចាបិ ភវំ គោតមោ ឯវមាហ អថខ្វេត្ថ ព្រាហ្មណា ឯវមេតំ មញ្ញន្តិ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។

១ ឱ. មិច្ឆាទិដ្ឋិនោ ។

បពិត្រព្រះគោតមដ៏ចម្រើន សុទ្ទៈក្តី... បពិត្រព្រះគោតមដ៏ចម្រើន វណ្ណៈទាំង ៤ (បើ) ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យអាក្រក់ និយាយពាក្យឥតប្រយោជន៍ មានចិត្តរំពៃចង់បានទ្រព្យគេ មានចិត្តគុំគួន មានគំនិតយល់ខុស លុះរំលាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ នឹងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ទាំងអស់ពុំខានទេ ។ ម្នាលអស្សលាយនៈ បណ្តាវណ្ណៈទាំង ៤ នុ៎ះ ពួកព្រាហ្មណ៍មានកម្លាំងដូចម្តេច មានទីពឹងពំនាក់ដូចម្តេច បានជាពួកព្រាហ្មណ៍ហ៊ាននិយាយយ៉ាងនេះ ក្នុងរឿងនុ៎ះថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រហ្មដូច្នោះ ។ ព្រះគោតមដ៏ចម្រើនត្រាស់យ៉ាងនេះ ក៏សមដែរ តែថាពួកព្រាហ្មណ៍នៅតែយល់សេចក្តីនុ៎ះ ក្នុងរឿងនុ៎ះយ៉ាងនេះដដែលថា ពួកព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀត ជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រះព្រហ្ម ។

[៣៦] តំ កឹ មញ្ញសិ អស្សលាយន ព្រាហ្មណោវ នុ ខោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុមិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ បិសុណាយ វាចាយ បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈា-លុ អព្យាបន្នចិត្តោ សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ នោ ខត្តិយោ នោ វេស្សោ នោ សុទ្ទោតិ ។ នោ ហិទំ ភោ គោតម ខត្តិយោបិ ហិ ភោ គោតម បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុមិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ បិសុណាយ វាចាយ បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈាលុ អព្យាបន្នចិត្តោ សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ព្រាហ្មណោបិ ហិ ភោ គោតម... វេស្សោបិ ហិ ភោ គោតម...

[៣៦] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច លុះតែព្រាហ្មណ៍វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ទើបទៅកើតក្នុងសុគតិសួគ៌ទេវលោកបាន ក្សត្រិយ៍ទៅមិនបាន វេស្សៈទៅមិនបាន សុទ្ទៈក៏ទៅមិនបានទេឬ ។ អស្សលាយនមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន មិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន តាមពិត ក្សត្រិយ៍ក្តី វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោកដែរ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្តី... បពិត្រព្រះគោតមដ៏ចម្រើន វេស្សៈក្តី... បពិត្រព្រះគោតមដ៏ចម្រើន

សុទ្ទាបិ ហិ ភោ គោតម... សព្វេបិ ហិ ភោ គោតម ចត្តារោ វណ្ណា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុមិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា បិសុណាយ វាចាយ បដិវិរតា ផរុសាយ វាចាយ បដិវិរតា សម្ផប្បលាបា បដិវិរតា អនភិជ្ឈាលូ អព្យាបន្នចិត្តា សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យុន្តិ ។ ឯត្ថ អស្សលាយន ព្រាហ្មណានំ កឹ ពលំ កោ អស្សាសោ យទេត្ថ ព្រាហ្មណា ឯវមាហំសុ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ កិញ្ចាបិ ភវំ គោតមោ ឯវមាហ អថខ្វេត្ថ ព្រាហ្មណា ឯវមេតំ មញ្ញន្តិ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។

[៣៧] តំ កឹ មញ្ញសិ អស្សលាយន ព្រាហ្មណោ វ នុ ខោ បហោតិ អស្មឹ បទេសេ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតុំ នោ ខត្តិយោ

សុទ្ធៈក្តី... បពិត្រព្រះគោតមដ៏ចម្រើន តាមពិតសូម្បីវណ្ណៈទាំង ៤ បើវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោកទាំងអស់ ពុំខានឡើយ ។ ម្នាលអស្សលាយនៈ បណ្តាវណ្ណៈទាំង ៤ នុ៎ះពួកព្រាហ្មណ៍មានកម្លាំងដូចម្តេច មានទីពឹងពំនាក់ដូចម្តេច បានជាពួកព្រាហ្មណ៍ហ៊ាននិយាយយ៉ាងនេះ ក្នុងរឿងនុ៎ះថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រហ្មដូច្នោះ ។ ព្រះគោតមដ៏ចម្រើន ត្រាស់យ៉ាងនេះ ក៏សមដែរហើយ តែថាពួកព្រាហ្មណ៍ នៅតែសំគាល់សេចក្តីនុ៎ះ ក្នុងរឿងនុ៎ះយ៉ាងនេះដដែលថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រះព្រហ្ម ។

[៣៧] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច លុះតែព្រាហ្មណ៍ទើបគួរចម្រើនចិត្តមេត្តា មិនមានពៀរ មិនមានព្យាបាទ ក្នុងប្រទេសនោះបាន ក្សត្រិយ៍ចម្រើនមិនបាន

ជោ វេស្សោ ជោ សុទ្ទោតិ ។ ជោ ហិជំ ភោ គោតម ខត្តិយោបិ ហិ ភោ គោតម បហោតិ អស្មឹ បទេសេ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតុំ ព្រាហ្មណោបិ ហិ ភោ គោតម... វេស្សោបិ ហិ ភោ គោតម... សុទ្ទោបិ ហិ ភោ គោតម... សព្វេបិ ហិ ភោ គោតម ចត្តារោ វណ្ណា បហោន្តិ អស្មឹ បទេសេ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតុន្តិ ។ ឯត្ថ អស្សលាយន ព្រាហ្មណានំ កឹ ពលំ កោ អស្សាសោ យទេត្ថ ព្រាហ្មណា ឯវមាហំសុ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ កិញ្ចាបិ ភវំ គោតមោ ឯវមាហ អថខ្វេត្ថ ព្រាហ្មណា ឯវមេតំ មញ្ញន្តិ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។

វេស្សៈចម្រើនមិនបាន សុទ្ទៈក៏ចម្រើនមិនបាន ទេឬ ។ អស្សលាយន-មាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន មិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន តាមពិត ក្សត្រិយ៍ក្តី ក៏គួរចម្រើនចិត្តមេត្តា មិនមានពៀរ មិនមានព្យាបាទ ក្នុងប្រទេសនោះបានដែរ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្តី... បពិត្រព្រះគោតមដ៏ចម្រើន វេស្សៈក្តី... បពិត្រព្រះគោតមដ៏ចម្រើន សុទ្ទៈក្តី... បពិត្រព្រះគោតមដ៏ចម្រើន វណ្ណៈទាំង ៤ តាមពិត សុទ្ធតែគួរចម្រើនចិត្តមេត្តា មិនមានពៀរ មិនមានព្យាបាទ ក្នុងប្រទេសនោះបាន ទាំងអស់គ្នា ។ ម្នាលអស្សលាយនៈ បណ្តាវណ្ណៈទាំង ៤ នុ៎ះ ពួកព្រាហ្មណ៍មានកម្លាំងដូចម្តេច មានទីពឹងពំនាក់ដូចម្តេច បានជាពួកព្រាហ្មណ៍ហ៊ាននិយាយយ៉ាងនេះ ក្នុងរឿងនុ៎ះថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀត ជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រហ្មដូច្នោះ ។ ព្រះគោតមដ៏ចម្រើនត្រាស់យ៉ាងនេះ ក៏សមដែរ តែថាពួកព្រាហ្មណ៍ នៅតែសំគាល់សេចក្តីនុ៎ះ ក្នុងរឿងនុ៎ះយ៉ាងនេះដដែលថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈទៀត ជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រះព្រហ្ម ។

[៣៨] តំ កឹ មញ្ញសិ អស្សលាយន ព្រាហ្មណោ វ នុ ខោ បហោតិ សោត្ថឹ សិនានំ(១) អាទាយ នទឹ គន្ត្វា រជោជល្លំ បវាហេតុំ នោ ខត្តិយោ នោ វេស្សោ នោ សុទ្ទោតិ ។ នោ ហិទំ ភោ គោតម ខត្តិយោបិ ហិ ភោ គោតម បហោតិ សោត្ថឹ សិនានំ អាទាយ នទឹ គន្ត្វា រជោជល្លំ បវាហេតុំ ព្រាហ្មណោបិ ហិ ភោ គោតម... វេស្សោបិ ហិ ភោ គោតម... សុទ្ទោបិ ហិ ភោ គោតម... សព្វេបិ ហិ ភោ គោតម ចត្តារោ វណ្ណា បហោន្តិ សោត្ថឹ សិនានំ អាទាយ នទឹ គន្ត្វា រជោជល្លំ បវាហេតុន្តិ ។ ឯត្ថ អស្សលាយន ព្រាហ្មណានំ កឹ ពលំ កោ អស្សាសោ យទេត្ថ ព្រាហ្មណា ឯវមាហំសុ ព្រាហ្មណោ វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ កិញ្ចាបិ ភវំ គោតមោ ឯវមាហ អថខ្វេត្ថ ព្រាហ្មណា ឯវមេតំ មញ្ញន្តិ

១ ឱ. សោត្ថឹ សិនានឹ ។ ម. សោត្ថិ សិនានិ ។

[៣៨] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច លុះតែព្រាហ្មណ៍ទើបគួរនាំយកកញ្ចប់គ្រឿងលំអិតសម្រាប់ដុសកាយនិងគ្រឿងផ្ងូត ទៅកាន់ស្ទឹង ដើម្បីជម្រះក្អែលបាន ក្សត្រិយ៍មិនគួរ វេស្សៈមិនគួរ សុទ្ទៈមិនគួរទេឬ ។ អស្សលាយនមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន មិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន តាមពិត ក្សត្រិយ៍ក្តី ក៏គួរកាន់យកកញ្ចប់គ្រឿងលំអិត សម្រាប់ដុសកាយនិងគ្រឿងផ្ងូត ទៅកាន់ស្ទឹង ដើម្បីជម្រះក្អែលដែរ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្តី... បពិត្រព្រះគោតមដ៏ចម្រើន វេស្សៈក្តី... បពិត្រព្រះគោតមដ៏ចម្រើន សុទ្ទៈក្តី... បពិត្រព្រះគោតមដ៏ចម្រើន តាមពិត វណ្ណៈទាំង ៤ សុទ្ធតែគួរកាន់យកកញ្ចប់គ្រឿងលំអិត សម្រាប់ដុសកាយ និងគ្រឿងផ្ងូត ទៅកាន់ស្ទឹង ដើម្បីជម្រះក្អែលបានទាំងអស់គ្នា ។ ម្នាលអស្សលាយនៈ បណ្តាវណ្ណៈទាំង ៤ នុ៎ះ ពួកព្រាហ្មណ៍មានកម្លាំងដូចម្តេច មានទីពឹងពំនាក់ដូចម្តេច បានជាពួកព្រាហ្មណ៍ ហ៊ាននិយាយយ៉ាងនេះ ក្នុងរឿងនុ៎ះថា ព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រហ្មដូច្នោះ ។ ព្រះគោតមដ៏ចម្រើន ត្រាស់យ៉ាងនេះ ក៏សមដែរ តែថាពួកព្រាហ្មណ៍ នៅតែសំគាល់សេចក្តីនុ៎ះ ក្នុងរឿងនុ៎ះយ៉ាងនេះ

ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។

[៣៩] តំ កឹ មញ្ញសិ អស្សលាយន ឥធ រាជា ខត្តិយោ មុទ្ធាវសិត្តោ នានាជច្ចានំ បុរិសានំ បុរិសសតំ សន្និបាតេយ្យ អាយន្តុ ភោន្តោ យេ តត្ថ ខត្តិយកុលា ព្រាហ្មណកុលា រាជញ្ញកុលា ឧប្បន្នា សាកស្ស វា[១] សាលស្ស វា សលឡស្ស វា ចន្ទនស្ស វា បទុមកស្ស វា ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេន្តុ តេជោ បាតុករោន្តុ អាយន្តុ បន ភោន្តោ យេ ច[២] តត្ថ ចណ្ឌាលកុលា នេសាទ-កុលា វេណុកុលា[៣] រថការកុលា បុក្កុសកុលា ឧប្បន្នា សាបានទោណិយា វា សូករទោណិយា វា រជកទោណិយា វា ឯលណ្ឌកដ្ឋស្ស វា ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេន្តុ តេជោ បាតុករោន្តូតិ

១ ឱ. សាកស្ស វាតិ ន ទិស្សតិ ។ ២ ឱ. ចសទ្ទោ នត្ថិ ។ ៣ ឱ. វេណកុលា ។

ជដែលថា ពួកព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀត ជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រះព្រហ្ម ។

[៣៩] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច ក្សត្រិយ៍ជាព្រះរាជាក្នុងលោកនេះ បានមុទ្ធាភិសេកហើយ ប្រជុំពួកបុរស មានជាតិផ្សេង ៗ ចំនួន ១០០ នាក់ ដោយព្រះតម្រាស់ថា អ្នកដ៏ចម្រើនទាំងឡាយចូរមក បណ្តាពួកបុរសទាំងនោះ ពួកបុរសណាដែលចេញអំពីពួកខត្តិយត្រកូលក្តី ព្រាហ្មណត្រកូលក្តី រាជញ្ញត្រកូលក្តី មកចួបជុំគ្នាហើយ ពួកបុរសនោះចូរកាន់យកពំនួតភ្លើងខាងលើដែលធ្វើពីឈើស្រោលក្តី ឈើខ្លឹមក្តី ដើមស្រល់ក្តី ដើមចន្ទន៍ក្តី ដើមឈូកក្រហមក្តី ហើយចូរពួតភ្លើង ចូរធ្វើភ្លើងឲ្យកើតប្រាកដឡើង មួយទៀត អ្នកដ៏ចម្រើនទាំងឡាយចូរមក បណ្តាពួកបុរសទាំងនោះ ពួកបុរសណាដែលចេញអំពីពួកចណ្ឌាលត្រកូលក្តី នេសាទត្រកូលក្តី វេណុត្រកូល (ត្រកូលអ្នកត្បាញឫស្សី) ក្តី រថការត្រកូល (ត្រកូលជាងរថ) ក្តី បុក្កុសត្រកូល (ត្រកូលអ្នកចាក់សម្រាម) ក្តី មកចួបជុំគ្នាហើយ ពួកបុរសនោះ ចូរកាន់យកពំនួតភ្លើងខាងលើដែលធ្វើពីស្នូកឆ្កែក្តី ស្នូកជ្រូកក្តី ស្នូកជាងជ្រលក់ក្តី ដើមល្ហុងប្រេងក្តី ហើយចូរពួតភ្លើង ចូរធ្វើភ្លើងឲ្យកើតប្រាកដឡើង ដូច្នេះ

តំ កឹ មញ្ញសិ អស្សលាយន យោ ច ឥមេ ខោ[1] ខត្តិយកុលា ព្រាហ្មណកុលា រាជញ្ញកុលា ឧប្បន្នេហិ សាកស្ស វា សាលស្ស វា សលឡស្ស វា ចន្ទនស្ស វា បទុមកស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ ចាតុកតោ សោ ឯវ នុ ខ្វស្ស អគ្គិ អច្ចិមា ចេវ[2] វណ្ណិមា ច បភស្សរោ ច តេន ច សក្កា អគ្គិនា អគ្គិករណីយំ កាតុំ យោ បន សោ ចណ្ឌាលកុលា នេសាទកុលា វេណុកុលា រថការកុលា បុក្កុសកុលា ឧប្បន្នេហិ សាបានទោណិយា វា សូករទោណិយា វា រជកទោណិយា វា ឯលណ្ឌកដ្ឋស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ ចាតុកតោ ស្វាស្ស អគ្គិ ន ចេវ អច្ចិមា ន ច វណ្ណិមា ន ច បភស្សរោ ន ច តេន សក្កា អគ្គិនា អគ្គិករណីយំ កាតុន្តិ ។ នោ ហិទំ ភោ គោតម យោបិ[3] សោ ភោ គោតម

១ ឱ. ឯវន្នុ ខោ សោតិ ទិស្សតិ ។ ២ ឱ. ច ។ ៣ ឱ. បិសទ្ទោ នត្ថិ ។

ព្រាហ្មណវគ្គ អស្សលាយនសូត្រ អំពីឧបមាដោយការបង្កាត់ភ្លើង

ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច ភ្លើងណា ដែលពួកបុរសចេញអំពីខត្តិយត្រកូលក្តី ព្រាហ្មណត្រកូលក្តី រាជញ្ញ-ត្រកូលក្តី មកចួបជុំគ្នាហើយកាន់យកពំនួតភ្លើងខាងលើ ដែលធ្វើពីឈើស្រាយក្តី ឈើខ្លឹមក្តី ដើមស្រល់ក្តី ដើមចន្ទន៍ក្តី ដើមឈូកក្រហមក្តី មកពួត ភ្លើងក៏ឆេះប្រាកដឡើង ភ្លើងនោះឯង ទើបមានអណ្តាត មានពណ៌ ទាំងមានពន្លឺ បុគ្គលអាចធ្វើកិច្ចការដែលត្រូវធ្វើដោយភ្លើង ដោយសារភ្លើងនោះ បានឬ ចំណែកឯភ្លើងណា ដែលពួកបុរសចេញអំពីពួកចណ្ឌាលត្រកូលក្តី នេសាទត្រកូលក្តី វេណុត្រកូលក្តី រថការ-ត្រកូលក្តី បុក្កុសត្រកូលក្តី មកចួបជុំគ្នាហើយកាន់យកឈើពំនួតភ្លើងខាងលើ ដែលធ្វើពីស្នូកឆ្កែក្តី ស្នូកជ្រូកក្តី ស្នូកជាងជ្រលក់ក្តី ដើមល្ហុងប្រេងក្តី មកពួត ភ្លើងក៏ឆេះប្រាកដឡើងដែរ តែភ្លើងនោះ មិនមានអណ្តាត មិនមានពណ៌ ទាំងមិនមានពន្លឺ បុគ្គលមិនអាចធ្វើកិច្ចការដែលត្រូវធ្វើដោយភ្លើង ដោយសារភ្លើងនោះបានទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន ភ្លើងណា

ខត្តិយកុលា ព្រាហ្មណកុលា រាជញ្ញកុលា ឧប្បន្នេហិ សាកស្ស វា សាលស្ស វា សលឡស្ស វា ចន្ទនស្ស វា បទុមកស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ ចាតុកតោ ស្វាស្ស អគ្គិ អច្ចិមា ច វណ្ណិមា ច បភស្សរោ ច តេន ច សក្កា អគ្គិនា អគ្គិករណីយំ កាតុំ យោបិ សោ ចណ្ឌាលកុលា នេសាទ-កុលា វេណុកុលា រថការកុលា បុក្កុសកុលា ឧប្បន្នេហិ សាបានទោណិយា វា សូករទោណិយា វា រជកទោណិយា វា ឯលណ្ឌកដ្ឋស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ ចាតុកតោ សោបស្ស[១] អគ្គិ អច្ចិមា ច វណ្ណិមា ច បភស្សរោ ច តេនបិ ច សក្កា អគ្គិនា អគ្គិករណីយំ កាតុំ សព្វោបិ ហិ ភោ គោតម អគ្គិ អច្ចិមា ច វណ្ណិមា ច បភស្សរោ ច សព្វេនបិ ច សក្កា អគ្គិនា អគ្គិករណីយំ កាតុន្តិ ។ ឯត្ថ អស្ស-លាយន ព្រាហ្មណានំ កឹ ពលំ កោ អស្សាសោ

១ ឱ. ច ។

ដែលពួកបុរស ចេញអំពីខត្តិយត្រកូលក្តី ព្រាហ្មណត្រកូលក្តី រាជញ្ញ-ត្រកូលក្តី មកចួបជុំគ្នា ហើយកាន់យកពំនួតភ្លើងដែលធ្វើពីឈើស្រាយក្តី ឈើខ្ទឹមក្តី ដើមស្រល់ក្តី ដើមចន្ទន៍ក្តី ដើមឈូកក្រហមក្តី មកពួត ភ្លើងក៏ឆេះប្រាកដឡើង ភ្លើងនោះឯង មានអណ្តាត មានពណ៌ មាន ពន្លឺ បុគ្គលអាចធ្វើកិច្ចការដែលត្រូវធ្វើដោយភ្លើង ដោយសារភ្លើងនោះ ក៏បាន ចំណែកឯភ្លើងណា ដែលពួកបុរសចេញ អំពីចណ្ឌាលត្រកូល ក្តី នេសាទត្រកូលក្តី វេណុត្រកូលក្តី រថការត្រកូលក្តី បុក្កុសត្រកូលក្តី មកចួបជុំគ្នា ហើយកាន់យកឈើពំនួតភ្លើងខាងលើ ដែលធ្វើពីស្នូកឆ្កែក្តី ស្នូកជ្រូកក្តី ស្នូកជាងជ្រលក់ក្តី ដើមល្ហុងប្រេងក្តី មកពួត ភ្លើងក៏ឆេះ ប្រាកដឡើង ភ្លើងនោះឯង ក៏មានអណ្តាត មានពណ៌ មានពន្លឺ បុគ្គល អាចធ្វើកិច្ចការដែលត្រូវធ្វើដោយភ្លើង ដោយសារភ្លើងនោះ បានដូចគ្នា បពិត្រព្រះគោតមដ៏ចម្រើន ព្រោះភ្លើងទាំងអស់ សុទ្ធតែមានអណ្តាត មានពណ៌ ទាំងមានពន្លឺ បុគ្គលអាចធ្វើកិច្ចការដែលត្រូវធ្វើដោយភ្លើង ដោយសារភ្លើងនោះបានទាំងអស់ ។ ម្នាលអស្សលាយនៈ បណ្តាវណ្ណៈ ទាំង ៤ នោះ ពួកព្រាហ្មណ៍មានកម្លាំងដូចម្តេច មានទីពឹងពំនាក់ដូចម្តេច

យេនេត្ថ ព្រាហ្មណា ឯវមាហំសុ ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ព្រាហ្មណោវ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណាវ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណាវ ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ។ កិញ្ចាបិ ភវំ គោតមោ ឯវមាហ អថខ្វេត្ថ ព្រាហ្មណា ឯវមេតំ មញ្ញន្តិ ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។

[៤០] តំ កឹ មញ្ញសិ អស្សលាយន ឥធ ខត្តិយកុមារោ ព្រាហ្មណកញ្ញាយ សទ្ធឹ សំវាសំ កប្បេយ្យ តេសំ សំវាសមន្វាយ បុត្តោ ជាយេថ យោ សោ ខត្តិយកុមារេន ព្រាហ្មណកញ្ញាយ បុត្តោ ឧប្បន្នោ សិយា សោ មាតុបិ សទិសោ បិតុបិ សទិសោ

បានជាពួកព្រាហ្មណ៍ ហ៊ាននិយាយយ៉ាងនេះ ក្នុងរឿងនុ៎ះថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ពួកព្រាហ្មណ៍ទើបជាវណ្ណៈស វណ្ណៈឯទៀតជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍ទើបបរិសុទ្ធ មិនមែនពួកព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ ជាបុត្រជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្ម ជាអ្នកបង្កើត មានព្រហ្ម ជាអ្នកនិម្មិត ជាញាតិនឹងព្រហ្មដូច្នោះ ។ ព្រះគោតមដ៏ចម្រើនត្រាស់យ៉ាងនេះ ក៏សមដែរ តែថាពួកព្រាហ្មណ៍នៅតែសំគាល់សេចក្តីនុ៎ះក្នុងរឿងនុ៎ះយ៉ាងនេះដដែលថា ពួកព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រះព្រហ្ម ។

[៤០] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះ ដូចម្តេច (បើ) ខត្តិយកុមារ ក្នុងលោកនេះ សម្រេចសំវាសជាមួយនឹងព្រាហ្មណកញ្ញា កើតបុត្រម្នាក់ឡើង ព្រោះអាស្រ័យសំវាសនៃជនទាំងពីរនាក់នោះ បុត្រដែលកើតឡើង ដោយខត្តិយកុមារនឹងព្រាហ្មណកញ្ញានោះ ប្រហែលនឹងមាតាផង ប្រហែលនឹងបិតាផង

ខត្តិយោតិបិ វត្តព្វោ ព្រាហ្មណោតិបិ វត្តព្វោតិ ។ យោ សោ ភោ គោតម ខត្តិយកុមារេន ព្រាហ្មណកញ្ញាយ បុត្តោ ឧប្បន្នោ សិយា សោ មាតុបិ សទិសោ បិតុបិ សទិសោ ខត្តិយោតិបិ វត្តព្វោ ព្រាហ្មណោតិបិ វត្តព្វោតិ ។

[៤១] តំ កឹ មញ្ញសិ អស្សលាយន ឥធ ព្រាហ្មណកុមារោ ខត្តិយកញ្ញាយ សទ្ធឹ សំវាសំ កប្បេយ្យ តេសំ សំវាសមន្វាយ បុត្តោ ជាយេថ យោ សោ ព្រាហ្មណកុមារេន ខត្តិយកញ្ញាយ បុត្តោ ឧប្បន្នោ សិយា សោ មាតុបិ សទិសោ បិតុបិ សទិសោ ខត្តិយោតិបិ វត្តព្វោ ព្រាហ្មណោតិបិ វត្តព្វោតិ ។ យោ សោ ភោ គោតម ព្រាហ្មណកុមារេន ខត្តិយកញ្ញាយ បុត្តោ ឧប្បន្នោ សិយា សោ មាតុបិ សទិសោ បិតុបិ សទិសោ ខត្តិយោតិបិ វត្តព្វោ ព្រាហ្មណោតិបិ វត្តព្វោតិ ។

តើគេគួរហៅថា ក្សត្រិយ៍ ឬគេគួរហៅថា ព្រាហ្មណ៍ ។ អស្សលាយនៈ ក្រាបបង្គំទូលថា បពិត្រព្រះគោតម ដ៏ចម្រើន បុត្រដែលកើតឡើង ដោយខត្តិយកុមារនិងព្រាហ្មណកញ្ញានោះ ប្រហែលនឹងមាតាផង ប្រហែលនឹងបិតាផង គេគួរហៅថា ក្សត្រិយ៍ក៏បាន ហៅថា ព្រាហ្មណ៍ក៏បាន ។

[៤១] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច (បើ) ព្រាហ្មណកុមារក្នុងលោកនេះ សម្រេចសំវាស ជាមួយនឹងខត្តិយកញ្ញា កើតបុត្រម្នាក់ឡើង ព្រោះអាស្រ័យសំវាសនៃជនទាំងពីរនាក់នោះ បុត្រដែលកើតដោយព្រាហ្មណកុមារនិងខត្តិយកញ្ញានោះ ប្រហែលនឹងមាតាផង ប្រហែលនឹងបិតាផង តើគេគួរហៅថា ក្សត្រិយ៍ ឬគេគួរហៅថា ព្រាហ្មណ៍ ។ បពិត្រព្រះគោតមដ៏ចម្រើន បុត្រដែលកើតឡើង ដោយព្រាហ្មណកុមារនិងខត្តិយកញ្ញានោះ ប្រហែលនឹងមាតាផង ប្រហែលនឹងបិតាផង គេគួរហៅថា ក្សត្រិយ៍ក៏បាន គេគួរហៅថា ព្រាហ្មណ៍ក៏បាន ។

ព្រាហ្មណវគ្គស្ស អស្សលាយនសុត្តេ វលវាសម្បយោជនូបមា

[៤២] តំ កឹ មញ្ញសិ អស្សលាយន ឥធ វលវំ គទ្រភេន សម្បយោជេយ្យុំ តេសំ សម្បយោគមន្វាយ កិស្សរោ(១) ជាយេថ យោ សោបិ(២) វលវាយ គទ្រភេន កិស្សរោ(៣) ឧប្បន្នោ សិយា សោ មាតុបិ សទិសោ បិតុបិ សទិសោ អស្សោតិបិ វត្តព្វោ គទ្រភោតិបិ វត្តព្វោតិ ។ សោ កុមារណ្ឌុបិ(៤) សោ ភោ គោតម អស្សតរោ ហោតិ ឥទំ ហិស្ស ភោ គោតម នានាករណំ បស្សាមិ អមុត្រ ច(៥) បន សានំ(៦) ន កិញ្ចិ នានាករណំ បស្សាមីតិ ។

[៤៣] តំ កឹ មញ្ញសិ អស្សលាយន ឥធាស្សុ ទ្វេ មាណវកា ភាតរោ សោទរិយា(៧) ឯកោ អជ្ឈាយកោ ឧបនីតោ ឯកោ អនជ្ឈាយកោ អនុបនីតោ កមេត្ថ ព្រាហ្មណា បឋមំ ភោជេយ្យុំ សទ្ធេ វា ថាលិបាកេ វា

---

១ ឱ. កិសោរោ ។ ២ ឱ. អបិសទ្ទោ នត្ថិ ។ ៣ ឱ. កិសារោ ។ ៤ ឱ. វេកុរញ្ញាយាតិ ទិស្សតិ ។ ម. កុណ្ឌន្តិ ទិស្សតិ ។ ៥ ឱ. ចសទ្ទោ នត្ថិ ។ ៦ ម. បនេសានំ ។ ៧ ឱ. ម. សឧទរិយា ។

ព្រាហ្មណវគ្គ អស្សលាយនសូត្រ ឧបមាដោយការបង្កាត់សេះនឹងបាលា

[៤២] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច (បើ) ពួកមនុស្សក្នុងលោកនេះ យកមេសេះទៅបង្កាត់កូននឹងបាលា ក៏កើតកូនឡើង ព្រោះអាស្រ័យសំវាសនៃសត្វទាំងពីរនោះ កូនដែលកើតឡើងដោយមេសេះនិងបាលានោះ ប្រហែលនឹងមេផង ប្រហែលនឹងបាផង តើគេគួរហៅថា សេះ ឬគេគួរហៅថា លា ។ អស្សលាយនៈក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន កូនសត្វនោះជាកូនសេះអស្សតរ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គគ្រាន់តែឃើញនូវអំពើផ្សេង ៗ នេះ របស់សេះអស្សតរនោះប៉ុណ្ណោះ ឯនឹងឃើញនូវអំពើផ្សេង ៗ ណាមួយ របស់មាណពជំទង់ទាំងនុ៎ះ ក្នុងន័យខាងដើមឯណោះផង ក៏ទេ ។

[៤៣] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច (បើ) មាណពពីរនាក់ ក្នុងលោកនេះ ជាបងប្អូននឹងគ្នាកើតក្នុងឧទរជាមួយគ្នា មាណពម្នាក់ជាអ្នកចេះមន្តបានបទ មាណពម្នាក់ទៀត ជាអ្នកមិនចេះមន្ត មិនបានបទ បណ្តាមាណពទាំងពីរនោះ តើពួកព្រាហ្មណ៍អញ្ជើញអ្នកណាឲ្យបរិភោគនូវសទ្ធភត្ត (ភត្តដែលគេឧទ្ទិសដល់បុគ្គលស្លាប់) ទាំងឡាយ ឬនូវថាលិបាកភត្ត (សម្រាប់) ទាំងឡាយ

យញ្ញេ វា ចាហុនេ[១] វាតិ ។ យោ សោ ភោ គោតម មាណវកោ អជ្ឈាយកោ ឧបនីតោ តមេត្ថ ព្រាហ្មណា បឋមំ ភោជេយ្យុំ សទ្ធេ វា ថាលិបាកេ វា យញ្ញេ វា ចាហុនេ វា កឹ ហិ ភោ គោតម អនជ្ឈាយកេ អនុបនីតេ ទិន្នំ មហប្ផលំ ភវិស្សតីតិ ។

[៤៤] តំ កឹ មញ្ញសិ អស្សលាយន ឥធាស្សុ ទ្វេ មាណវកា ភាតរោ សោទរិយា ឯកោ អជ្ឈាយកោ ឧបនីតោ ទុស្សីលោ បាបធម្មោ ឯកោ អនជ្ឈាយកោ អនុបនីតោ សីលវា កល្យាណធម្មោ កមេត្ថ ព្រាហ្មណា បឋមំ ភោជេយ្យុំ សទ្ធេ វា ថាលិបាកេ វា យញ្ញេ វា ចាហុនេ វាតិ ។ យោ សោ ភោ គោតម មាណវកោ អនជ្ឈាយកោ

១ ម. បាហុនកេ ។

នូវយញ្ញភត្ត (ភត្តដែលគេរៀបបូជា) ទាំងឡាយ ឬបាហុនភត្ត (ភត្តដែលគេនាំមកដើម្បីអាគន្តុក:) ទាំងឡាយ មុនគេ ។ អស្សលាយនៈ ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន បណ្តាមាណពទាំងពីរនុ៎ះ មាណពណាចេះមន្ត បានបទ ពួកព្រាហ្មណ៍គួរអញ្ជើញមាណពនោះឲ្យបរិភោគសទ្ធភត្តទាំងឡាយ ឬនូវថាលិបាកភត្តទាំងឡាយ នូវយញ្ញភត្តទាំងឡាយ ឬនូវបាហុនភត្តទាំងឡាយ មុនគេ បពិត្រព្រះគោតមដ៏ចម្រើន ទានដែលបុគ្គលឲ្យដល់មាណពដែលមិនចេះមន្ត មិនបានបទ នឹងជាទានមានផលច្រើនដូចម្តេចបាន ។

[៤៤] ព្រះអង្គត្រាស់សួរថា ម្នាលអស្សលាយនៈ អ្នកយល់សេចក្តីនោះដូចម្តេច (បើ) មានមាណពទាំងពីរនាក់ ក្នុងលោកនេះ ជាបងប្អូននឹងគ្នា កើតក្នុងឧទរជាមួយគ្នា ម្នាក់ជាអ្នកចេះមន្ត បានបទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាក់ទៀត ជាអ្នកមិនចេះមន្ត មិនបានបទ តែជាអ្នកមានសីល មានធម៌ល្អ បណ្តាមាណពទាំងពីរនាក់នោះ តើពួកព្រាហ្មណ៍អញ្ជើញមាណពណា ឲ្យបរិភោគ នូវសទ្ធភត្តទាំងឡាយ ឬនូវថាលិបាកភត្តទាំងឡាយ នូវយញ្ញភត្តទាំងឡយ ឬនូវបាហុនភត្តទាំងឡាយ មុនគេ ។ អស្សលាយនមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន មាណពណា ដែលមិនចេះមន្ត

អនុបនីតោ សីលវា កល្យាណធម្មោ តមេត្ថ ព្រាហ្មណា បឋមំ ភោជេយ្យុំ សទ្ធេ វា ថាលិបាកេ វា យញ្ញេ វា បាហុនេ វា កឹ ហិ ភោ គោតម ទុស្សីលេ បាបធម្មេ ទិន្នំ មហប្ផលំ ភវិស្សតីតិ ។ បុព្វេ ខោ ត្វំ អស្សលាយន ជាតឹ អគមាសិ ជាតឹ គន្ត្វា មន្តេ អគមាសិ មន្តេ គន្ត្វា តមេវ ឋបេត្វា[១] ចាតុវណ្ណឹ សុទ្ធឹ បច្ចាគតោ យមហំ បញ្ញបេមីតិ ។ ឯវំ វុត្តេ អស្សលាយនោ មាណវោ តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។

[៤៩] អថខោ ភគវា អស្សលាយនំ មាណវំ តុណ្ហីភូតំ មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា អស្សលាយនំ មាណវំ ឯតទ-វោច ភូតបុព្វំ អស្សលាយន សត្តន្នំ ព្រាហ្មណិសីនំ

១ ឱ. តមេតំ ត្វន្តិ ទិស្សតិ ។ ម. តបេ អគមាសិ ។ តបេ គន្ត្វាតិ ទិស្សតិ ។

មិនបានបទ តែជាអ្នកមានសីល មានធម៌ល្អ បណ្តាមាណពទាំងពីរនាក់នុ៎ះ ពួកព្រាហ្មណ៍គួរអញ្ជើញមាណពនោះ ឲ្យបរិភោគនូវសទ្ធកត្តទាំងឡាយ ឬនូវថាលិបាកកត្តទាំងឡាយ នូវយញ្ញកត្តទាំងឡាយ ឬនូវបាហុនកត្តទាំងឡាយ មុនគេ បពិត្រព្រះគោតមដ៏ចម្រើន ទានដែលបុគ្គលឲ្យដល់មាណព ទ្រុស្តសីល មានធម៌ដ៏លាមក នឹងជាទានមានផលច្រើនដូចម្តេចបាន ។ ម្នាលអស្សលាយនៈ កាលពីមុន អ្នកអាងជាតិកំណើត លុះអាងជាតិកំណើតហើយ អ្នកអាងមន្តទាំងឡាយ លុះអាងមន្តទាំងឡាយហើយ ត្រឡប់ជាលើកលែងនូវមន្តនោះ ហើយមកប្រកាន់យកនូវសេចក្តីបរិសុទ្ធក្នុងវណ្ណៈទាំង ៤ តាមដែលតថាគតបញ្ញត្តវិញ ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អស្សលាយនមាណពក៏អង្គុយស្ងៀម ក្រអឹម ទន់កល្បៀក ដាក់មុខជ្រប់ លែងមាត់សោះ ។

[៤៥] លុះព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ ថាអស្សលាយនមាណពនៅស្ងៀម ក្រអឹម ទន់កល្បៀក ដាក់មុខជ្រប់ លែងមាត់កហើយ ទើបទ្រង់ត្រាស់នឹងអស្សលាយនមាណពដូច្នេះថា ម្នាលអស្សលាយនៈ កាលពីព្រេងនាយ មានព្រាហ្មណឥសី ៧ នាក់ ដែលអាស្រ័យ

អរញ្ញាយតនេ បណ្ណកុដីសុ សម្មន្តានំ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ អស្សោសិ ខោ អស្សលាយន អសិតោ ទេវលោ ឥសិ សត្តន្នំ កិរ ព្រាហ្មណិសីនំ អរញ្ញាយតនេ បណ្ណកុដីសុ សម្មន្តានំ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ អថខោ អស្សលាយន អសិតោ ទេវលោ ឥសិ កេសមស្សុំ កប្បេត្វា មញ្ជេដ្ឋវណ្ណានិ ទុស្សានិ និវាសេត្វា អគលិយោ() ឧបាហនា អារោហិត្វា ជាតរូបមយំ ទណ្ឌំ គហេត្វា សត្តន្នំ ព្រាហ្មណិសីនំ បត្តិណ្ឌិលេ(២) បាតុរហោសិ ។ អថខោ អស្សលាយន អសិតោ ទេវលោ ឥសិ សត្តន្នំ ព្រាហ្មណិសីនំ បត្តិណ្ឌិលេ ចង្កមមានោ ឯវមាហ ហន្ទ កោ នុ ខោ ឥមេ ភវន្តោ ព្រាហ្មណិសយោ គន្តា(៣)

១ ឱ. អដលិយោ ។ ម. បដលិយោ ។ ២ ឱ. ម. បត្តណ្ឌិលេ ។ ៣ ឱ. គតា ។

នៅក្នុងបណ្ណកុដិ (កុដិស្លឹក) ទាំងឡាយ នាដងព្រៃ កើតគំនិតអាក្រក់ មានសភាពយ៉ាងនេះថា ពួកព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀត ជាវណ្ណៈថោកទាប ។ បេ ។ ជាញាតិនឹងព្រហ្ម ។ ម្នាលអស្សលាយនៈ អសិតទេវលឥសី បានឮដំណឹងថា ព្រាហ្មណឥសីទាំង ៧ នាក់ ដែលអាស្រ័យនៅក្នុងបណ្ណកុដិទាំងឡាយ នាដងព្រៃ កើតគំនិតអាក្រក់ មានសភាពយ៉ាងនេះថា ពួកព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរ ។ បេ ។ ជាញាតិនឹងព្រហ្ម ។ ម្នាលអស្សលាយនៈ គ្រានោះ អសិតទេវលឥសី កោរសក់ និងពុកមាត់ពុកចង្កា ស្លៀកសំពត់ពណ៌ហង្សបាទ ពាក់ស្បែកជើង ៤ ជាន់ កាន់ដំបងដែលរចនាដោយប្រាក់និងមាស ស្រាប់តែឃើញប្រាកដនាបរិវេណនៃបណ្ណសាលា របស់ព្រាហ្មណឥសីទាំង ៧ នាក់ ។ ម្នាលអស្សលាយនៈ លំដាប់នោះ អសិតទេវលឥសីដើរវេរាក្បែរបរិវេណនៃបណ្ណសាលារបស់ព្រាហ្មណឥសីទាំង ៧ នាក់ ក៏ស្រែកហៅយ៉ាងនេះថា ចុះព្រាហ្មណឥសីដ៏ចម្រើនទាំងនេះ ទៅឯណាទៅហើយ

**៧៧**

ព្រាហ្មណវគ្គស្ស អស្សលាយនសុត្តេ ភូតបុព្វកថា

ហន្ទ កោ នុ ខោ ឥមេ ភវន្តោ ព្រាហ្មណិសយោ គតាតិ ។ អថខោ អស្សលាយន សត្ត ព្រាហ្មណិសយោ អសិតំ ទេវលំ ឥសឹ ឯតទវោចុំ[១] កោ នាយំ[២] គាមណ្ឌលរូបោ វិយ សត្តន្នំ ព្រាហ្មណិសីនំ បត្តិណ្ឌិលេ ចង្កមមានោ ឯវមាហ ហន្ទ កោ នុ ខោ ឥមេ ភវន្តោ ព្រាហ្មណិសយោ គតា ហន្ទ កោ នុ ខោ ឥមេ ភវន្តោ ព្រាហ្មណិសយោ គតាតិ ហន្ទ នំ អភិសបិស្សាមាតិ ។ អថខោ អស្សលាយន សត្ត ព្រាហ្មណិសយោ អសិតំ ទេវលំ ឥសឹ អភិសបឹសុ ភស្មា ចបលី[៣] ហោហិ ភស្មា ចបលី ហោហិ ភស្មា ចបលី ហោហីតិ ។ យថា យថា ខោ អស្សលាយន សត្ត ព្រាហ្មណិសយោ អសិតំ ទេវលំ ឥសឹ អភិសបឹសុ តថា តថា អសិតោ ទេវលោ ឥសិ អភិរូបតរោ ចេវ ហោតិ ទស្សនីយតរោ ច បាសាទិកតរោ ច ។

---

១ ឱ. អថខោ អស្សលាយន សត្តន្នំ ព្រាហ្មណិសីនំ ឯតទហោសីតិ ទិស្សតិ ។ ម. អថ អស្សលាយន... ។ ២ ម. បនាយំ ។ ៣ ឱ. ម. វសលី ។

ចុះព្រាហ្មណឥសីដ៏ចម្រើនទាំងនេះ ទៅឯណាទៅហើយ ។ ម្នាលអស្សលាយនៈ ព្រាហ្មណឥសីទាំង ៧ នាក់ ក៏និយាយនឹងអសិតទេវលឥសីដូច្នេះថា យើនរណាហ្នឹង មានសភាពដូចជាក្មេងអ្នកស្រុក មកដើរអេកក្បែរបរិវេណនៃបណ្ណសាលា របស់ព្រាហ្មណឥសីទាំង ៧ នាក់ ស្រែកហៅយ៉ាងនេះថា ចុះព្រាហ្មណឥសីដ៏ចម្រើនទាំងនេះ ទៅឯណាទៅហើយ ចុះព្រាហ្មណឥសីដ៏ចម្រើនទាំងនេះទៅឯណាហើយដូច្នេះ បើដូច្នោះ យើងនឹងប្រទេចផ្ដាសាវា ។ ម្នាលអស្សលាយនៈ លំដាប់នោះព្រាហ្មណឥសីទាំង ៧ នាក់ ក៏ប្រទេចផ្ដាសា នូវអសិតទេវលឥសីថា បុរសចង្រៃឯងចូរវិនាសដូចជាផេះ បុរសចង្រៃឯងចូរវិនាសដូចជាផេះ បុរសចង្រៃឯងចូរវិនាសដូចជាផេះ ។ ម្នាលអស្សលាយនៈ ព្រាហ្មណឥសីទាំង ៧ នាក់ ប្រទេចផ្ដាសាអសិតទេវលឥសី យ៉ាងណា យ៉ាងណា ក៏អសិតទេវលឥសី រឹងរឹតតែមានរូបល្អក្រៃលែងផង គួរពិតពឹលរមើលមើលក្រៃលែងផង គួរជាទីជ្រះថ្លាក្រៃលែងផង យ៉ាងនោះ ៗ ។

អថខោ អស្សលាយន សត្តន្នំ ព្រាហ្មណិសីនំ ឯតទ-ហោសិ មោឃំ វត នោ តតោ អប្ផលំ ព្រហ្មចរិយំ មយំ ហិ បុព្វេ យំ អភិសចាម ភស្មា ចបលី ហោហីតិ ភស្មា[១] ភវតិ ឯកច្ចោ ឥមំ បន មយំ យថា យថា អភិសចាម តថា តថា អភិរូបតរោ ចេវ ហោតិ ទស្សនីយតរោ ច បាសាទិកតរោ ចាតិ ។ ន ភវន្តានំ មោឃំ តតោ ន បនាប្ផលំ ព្រហ្មចរិយំ ឥង្ឃ ភវន្តោ យោ មយិ មនោបទោសោ តំ បជហថាតិ ។ យោ ភវតិ មនោបទោសោ តំ បជហាម កោ នុ ភវំ ហោតីតិ ។ សុតោ នោ ភវន្តំ អសិតោ ទេវលោ ឥសីតិ ។ ឯវំ ភោតិ[២] ។ សោ ខ្វាហំ ភោ ហោមីតិ ។ អថខោ អស្សលាយន

---

១ ឱ. ភស្មាវ ។ ២ ឱ. ម. ឥតិសទ្ទោ នត្ថិ ។

ម្នាលអស្សលាយនៈ ព្រាហ្មណឥសីទាំង ៧ នាក់ ក៏មានសេចក្ដីត្រិះរិះ ដូច្នេះថា ឱហ្ន៎ តបៈរបស់ពួកយើង សោះសូន្យហើយតើ ព្រហ្មចរិយៈ របស់ពួកយើង មិនមានផលទេតើ ព្រោះកាលពីមុន ពួកយើងប្រទេច ផ្ដាសានូវមនុស្សណាថា បុរសចង្រៃឯងចូរវិនាសដូចជាផេះដូច្នេះ មនុស្ស ខ្លះនោះរលាយទៅជាផេះទៅហើយ តែឥឡូវពួកយើង ប្រទេចផ្ដាសា បុរសនេះយ៉ាងណា ៗ បុរសនោះរឹងរឹតតែមានរូបល្អក្រៃលែងផង គួរពិត ពិលរមិលមើលក្រៃលែងផង គួរជាទីជ្រះថ្លាក្រៃលែងផង យ៉ាងនោះ ៗ ។ អសិតទេវលឥសី និយាយប្រាប់ថា តបៈរបស់អ្នកដ៏ចម្រើនទាំងឡាយ មិនទាន់សោះសូន្យនៅឡើយទេ ទាំងព្រហ្មចរិយៈក៏មិនមែនឥតផលដែរ ណ្ហើយបើអ្នកដ៏ចម្រើនទាំងឡាយ មានចិត្តប្រទូស្តមករកយើងបែបណា ចូរលះចិត្តប្រទូស្ត បែបនោះចេញ ។ ព្រាហ្មណឥសីទាំង ៧ នាក់ និយាយថា បើមានចិត្តប្រទូស្តបែបណា ពួកយើងនឹងលះបង់ នូវចិត្ត ប្រទូស្តបែបនោះចេញ ចុះអ្នកដ៏ចម្រើន ជាអ្វីទៅអេះ ។ អសិត-ទេវលឥសីសួរថា ចុះអ្នកដ៏ចម្រើនទាំងឡាយ ដែលឮឈ្មោះអសិត-ទេវលឥសី ដែរឬទេ ។ ឥសីទាំង ៧ នាក់ឆ្លើយថា បាទលោក ដ៏ចម្រើន ។ អសិតទេវលឥសីប្រាប់ថា ម្នាលអ្នកដ៏ចម្រើន យើង ហ្នឹងហើយ ជាអសិតទេវលឥសី ។ ម្នាលអស្សលាយនៈ គ្រានោះ

## ៧៩

### ព្រាហ្មណវគ្គស្ស អស្សលាយនសុត្តេ ភូតបុព្វកថា

សត្ត ព្រាហ្មណិសយោ អសិតំ ទេវលំ ឥសឹ អភិវាទេតុំ ឧបក្កមឹសុ[១] ។ អថខោ អស្សលាយន អសិតោ ទេវលោ ឥសិ សត្ត ព្រាហ្មណិសយោ ឯតទវោច សុតមេតំ ភោ សត្តន្នំ កិរ ព្រាហ្មណិសីនំ អរញ្ញាយតនេ បណ្ណកុដីសុ សម្មន្តានំ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា វ ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ។ ឯវំ ភោតិ ។ ជានន្តិ បន ភោន្តោ យា ជនិមាតា[២] ព្រាហ្មណំយេវ អគមាសិ នោ អព្រាហ្មណន្តិ ។ នោ ហិទំ ភោ ។ ជានន្តិ បន ភោន្តោ

១ ឱ. ឧបសង្កមឹសុ ។ ២ ម. ជនិកា មាតា ។

ព្រាហ្មណវគ្គ អស្សលាយនសូត្រ ទ្រង់ដំណាលរឿងព្រេង

ព្រាហ្មណឥសីទាំង ៧ នាក់ ចូលទន្ទបទៅក្រាបថ្វាយបង្គំអសិតទេវលឥសី ។ ម្នាលអស្សលាយនៈ លំដាប់នោះ អសិតទេវលឥសី និយាយនឹងព្រាហ្មណឥសីទាំង ៧ នាក់ ដូច្នេះថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ខ្ញុំបានឮថា ព្រាហ្មណឥសីទាំង ៧ នាក់ ដែលនៅអាស្រ័យក្នុងបណ្ណកុដិទាំងឡាយ នាដងព្រៃ កើតទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា ពួកព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរ វណ្ណៈឯទៀតជាវណ្ណៈថោកទាប ពួកព្រាហ្មណ៍ទើបជាវណ្ណៈស វណ្ណៈឯទៀតជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍ទើបបរិសុទ្ធ មិនមែនពួកព្រាហ្មណ៍ មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ ជាបុត្រជាឱរសរបស់ព្រហ្ម កើតពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាអ្នកបង្កើត មានព្រហ្មជាអ្នកនិម្មិត ជាញាតិនឹងព្រហ្ម ដូច្នេះមែនឬ ។ ឥសីទាំង ៧ នាក់ឆ្លើយថា បពិត្រលោកដ៏ចម្រើន យ៉ាងហ្នឹងមែនហើយ ។ អសិតទេវលឥសីសួរទៀតថា អ្នកដ៏ចម្រើនទាំងឡាយដឹងថាស្ត្រី ដែលជាមាតាបង្កើត (របស់អ្នកទាំងឡាយ) សុទ្ធតែយកព្រាហ្មណ៍ជាស្វាមី មិនយកបុរស ដែលមិនមែនព្រាហ្មណ៍ទេឬ ។ មិនយកទេ លោកដ៏ចម្រើន ។ ចុះអ្នកដ៏ចម្រើនទាំងឡាយ ដឹងថា

យា ជនិមាតុ មាតា យាវ សត្តមា មាតុ[១] មាតាមហយុគា ព្រាហ្មណំយេវ អគមាសិ នោ អព្រាហ្មណន្តិ ។ នោ ហិទំ ភោ ។ ជានន្តិ បន ភោន្តោ យោ ជនិបិតា[២] ព្រាហ្មណំយេវ អគមាសិ នោ អព្រាហ្មណិន្តិ ។ នោ ហិទំ ភោ ។ ជានន្តិ បន ភោន្តោ យោ ជនិបិតុ បិតា យាវ សត្តមា បិតុ[៣] បិតាមហយុគា ព្រាហ្មណឹយេវ អគមាសិ នោ អព្រាហ្មណិន្តិ ។ នោ ហិទំ ភោ ។ ជានន្តិ បន ភោន្តោ យថា គព្ភស្ស អវក្កន្តិ ហោតីតិ ។ ជានាម មយំ ភោ យថា គព្ភស្ស អវក្កន្តិ ហោតិ ឥធ មាតាបិតរោ ច[៤] សន្និបតិតា ហោន្តិ មាតា ច ឧតុនី ហោតិ គន្ធព្វោ ច បច្ចុបដ្ឋិតោ ហោតិ ឯវំ តិណ្ណំ សន្និចាតា គព្ភស្ស អវក្កន្តិ ហោតីតិ ។

---

១ ឱ. មាតូតិ ន ទិស្សតិ ។ ២ ម. ជនតោ បិតា ។ ៣ ឱ. បិតូតិ ន ទិស្សតិ ។ ៤ ឱ. វ ។

ស្ត្រីដែលជាមាតានៃមាតាបង្កើត (របស់អ្នកទាំងឡាយ) ដរាបដល់គូនៃជីដូនរបស់ម្តាយ ៧ តមក សុទ្ធតែយកព្រាហ្មណ៍ជាស្វាមី មិនយកបុរសដែលមិនមែនព្រាហ្មណ៍ទេឬ ។ មិនយកទេ លោកដ៏ចម្រើន ។ ចុះអ្នកដ៏ចម្រើនទាំងឡាយ ដឹងថាប្រុសដែលជាបិតាបង្កើត (របស់អ្នកទាំងឡាយ) សុទ្ធតែយកព្រាហ្មណីជាភរិយា មិនយកស្ត្រីដែលមិនមែនជាព្រាហ្មណីទេឬ ។ មិនយកទេ លោកដ៏ចម្រើន ។ ចុះអ្នកដ៏ចម្រើនទាំងឡាយដឹងថា ប្រុសដែលជាបិតានៃបិតាបង្កើត (របស់អ្នកទាំងឡាយ) ដរាបដល់គូនៃជីតារបស់បិតា ៧ តមក សុទ្ធតែយកព្រាហ្មណីជាភរិយា មិនយកស្ត្រីដែលមិនមែនជាព្រាហ្មណីទេឬ ។ មិនយកទេ លោកដ៏ចម្រើន ។ ចុះអ្នកដ៏ចម្រើនទាំងឡាយដឹងថា ការចុះកាន់គភ៌ យ៉ាងណាដែរឬ ។ បពិត្រលោកដ៏ចម្រើន ពួកយើងដឹងថា ការចុះកាន់គភ៌ (បីយ៉ាង) គឺក្នុងលោកនេះមាតានិងបិតាចួបជុំគ្នា ១ មាតាមានរដូវ ១ សត្វបានចុះមកកើតប្រាកដ ១ ការប្រជុំហេតុទាំង ៣ នេះ ទើបឈ្មោះថា ការចុះកាន់គភ៌ ។

៨១

ព្រាហ្មណវគ្គស្ស អស្សលាយនសុត្តេ ភូតបុព្វកថា

ជានន្តិ បន ភោន្តោ យក្ខោ សោ គន្ធព្វោ ខត្តិយោ វា ព្រាហ្មណោ វា វេស្សោ វា សុទ្ទោ វាតិ ។ ន មយំ ភោ ជានាម យក្ខោ សោ គន្ធព្វោ ខត្តិយោ វា ព្រាហ្មណោ វា វេស្សោ វា សុទ្ទោ វាតិ ។ ឯវំ សន្តេ ភោន្តោ[១] ជានាថ កោ តុម្ហេ ហោថាតិ ។ ឯវំ សន្តេ ភោ ន មយំ ជានាម កោចិ មយំ ហោមាតិ ។ តេ ហិ នាម អស្សលាយន សត្ត ព្រាហ្មណិសយោ អសិតេន ទេវលេន ឥសិនា សកោ ជាតិវាទេ សមនុយុញ្ជិយមានា សមនុគ្គាហិយមានា សមនុភាសិយមានា ន សម្បាយិស្សន្តិ កឹ បន ត្វំ ឯតរហិ មយា សកស្មឹ ជាតិវាទេ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ សម្បាយិស្សសិ យេសំ ត្វំ សាចរិយកោ ន បុណ្ណោ ទព្វិគ្គាហោតិ ។

---

១ ឱ. ម. ភោ ។

ចុះអ្នកដ៏ចម្រើនទាំងឡាយដឹងថា សត្វនោះជាក្សត្រិយ៍ ឬជាព្រាហ្មណ៍ ជាវេស្សៈឬសុទ្ទៈដែរឬទេ ។ បពិត្រលោកដ៏ចម្រើន យើងទាំងឡាយមិនដឹងថា សត្វនោះជាក្សត្រិយ៍ ឬជាព្រាហ្មណ៍ ជាវេស្សៈ ឬក៏ជាសុទ្ទៈទេ ។ កាលបើយ៉ាងនេះ អ្នកដ៏ចម្រើនទាំងឡាយដឹងថា ពួកអ្នកនឹងទៅជាអ្វីឬទេ ។ បពិត្រលោកដ៏ចម្រើន កាលបើយ៉ាងនេះ យើងទាំងឡាយមិនដឹងថា ពួកយើងនឹងទៅជាអ្វីទេ ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអស្សលាយនៈ សព្វបើអសិតទេវលឥសី ដេញដោល សាកសួរសួរឈ្វេចឈ្វី ក្នុងជាតិវាទជារបស់ខ្លួនប៉ុណ្ណឹង ព្រាហ្មណឥសី ទាំង ៧ នាក់នោះ មិនដឹងទៅហើយ ចំណង់បើឥឡូវនេះ តថាគតដេញដោល សាកសួរ សួរឈ្វេចឈ្វី ក្នុងជាតិវាទជារបស់ខ្លួន ធ្វើម្ដេចអ្នកនឹងដឹងបាន អ្នកមិនស្មើនឹងបុណ្ណៈ ជាអ្នកកាន់វែក ដែលជាកូនសិស្សរបស់ឥសីទាំង ៧ នាក់នោះផង ។

[៤៦] ឯវំ វុត្តេ អស្សលាយនោ មាណវោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

អស្សលាយនសុត្តំ តតិយំ និដ្ឋិតំ ។

[៤៦] *កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ អស្សលាយនមាណព ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតម ដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ តាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់សរណៈ ស្មើដោយជីវិត ។*

ចប់ អស្សលាយនសូត្រ ទី ៣ ។

# ចតុត្ថំ ឃោដមុខសុត្តំ

[៤៧] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា ឧទេនោ ពារាណសិយំ វិហរតិ ខេមិយម្ពវនេ ។ តេន ខោ បន សមយេន ឃោដមុខោ ព្រាហ្មណោ ពារាណសឹ អនុប្បត្តោ ហោតិ កេនចិទេវ ករណីយេ-ន ។ អថខោ ឃោដមុខោ ព្រាហ្មណោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន ខេមិយម្ពវនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន អាយស្មា ឧទេនោ អព្ភោកាសេ ចង្កមតិ ។ អថខោ ឃោដមុខោ ព្រាហ្មណោ យេន អាយស្មា ឧទេនោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា ឧទេនេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា អាយស្មន្តំ ឧទេនំ ចង្កមន្តំ អនុចង្កមមានោ ឯវមាហ អម្ភោ សមណ នត្ថិ ធម្មិកោ បរិព្វជោ[១] ឯវំ មេ ឯត្ថ ហោតិ តញ្ច ខោ ភវន្តរូបានំ វា អទស្សនា យោ វា បនេត្ថ ធម្មោតិ ។

១ ឱ. បរិព្វាជោតិ ទិស្សតិ ។

# ឃោដមុខសូត្រ ទី ៤

[៤៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ឧទេនភិក្ខុមានអាយុ នៅក្នុងខេមិយម្ពវ័ន (ព្រៃស្វាយ ឈ្មោះខេមិយៈ) ជិតក្រុងពារាណសី ។ ក៏សម័យនោះ ព្រាហ្មណ៍ឈ្មោះឃោដមុខ បានមកដល់ក្រុងពារាណសី ដោយកិច្ចការណាមួយ ។ លំដាប់នោះ ឃោដមុខព្រាហ្មណ៍ ដើរចង្រ្កមទៅ ដើរចង្រ្កមមក ដើម្បីសម្រាកស្មង បន្តិច រួចចូលសំដៅទៅកាន់ខេមិយម្ពវ័ន ។ សម័យនោះឯង ឧទេនភិក្ខុមានអាយុ កំពុងចង្រ្កមក្នុងទីវាល ។ ខណៈនោះ ឃោដមុខព្រាហ្មណ៍ចូលសំដៅ ទៅរកឧទេនភិក្ខុមានអាយុ ត្រង់កន្លែងដែលលោកនៅ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅរកឧទេនភិក្ខុមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ដើរចង្រ្កមតាមឧទេនភិក្ខុមានអាយុ ដែលកំពុងចង្រ្កម និយាយយ៉ាងនេះបណ្តើរថា បពិត្រសមណៈដ៏ចម្រើន ផ្នួសប្រកបដោយធម៌មិនមានទេ សេចក្តីចូលចិត្តរបស់ខ្ញុំក្នុងផ្នួសនេះយ៉ាងនេះ បានជាខ្ញុំចូលចិត្តដូច្នោះ ព្រោះមិនឃើញជនទាំងឡាយ មានសភាពដូចលោកដ៏ចម្រើនផង ព្រោះមិនឃើញធម៌ក្នុងផ្នួសនេះផង ។

[៤៨] ឯវំ វុត្តេ អាយស្មា ឧទេនោ ចង្កមា ឱរោហិត្វា វិហារំ បវិសិត្វា បញ្ញត្តេ អាសនេ និសីទិ ។ ឃោដមុខោបិ ខោ ព្រាហ្មណោ ចង្កមា ឱរោហិត្វា វិហារំ បវិសិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ ឃោដមុខំ ព្រាហ្មណំ អាយស្មា ឧទេនោ ឯតទវោច សំវិជ្ជន្តេ ខោ ព្រាហ្មណ អាសនានិ សចេ អាកង្ខសិ និសីទាតិ ។ ឯតទេវ ខោ បន មយំ ភោតោ ឧទេនស្ស អាគមយមានា ន[១] និសីទាម កថំ ហិ នាម មាទិសោ បុព្វេ អនិមន្តិតោ អាសនេ និសីទិតព្វំ មញ្ញេយ្យាតិ ។ អថខោ ឃោដមុខោ ព្រាហ្មណោ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឃោដមុខោ ព្រាហ្មណោ អាយស្មន្តំ ឧទេនំ ឯតទវោច អម្ភោ សមណ នត្ថិ ធម្មិកោ បរិព្វាជោ ឯវំ មេ ឯត្ថ ហោតិ តញ្ច ខោ

១ ម. នសទ្ទោ នត្ថិ ។

[៤៨] កាលឃោដមុខព្រាហ្មណ៍ និយាយយ៉ាងនេះហើយ ឧទេនភិក្ខុមានអាយុ ក៏ចុះអំពីទីចង្រ្កមចូលទៅកាន់វិហារ ហើយអង្គុយលើអាសនៈ ដែលគេក្រាលបម្រុងទុក ។ ចំណែកឃោដមុខព្រាហ្មណ៍ ក៏ចុះអំពីចង្រ្កម ហើយចូលទៅកាន់វិហារ ឋិតក្នុងទីដ៏សមគួរដែរ ។ លុះឃោដមុខព្រាហ្មណ៍ ឋិតក្នុងទីដ៏សមគួរហើយ ទើបឧទេនភិក្ខុមានអាយុនិយាយដូច្នេះថា ម្នាលព្រាហ្មណ៍ អាសនៈទាំងឡាយមានគ្រប់គ្រាន់ ប្រសិនបើអ្នកត្រូវការ អញ្ជើញអង្គុយចុះ ។ ឃោដមុខព្រាហ្មណ៍ឆ្លើយថា យើងរង់ចាំឧទេនភិក្ខុដ៏ចម្រើនទេតើ យើងមិនហ៊ានអង្គុយលើអាសនៈទុំះទេ ព្រោះថាបុគ្គលប្រហែលដូចខ្ញុំ បើគេមិនអញ្ជើញមុនហើយ ធ្វើម្តេចនឹងហ៊ានអង្គុយលើអាសនៈ ។ លំដាប់នោះ ឃោដមុខព្រាហ្មណ៍ កាន់យកអាសនៈដ៏ទាបមួយ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះឃោដ-មុខព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយដូច្នេះនឹងឧទេន-ភិក្ខុមានអាយុថា បពិត្រសមណៈដ៏ចម្រើន ផ្នួសប្រកបដោយធម៌មិនមានទេ សេចក្តីចូលចិត្តរបស់ខ្ញុំ ក្នុងផ្នួសយ៉ាងនេះ បានជាខ្ញុំចូលចិត្តដូច្នោះ

ភវន្តរូបានំ វា អនុស្សុតា យោ វា បនេត្ថ ធម្មោតិ ។ សចេ ខោ បន មេ ត្វំ ព្រាហ្មណ អនុមញ្ញេយ្យំ អនុជានេយ្យាសិ បដិក្កោសេតព្វញ្ច បដិក្កោសេយ្យាសិ យស្ស ច បន មេ ភាសិតស្ស អត្ថំ ន ជានេយ្យាសិ មមំយេវ តត្ថ ឧត្តរឹ បដិបុច្ឆេយ្យាសិ ឥទំ ភោ ឧទេន កថំ ឥមស្ស ក្វត្ថោតិ ឯវំ កត្វា សិយា នោ ឯត្ថ កថាសល្លាបោតិ ។ អនុមញ្ញេយ្យំ ខ្វាហំ ភោតោ ឧទេនស្ស អនុជានិស្សាមិ បដិក្កោសិតព្វញ្ច បដិក្កោសិស្សាមិ យស្ស ច បនាហំ ភោតោ ឧទេនស្ស ភាសិតស្ស អត្ថំ ន ជានិស្សាមិ ភវន្តំយេវ តត្ថ ឧទេនំ ឧត្តរឹ បដិបុច្ឆិស្សាមិ ឥទំ ភោ ឧទេន កថំ ឥមស្ស ក្វត្ថោតិ ឯវំ កត្វា ហោតុ នោ ឯត្ថ កថាសល្លាបោតិ ។

[៤៩] ចត្តារោមេ ព្រាហ្មណ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ កតមេ ចត្តារោ ឥធ ព្រាហ្មណ ឯកច្ចោ បុគ្គលោ អត្តន្តបោ ហោតិ អត្តបរិតាបនានុយោគមនុយុត្តោ ឥធ បន ព្រាហ្មណ ឯកច្ចោ

ព្រោះមិនឃើញជនទាំងឡាយ មានសភាពដូចលោកដ៏ចម្រើនផង ព្រោះមិនឃើញធម៌ ក្នុងផ្ទួសនេះផង ។ ឧទេនភិក្ខុតបថា ម្នាលព្រាហ្មណ៍ ប្រសិនបើអ្នកត្រូវការចង់ដឹងភាសិតដែលគួរដឹង ត្រូវឃាត់ភាសិតដែលគួរឃាត់របស់អាត្មា បើអ្នកមិនដឹងនូវសេចក្តីនៃភាសិតណា របស់អាត្មាទេ អ្នកត្រូវសួរក្នុងភាសិតនោះ នឹងអាត្មាតទៅទៀតថា បពិត្រឧទេនដ៏ចម្រើន ភាសិតនេះដូចម្តេច សេចក្តីនៃភាសិតនេះដូចម្តេច កាលបើធ្វើយ៉ាងនេះហើយ យើងទាំង ២ នាក់ទើបគួរនឹងចរចាគ្នា ក្នុងភាសិតនុ៎ះ តទៅទៀតបាន ។ យោជមុខព្រាហ្មណ៍ឆ្លើយថា ខ្ញុំត្រូវដឹងនូវភាសិតដែលគួរដឹង ត្រូវឃាត់នូវភាសិតដែលគួរឃាត់ របស់ឧទេនដ៏ចម្រើន តែថាបើខ្ញុំមិនដឹងនូវសេចក្តីនៃភាសិតណា របស់ឧទេនដ៏ចម្រើនទេ ខ្ញុំនឹងសួរនូវឧទេនដ៏ចម្រើនក្នុងភាសិតនោះ តទៅទៀតថា បពិត្រឧទេនដ៏ចម្រើន ភាសិតនេះដូចម្តេច សេចក្តីនៃភាសិតនេះដូចម្តេច លុះធ្វើយ៉ាងនេះហើយ យើងទាំង ២ នាក់ ទើបគួរនឹងចរចាគ្នា ក្នុងភាសិតនុ៎ះ តទៅទៀតបាន ។

[៤៩] ឧទេនភិក្ខុតបថា ម្នាលព្រាហ្មណ៍ បុគ្គល ៤ ពួកនេះ មានក្នុងលោក បុគ្គល ៤ ពួកតើដូចម្តេច ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកក្តៅខ្លួនឯង ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមក្តៅខ្លួនឯង ១ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះក្នុងលោក

បុគ្គលោ បរន្តបោ ហោតិ បរបរិតាបនានុយោគមនុយុត្តោ ឥធ បន ព្រាហ្មណ ឯកច្ចោ បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ឥធ បន ព្រាហ្មណ ឯកច្ចោ បុគ្គលោ នេវត្តន្តបោ ហោតិ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ឥមេសំ ព្រាហ្មណ ចតុន្នំ បុគ្គលានំ កតមោ តេ បុគ្គលោ ចិត្តំ អារាធេតីតិ ។ យ្វាយំ ភោ ឧទេន បុគ្គលោ អត្តន្តបោ អត្តបរិតាបនានុយោគមនុយុត្តោ អយំ មេ បុគ្គលោ ចិត្តំ នារាធេតិ យោបាយំ ភោ ឧទេន បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ

នេះ ជាអ្នកកម្តៅបុគ្គលដទៃ ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃ ១ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ កម្តៅខ្លួនឯង ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯងផង កម្តៅបុគ្គលដទៃ ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃផង ១ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមិនកម្តៅខ្លួនឯង ទាំងមិនបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯង ជាអ្នកមិនកម្តៅបុគ្គលដទៃ ទាំងមិនបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃ បុគ្គលនោះ មិនកម្តៅខ្លួនឯង មិនកម្តៅបុគ្គលដទៃ មិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរំលត់ទុក្ខ ត្រជាក់ត្រជំ ទទួលសេចក្តីសុខ មានខ្លួនដ៏ប្រសើរ ១ ម្នាលព្រាហ្មណ៍ បណ្តាបុគ្គលទាំង ៤ ពួកនេះ តើបុគ្គលណាអាចញុំាងចិត្តអ្នក ឲ្យត្រេកអរបាន ។ ឃោដមុខព្រាហ្មណ៍តបថា បពិត្រឧទេនដ៏ចម្រើន បុគ្គលណា កម្តៅខ្លួនឯង ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯង បុគ្គលនេះ មិនអាចញុំាងចិត្តខ្ញុំឲ្យត្រេកអរបានទេ បពិត្រឧទេនដ៏ចម្រើន បុគ្គលណា កម្តៅបុគ្គលដទៃ ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃ

៨៧



អយម្បិ មេ បុក្កលោ ចិត្តំ ឆាភេតិ យោចាយំ ភោ ឱនេន បុក្កលោ អត្តន្តថោ ច អត្តបរិតាបឆានុយោគមនុយុត្តោ បរន្តថោ ច បរបរិតាបឆានុយោគមនុយុត្តោ អយម្បិ មេ បុក្កលោ ចិត្តំ ឆាភេតិ យោ ច ខោ អយំ ភោ ឱនេន បុក្កលោ នេវត្តន្តថោ ឆាត្តបរិតាបឆានុយោគមនុយុត្តោ ន បរន្តថោ ន បរបរិតាបឆានុយោគមនុយុត្តោ សោ អនត្តន្តថោ ច អបរន្តថោ ច[១] និច្ឆេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ អយំ មេ បុក្កលោ ចិត្តំ អាភេតីតិ ។ កស្មា បន តេ ព្រាហ្មណា ឥមេ តយោ បុក្កលា ចិត្តំ ឆាភេន្តីតិ ។ យ្វាយំ ភោ ឱនេន បុក្កលោ អត្តន្តថោ អត្តបរិតាបឆានុយោគមនុយុត្តោ សោ អត្តានំ សុខកាមំ ទុក្ខប្បដិក្កូលំ អាតាបេតិ បរិ-តាបេតិ ឥមិនា មេ អយំ បុក្កលោ ចិត្តំ ឆាភេតិ

១ ឱ. ម. ចសទ្ទោ នត្ថិ ។

បុគ្គលនេះឯង មិនអាចញុំាងចិត្តខ្ញុំ ឲ្យត្រេកអរបានទេ បពិត្រឧទេនដ៏ចម្រើន បុគ្គលណា កម្តៅខ្លួនឯង ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯងផង កម្តៅបុគ្គលដទៃ ទាំងបានប្រកបរឿយ ៗ នូវការព្យាយាម កម្តៅបុគ្គលដទៃផង បុគ្គលនេះឯង មិនអាចញុំាងចិត្តខ្ញុំ ឲ្យត្រេកអរបានទេ បពិត្រឧទេនដ៏ចម្រើន លុះតែបុគ្គលណា មិនកម្តៅខ្លួនឯង ទាំងមិនបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯង មិនក-ម្តៅបុគ្គលដទៃ ទាំងមិនបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃ បុគ្គលនោះមិនបានកម្តៅខ្លួនឯងផង មិនបានកម្តៅបុគ្គលដទៃផង មិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរំលត់ទុក្ខ ត្រជាក់ត្រជុំ ទទួលសេចក្តីសុខ មានខ្លួនដ៏ប្រសើរ ក្នុងបច្ចុប្បន្ននេះ បុគ្គលនេះ ទើបអាចញុំាងចិត្តខ្ញុំ ឲ្យត្រេកអរបាន ។ ឧទេនភិក្ខុសួរថា ម្នាលព្រាហ្មណ៍ ចុះហេតុអ្វីបានជាបុគ្គលទាំង ៣ ពួកនេះ មិនអាចញុំាងចិត្តអ្នកឲ្យត្រេកអរបាន ។ ឃោដមុខព្រាហ្មណ៍ឆ្លើយថា បពិត្រឧទេនដ៏ចម្រើន បុគ្គលណា កម្តៅខ្លួនឯង ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯង បុគ្គលនោះ ឈ្មោះថា ដុតកម្តៅខ្លួន ដែលប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ ដោយហេតុនេះបានជាបុគ្គលនេះ មិនអាចញុំាងចិត្តខ្ញុំឲ្យត្រេកអរបានទេ

យោចាយំ ភោ ឧទេន បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ សោ បរំ សុខកាមំ ទុក្ខប្បដិក្កូលំ អាតាបេតិ បរិតាបេតិ ឥមិនា មេ អយំ បុគ្គលោ ចិត្តំ នារាធេតិ យោចាយំ ភោ ឧទេន បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ សោ អត្តានញ្ច បរញ្ច សុខកាមេ ទុក្ខប្បដិក្កូលេ អាតាបេតិ បរិតាបេតិ ឥមិនា មេ អយំ បុគ្គលោ ចិត្តំ នារាធេតិ យោ ច ខោ អយំ ភោ ឧទេន បុគ្គលោ នេវត្តន្តបោ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ សោ អត្តានញ្ច បរញ្ច សុខកាមេ ទុក្ខប្បដិក្កូលេ នេវ អាតាបេតិ ន បរិតាបេតិ ឥមិនា មេ អយំ បុគ្គលោ ចិត្តំ អារាធេតីតិ ។

បពិត្រឧទេនដ៏ចម្រើន បុគ្គលណា កម្តៅបុគ្គលដទៃ ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃ បុគ្គលនោះ ឈ្មោះថា ដុតកម្តៅបុគ្គលដទៃ ដែលប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ ដោយហេតុនេះបានជាបុគ្គលនេះ មិនអាចញ៉ាំងចិត្តខ្ញុំឲ្យត្រេកអរបានទេ បពិត្រឧទេនដ៏ចម្រើន បុគ្គលណា កម្តៅខ្លួនឯង ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯងផង កម្តៅបុគ្គលដទៃ ទាំងបានប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃផង បុគ្គលនោះ ឈ្មោះថា ដុតកម្តៅខ្លួនឯងផង បុគ្គលដទៃផង ដែលប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ ដោយហេតុនេះបានជាបុគ្គលនេះ មិនអាចញ៉ាំងចិត្តខ្ញុំ ឲ្យត្រេកអរបានទេ បពិត្រឧទេនដ៏ចម្រើន លុះតែបុគ្គលណា មិនកម្តៅខ្លួនឯង ទាំងមិនប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃ បុគ្គលនោះ ឈ្មោះថា មិនកម្តៅខ្លួនឯង មិនកម្តៅបុគ្គលដទៃ មិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរំលត់ទុក្ខត្រជាក់ត្រជំ ទទួលសេចក្តីសុខ មានខ្លួនដ៏ប្រសើរ ក្នុងបច្ចុប្បន្ននេះ បុគ្គលនោះ មិនបានឈ្មោះថា ដុតកម្តៅខ្លួនឯងផង បុគ្គលដទៃផង ដែលប្រាថ្នាសេចក្តីសុខ ខ្ពើមសេចក្តីទុក្ខ ដោយហេតុនេះ ទើបបុគ្គលនេះអាចញ៉ាំងចិត្តខ្ញុំឲ្យត្រេកអរបាន ។

ព្រាហ្មណវគ្គស្ស យោធមុខសុត្តេ ទ្វេ បរិសា

[៩០] ទ្វេមា ព្រាហ្មណា បរិសា កតមា ទ្វេ ឥធ ព្រាហ្មណា ឯកច្ចា បរិសា សារត្តរត្តា មណិកុណ្ឌលេសុ បុត្តភរិយំ បរិយេសតិ ទាសីទាសំ បរិយេសតិ ខេត្តវត្ថុំ បរិយេសតិ ជាតរូបរជតំ បរិយេសតិ ឥធ បន ព្រាហ្មណា ឯកច្ចា បរិសា អសារត្តរត្តា មណិកុណ្ឌលេសុ បុត្តភរិយំ បហាយ ទាសីទាសំ បហាយ ខេត្តវត្ថុំ បហាយ ជាតរូបរជតំ បហាយ អគារស្មា អនគារិយំ បព្វជិតា ឃ្វាយំ[១] ព្រាហ្មណា បុគ្គលោ នេវត្តន្តបោ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ឥមំ ត្វំ ព្រាហ្មណា បុគ្គលំ កតមស្សំ បរិសាយំ ពហុលំ សមនុបស្សសិ យា ចាយំ បរិសា សារត្តរត្តា មណិកុណ្ឌលេសុ បុត្តភរិយំ បរិយេសតិ ទាសីទាសំ បរិយេសតិ ខេត្តវត្ថុំ បរិយេសតិ

---

១ ឱ. ម. ស្វាយំ ។

[៩០] ឧទេនភិក្ខុតបថា ម្នាលព្រាហ្មណ៍ បរិស័ទនេះមាន ២ ពួក បរិស័ទ ២ ពួកតើដូចម្ដេចខ្លះ ម្នាលព្រាហ្មណ៍ បរិស័ទខ្លះក្នុងលោកនេះ ប្រកបដោយសេចក្ដីត្រេកអរក្នុងកែវមណីនិងកុណ្ឌលទាំងឡាយ ហើយស្វែងរកកូនប្រពន្ធ ស្វែងរកខ្ញុំស្រី ខ្ញុំប្រុស ស្វែងរកស្រែចម្ការ ស្វែងរកមាសប្រាក់ ១ ម្នាលព្រាហ្មណ៍ មួយទៀត បរិស័ទខ្លះ ក្នុងលោកនេះ មិនប្រកបដោយសេចក្ដីត្រេកអរក្នុងកែវមណីនិងកុណ្ឌលទាំងឡាយទេ ហើយលះបង់កូនប្រពន្ធ លះបង់ខ្ញុំស្រី ខ្ញុំប្រុស លះបង់ស្រែចម្ការ លះបង់មាសប្រាក់ រួចចេញចាកផ្ទះចូលទៅកាន់ផ្នួស ១ ម្នាលព្រាហ្មណ៍ បុគ្គលណាមិនកម្ដៅខ្លួនឯង ទាំងមិនបានប្រកបរឿយ ៗ នូវការព្យាយាមកម្ដៅខ្លួនឯង មិនកម្ដៅបុគ្គលដទៃ ទាំងមិនបានប្រកបរឿយ ៗ នូវការព្យាយាមកម្ដៅបុគ្គលដទៃ បុគ្គលនោះឈ្មោះថា មិនកម្ដៅខ្លួនឯង ទាំងមិនកម្ដៅបុគ្គលដទៃ មិនមានសេចក្ដីស្រេកឃ្លាន មានតែសេចក្ដីរំលត់ទុក្ខ ត្រជាក់ត្រជុំ ទទួលសេចក្ដីសុខ មានខ្លួនដ៏ប្រសើរ ក្នុងបច្ចុប្បន្ននេះ នែព្រាហ្មណ៍ បរិស័ទណា ដែលប្រកបដោយសេចក្ដីត្រេកអរក្នុងកែវមណីនិងកុណ្ឌល ស្វែងរកកូនប្រពន្ធ ស្វែងរកខ្ញុំស្រី ខ្ញុំប្រុស ស្វែងរកស្រែចម្ការ

ជាតរូបរជតំ បរិយេសតិ យា ចាយំ បរិសា អសារត្តរត្តា មណិកុណ្ឌលេសុ បុត្តភរិយំ បហាយ ទាសីទាសំ បហាយ ខេត្តវត្ថុំ បហាយ ជាតរូបរជតំ បហាយ អគារស្មា អនគារិយំ បព្វជិតាតិ ។ ឥធាយំ ភោ ឧទេន បុគ្គលោ នេវត្តន្តបោ ជាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ឥមាហំ បុគ្គលំ យាយំ បរិសា អសារត្តរត្តា មណិកុណ្ឌលេសុ បុត្តភរិយំ បហាយ ទាសីទាសំ បហាយ ខេត្តវត្ថុំ បហាយ ជាតរូបរជតំ បហាយ អគារស្មា អនគារិយំ បព្វជិតា ឥមិស្សំ បរិសាយំ ពហុលំ សមនុបស្សាមីតិ ។ ឥទានេវ ខោ បន តេ ព្រាហ្មណ ភាសិតំ មយំ ឯវំ អាជានាម អម្ហាកំ សមណោ ឧត្តិ ធម្មិកោ បរិព្វជោ ឯវំ មេ ឯត្ថ ហោតិ

ស្វែងរកមាសប្រាក់ក្តី បរិស័ទណាដែលមិនប្រកបដោយសេចក្តីត្រេកអរ ក្នុងកែវមណីនិងកុណ្ឌល បានលះបង់កូនប្រពន្ធ លះបង់ខ្ញុំស្រី ខ្ញុំប្រុស លះបង់ស្រែចម្ការ លះបង់មាសប្រាក់ ហើយចេញចាកផ្ទះចូលទៅកាន់ផ្នួសក្តី អ្នកពិចារណាបុគ្គលនេះមើល តើណាប្រសើរជាងក្នុងបរិស័ទណា ។ ឃោដមុខព្រាហ្មណ៍ឆ្លើយថា បពិត្រឧទេនដ៏ចម្រើន បុគ្គលណាមិនកម្តៅខ្លួនឯង ទាំងមិនប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯង មិនកម្តៅបុគ្គលដទៃ ទាំងមិនប្រកបរឿយ ៗ នូវការព្យាយាមកម្តៅបុគ្គលដទៃ បុគ្គលនោះឈ្មោះថា មិនកម្តៅខ្លួនឯង មិនកម្តៅបុគ្គលដទៃ មិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរំលត់ទុក្ខ ត្រជាក់ត្រជំ ទទួលតែសេចក្តីសុខ មានខ្លួនដ៏ប្រសើរ ក្នុងបច្ចុប្បន្ននេះ បរិស័ទណា មិនប្រកបដោយសេចក្តីត្រេកអរ ក្នុងកែវមណីនិងកុណ្ឌល លះបង់កូននិងប្រពន្ធ លះបង់ខ្ញុំស្រី ខ្ញុំប្រុស លះបង់ស្រែចម្ការ លះបង់មាសប្រាក់ រួចចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ខ្ញុំពិចារណាមើលឃើញតែបុគ្គលនេះគ្រាន់បើជាងក្នុងបរិស័ទនេះ ។ ឧទេនភិក្ខុឆ្លើយថា ម្នាលព្រាហ្មណ៍ ឥឡូវនេះអាត្មាបានដឹងសំដីរបស់អ្នកយ៉ាងនេះថា បពិត្រសមណៈដ៏ចម្រើន ផ្នួសប្រកបដោយធម៌គ្មានទេ សេចក្តីចូលចិត្តរបស់ខ្ញុំក្នុងផ្នួសនេះយ៉ាងនេះ

ព្រាហ្មណវគ្គស្ស យោជមុខសុត្តេ បឋមបុគ្គលោ

តញ្ចូ ខោ ភវន្តរូចានំ វា អនស្សុដា យោ វា បនេត្ថ ជម្មោតិ ។ អទ្ធា ខោ មេ សា ភោ ឧនេន សានុត្តហា វាចា ភាសិតា អត្ថិ ជម្មិកោ បរិព្វជោ ឯវំ មេ ឯត្ថ ហោតិ ឯវញ្ចូ បន មំ ភវំ ឧនេនោ ជាបេតុ យេ ចិមេ ភោតា ឧនេនេន ចត្តារោ បុក្កលា សង្ខិត្តេន វុត្តា វិត្ថារេន អវិភត្តា សាធុ មេ ភវំ ឧនេនោ ឥមេ ចត្តារោ បុក្កលេ វិត្ថារេន វិភជតុ អនុកម្បំ ឧចាទាយាតិ ។ តេនហិ ព្រាហ្មណ សុណោហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ឯវំ ភោតិ ខោ យោជមុខោ ព្រាហ្មណោ អាយស្មតោ ឧនេនស្ស បច្ចស្សោសិ ។

[៥១] អាយស្មា ឧនេនោ ឯតទវោច កាតមោ ច ព្រាហ្មណ បុក្កលោ អត្តន្តបោ អត្តបរិតាបនានុ-យោគមនុយុត្តោ ឥធ ព្រាហ្មណ ឯកច្ចោ បុក្កលោ

ក៏សេចក្តីចូលចិត្តនោះឯង ព្រោះមិនបានឃើញជនទាំងឡាយដែលមានសភាពដូចជាលោកដ៏ចម្រើនផង ព្រោះមិនឃើញធម៌ក្នុងផ្នួសនេះផង ។ ឃោដមុខព្រាហ្មណ៍តបថា បពិត្រឧទេនដ៏ចម្រើន សំដីដែលប្រកបដោយហេតុនោះ លោកម្ចាស់បានសំដែងហើយដល់ខ្ញុំព្រះករុណាដោយពិតថា ផ្នួសប្រកបដោយធម៌មាន សេចក្តីចូលចិត្តរបស់ខ្ញុំព្រះករុណាក្នុងផ្នួសនុ៎ះយ៉ាងនេះ មួយទៀត លោកម្ចាស់ឧទេនដ៏ចម្រើន ចូរចាំទុកនូវខ្ញុំយ៉ាងហ្នឹងចុះ បុគ្គល ៤ ពួកណា ដែលលោកម្ចាស់ឧទេនដ៏ចម្រើនសំដែងហើយដោយសង្ខេប មិនធ្វើឲ្យពិស្តារដល់ខ្ញុំព្រះករុណា សូមលោកម្ចាស់ឧទេនដ៏ចម្រើន ញែកចែកនូវបុគ្គលទាំង ៤ ពួកនេះ ដោយសេចក្តីពិស្តារ ដល់ខ្ញុំព្រះករុណា ដោយអាស្រ័យសេចក្តីអនុគ្រោះ ។ ឧទេនភិក្ខុឆ្លើយថា ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ អាត្មានឹងសំដែង ។ ឃោដមុខព្រាហ្មណ៍ទទួលស្តាប់ពាក្យឧទេនភិក្ខុមានអាយុថា ព្រះករុណា លោកដ៏ចម្រើន ។

[៥១] ឧទេនភិក្ខុមានអាយុ បានពោលពាក្យនេះថា ម្នាលព្រាហ្មណ៍ ចុះបុគ្គលកម្តៅខ្លួនឯង ទាំងប្រកបរឿយ ៗ នូវការព្យាយាមកម្តៅខ្លួនឯង តើដូចម្តេច ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ

អចេលកោ ហោតិ មុត្តាចារោ ហត្ថាវលេខនោ ន ឯហិភទន្តិកោ ន តិដ្ឋភទន្តិកោ នាភិហតំ ន ឧទ្ទិស្សកតំ ន និមន្តនំ សាទិយតិ សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោបិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ[១] ន មុសលមន្តរំ ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ សោ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ ។ បេ ។ សត្តាគារិកោ វា ហោតិ

---

១ ន ទណ្ឌមន្តរន្តិបិ ។ ន ទណ្ឌកមន្តរន្តិបិ អម្ហាកំ បោត្ថកេ បាឋោ ទិស្សតិ ។ ឱរោបិយបោត្ថកេ ន ទណ្ឌមន្តរន្តិ បាឋោ ទិស្សតិ ។ តត្ថ ន ទណ្ឌមន្តរន្តិ បទំ យុត្តតរំ សព្វដ្ឋកថាសុ ភាវតោ ។ ន មណ្ឌមន្តរន្តិ បាឋោ កត្ថចិ បោត្ថកេ ទិស្សតិ ។ សោ ន សមេតិ អដ្ឋកថាសុ អភាវតោ ។

ជាអចេលក៍ (អាក្រាត) លះបង់មារយាទល្អ ស៊ីលិទ្ធដៃ (និងជម្រះឧច្ចារៈដោយម្រាមដៃ) បើមានគេហៅថាចូរមក ក៏មិនមក គេឃាត់ថាឈប់ក៏មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកមុន មិនត្រេកអរនឹងភត្តដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងកិច្ចនិមន្តន៍ អចេលក៍នោះ មិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ជើ មិនទទួលភត្ត ដែលគេនាំមកកន្លងធរណីទ្វារ មិនទទួលភត្តដែលគេនាំមកកន្លងកំណាត់ឈើ មិនទទួលភត្តដែលគេនាំមកកន្លងអង្រែ មិនទទួលភត្ត របស់មនុស្សពីរនាក់កំពុងបរិភោគ មិនទទួលភត្តរបស់ស្រីមានគភ៌ មិនទទួលភត្តរបស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលភត្តដែលពួកសាវ័កអចេលក៍អង្គាសមក មិនទទួលភត្តក្នុងទីដែលមានឆ្កែចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំ ដែលត្រាំដោយស្រូវទាំងពួង អចេលក៍នោះទទួលភត្តចំពោះតែក្នុងផ្ទះមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយមួយពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះពីរ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្លះ ។ បេ ។ ទទួលភត្តចំពោះតែក្នុងផ្ទះ ៧

សត្តាលោបិកោ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ តីហិបិ ទត្តីហិ យាបេតិ ។ បេ ។ សត្តហិបិ ទត្តីហិ យាបេតិ ឯកាហិកំបិ អាហារំ អាហារេតិ ទ្វីហិកំបិ អាហារំ អាហារេតិ ។ បេ ។ សត្តាហិកំបិ អាហារំ អាហារេតិ ឥតិ ឯវរូបំ អឌ្ឍមាសិកំបិ បរិយាយភត្តភោជនានុយោគ-មនុយុត្តោ វិហរតិ សោ សាកភក្ខោ វា ហោតិ សាមាកភក្ខោ វា ហោតិ នីវារភក្ខោ វា ហោតិ ទទ្ទុលភក្ខោ វា ហោតិ និយាសភក្ខោ វា ហោតិ ហដភក្ខោ វា ហោតិ កណភក្ខោ វា ហោតិ អាចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតិ តិណភក្ខោ វា ហោតិ គោមយភក្ខោ វា ហោតិ វនមូលផលាហារោ វា យាបេតិ បវត្តផលភោជី

ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ៧ ពំនូតខ្លះ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយកត្តុ ១ ភាជន៍តូចខ្លះ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយកត្តុ ២ ភាជន៍តូចខ្លះ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយកត្តុ ៣ ភាជន៍តូចខ្លះ ។ បេ ។ ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយកត្តុ ៧ ភាជន៍តូចខ្លះ ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ ។ បេ ។ ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ អចេលក៍ប្រកបដោយសេចក្ដីព្យាយាមក្នុងការផ្លាស់ប្ដូរនូវការបរិភោគភត្តរំលងកន្លះខែខ្លះ មានសភាពយ៉ាងនេះដូច្នេះឯង អចេលក៍នោះ មានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្កួយជាអាហារខ្លះ មានកំទេចស្បែក (ចំនៀរស្បែក) ជាអាហារខ្លះ មានជ័រជាអាហារខ្លះ[១] មានស្មៅឬសារាយ ជាអាហារខ្លះ មានកុណ្ឌកជាអាហារខ្លះ មានបាយក្ដាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមនិងផ្លែឈើក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះឯងខ្លះ

---

១ ត្រូវថែមពាក្យថា មានជ័រជាអាហារខ្លះ ដូច្នេះ ទៅក្នុងសៀវភៅទី ២០ ទំព័រ ២៩៣ បន្ទាត់ទី ១៧ និងក្នុងសៀវភៅទី ២៣ ទំព័រទី ១៣ បន្ទាត់ទី ១០ ឲ្យដូចជាសៀវភៅនេះផងចុះ ហើយត្រូវថែមបាលីថា និយាសភក្ខោ វា ហោតិ ក្នុងទំព័រខាងបាលីត្រង់កន្លែងនេះផង ។

សោ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ បំសុកូលានិបិ ធារេតិ តិរីដានិបិ ធារេតិ អជិនំបិ ធារេតិ អជិនក្ខិបំបិ ធារេតិ កុសចីរំបិ ធារេតិ វាកចីរំបិ ធារេតិ ផលកចីរំបិ ធារេតិ កេសកម្ពលំបិ ធារេតិ វាលកម្ពលំបិ ធារេតិ ឧលូកបក្ខំបិ ធារេតិ កេសមស្សុលោចកោបិ ហោតិ កេសមស្សុលោចនានុយោគមនុយុត្តោ ឧព្ភដ្ឋកោបិ ហោតិ អាសនបដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុដិកប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ ហោតិ កណ្ដកាបស្សយេ សេយ្យំ កប្បេតិ សាយតតិយកំបិ ឧទកោរោហណានុយោគមនុយុត្តោ វិហរតិ

អចេលក៍នោះ ទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំពត់បង្សុកូលខ្លះ ទ្រទ្រង់សំបកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់ស្បូវក្រងខ្លះ ទ្រទ្រង់សំពត់ត្បាញដោយសំបកក្រថៅខ្លះ ទ្រទ្រង់ចំរៀកក្តារ[១] ជាសំពត់ខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយរោមកន្ទុយសេះខ្លះ ទ្រទ្រង់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ទុក[២] សក់និងពុកមាត់ ប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមទុកសក់និងពុកមាត់ខ្លះ ឈរសម្រឹងហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោងប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមអង្គុយច្រហោងខ្លះ ដេកលើបន្លា សម្រេចការដេកលើបន្លាខ្លះ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដង គឺ ព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ

១ ត្រូវកែសព្ទដែលថា សំបកផ្លែឈើ ក្នុងសៀវភៅទី ២០ ទំព័រ ២៩៤ បន្ទាត់ទី ៩ និងសៀវភៅទី ២៣ ទំព័រទី ១៤ បន្ទាត់ទី ៤ មកជាសព្ទថា ចំរៀកក្តារ ដូច្នេះវិញ ។ ២ ត្រូវកែសព្ទថា ដកសក់និងពុកមាត់ ក្នុងសៀវភៅទី ១៥ ទំព័រទី ៩០ បន្ទាត់ទី ៤ មកជាសព្ទថា ទុកសក់និងពុកមាត់ ដូច្នេះវិញ ។

ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតាបនបរិតាបនានុយោគមនុយុត្តោ វិហរតិ អយំ វុច្ចតិ ព្រាហ្មណា បុគ្គលោ អត្តន្តបោ អត្តបរិតាបនានុយោគមនុយុត្តោ ។

[៤២] កតមោ ច ព្រាហ្មណា បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ ឥធ ព្រាហ្មណា ឯកច្ចោ បុគ្គលោ ឱរព្ភិកោ ហោតិ សូករិកោ[១] សាកុណិកោ មាគវិកោ លុទ្ទោ មច្ឆឃាតកោ ចោរោ ចោរឃាតកោ[២] ពន្ធនាគារិកោ យេ វា បនញ្ញេបិ កេចិ កុរូរកម្មន្តា អយំ វុច្ចតិ ព្រាហ្មណា បុគ្គលោ បរន្តបោ បរបរិតាបនានុយោគមនុយុត្តោ ។

[៤៣] កតមោ ច ព្រាហ្មណា បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ឥធ ព្រាហ្មណា ឯកច្ចោ បុគ្គលោ រាជា វា ហោតិ ខត្តិយោ មុទ្ធាវសិត្តោ ព្រាហ្មណោ វា មហា-

១ ឱ. សោករិកោ ។ ២ ម. ឯត្ថន្តរេ គោឃាតកោតិ ទិស្សតិ ។

អចេលក៍ប្រកបការព្យាយាមដុតកម្តៅកាយ ច្រើនប្រការ មានសភាព យ៉ាងនេះដូច្នេះឯង ម្នាលព្រាហ្មណ៍ នេះហៅថា បុគ្គលកម្តៅខ្លួនឯង ប្រកបការព្យាយាមដុតកម្តៅខ្លួនឯង ។

[៩២] ម្នាលព្រាហ្មណ៍ ចុះបុគ្គលកម្តៅអ្នកដទៃ ប្រកបការព្យាយាមដុតកម្តៅអ្នកដទៃ តើដូចម្តេច ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់ចៀម ជាអ្នកសម្លាប់ជ្រូក ជាអ្នកសម្លាប់សត្វស្លាប ជាអ្នកសម្លាប់ម្រឹគ ជាព្រាន ជាអ្នកសម្លាប់ត្រី ជាអ្នកលួច ជាអ្នកសម្លាប់ចោរ ជានាយគុក ពុំនោះសោត បុគ្គលណាមួយ ជាអ្នកធ្វើការងារអាក្រក់ ម្នាលព្រាហ្មណ៍ នេះហៅថា បុគ្គលដុតកម្តៅអ្នកដទៃ ប្រកបការព្យាយាមដុតកម្តៅអ្នកដទៃ ។

[៩៣] ម្នាលព្រាហ្មណ៍ ចុះបុគ្គលអ្នកដុតកម្តៅខ្លួនឯង ប្រកបការព្យាយាមដុតកម្តៅខ្លួនឯងផង កម្តៅអ្នកដទៃ ប្រកបការព្យាយាមដុតកម្តៅអ្នកដទៃផង តើដូចម្តេច ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាក្សត្រទ្រង់រាជ្យ ដែលបានមុទ្ធាភិសេករួចហើយក្តី ជាព្រាហ្មណមហា-

សាលោ សោ បុរត្ថិមេន នគរស្ស នវំ សន្ថាគារំ ការាបេត្វា កេសមស្សុំ ឱហារេត្វា ខរាជិនំ[១] និវាសេត្វា សប្បិតេលេន កាយំ អព្ភញ្ជិត្វា មិគវិសាណេន បិដ្ឋឹ កណ្ឌុវមានោ សន្ថាគារំ បវិសតិ សទ្ធឹ មហេសិយា ព្រាហ្មណេន ច បុរោហិតេន សោ តត្ថ អនន្តរហិតាយ ភូមិយា ហរិតូបលិត្តាយ សេយ្យំ កប្បេតិ សោ[២] ឯកិស្សា គាវិយា សរូបវច្ឆាយ យំ ឯកស្មឹ ថនេ ខីរំ ហោតិ តេន រាជា យាបេតិ យំ ទុតិយស្មឹ ថនេ ខីរំ ហោតិ តេន មហេសី យាបេតិ យំ តតិយស្មឹ ថនេ ខីរំ ហោតិ តេន ព្រាហ្មណោ បុរោហិតោ យាបេតិ យំ ចតុត្ថស្មឹ ថនេ ខីរំ ហោតិ តេន អគ្គឹ ជុហតិ អវសេសេន វច្ឆកោ យាបេតិ សោ ឯវមាហ ឯត្តកា ឧសភា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា វច្ឆតរា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា វច្ឆតរិយោ ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា អជា ហញ្ញន្តុ យញ្ញត្ថាយ ឯត្តកា ឧរព្ភា

---

១ ម. ខុរាជិនំ ។ ២ ម. សោតិ ន ទិស្សតិ ។

សាលក្តី ព្រះរាជាឬព្រាហ្មណ៍នោះ ឲ្យគេសាងរោងសម្រាប់ទទួលភ្ញៀវយ៉ាងថ្មី ក្នុងទិសខាងកើតនៃនគរ ហើយកោរសក់ ពុកមាត់ និងពុកចង្កា ស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចក លាបស្រឡាបកាយដោយទឹកដោះថ្លា និងប្រេង អេះខ្នងដោយស្នែងនៃម្រឹគ ហើយចូលទៅកាន់រោងសម្រាប់ទទួលភ្ញៀវ ព្រមទាំងមហេសី និងព្រាហ្មណ៍ជាបុរោហិត ព្រះរាជាឬព្រាហ្មណ៍នោះ ក៏សម្រេចសេយ្យាលើផែនដី ប្រាសចាកកម្រាលដែលគេលាបពណ៌ខៀវក្នុងទីនោះ ទឹកដោះណា មានក្នុងដោះមួយ របស់មេគោមួយដែលមានកូនខ្ចី ព្រះរាជាឬព្រាហ្មណ៍ ក៏ចិញ្ចឹមជីវិតដោយទឹកដោះនោះ ទឹកដោះណា មានក្នុងដោះទី ២ មហេសីក៏ចិញ្ចឹមជីវិតដោយទឹកដោះនោះ ទឹកដោះណា មានក្នុងដោះទី ៣ ព្រាហ្មណ៍ជាបុរោហិតក៏ចិញ្ចឹមជីវិតដោយទឹកដោះនោះ ទឹកដោះណា មានក្នុងដោះទី ៤ ក៏បូជាភ្លើងដោយទឹកដោះនោះ កូនគោចិញ្ចឹមជីវិតដោយទឹកដោះដ៏សេស ព្រះរាជាឬព្រាហ្មណ៍នោះមានវាចាយ៉ាងនេះថា គោឈ្មោលទាំងប៉ុណ្ណោះ ចូរគេសម្លាប់ដើម្បីយ័ញ្ញចុះ កូនគោឈ្មោលទាំងប៉ុណ្ណោះ ចូរគេសម្លាប់ដើម្បីយ័ញ្ញចុះ កូនគោញីទាំងប៉ុណ្ណោះ ចូរគេសម្លាប់ ដើម្បីយ័ញ្ញចុះ ពពែទាំងប៉ុណ្ណោះ ចូរគេសម្លាប់ ដើម្បីយ័ញ្ញចុះ ចៀមទាំងប៉ុណ្ណោះ

ហញ្ញន្តុ យញ្ញត្ថាយ[១] ឯត្តកា រុក្ខា ឆិជ្ជន្តុ យូបត្ថាយ ឯត្តកា ទព្ភា លុយន្តុ បរិសត្ថាយាតិ យេបិស្ស តេ ហោន្តិ ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ ទណ្ឌតជ្ជិតា ភយតជ្ជិតា អស្សុមុខា រោទមានា បរិកម្មានិ ករោន្តិ អយំ វុច្ចតិ ព្រាហ្មណ បុគ្គលោ អត្តន្តបោ ច អត្តបរិតាបនានុយោគមនុយុត្តោ បរន្តបោ ច បរបរិតាបនានុយោគមនុយុត្តោ ។

[៩៨] កតមោ ច ព្រាហ្មណ បុគ្គលោ នេវត្តន្តបោ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតិ ឥធ ព្រាហ្មណ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ

---

១ ម. ឯត្តន្តរេ ឯត្តកា អស្សា ហញ្ញន្តុ យញ្ញត្ថាយាតិ ទិស្សតិ ។ បរិហីសត្ថាយាតីតិ ទិស្សតិ ។

ចូរគេសម្លាប់ ដើម្បីយ័ញ្ញចុះ ឈើទាំងប៉ុណ្ណោះ ចូរគេកាប់ដើម្បីប្រយោជន៍ដល់ប្រាសាទចុះ ទ្រព្យទាំងប៉ុណ្ណោះ ចូរពុកផុយទៅដើម្បីលំបាក (ដល់ម្ចាស់ទ្រព្យ) ចុះ មួយទៀត ជនទាំងឡាយណា ដែលជាខ្ញុំក្តី ជាអ្នកបម្រើក្តី ជាកម្មករក្តី របស់ព្រះរាជាឬព្រាហ្មណ៍នោះ ជនទាំងនោះ ត្រូវអាជ្ញាគម្រាម ត្រូវភ័យគម្រាម មានមុខទទឹកដោយទឹកភ្នែក ទួញយំ ធ្វើបរិកម្ម ម្នាលព្រាហ្មណ៍ នេះហៅថា បុគ្គលក្តៅខ្លួនឯង ប្រកបការព្យាយាមក្តៅខ្លួនឯងផង ក្តៅអ្នកដទៃ ប្រកបការព្យាយាមក្តៅអ្នកដទៃផង ។

[៩៨] ម្នាលព្រាហ្មណ៍ ចុះបុគ្គលមិនក្តៅខ្លួនឯង ទាំងមិនប្រកបការព្យាយាមក្តៅខ្លួនឯង មិនក្តៅអ្នកដទៃ ទាំងមិនប្រកបការព្យាយាមក្តៅអ្នកដទៃ តើដូចម្តេច បុគ្គលនោះ មិនក្តៅខ្លួនឯង មិនក្តៅអ្នកដទៃ មិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរំលត់ទុក្ខត្រជាក់ត្រជុំ ទទួលសេចក្តីសុខ មានខ្លួនដ៏ប្រសើរ ក្នុងបច្ចុប្បន្ននេះ ម្នាលព្រាហ្មណ៍ ព្រះតថាគតកើតឡើងក្នុងលោក ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹងនិងកិរិយាដែលព្រះអង្គគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរទៅ

លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សា-នំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិ-បុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា កុលេ បច្ចាជាតោ សោ តំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភតិ ។ សោ តេន សទ្ធាបដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ សម្ពាធោ ឃរា-វាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា ន យិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្ត-

កាន់ព្រះនិព្វាន ព្រះអង្គទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹង នូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះ ទ្រង់បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាចំពោះព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយប្រកាស ទ្រង់សំដែងធម៌មានលំអបទដើម មានលំអបទកណ្ដាល និងបទចុង ព្រះអង្គប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។ គហបតីក្តី កូនគហបតីក្តី បុគ្គលកើតក្រោយក្នុងត្រកូលណាមួយក្តី ស្តាប់ធម៌នោះ លុះបុគ្គលនោះស្តាប់ធម៌នោះហើយ បានចំពោះនូវសទ្ធា ក្នុងព្រះតថាគត ។ បុគ្គលនោះប្រកបព្រមដោយការបានចំពោះ នូវសទ្ធានោះ ហើយមានសេចក្តីពិចារណាដូច្នេះថា ការនៅគ្រប់គ្រងផ្ទះ ចង្អៀតណាស់ ជាផ្លូវហូរមកនៃធូលីគឺកិលេស មានតែបព្វជ្ជា ទើបមានឱកាស បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌តែមួយយ៉ាង

បរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្តំ បហាយ មហន្តំ វា ញាតិបរិវដ្តំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។

[៥៥] សោ ឯវំ បព្វជិតោ សមានោ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ទិន្នាទាយី ទិន្នប្បដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរតិ អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ អារាចារី វិរតោ មេថុនា គាមធម្មា មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ច-

បរិសុទ្ធតែមួយយ៉ាង ឲ្យដូចជាស័ង្ខដែលគេខាត់ឡើយ បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់និងពុកចង្កា ហើយស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះសម័យខាងក្រោយមក បុគ្គលនោះ ក៏លះបង់គំនរភោគៈតិចផង លះបង់គំនរភោគៈច្រើនផង លះបង់នូវញាតិវង្សតិចផង លះបង់នូវញាតិវង្សច្រើនផង ហើយកោរសក់ពុកមាត់និងពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។

[៥៥] កាលបើបុគ្គលនោះ បួសយ៉ាងនេះហើយ ក៏សមាទាននូវសិក្ខានិងសាជីវៈ របស់ភិក្ខុទាំងឡាយ លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្ដីអៀនខ្មាស ដល់នូវសេចក្ដីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ដល់សត្វទាំងអស់ លះបង់នូវអទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នានូវរបស់ដែលគេឲ្យ មិនមានចិត្តលួច មានខ្លួនដ៏ស្អាត លះបង់នូវអព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ប្រព្រឹត្តល្អ ចៀសវាង វៀរចាកមេថុនដែលជាធម៌របស់អ្នកស្រុក លះបង់នូវមុសាវាទ វៀរចាកមុសាវាទ ជាអ្នកពោលនូវ

វាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទ-
កោ លោកស្ស បិសុណំ វាចំ បហាយ បិសុ-
ណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា
ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា
សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ
ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា
សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ
វាចំ ភាសិតា ហោតិ ផរុសំ វាចំ បហាយ ផរុសាយ
វាចាយ បដិវិរតោ ហោតិ យា សា វាចា
នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី
ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ
ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា
បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី
ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា

ពាក្យពិត តនូវពាក្យពិត មានសំដីខ្ជាប់ខ្ជួន ពោលនូវពាក្យគួរអ្នកផងជឿបាន មិនពោលបំភ្លាត់សត្វលោកឡើយ លះបង់នូវបិសុណវាចា វៀរចាកបិសុណវាចា ឮពាក្យពីខាងនេះមិនទៅប្រាប់ខាងនោះ ដើម្បីបំបែកជនខាងនោះឡើយ ឬឮអំពីខាងនោះ មិនមកប្រាប់ដល់ជនទាំងឡាយខាងនេះ ដើម្បីបំបែកជនខាងនោះឡើយ ជាអ្នកផ្សះផ្សា នូវពួកជនដែលបែកគ្នាហើយផង ជាអ្នកជួយផ្សងផ្តើម ដល់ពួកជន ដែលបានប្រកបដោយប្រយោជន៍ហើយផង ជាអ្នករីករាយនឹងសេចក្តីព្រមព្រៀង ត្រេកអរនឹងសេចក្តីព្រមព្រៀង ពេញចិត្តនឹងសេចក្តីព្រមព្រៀង ជាអ្នកពោលតែសំដីដែលធ្វើនូវសេចក្តីព្រមពៀង ជាអ្នកលះបង់ផរុសវាចា វៀរចាកផរុសវាចា សំដីណា ដែលជាសំដីឥតទោស ជាសុខដល់ត្រចៀក គួរជាទីស្រឡាញ់ តាំងនៅក្នុងហឫទ័យ ជាសំដីអ្នកក្រុងជាទីរីករាយដល់ជនច្រើន ជាទីគាប់ចិត្តដល់ជនច្រើន តែងពោលតែសំដីមានសភាពដូច្នោះ លះបង់នូវសម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ពោលតាមកាលគួរ ពោលពាក្យពិត ពោលពាក្យជាអត្ថ ពោលពាក្យជាធម៌ ពោលពាក្យជាវិន័យ ពោលសំដីដែលគួរកប់ទុកក្នុងហឫទ័យ

កាលេន សាបទេសំ បរិយន្តវតឹ អត្ថសំហិតំ ។ សោ វីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ឯកភត្តិកោ ហោតិ រត្តូបរតោ វិរតោ វិកាលភោជនា នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ ហោតិ មា-លាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ហោតិ ឧច្ចាសយនមហាសយនា បដិវិរតោ ហោតិ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ ហោតិ អាមក-ធញ្ញប្បដិគ្គហណា បដិវិរតោ ហោតិ អាមកមំសប្បដិ-គ្គហណា បដិវិរតោ ហោតិ ឥត្ថីកុមារិកាបដិគ្គហណា បដិវិរតោ ហោតិ ទាសីទាសប្បដិគ្គហណា បដិវិរតោ ហោតិ អជេឡកប្បដិគ្គហណា បដិវិរតោ ហោតិ កុក្កុ-ដសូករប្បដិគ្គហណា បដិវិរតោ ហោតិ ហត្ថិគវាស្សវ-លវប្បដិគ្គហណា បដិវិរតោ ហោតិ ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ ហោតិ ទូតេយ្យប្បហីណគមនានុយោគា បដិវិរតោ ហោតិ កយវិក្កយា បដិវិរតោ ហោតិ

ជាសំដីប្រកបដោយហេតុ ប្រកបដោយគ្រឿងប្រៀបធៀប ដោយកាលគួរ មានដើម មានចុង ប្រកបដោយប្រយោជន៍ ។ បុគ្គលនោះវៀរចាកការផ្តិលផ្តាច់នូវពីជគាមនិងភូតគាម ជាអ្នកបរិភោគភត្តតែ ១ ពេល វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងកាលខុស វៀរចាកការរាំ ច្រៀង ប្រគំ និងការមើលនូវល្បែងផ្សេង ៗ ដែលជាសត្រូវដល់សាសនា ជាអ្នកវៀរចាកការប្រដាប់តាក់តែងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ជាអ្នកវៀរចាកការដេកលើទីសេនាសនៈខ្ពស់ និងទីសេនាសនៈប្រសើរ ជាអ្នកវៀរចាកការទទួលនូវមាសនិងប្រាក់ ជាអ្នកវៀរចាកការទទួលនូវធញ្ញជាតិស្រស់ ជាអ្នកវៀរចាកការទទួលនូវសាច់ស្រស់ ជាអ្នកវៀរចាកការទទួល នូវស្រីនិងនាងកុមារិកា ជាអ្នកវៀរចាកការទទួលនូវខ្ញុំស្រីនិងខ្ញុំប្រុស ជាអ្នកវៀរចាកការទទួលនូវពពែនិងចៀម ជាអ្នកវៀរចាកការទទួលនូវមាន់និងជ្រូក ជាអ្នកវៀរចាកការទទួលនូវដំរី គោ សេះ លា ឈ្មោល និងញី ជាអ្នកវៀរចាកការទទួលនូវស្រែនិងចម្ការ ជាអ្នកវៀរចាកកិរិយាប្រកបរឿយ ៗ នូវទូតកម្ម គឺ នាំសំបុត្រ ឬពាក្យបណ្តាំរបស់គ្រហស្ថ ជាអ្នកវៀរចាកកិរិយាលក់ដូរ

តុលាកូដកំសកូដមានកូដា បដិវិរតោ ហោតិ ឧក្កោដនវញ្ចននិកតិសាវិយោគា បដិវិរតោ ហោតិ ឆេទនវធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ ហោតិ ។ សោ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌចាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សេយ្យថាបិ នាម បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្តភារោ ឌេតិ ឯវមេវ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌចាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។ សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី

ជាអ្នកវៀរចាកការឆបោកដោយជញ្ជីង ឆបោកដោយភាជន៍មាស ទាំងឆ-បោកដោយរង្វាស់រង្វាល់ ជាអ្នកវៀរចាកកិរិយាសើរើ បញ្ឆោត បន្ទំ នឹងកោងកាច ជាអ្នកវៀរចាកកិរិយាកាត់ សម្លាប់ ចាប់ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់កំហែងយកទ្រព្យ ។ បុគ្គលនោះ ជាអ្នកសន្តោសដោយចីវរគ្រាន់តែការពារនូវកាយ សន្តោសដោយបិណ្ឌបាត គ្រាន់តែរក្សានូវផ្ទៃ បើទៅក្នុងទីណា ៗ កាន់យកត្រឹមតែចីវរ និងបិណ្ឌបាតប៉ុណ្ណោះទៅ ។ ដូចជាបក្សីសកុណជាតិ បើហើរទៅក្នុងទីណា ៗ មានតែទម្ងន់ស្លាបទៅក្នុងទីនោះ ៗ យ៉ាងណាមិញ ភិក្ខុជាអ្នកសន្តោសដោយចីវរគ្រាន់តែរក្សានូវកាយ សន្តោសដោយបិណ្ឌបាត គ្រាន់តែរក្សានូវផ្ទៃ បើទៅក្នុងទីណា ៗ កាន់យកត្រឹមតែចីវរនិងបិណ្ឌបាតប៉ុណ្ណោះទៅ យ៉ាងនោះដែរ ។ ភិក្ខុនោះ ប្រកបដោយសីលក្ខន្ធ ដ៏ប្រសើរនេះហើយ រមែងបានតែសេចក្តីសុខ ដែលមិនមានទោសក្នុងសន្តាន ។ ភិក្ខុនោះ ឃើញរូបដោយភ្នែក មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជន:

យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសា-រិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ

ពួកអកុសលធម៌ដ៏លាមក គឺអភិជ្ឈានិងទោមនស្ស រមែងជាប់តាមភិក្ខុនុ៎ះ ព្រោះកិរិយាមិនសង្រួមនូវចក្ខុន្ទ្រិយណា ភិក្ខុនោះក៏ប្រតិបត្តិដើម្បីសង្រួម នូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ ភិក្ខុនោះ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរស ដោយអណ្តាត... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ... ដឹងនូវធម៌ដោយចិត្ត ក៏មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ពួកអកុសល-ធម៌ដ៏លាមក គឺអភិជ្ឈានិងទោមនស្ស រមែងជាប់តាមភិក្ខុនុ៎ះ ព្រោះ កិរិយាមិនសង្រួមនូវមនិន្ទ្រិយណា ភិក្ខុនោះក៏ប្រតិបត្តិដើម្បីសង្រួម នូវ មនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះ ប្រកបដោយការសង្រួមនូវឥន្ទ្រិយដ៏ប្រសើរនេះហើយ រមែង ទទួលនូវសេចក្តីសុខ ដែលមិនលាយឡំដោយកិលេស ក្នុងសន្តាន ។ ភិក្ខុនោះ កាលឈានទៅមុខ ឬឈានថយក្រោយ ក៏ដឹងខ្លួន កាល មើលទៅមុខ ឬមើលទៅទិសផ្សេង ៗ ក៏ដឹងខ្លួន កាលបត់ដៃជើង ឬលាដៃជើង ក៏ដឹងខ្លួន កាលទ្រទ្រង់ នូវសង្ឃាដី បាត្រ ចីវរ

សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។

[៤៦] សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី

ក៏ដឹងខ្លួន កាលស៊ី ផឹក ទំពាស៊ី ទទួលរស ក៏ដឹងខ្លួន កាលបន្ទោបង់នូវឧច្ចារៈនិងបស្សាវៈ ក៏ដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ឬស្ងៀម ក៏ដឹងខ្លួន (ទាំងអស់) ។

[៤៦] ភិក្ខុនោះ ប្រកបព្រមដោយសីលក្ខន្ធដ៏ប្រសើរនេះផង ប្រកបព្រមដោយការសង្រួមនូវឥន្ទ្រិយដ៏ប្រសើរនេះផង ប្រកបព្រមដោយសតិ និងសម្បជញ្ញៈដ៏ប្រសើរនេះផង ស្វែងរកតែទីសេនាសនៈស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ ញកភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ។ ភិក្ខុនោះលុះត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏អង្គុយពែនភ្នែន តម្រង់កាយឲ្យត្រង់ ផ្ចង់សតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះ លះបង់នូវអភិជ្ឈាក្នុងលោក មានចិត្តប្រាសចេញចាកអភិជ្ឈា ជម្រះចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់នូវព្យាបាទជាគ្រឿងប្រទូស្ត មានចិត្តមិនប្រកបដោយព្យាបាទ មានសេចក្ដីអនុគ្រោះដល់សព្វសត្វដោយប្រយោជន៍ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទជាគ្រឿងប្រទូស្ត លះបង់នូវថីនមិទ្ធៈ ប្រាសចេញចាកថីនមិទ្ធៈ មានសេចក្ដីសំគាល់

សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុស-លេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

[៤៧] សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ

នូវពន្ធី មានសតិនិងសម្បជញ្ញៈ ជម្រះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ មិនមានសេចក្តីរវើរវាយ មានចិត្តស្ងប់ស្ងាត់ក្នុងសន្តាន ជម្រះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់នូវវិចិកិច្ឆា មានវិចិកិច្ឆាកន្លងហើយ មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[៥៧] លុះភិក្ខុនោះ លះបង់នីវរណៈទាំង ៥ យ៉ាងនេះ ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម្មជាតធ្វើបញ្ញា ឲ្យមានកម្លាំងថយបានហើយ ក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសេចក្តីស្ងាត់ ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ លុះរម្ងាប់នូវវិតក្កៈនិងវិចារៈអស់ហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺមានសភាពជាចិត្តខ្ពស់ឯក ឥតមានវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិប៉ុណ្ណោះ ក៏សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ លុះមានចិត្តនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផងថែមទាំងមានសតិនិងសម្បជញ្ញៈផង សោយនូវសុខដោយនាមកាយផង

យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

[៥៨] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្ស-តិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ

ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គល ដែលបានតតិយជ្ឈាន នោះថា ជម្មតាបុគ្គលដែលបាននូវតតិយជ្ឈានហើយ រមែងប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះហេតុនៃតតិយជ្ឈានណា ក៏បានដល់ នូវតតិយជ្ឈាននោះ ទើបសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ លុះលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្ស និងទោមនស្សអស់ទៅក្នុងកាលមុនផង ទើបបានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានស្មារតីបរិសុទ្ធដោយឧបេក្ខាវេទនា ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

[៩៨] កាលបើចិត្តរបស់ភិក្ខុនោះ តាំងនៅល្អបរិសុទ្ធចាកនីវរណធម៌ ជាចិត្តផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ដោយប្រការដូច្នេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺប្រាជ្ញារលឹកឃើញនូវលំដាប់ខន្ធដែលអាស្រ័យនៅក្នុងកាលមុន ភិក្ខុនោះ រលឹកឃើញនូវបុព្វេនិវាស គឺលំដាប់ខន្ធដែលអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ គឺរលឹកឃើញបាន ១ ជាតិខ្លះ

ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ ជាតិសតំបិ ជាតិសហស្សំបិ ជាតិសតសហស្សំបិ អនេកេបិ សំវដ្តកប្បេ អនេកេ-បិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំ-សុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំ-គោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិ-សំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូ-បបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

[៤៩] សោ ឯវំ សមាហិតេ ចិត្តេ បរិ-សុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ

២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ ជាតិខ្លះ ១ សែនជាតិខ្លះ រហូតដល់អនេកសំវដ្តកប្បខ្លះ អនេកវិវដ្តកប្បខ្លះ និង អនេកសំវដ្តវិវដ្តកប្បខ្លះ ភិក្ខុនោះដឹងថា អាត្មាអញបានកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រកូលយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតអំពីទីនោះហើយ បានទៅកើតក្នុងទីឯណោះទៀត លុះអាត្មាអញទៅកើតក្នុងទីនោះហើយ ក៏មានឈ្មោះយ៉ាងនេះ មានគោត្រកូលយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតអំពីទីនោះ ក៏បានមកកើតក្នុងទីនេះ ភិក្ខុនោះ រលឹកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ គឺរូបនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រកូល ដោយប្រការដូច្នេះ ។

[៥៩] កាលបើចិត្តរបស់ភិក្ខុតាំងនៅល្អ បរិសុទ្ធចាកនីវរណធម៌ ជាចិត្តផូរផង់ ឥតមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស

មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា ។ បេ ។ អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមា-ទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា ។ បេ ។ អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ

មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រ ទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាដឹង នូវចុតិនិងបដិសន្ធិ របស់សត្វទាំង-ឡាយ ភិក្ខុនោះមានចក្ខុទិព្វ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ក៏បាន ឃើញនូវពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ អាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ ភិក្ខុនោះដឹង ច្បាស់នូវសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ។ បេ ។ តិះដៀលនូវព្រះអរិយបុគ្គល មាន សេចក្តីយល់ខុស ប្រកាន់អំពើដែលយល់ខុស លុះសត្វទាំងអម្បាល នោះ បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ក៏រមែងចូលទៅ កើត ក្នុងកំណើតនៃតិរច្ឆាន ប្រេត អសុរកាយ និងនរក អើហ្ន៎ ចំណែកសត្វពួកនេះ ប្រកបដោយកាយសុចរិត ។ បេ ។ ជាសត្វមិន តិះដៀល នូវព្រះអរិយបុគ្គល មានសេចក្តីយល់ត្រូវ ប្រកាន់នូវអំពើ ដែលយល់ត្រូវ លុះសត្វទាំងអម្បាលនោះ បែកធ្លាយរាងកាយ ខាង មុខអំពីសេចក្តីស្លាប់ ក៏រមែងទៅកាន់សុគតិសួគ៌ទេវលោក ភិក្ខុនោះ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញ នូវពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ

សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។

[៦០] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ

មានរូបល្អខ្លះ រូបអាក្រក់ខ្លះ មានគតិល្អខ្លះ គតិអាក្រក់ខ្លះ រមែងដឹងនូវពួកសត្វ ប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន យ៉ាងនេះឯង ។

[៦០] កាលបើចិត្តរបស់ភិក្ខុតាំងនៅល្អ បរិសុទ្ធ ជាចិត្តផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវធម៌ ដែលធ្វើនូវអាសវៈឲ្យអស់ទៅ ។ ភិក្ខុនោះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសភាពរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាផ្លូវប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាសភាពរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះជាផ្លូវប្រតិបត្តិទៅកាន់ទីរលត់អាសវៈ ។ កាលបើភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចចាកកាមាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចផុតស្រឡះហើយ សេចក្តីដឹងថា ចិត្តផុតស្រឡះហើយ ក៏កើតមានប្រាកដ មួយទៀត ភិក្ខុដឹងច្បាស់ថា ជាតិរបស់អញអស់ហើយ ព្រហ្មចរិយធម៌សម្រេចហើយ

កាតុំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ អយំ វុច្ចតិ ព្រាហ្មណ បុគ្គលោ នេវត្តន្តបោ នាត្តបរិតាបនានុយោគមនុយុត្តោ ន បរន្តបោ ន បរបរិតាបនានុយោគមនុយុត្តោ សោ អនត្តន្តបោ អបរន្តបោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ ។

[៦១] ឯវំ វុត្តេ ឃោដមុខោ ព្រាហ្មណោ អាយស្មន្តំ ឧទេនំ ឯតទវោច អភិក្កន្តំ ភោ ឧទេន អភិក្កន្តំ ភោ ឧទេន សេយ្យថាបិ ភោ ឧទេន និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា ឧទេនេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ ឧទេនំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ ឧទេនោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

កិច្ចដែលត្រូវធ្វើ ក៏បានធ្វើស្រេចអស់ហើយ កិច្ចដទៃក្រៅពីនេះមិនមានឡើយ ម្នាលព្រាហ្មណ៍ នេះហៅថា បុគ្គលមិនកម្តៅខ្លួនឯង ទាំងមិនប្រកបការព្យាយាមកម្តៅខ្លួនឯង មិនកម្តៅអ្នកដទៃ ទាំងមិនប្រកបការព្យាយាមកម្តៅអ្នកដទៃ បុគ្គលនោះឈ្មោះថា មិនកម្តៅខ្លួនឯង ទាំងមិនកម្តៅអ្នកដទៃ មិនមានសេចក្តីស្រេកឃ្លាន មានតែសេចក្តីរលត់ទុក្ខត្រជាក់ត្រជំ សោយសេចក្តីសុខ មានខ្លួនប្រសើរ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ក្នុងបច្ចុប្បន្ននេះឯង ។

[៦១] កាលដែលឧទេនភិក្ខុ ពោលយ៉ាងនេះរួចហើយ ឃោដមុខ-ព្រាហ្មណ៍ បាននិយាយនឹងឧទេនភិក្ខុមានអាយុដូច្នេះថា បពិត្រឧទេនដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រឧទេនដ៏ចម្រើន ភ្លឺច្បាស់ណាស់ ធម៌ដែលលោកម្ចាស់ឧទេនដ៏ចម្រើន សំដែងដោយអនេកបរិយាយយ៉ាងនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលបិទបាំង ពុំនោះដូចគេប្រាប់ផ្លូវ ដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា បុរសមានចក្ខុ រមែងឃើញរូបទាំងឡាយបាន ខ្ញុំសូមដល់នូវព្រះឧទេនដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងជាទីពឹងទីរលឹក ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះឧទេនដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត ។

១១១

ព្រាហ្មណវគ្គស្ស យោជមុខសុត្តេ យោជមុខស្ស សរណគមនំ

មា ខោ មំ ត្វំ ព្រាហ្មណ សរណំ អគមាសិ តមេវ ត្វំ ភគវន្តំ សរណំ គច្ឆាហិ យមហំ សរណំ គតោតិ ។ កហំ បន ភោ ឧទេន ឯតរហិ សោ ភវំ គោតមោ វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ បរិនិព្វុតោ ខោ ព្រាហ្មណ ឯតរហិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោតិ ។ សចេ ហិ មយំ ភោ ឧទេន សុណេយ្យាម តំ ភវន្តំ គោតមំ ទសសុ[១] យោជនេសុ ទសបិ មយំ យោជនានិ គច្ឆេយ្យាម តំ ភវន្តំ គោតមំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ សចេ[២] មយំ ភោ ឧទេន សុណេយ្យាម តំ ភវន្តំ គោតមំ វីសតិយា យោជនេសុ... តឹសតិយា យោជនេសុ... ចត្តាឡីសាយ យោជនេសុ... បញ្ញាសាយ យោជនេសុ បញ្ញាសំបិ មយំ យោជនានិ គច្ឆេយ្យាម តំ ភវន្តំ គោតមំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ យោជនសតេបិ មយំ ភោ ឧទេន សុណេយ្យាម តំ ភវន្តំ គោតមំ យោជនសតំបិ

---

១ ឱ. ទសសុបិ ។ ២ ឱ. ហិសទ្ទោ ទិស្សតិ ។

ឧទេនភិក្ខុតបថា ម្នាលព្រាហ្មណ៍ អ្នកកុំយកអាត្មា ជាទីពឹងឡើយ អាត្មាយកព្រះមានព្រះភាគអង្គណាជាទីពឹង អ្នកចូរយកព្រះមានព្រះភាគអង្គនោះជាទីពឹងចុះ ។ ឃោដមុខព្រាហ្មណ៍សួរថា បពិត្រព្រះឧទេនដ៏ចម្រើន ចុះឥឡូវនេះ ព្រះគោតមដ៏ចម្រើន ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ គង់នៅក្នុងទីណា ។ ឧទេនភិក្ខុតបថា ម្នាលព្រាហ្មណ៍ ឥឡូវនេះ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិនិព្វានទៅហើយ ។ ឃោដមុខ-ព្រាហ្មណ៍តបថា បពិត្រព្រះឧទេនដ៏ចម្រើន ប្រសិនបើយើងខ្ញុំ ឮដំណឹងថា ព្រះគោតមដ៏ចម្រើនអង្គនោះ គង់ក្នុងទីចំនួន ១០ យោជន៍ យើងខ្ញុំគួរទៅកាន់ទីចំនួន ១០ យោជន៍ ដើម្បីចួបនឹងព្រះគោតមដ៏ចម្រើន ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះដែរ បពិត្រព្រះឧទេនដ៏ចម្រើន ប្រសិនបើយើងខ្ញុំ ឮដំណឹងថា ព្រះគោតមដ៏ចម្រើនអង្គនោះ គង់ក្នុងទីចំនួន ២០ យោជន៍... ក្នុងទីចំនួន ៣០ យោជន៍... ក្នុងទីចំនួន ៤០ យោជន៍... ក្នុងទីចំនួន ៥០ យោជន៍ យើងខ្ញុំ ក៏គួរទៅកាន់ទីចំនួន ៥០ យោជន៍ ដើម្បីចួបនឹងព្រះគោតមដ៏ចម្រើន ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះដែរ បពិត្រព្រះឧទេនដ៏ចម្រើន ប្រសិនបើយើងខ្ញុំ ឮដំណឹងថា ព្រះគោតមដ៏ចម្រើនអង្គនោះ គង់ក្នុងទីចំនួន ១០០ យោជន៍

មយំ គច្ឆេយ្យាម តំ ភវន្តំ គោតមំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ យតោ ច ខោ ភោ ឧទេន បរិនិព្វុតោ សោ ភវំ គោតមោ បរិនិព្វុតំបិ មយំ តំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ ឧទេនោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតំ អត្ថិ ច មេ ភោ ឧទេន អង្គរាជា ទេវសិកំ និច្ចភិក្ខំ ទទាតិ តតោ អហំ ភោតោ ឧទេនស្ស ឯកំ និច្ចភិក្ខំ ទទាមីតិ ។

[៦២] កឹ បន តេ ព្រាហ្មណ អង្គរាជា ទេវសិកំ និច្ចភិក្ខំ ទទាតីតិ ។ បញ្ចបិ[១] ភោ ឧទេន កហាបណសតានីតិ ។ ន ខោ ព្រាហ្មណ កប្បតិ

១ ឱ. អបិសទ្ទោ ន ទិស្សតិ ។

យើងខ្ញុំ ក៏គួរតែទៅ កាន់ទីចំនួន ១០០ យោជន៍ ដើម្បីចួបនឹងព្រះគោតមដ៏ចម្រើន ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះដែរ បពិត្រព្រះឧទេនដ៏ចម្រើន កាលបើព្រះគោតមដ៏ចម្រើន ព្រះអង្គបរិនិព្វានទៅហើយ ក៏យើងខ្ញុំសូមដល់ នូវព្រះគោតមដ៏ចម្រើនអង្គនោះ ដែលព្រះអង្គបរិនិព្វានទៅហើយផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះឧទេនដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះករុណា ថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមតទៅ បពិត្រព្រះឧទេនដ៏ចម្រើន ព្រះរាជាក្នុងដែនអង្គៈ ទ្រង់ប្រទាននិច្ចភិក្ខា ដល់ខ្ញុំព្រះករុណា តែសព្វ ៗ ថ្ងៃ ខ្ញុំព្រះករុណាសូមប្រគេននិច្ចភិក្ខាមួយចំណែក អំពីនិច្ចភិក្ខានោះ ដល់ព្រះឧទេនដ៏ចម្រើន ។

[៦២] ឧទេនភិក្ខុសួរថា ម្នាលព្រាហ្មណ៍ ចុះព្រះបាទអង្គៈទ្រង់ប្រទាននិច្ចភិក្ខាប៉ុន្មាន ដល់អ្នក សព្វ ៗ ថ្ងៃ ។ ឃោដមុខព្រាហ្មណ៍តបថា បពិត្រព្រះឧទេនដ៏ចម្រើន ព្រះបាទអង្គៈ ទ្រង់ប្រទាន ៥០០ កហាបណៈ ។ ឧទេនភិក្ខុតបថា ម្នាលព្រាហ្មណ៍ យើងមិនគួរ

ជាតរូបរជតំ បដិគ្គហេតុន្តិ ។ សចេ តំ ភោ ឧទេន(១) ន កប្បតិ វិហារំ ភោតោ ឧទេនស្ស ការាបេស្សាមីតិ ។ សចេ ខោ មេ ត្វំ ព្រាហ្មណ វិហារំ ការាបេតុកាមោ ចាដលិបុត្តេ សង្ឃស្ស ឧបដ្ឋានសាលំ ការាបេហីតិ ។ ឥមិនាហំ(២) ភោតោ ឧទេនស្ស ភិយ្យោសោ មត្តាយ អត្តមនោ អភិរទ្ធោ យំ មំ ភវំ ឧទេនោ សង្ឃេ ទានេ(៣) សមាទបេតិ ឯសាហំ ភោ ឧទេន ឯតិស្សា ច និច្ចភិក្ខាយ អបរាយ ច និច្ចភិក្ខាយ ចាដលិបុត្តេ សង្ឃស្ស ឧបដ្ឋានសាលំ ការាបេស្សាមីតិ ។ អថខោ ឃោដមុខោ ព្រាហ្មណោ ឯតិស្សា ច និច្ចភិក្ខាយ អបរាយ ច និច្ចភិក្ខាយ ចាដលិបុត្តេ សង្ឃស្ស ឧបដ្ឋានសាលំ ការាបេសិ ។ សា ឯតរហិ ឃោដមុខីតិ វុច្ចតីតិ ។

ឃោដមុខសុត្តំ ចតុត្ថំ និដ្ឋិតំ ។

---

១ ឱ. ម. ភោតោ ឧទេនស្សាតិ ទិស្សតិ ។ ២ ឱ. ឥមិនាបហំ ។ ៣ ឱ. ម. ទានំ ។

ទទួលមាសនិងប្រាក់ទេ ។ យោដមុខព្រាហ្មណ៍ឆ្លើយថា បពិត្រព្រះឧទេនដ៏ចម្រើន បើមាសនោះមិនគួរ ខ្ញុំព្រះករុណានឹងឲ្យជាងធ្វើវិហារប្រគេនលោកម្ចាស់ឧទេនដ៏ចម្រើន ។ ឧទេនភិក្ខុតបថា ម្នាលព្រាហ្មណ៍ បើអ្នកចង់ឲ្យជាងធ្វើវិហារឲ្យអាត្មា ចូរឲ្យជាងសង់ឧបដ្ឋានសាលាប្រគេនសង្ឃ នៅក្នុងបាដលិបុត្តវិញចុះ ។ យោដមុខព្រាហ្មណ៍ពោលថា លោកម្ចាស់ឧទេនដ៏ចម្រើន បបួលខ្ញុំព្រះករុណាឲ្យធ្វើទានចំពោះសង្ឃ ដោយហេតុណា ខ្ញុំព្រះករុណាមានចិត្តត្រេកអររីករាយពន់ប្រមាណ ចំពោះលោកម្ចាស់ឧទេនដ៏ចម្រើន ដោយហេតុនេះ បពិត្រលោកម្ចាស់ឧទេនដ៏ចម្រើន ខ្ញុំព្រះករុណានេះ នឹងឲ្យជាងធ្វើឧបដ្ឋានសាលាប្រគេនសង្ឃក្នុងក្រុងបាដលិបុត្ត ដោយនិច្ចភិក្ខានេះផង ដោយនិច្ចភិក្ខាដទៃផង ។ លំដាប់នោះ យោដមុខព្រាហ្មណ៍ ក៏ឲ្យជាងធ្វើឧបដ្ឋានសាលាប្រគេនសង្ឃក្នុងក្រុងបាដលិបុត្ត ដោយនិច្ចភិក្ខានុំះផង ដោយនិច្ចភិក្ខាដទៃផង ។ ឥឡូវនេះ សាលានេះ គេហៅថា យោដមុខី ។

ចប់ យោដមុខសូត្រ ទី ៤ ។

# បញ្ចមំ ចង្កីសុត្តំ

[៦៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន យេន ឱចាសាទំ[១] ជាម កោសលានំ ព្រាហ្មណគ្គាមោ តទវសរិ ។ តត្រ សុទំ ភគវា ឱចាសាទេ វិហរតិ ឧត្តរេន ឱចាសាទំ ទេវវនេ សាលវនេ ។ តេន ខោ បន សមយេន ចង្កី ព្រាហ្មណោ ឱចាសាទំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគំ រញ្ញា បសេនទិនា កោសលេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ។

[៦៤] អស្សោសុំ ខោ ឱចាសាទកា[២] ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ ឱចាសាទំ អនុប្បត្តោ ឱចាសាទេ វិហរតិ ឧត្តរេន ឱចាសាទំ ទេវវនេ សាលវនេ

---

១ ឱ. ឱបសាទំ ។ ២ ឱ. ឱបសាទកា ។

# ចង្កីសូត្រ ទី ៥

[៦៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃជាច្រើន ក៏បានដល់ទៅស្រុកព្រាហ្មណ៍ ឈ្មោះឱបាសាទ របស់ដែនកោសល ។ ដំណឹងនោះឮថា ព្រះមានជោគទ្រង់គង់ក្នុងសាលវ័នជាទេវវ័ន[១] នៅខាងជើងឱបាសាទគ្រាម ជិតឱបាសាទគ្រាម ។ ក្នុងសម័យនោះឯង មានព្រាហ្មណ៍ម្នាក់ ឈ្មោះចង្កី នៅអាស្រ័យនឹងឱបាសាទគ្រាម ដែលជាស្រុកកុះករដោយសត្វនិងមនុស្ស បរិបូណ៌ដោយស្មៅឧសនិងទឹក បរិបូណ៌ដោយធញ្ញាហារ ជាស្រុកព្រះរាជទ្រព្យ ដែលព្រះរាជាបសេនទិកោសល ទ្រង់ព្រះរាជទានជាព្រះរាជអំណោយដ៏ប្រសើរ គឺទ្រង់ប្រទានដោយដាច់ខាត ។

[៦៤] ពួកព្រាហ្មណ៍និងគហបតីនៅក្នុងឱបាសាទគ្រាម បានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្រទ្រង់ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ទ្រង់ពុទ្ធដំណើរមកកាន់ចារិក ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃជាច្រើន បានដល់មកឱបាសាទគ្រាម ឥឡូវនេះមកគង់ក្នុងឱបាសាទគ្រាម ក្នុងសាលវ័នជាទេវវ័ន នៅខាងជើងឱបាសាទគ្រាម

១ ក្នុងព្រៃនោះ អ្នកផងតែងធ្វើពលីកម្មថ្វាយពួកទេវតា បានជាហៅថា ទេវវ័ន ឬនឹងហៅថា សាលវ័ន ក៏បាន ។ អដ្ឋកថា ។

១១៤

ព្រាហ្មណវគ្គស្ស ចង្កីសុត្តេ ពុទ្ធគុណប្បសំសា

តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណិំ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ

កិត្តិសព្ទល្អ នៃព្រះគោតមដ៏ចម្រើន អង្គនោះ ឮល្បីខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានជោគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹង និងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានព្រះដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះអង្គបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា ចំពោះព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ហើយប្រកាស ទ្រង់សំដែងធម៌ មានលំអបទដើម មានលំអបទកណ្តាលនិងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់

សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ ឱចាសាទកា ព្រាហ្មណគហបតិកា ឱចាសាទកា និក្ខមិត្វា សង្ឃា សង្ឃីគណីភូតា ឧត្តរេន មុខា គច្ឆន្តិ យេន ទេវវនំ សាលវនំ ។ តេន ខោ បន សមយេន ចង្កី ព្រាហ្មណោ ឧបរិ បាសាទេ ទិវា សេយ្យំ ឧបគតោ ហោតិ(១) ។

[៦៤] អទ្ទសា ខោ ចង្កី ព្រាហ្មណោ ឱចាសាទកេ ព្រាហ្មណគហបតិកេ ឱចាសាទា និក្ខមិត្វា សង្ឃេ សង្ឃីគណីភូតេ ឧត្តរេន មុខេ គច្ឆន្តេ យេន ទេវវនំ សាលវនំ ទិស្វាន ខត្តំ អាមន្តេសិ កិន្នុ ខោ ភោ ខត្តេ ឱចាសាទកា ព្រាហ្មណគហបតិកា ឱចាសាទា និក្ខមិត្វា សង្ឃា សង្ឃីគណីភូតា ឧត្តរេន មុខា គច្ឆន្តិ យេន ទេវវនំ សាលវនន្តិ ។ អត្ថិ ភោ ចង្កី សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ ឱចាសាទំ អនុប្បត្តោ

១ ម. ហោតីតិ ន ទិស្សតិ ។

ក៏ដំណើរដែលបានឃើញបានចួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។ លំដាប់នោះ ពួកព្រាហ្មណ៍និងគហបតី នៅក្នុងឱបាសាទគ្រាម ចេញអំពីឱបាសាទគ្រាមជាពួក ជាក្រុម ជាគណ: មានមុខឆ្ពោះទៅកាន់ឧត្តរទិស សំដៅទៅកាន់សាលវ័នជាទេវវ័ន ។ ក៏សម័យនោះឯង ចង្កីព្រាហ្មណ៍ចូលទៅដេកក្នុងវេលាថ្ងៃ ឰដ៏ប្រាសាទជាន់ខាងលើ ។

[៦៥] ចង្កីព្រាហ្មណ៍ បានឃើញពួកព្រាហ្មណ៍ និងគហបតី នៅក្នុងឱបាសាទគ្រាម ចេញអំពីឱបាសាទគ្រាម ជាពួក ជាក្រុម ជាគណ: មានមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរត្រសង់ទៅកាន់សាលវ័នជាទេវវ័ន លុះឃើញហើយ ក៏និយាយទៅរកខត្តាមាត្យថា ម្នាលខត្ត: ចុះហេតុដូចម្តេច បានជាពួកព្រាហ្មណ៍និងគហបតី នៅក្នុងឱបាសាទ-គ្រាម ជាពួក ជាក្រុម ជាគណ: មានមុខឆ្ពោះទៅកាន់ឧត្តរទិស ដើរត្រសង់ទៅកាន់សាលវ័នជាទេវវ័ន ។ ខត្តាមាត្យជំរាបថា បពិត្រលោកចង្កីដ៏ចម្រើន មានព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យ-ត្រកូល ទ្រង់ព្រះផ្នួស ទ្រង់ពុទ្ធដំណើរមកកាន់ចារិកក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃ ជាច្រើន ឥឡូវ បានមកដល់ឱបាសាទគ្រាម

ឱបាសាទេ វិហរតិ ឧត្តរេន ឱបាសាទំ ទេវវនេ សាលវនេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តមេតេ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមន្តីតិ ។ តេនហិ ភោ ខត្តេ យេន ឱបាសាទកា ព្រាហ្មណគហបតិកា តេនុបសង្កម ឧបសង្កមិត្វា ឱបាសាទកេ ព្រាហ្មណគហបតិកេ ឯវំ វទេហិ ចង្កី ភោ ព្រាហ្មណោ ឯវមាហ អាគមេន្តុ កិរ ភវន្តោ ចង្កីបិ ព្រាហ្មណោ សមណំ គោតមំ ទស្ស-នាយ ឧបសង្កមិស្សតីតិ[១] ។ ឯវំ ភោតិ ខោ សោ ខត្តា ចង្កិស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន ឱបាសាទ-កា ព្រាហ្មណគហបតិកា តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. ម. ឧបសង្កមិស្សតីតិ ។

ទ្រង់គង់នៅក្នុងសាលវ័នជាទេវវ័ន ក្បែរឱបាសាទគ្រាម ជាខាងជើងនៃឱបាសាទគ្រាម ក៏កិត្តិសព្ទល្អ នៃព្រះគោតមដ៏ចម្រើននោះ ឮល្បីខ្ចរខ្ចាយសុសសាយមក យ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគតជ្រាបច្បាស់នូវលោក ជាបុគ្គលប្រសើរបំផុត ជាសារថីទូន្មាននូវបុរសជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ពួកព្រាហ្មណ៍និងគហបតីទាំងនុ៎ះ ដើរចូលទៅដើម្បីគាល់ព្រះគោតមដ៏ចម្រើន ។ ចង្កី-ព្រាហ្មណ៍និយាយថា ម្នាលខត្តៈដ៏ចម្រើន បើដូច្នោះ អ្នកចូរចូលទៅរកពួកព្រាហ្មណ៍និងគហបតីដែលនៅក្នុងឱបាសាទគ្រាម លុះចូលទៅដល់ហើយ និយាយនឹងពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងឱបាសាទគ្រាម យ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ចង្កីព្រាហ្មណ៍បាននិយាយយ៉ាងនេះថា សូមឲ្យអ្នកដ៏ចម្រើនទាំងឡាយ រង់ចាំបន្តិចសិន ដ្បិតចង្កី-ព្រាហ្មណ៍ចង់ចូលទៅគាល់ព្រះសមណគោតមដែរ ។ ខត្តាមាត្យនោះទទួលពាក្យចង្កីព្រាហ្មណ៍ថា បាទ លោកដ៏ចម្រើន រួចចូលទៅរកពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងឱបាសាទគ្រាម លុះចូលទៅដល់ហើយ

ឱបាសាទកេ ព្រាហ្មណគហបតិកេ ឯតទហោច ចង្កី ភោ ព្រាហ្មណោ ឯវមាហ អាគមេន្តុ ភវន្តោ ចង្កីបិ ព្រាហ្មណោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។

[៦៦] តេន ខោ បន សមយេន នានាវេរជ្ជកានំ ព្រាហ្មណានំ បញ្ចមត្តានិ ព្រាហ្មណសតានិ ឱបាសាទេ បដិវសន្តិ កេនចិទេវ ករណីយេន ។ អស្សោសុំ ខោ តេ ព្រាហ្មណា ចង្កី កិរ ព្រាហ្មណោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។ អថ(១) តេ ព្រាហ្មណា យេន ចង្កី ព្រាហ្មណោ តេនុបសង្កមឹសុ ឧបសង្កមិត្វា ចង្កឹ ព្រាហ្មណំ ឯតទវោចុំ សច្ចំ កិរ ភវំ ចង្កី សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។ ឯវំ ខោ(២) ភោ ហោតិ អហំបិ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សាមីតិ ។ មា ភវំ ចង្កី សមណំ គោតមំ ទស្សនាយ ឧបសង្កមិ

១ ឱ. ម. អថខោ ។ ២ ឱ. ម. ខោ មេ ។

បានពោលទៅរកពួកព្រាហ្មណ៍និងគហបតី ដែលនៅក្នុងឱបាសាទគ្រាម ដូច្នេះថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ចង្កីព្រាហ្មណ៍និយាយយ៉ាងនេះថា សូមឲ្យអ្នកទាំងឡាយ រង់ចាំបន្តិចសិន ដ្បិតចង្កីព្រាហ្មណ៍ ចង់ចូលទៅគាល់ព្រះគោតមដែរ ។

[៦៦] ក៏សម័យនោះឯង បណ្តាពួកព្រាហ្មណ៍ ដែលមកអំពីដែនដទៃផ្សេង ៗ មានពួកព្រាហ្មណ៍ចំនួន ៥០០ នាក់ នៅអាស្រ័យក្នុងឱបាសាទគ្រាម ដោយកិច្ចណានីមួយ ។ ពួកព្រាហ្មណ៍ទាំងនោះ បានឮថា ចង្កីព្រាហ្មណ៍ នឹងចូលទៅគាល់ព្រះសមណគោតម ។ ទើបព្រាហ្មណ៍ទាំងនោះ នាំគ្នាចូលទៅរកចង្កីព្រាហ្មណ៍ ត្រង់កន្លែងដែលគាត់នៅ លុះចូលទៅដល់ហើយ បាននិយាយទៅរកចង្កីព្រាហ្មណ៍ ដូច្នេះថា ឮថា ចង្កីដ៏ចម្រើន នឹងចូលទៅគាល់ព្រះសមណគោតមមែនឬ ។ ចង្កីព្រាហ្មណ៍ឆ្លើយថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ យ៉ាងហ្នឹងហើយ ខ្ញុំឯងនឹងទៅគាល់ព្រះសមណគោតមមែន ។ ពួកព្រាហ្មណ៍និយាយឃាត់ថា ចង្កីដ៏ចម្រើន កុំចូលទៅគាល់ព្រះសមណគោតម

ព្រាហ្មណវគ្គស្ស ចង្កីសុត្តេ ចង្កិប្បសំសា

ន អរហតិ ភវំ ចង្កី សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ ចង្កឹ ទស្សនាយ ឧបសង្កមិតុំ ភវញ្ហិ ចង្កី ឧភតោសុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន យម្បិ ភវំ ចង្កី ឧភតោសុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឥមិនាបង្គេន ន អរហតិ ភវំ ចង្កី សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ ចង្កឹ ទស្សនាយ ឧបសង្កមិតុំ ភវញ្ហិ ចង្កី អឌ្ឍោ មហទ្ធនោ មហាភោគោ ភវញ្ហិ ចង្កី តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្ប-ភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករ-ណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ

ឡើយ ចង្កីដ៏ចម្រើន មិនគួរចូលទៅគាល់ព្រះសមណគោតមទេ គួរតែព្រះសមណគោតម ចូលមកចួបនឹងចង្កីដ៏ចម្រើនវិញ ដ្បិតចង្កីដ៏ចម្រើន មានកំណើតបរិសុទ្ធទាំងពីរចំណែក គឺខាងមាតានិងខាងបិតា ប្រសូតចាកគភ៌ដ៏បរិសុទ្ធ តាំងអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មក មិនមានអ្នកណាមួយ រិះគន់តិះដៀលដោយពោលដល់ជាតិកំណើតបានឡើយ ចង្កីដ៏ចម្រើន មានកំណើតបរិសុទ្ធ ទាំងពីរចំណែក គឺខាងមាតានិងខាងបិតា ប្រសូតចាកគភ៌ដ៏បរិសុទ្ធ តាំងអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មក មិនមានអ្នកណាមួយ រិះគន់តិះដៀល ដោយពោលដល់ជាតិកំណើតបានឡើយ ដោយហេតុណា ហេតុនោះ បានជាចង្កីដ៏ចម្រើន មិនគួរចូលទៅគាល់ព្រះសមណគោតមទេ គួរតែព្រះសមណគោតមចូលមកចួបនឹងចង្កីដ៏ចម្រើនវិញ មួយទៀត ចង្កីដ៏ចម្រើន ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងបរិភោគច្រើន មិនតែប៉ុណ្ណោះ ចង្កីដ៏ចម្រើន ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈ ជាគម្រប់ ៥ ជាអ្នកស្គាល់នូវបទ និងវេយ្យាករណ៍ ជាអ្នកមិនខ្ពនថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ

ភវញ្ហិ ចង្កី អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អខុទ្ទាវកាសោ ទស្សនាយ ភវញ្ហិ ចង្កី សីលវា ពុឌ្ឍសីលី ពុឌ្ឍសីលេន សមន្នាគតោ ភវញ្ហិ ចង្កី កល្យាណវាចោ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា ភវញ្ហិ ចង្កី ពហុន្នំ អាចរិយបាចរិយោ តីណិ មាណវកសតានិ មន្តេ វាចេតិ ភវញ្ហិ ចង្កី រញ្ញោ បសេនទិស្ស កោសលស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ ភវញ្ហិ ចង្កី ព្រាហ្មណស្ស បោក្ខរសាតិស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ ភវញ្ហិ ចង្កី ឱបាសាទំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា បសេនទិនា កោសលេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ យស្មា ភវំ ចង្កី

មួយទៀត ចង្កីដ៏ចម្រើន មានរូបល្អ គួរពិតពិលរមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយពណ៌សម្បុរដ៏ល្អក្រៃលែង មានព្រះវណ្ណស្រដៀងនឹងព្រហ្ម មានសរីរៈស្រដៀងគ្នានឹងព្រហ្ម មានសណ្ឋានកាយគួរឲ្យចង់មើលមិនលែង មួយទៀត ចង្កីដ៏ចម្រើន ជាអ្នកមានសីល មានសីលដ៏ចម្រើន ប្រកបដោយសីលដ៏ចម្រើន មួយទៀត ចង្កីដ៏ចម្រើន មានសំដីពីរោះ និយាយសំដីពីរោះ ប្រកបដោយសំដីអ្នកក្រុង ជាសំដីច្បាស់លាស់ប្រាសចាកទោស អាចញ៉ាំងអ្នកស្តាប់ឲ្យចូលចិត្តសេចក្តីជាក់លាក់បាន មួយទៀត ចង្កីដ៏ចម្រើន ជាអាចារ្យ ជាប្រធានលើអាចារ្យនៃពួកជនច្រើន បានបង្រៀនមន្តមាណព ៣០០ នាក់ មួយទៀត ចង្កីដ៏ចម្រើន ព្រះបាទបសេនទិកោសលតែងធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា កោតក្រែង ទាំងបោក្ខរសាតិព្រាហ្មណ៍ ក៏តែងធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជា កោតក្រែងចង្កីដ៏ចម្រើនដែរ មួយទៀត ចង្កីដ៏ចម្រើន នៅគ្រប់គ្រងឱបាសាទគ្រាម ដែលជាស្រុកកុះករដោយមនុស្សនិងសត្វ សម្បូណ៌ដោយស្មៅ ឧស និងទឹក បរិបូណ៌ដោយធញ្ញាហារ ជាស្រុកព្រះរាជទ្រព្យ ដែលព្រះបាទបសេនទិកោសល ប្រទានជាព្រះរាជអំណោយដ៏ប្រសើរ គឺទ្រង់ប្រទានដោយដាច់ខាត ចង្កីដ៏ចម្រើន

ព្រាហ្មណវគ្គស្ស ចង្កីសុត្តេ ភគវន្តវណ្ណកថា

ឱបាសាទំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគំ រញ្ញា បសេនទិនា កោសលេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ឥមិនាបង្គេន ន អរហតិ ភវំ ចង្កី សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ ចង្កី ទស្សនាយ ឧបសង្កមិតុន្តិ ។

[៦៧] ឯវំ វុត្តេ ចង្កី ព្រាហ្មណោ តេ ព្រាហ្មណេ ឯតទវោច តេនហិ ភោ មមាបិ សុណាថ យថា យថា មយមេវ អរហាម តំ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ ន ត្វេវ អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ សមណោ ខលុ ភោ គោតមោ ឧភតោសុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន យម្បិ សមណោ គោតមោ ឧភតោ-សុជាតោ ។ បេ ។ ជាតិវាទេន ឥមិនាបង្គេន

នៅគ្រប់គ្រងឱបាសាទគ្រាម ដែលជាស្រុកកុះករដោយមនុស្សនិងសត្វ សម្បូណ៌ដោយស្មៅ ឧស និងទឹក បរិបូណ៌ដោយធញ្ញាហារ ជាស្រុកព្រះរាជទ្រព្យ ដែលព្រះបាទបសេនទិកោសល ប្រទានជាព្រះរាជ-អំណោយដ៏ប្រសើរ គឺព្រះរាជទានដោយដាច់ខាត ដោយហេតុណា ហេតុនេះបានជាថាចង្កីដ៏ចម្រើន មិនគួរចូលទៅចួបនឹងព្រះសមណគោតមឡើយ គួរតែព្រះសមណគោតម ចូលមកចួបនឹងចង្កីដ៏ចម្រើនវិញ ។

[៦៧] កាលបើពួកព្រាហ្មណ៍ និយាយយ៉ាងនេះហើយ ចង្កី-ព្រាហ្មណ៍ក៏និយាយនឹងព្រាហ្មណ៍ទាំងនោះ យ៉ាងនេះថា នែអ្នកដ៏ចម្រើន បើដូច្នោះ ចូរស្តាប់ពាក្យខ្ញុំសិនថា បើទុកជាយ៉ាងណា ៗ ក៏គួរតែយើងចូលទៅគាល់ព្រះសមណគោតមនោះវិញ មិនគួរឲ្យព្រះគោតមដ៏ចម្រើននោះចូលមកចួបនឹងយើងទេ នែអ្នកទាំងឡាយដ៏ចម្រើន ឮថាព្រះសមណ-គោតម មានជាតិបរិសុទ្ធទាំងពីរចំណែក គឺខាងព្រះមាតានិងព្រះបិតាប្រសូតចាកគភ៌ដ៏បរិសុទ្ធ តាំងពីតំណ នៃព្រះអយ្យកោអយ្យិកា ជាគម្រប់ ៧ មក មិនមានអ្នកណាតិះដៀល ដោយពោលដល់ជាតិកំណើតបានឡើយ ព្រះសមណគោតម មានជាតិដ៏ល្អ ទាំងពីរចំណែក ។ បេ ។ ដោយពោលដល់ជាតិកំណើតបានឡើយ ដោយហេតុណា ហេតុនេះ

ន អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ អថខោ មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ខលុ ភោ គោតមោ បហូតំ ហិរញ្ញសុវណ្ណំ ឱហាយ បព្វជិតោ ភូមិគតំ ច វេហាសដ្ឋញ្ច សមណោ ខលុ ភោ គោតមោ ទហរោ វ សមានោ សុសុកាឡ-កេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អគារស្មា អនគារិយំ បព្វជិតោ សមណោ ខលុ ភោ គោតមោ អកាមកានំ មាតាបិតូនំ អស្សុមុខានំ រុទន្តានំ កេសមស្សុំ ឱហារេត្វា កា-សាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ សមណោ ខលុ ភោ គោតមោ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អខុទ្ទាវកាសោ ទស្សនាយ សមណោ ខលុ ភោ គោតមោ សីលវា

មិនគួរឲ្យព្រះគោតមដ៏ចម្រើននោះ ចូលមកចួបនឹងយើងទេ គួរតែយើងរាល់គ្នា ចូលទៅគាល់ព្រះគោតមដ៏ចម្រើននោះដោយពិត នៃអ្នកទាំងឡាយដ៏ចម្រើន ព្រោះថាព្រះសមណគោតម ទ្រង់លះបង់មាសប្រាក់មានប្រមាណច្រើន ដែលឋិតនៅលើផែនដី ទាំងឋិតនៅក្នុងវេហាស៍ គឺក្នុងប្រាសាទជាន់លើ ហើយចេញទៅទ្រង់ព្រះផ្នួស នៃគ្នាយើង ព្រោះថាព្រះសមណគោតម ព្រះអង្គជាកំលោះនៅឡើយ មានព្រះកេសាខ្មៅស្រិល ប្រកបដោយវ័យដ៏ចម្រើន គឺបឋមវ័យ ទ្រង់ចេញចាកគេហដ្ឋានចូលទៅកាន់ផ្នួស នៃគ្នាយើង ព្រោះថាព្រះសមណគោតម កាលព្រះវរមាតាបិតាមិនពេញព្រះហឫទ័យ (នឹងការទ្រង់ព្រះផ្នួស) កំពុងមានព្រះភក្ត្រជោកជាំ ដោយទឹកព្រះនេត្រ ទ្រង់ព្រះកន្សែងសោយសោក ព្រះអង្គទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ ទ្រង់ព្រះកាសាវពស្ត្រ ហើយចេញចាកគេហដ្ឋាន ចូលទៅកាន់ផ្នួស នៃគ្នាយើង ព្រោះថាព្រះសមណគោតម មានព្រះរូបល្អ គួរឲ្យរមិលមើល គួរជាទីជ្រះថ្លា ប្រកបដោយព្រះវណ្ណៈដ៏ល្អក្រៃលែង មានព្រះវណ្ណៈស្រដៀងនឹងព្រហ្ម មានព្រះសរីរៈស្រដៀងនឹងព្រហ្ម មានព្រះសណ្ឋានរាងកាយ គួរឲ្យចង់មើលមិនលែង នៃគ្នាយើង ព្រោះថាព្រះសមណគោតម ទ្រង់មានសីល

ព្រាហ្មណវគ្គស្ស ចង្កីសុត្តេ ភគវន្តវណ្ណកថា

អរិយសីលី កុសលសីលី កុសលេន សីលេន សមន្នាគតោ សមណោ ខលុ ភោ គោតមោ ក-ល្យាណវាចោ កល្យាណវាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិសដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា សមណោ ខលុ ភោ គោតមោ ពហុន្នំ អាចរិយប្បាចរិយោ សមណោ ខលុ ភោ គោតមោ ខីណកាមរាគោ វិគតចាបល្លោ សមណោ ខលុ ភោ គោតមោ កម្មវាទី កិរិយវាទី អបាបបុរេក្ខារោ ព្រហ្មញ្ញាយ បជាយ សមណោ ខលុ ភោ គោតមោ ឧច្ចាកុលា បព្វជិតោ អសំភិន្នា ខត្តិយកុលា សមណោ ខលុ ភោ គោតមោ អឌ្ឍកុលា បព្វជិតោ មហទ្ធនា មហាភោគា សមណំ ខលុ ភោ គោតមំ តិរោរដ្ឋា

មានសីលដ៏ប្រសើរ មានសីលជាកុសល ប្រកបដោយសីលជាកុសល នៃគ្នាយើង ឮថាព្រះសមណគោតម មានព្រះវាចាពីរោះ មានព្រះពុទ្ធ-ដីកាដ៏ពីរោះ ប្រកបដោយវាចាជារបស់អ្នកក្រុង ជាព្រះវាចាច្បាស់លាស់ ប្រាសចាកទោស អាចញុាំងអ្នកស្តាប់ឲ្យចូលចិត្តសេចក្តីច្បាស់លាស់បាន នៃគ្នាយើង ឮថាព្រះសមណគោតម ជាអាចារ្យជាប្រធានលើអាចារ្យ របស់ពួកជនច្រើន នៃគ្នាយើង ឮថាព្រះសមណគោតម អស់កាមរាគហើយ ប្រាសចាកសេចក្តីស្រើបស្រាលហើយ នៃគ្នាយើង ឮថាព្រះសមណគោតម ជាកម្មវាទី ជាកិរិយវាទី ព្រះអង្គទ្រង់ធ្វើជម៌ដែលគ្មានបាបទុកជាខាងមុខ ក្នុងពួកព្រាហ្មណ៍និងពួកសត្វ នៃគ្នាយើង ឮថាព្រះសមណគោតម ចេញចាកត្រកូលដ៏ខ្ពង់ខ្ពស់ ជាត្រកូលក្សត្រិយ៍ មិនលាយឡំ ហើយមកទ្រង់ព្រះផ្នួស នៃគ្នាយើង ឮថាព្រះសមណ-គោតម ចេញចាកត្រកូលដ៏ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មកទ្រង់ព្រះផ្នួស នៃគ្នាយើង ឮថាពួកមនុស្សអ្នកនៅដែនក្រៅ

តិរោជនបថា សំបុច្ឆិតុំ អាគច្ឆន្តិ សមណំ ខលុ ភោ គោតមំ អនេកានិ ទេវតាសហស្សានិ បាណេហិ សរណំ គតានិ សមណំ ខលុ ភោ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ សមណោ ខលុ ភោ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ សមន្នាគតោ សមណំ ខលុ ភោ គោតមំ រាជា មាគធោ សេនិយោ ពិម្ពិសារោ សបុត្តទារោ បាណេហិ សរណំ គតោ សមណំ ខលុ ភោ គោតមំ រាជា បសេនទិ កោសលោ សបុត្តទារោ បាណេហិ សរណំ គតោ សមណំ ខលុ ភោ គោតមំ ព្រាហ្មណោ បោក្ខរសាតិ សបុត្តទារោ បាណេហិ សរណំ គតោ សមណោ ខលុ ភោ គោតមោ

អ្នកនៅជនបទក្រៅ តែងនាំគ្នាមកសាកសួរព្រះសមណគោតម នៃគ្នាយើង ឮថា ទេវតាច្រើនពាន់ បានដល់ព្រះសមណគោតម ជាទីពឹងស្មើដោយជីវិត នៃគ្នាយើង ឮថា កិត្តិសព្ទល្អនៃព្រះសមណគោតម ល្បីខ្ចរខ្ចាយសុសសាយទៅ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ប្រសើរបំផុត ជាសារថីទូន្មាននូវបុរស ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ បានត្រាស់ដឹងនូវចតុរារិយសច្ចធម៌ ទ្រង់លែងវិលមកកាន់ភពថ្មីទៀត នៃគ្នាយើង ឮថា ព្រះសមណគោតម ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ នៃគ្នាយើង ឮថា ព្រះបាទមាគធសេនិយពិម្ពិសារ ព្រមទាំងព្រះរាជបុត្រ ព្រះអគ្គមហេសី បានដល់ព្រះសមណគោតម ជាទីពឹងស្មើដោយជីវិត នៃគ្នាយើង ឮថា ព្រះបាទបសេនទិកោសល ព្រមទាំងព្រះរាជបុត្រ ព្រះអគ្គមហេសី បានដល់ព្រះសមណគោតមជាទីពឹងស្មើដោយជីវិត នៃគ្នាយើង ឮថា បោក្ខរសាតិព្រាហ្មណ៍ ព្រមទាំងបុត្រនិងភរិយា បានដល់ព្រះសមណ-គោតមជាទីពឹងស្មើដោយជីវិត នៃគ្នាយើង ឮថា ព្រះសមណគោតម

ព្រាហ្មណវគ្គស្ស ចង្កីសុត្តេ ភគវន្តវណ្ណកថា

ឱបាសាទំ អនុប្បត្តោ ឱបាសាទេ វិហរតិ ឧត្តរេន ឱបាសាទំ ទេវវនេ សាលវនេ យេ បន ខោ កេចិ សមណា វា ព្រាហ្មណា វា អម្ហាកំ គាមក្ខេត្តំ អាគច្ឆន្តិ អតិថិនោ តេ ហោន្តិ អតិថី ខោ បនម្ហេហិ សក្កាតព្វា គរុកាតព្វា មានេតព្វា បូជេតព្វា យម្បិ ភោ សមណោ គោតមោ ឱបាសាទំ អនុប្បត្តោ ឱបាសាទេ វិហរតិ ឧត្តរេន ឱបាសាទំ ទេវវនេ សាលវនេ អតិថិម្ហាកំ សមណោ គោតមោ អតិថិ ខោ បនម្ហេហិ សក្កាតព្វោ គរុកាតព្វោ មានេតព្វោ បូជេតព្វោ ឥមិនាបង្គេន ន អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ អថខោ មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ ឯត្តកំ ខោ អហំ ភោ តស្ស ភោតោ គោតមស្ស វណ្ណេ បរិយាបុណាមិ ន ច សោ ភវំ គោតមោ ឯត្តកវណ្ណោ អបរិមាណវណ្ណោ ហិ សោ ភវំ គោតមោ ឯកមេកេនបិ ភោ អង្គេន សមន្នាគតោ

ស្តេចមកដល់ឱបាសាទគ្រាមហើយ ឥឡូវនេះ គង់នៅក្នុងសាលវ័ន ជាទេវវ័ន ជាខាងជើងឱបាសាទគ្រាម ជិតឱបាសាទគ្រាម ពួកសមណៈ ឬព្រាហ្មណ៍ ណាមួយ ដែលមកដល់គាមក្ខេត្ត របស់យើងហើយ ពួកសមណព្រាហ្មណ៍ទាំងនោះ សុទ្ធតែជាភ្ញៀវ របស់យើង ភ្ញៀវហ្នឹងឯង ត្រូវតែយើងធ្វើសក្ការៈ គោរព រាប់អាន បូជា នៃគ្នាយើង ក៏ព្រះសមណគោតមនេះឯង ស្តេចមកដល់ ឱបាសាទគ្រាមហើយ ឥឡូវនេះ គង់ក្នុងសាលវ័នជាទេវវ័ន ជាខាងជើងឱបាសាទគ្រាម ជិតឱបាសាទគ្រាម ឯព្រះសមណគោតមជាភ្ញៀវរបស់យើង ភ្ញៀវហ្នឹងឯង ក៏ត្រូវតែយើងធ្វើសក្ការៈ គោរព រាប់អាន បូជា ដោយហេតុនេះហើយ បានជាមិនគួរឲ្យព្រះសមណគោតមដ៏ចម្រើននោះ ចូលមកចួបនឹងយើងឡើយ តាមពិតគួរតែពួកយើងចូលទៅគាល់ព្រះសមណគោតមដ៏ចម្រើននោះវិញ នៃគ្នាយើង ខ្ញុំដឹងគុណ (ដែលគួរសរសើរ) របស់ព្រះគោតម ដ៏ចម្រើននោះ ត្រឹមតែប៉ុណ្ណោះឯង តែព្រះគោតមដ៏ចម្រើននោះ មិនមែនមានគុណ ដែលគួរសរសើរ ត្រឹមតែប៉ុណ្ណោះទេ ព្រោះព្រះគោតមដ៏ចម្រើននោះ មានគុណនឹងរាប់នឹងប្រមាណពុំបាន នៃគ្នាយើង ព្រះគោតមដ៏ចម្រើននោះ ទោះបីព្រះអង្គប្រកប ដោយអង្គតែមួយ ៗ

ន អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ អថខោ មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុន្តិ[១] ។ តេនហិ ភោ សព្វេវ មយំ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សាមាតិ ។ អថខោ ចង្កី ព្រាហ្មណោ មហតា ព្រាហ្មណគណេន សទ្ធឹ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ តេន ខោ បន សមយេន ភគវា វុឌ្ឍេហិ វុឌ្ឍេហិ ព្រាហ្មណេហិ សទ្ធឹ កិញ្ចិ កិញ្ចិ កថំ សារាណីយំ វីតិសារេត្វា និសិន្នោ ហោតិ ។

[៦៨] តេន ខោ បន សមយេន កាបឋិកោ នាម[២] មាណវោ ទហរោ វុត្តសិរោ សោឡសវស្សុទ្ទេ-សិកោ ជាតិយា តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុ-កេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ

---

១ ឱ. ម. ឥតិសទ្ទោ ន ទិស្សតិ ។ ២ ឱ. កាបដ្ឋិកោ នាម ។ ម. កាបដិកោ នាម ។

ព្រះគោតមដ៏ចម្រើននោះ ក៏មិនគួរនឹងចូលមកចួបនឹងយើងទេ តាមពិតគួរតែពួកយើងចូលទៅចួបនឹងព្រះគោតមដ៏ចម្រើននោះវិញ ។ ពួកព្រាហ្មណ៍និយាយគ្នាថា នែគ្នាយើង បើដូច្នោះ ពួកយើងទាំងអស់គ្នានឹងនាំគ្នាចូលទៅគាល់ព្រះសមណគោតម ។ ទើបចង្កីព្រាហ្មណ៍ ព្រមទាំងពួកព្រាហ្មណ៍ច្រើននាក់ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ពោលពាក្យណាមួយ ទៅរកពួកព្រាហ្មណ៍ចាស់ ៗ លុះបញ្ចប់ពាក្យដែលគួររលឹកហើយ ក៏ទ្រង់គង់ ។

[៦៨] សម័យនោះឯង មានមាណពកំលោះម្នាក់ ឈ្មោះកាបទិកៈ មានក្បាលកោរ មានអាយុប្រមាណ ១៦ ឆ្នាំ អំពីកំណើត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគម្រប់ ៥

បជកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខ-ណេសុ អនវយោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ សោ វុឌ្ឍានំ វុឌ្ឍានំ ព្រាហ្មណានំ ភគវតា សទ្ធឹ មន្តយមានានំ អន្តរន្តរា កថំ ឱបាតេតិ ។ អថខោ ភគវា កាបដិកំ មាណវំ អប្បសាទេសិ មា អាយស្មា ភារទ្វាជោ វុឌ្ឍានំ វុឌ្ឍានំ ព្រាហ្មណានំ មន្តយមានានំ អន្តរន្តរា កថំ ឱបាតេសិ(១) កថាបរិយោសានំ អា-យស្មា ភារទ្វាជោ អាគមេតូតិ ។

[៦៩] ឯវំ វុត្តេ ចង្កី ព្រាហ្មណោ ភគវន្តំ ឯតទវោច មា ភវំ គោតមោ កាបដិកំ មាណវំ អប្បសាទេសិ កុលបុត្តោ ច កាបដិកោ មាណវោ ពហុស្សុតោ ច កាបដិកោ មាណវោ បណ្ឌិតោ ច កាបដិកោ មាណវោ កល្យាណវាក្ករណោ ច កាបដិកោ មាណ-វោ បហោតិ ច កាបដិកោ មាណវោ ភោតា គោតមេន សទ្ធឹ អស្មឹ វចនេ បតិមន្តេតុន្តិ ។ អថខោ ភគវតោ

១ ឱ. ឱបាតេតុ ។ ម. ឱបាតេហិ ។

ជាអ្នកស្គាល់ នូវបទនិងវេយ្យាករណ៍ ជាអ្នកមិនខ្ពះថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ អង្គុយនៅក្នុងប្រជុំបរិស័ទនោះ ។ មាណពនោះ ក៏និយាយស្កាត់សំដីរបស់ពួកព្រាហ្មណ៍ចាស់ ៗ ដែលកំពុងតែប្រឹក្សា ទៅរកព្រះមានព្រះភាគ ។ ទើបព្រះមានព្រះភាគ ទ្រង់ឃាត់កាបទិកមាណពថា ភារទ្វាជៈមានអាយុ កុំនិយាយស្កាត់សំដី របស់ពួកព្រាហ្មណ៍ចាស់ ៗ ដែលកំពុងតែប្រឹក្សាឡើយ ភារទ្វាជៈមានអាយុ ចូរបង្អង់ចាំឲ្យចប់សំដីគេសិន ។

[៦៩] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ចង្កីព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា ព្រះគោតមដ៏ចម្រើន កុំឃាត់កាបទិកមាណពឡើយ ដ្បិតកាបទិកមាណព ជាកុលបុត្រផង ជាពហុស្សូតផង កាបទិកមាណព ជាបណ្ឌិតផង កាបទិកមាណព ជាអ្នកនិយាយពាក្យពីរោះផង កាបទិកមាណព អាចនឹងប្រឹក្សាក្នុងពាក្យនោះ ជាមួយនឹងព្រះគោតមដ៏ចម្រើនបានផង ។ ទើបព្រះ

ឯតទហោសិ អទ្ធា ខោ កាបដិកស្ស មាណវស្ស តេវិជ្ជកេ បាវចនេ កតំ ភវិស្សតិ តថា ហិ នំ ព្រាហ្មណា សំបុរេក្ខរោន្តីតិ ។ អថខោ កាបដិកស្ស មាណវស្ស ឯតទហោសិ យទា មេ សមណោ គោតមោ ចក្ខុនា ចក្ខុំ ឧបសំហរិស្សតិ អថាហំ សមណំ គោតមំ បញ្ហំ បុច្ឆិស្សាមីតិ ។ អថខោ ភគវា កាបដិកស្ស មាណវស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ យេន កាបដិកោ មាណវោ តេន ចក្ខូនិ ឧបសំហាសិ ។ អថខោ កាបដិកស្ស មាណវស្ស ឯតទហោសិ សមន្នាហរតិ ខោ មំ សមណោ គោតមោ យន្នូនាហំ សមណំ គោតមំ បញ្ហំ បុច្ឆេយ្យន្តិ ។ អថខោ កាបដិកោ មាណវោ ភគវន្តំ ឯតទវោច យមិទំ ភោ គោតម ព្រាហ្មណានំ បោរាណំ មន្តបទំ ឥតិហីតិហបរម្បរាយ បិដកសម្ប-ទាយ តត្ថ ច ព្រាហ្មណា ឯកំសេន និដ្ឋំ គច្ឆន្តិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥធ ភវំ គោតមោ កិមាហាតិ ។

មានដោគ មានព្រះតម្រិះយ៉ាងនេះថា កាបទិកមាណព មុខជានឹងបាន សម្រេចត្រៃវិជ្ជា ក្នុងព្រះពុទ្ធសាសនាដោយពិត ព្រោះហេតុនោះបាន ជាពួកព្រាហ្មណ៍ លើកកាបទិកមាណពនោះជាត្រីមុខ ។ គ្រានោះ កាបទិកមាណព មានសេចក្ដីត្រិះរិះ យ៉ាងនេះថា កាលណាបើព្រះ សមណគោតម ទ្រង់ឆ្មៀងព្រះនេត្រមកចំភ្នែករបស់អញ អញនឹងសួរ ប្រស្នាចំពោះព្រះសមណគោតម ក្នុងកាលនោះ ។ លំដាប់នោះ ព្រះ មានព្រះភាគ ទ្រង់ជ្រាបនូវបរិវិតក្កៈក្នុងចិត្តរបស់កាបទិកមាណពដោយ ព្រះហឫទ័យរបស់ព្រះអង្គហើយ ទើបឆ្មៀងព្រះនេត្រចំពោះទៅរកកាប- ទិកមាណព ។ គ្រានោះ កាបទិកមាណព មានសេចក្ដីត្រិះរិះយ៉ាង នេះថា ព្រះសមណគោតម មើលមកអញហើយតើ បើដូច្នោះមាន តែអញសួរប្រស្នាចំពោះព្រះសមណគោតម ។ លំដាប់នោះ កាបទិក- មាណព ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតម ដ៏ចម្រើន បទមន្តចាស់របស់ពួកព្រាហ្មណ៍ដែលប្រកាន់ត ៗ គ្នាថាដូច្នេះ ៗ ប្រកាន់តាមក្បួន ក៏បណ្ដាពួកព្រាហ្មណ៍ទាំងនោះ ពួកព្រាហ្មណ៍ដែល ដល់នូវសេចក្ដីចូលចិត្តដោយចំណែកមួយថា ពាក្យនេះពិត ឯពាក្យ ដទៃជាមោឃៈ ក្នុងសេចក្ដីនេះ ព្រះគោតមដ៏ចម្រើន ទ្រង់សំដែងថា ដូចម្ដេចទៅវិញ ។

[៧០] កឹ បន ភារទ្វាជ អត្ថិ កោចិ ព្រាហ្មណានំ ឯកព្រាហ្មណោបិ យោ ឯវមាហ អហមេតំ ជានាមិ អហមេតំ បស្សាមិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ នោ ហិទំ ភោ គោតម ។ កឹ បន ភារទ្វាជ អត្ថិ កោចិ ព្រាហ្មណានំ ឯកាចរិយោបិ ឯកាចរិយប្បាចរិយោបិ យាវ សត្តមា អាចរិយមហាយុគា[១] យោ ឯវមាហ អហមេតំ ជានាមិ អហមេតំ បស្សាមិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ នោ ហិទំ ភោ គោតម ។ កឹ បន ភារទ្វាជ យេបិ តេ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ

១ ឱ. ម. បិសទ្ទោ ទិស្សតិ ។

[៧០] ព្រះមានព្រះភាគត្រាស់ថា ម្នាលភារទ្វាជៈ ចុះបណ្តាព្រាហ្មណ៍ទាំងឡាយ មានព្រាហ្មណ៍ណាខ្លះ សូម្បីតែម្នាក់ ពោលយ៉ាងនេះថា អញដឹងហេតុនេះ អញឃើញហេតុនេះ ពាក្យនេះពិត ឯពាក្យដទៃជាមោឃៈ ដូច្នេះមានដែរឬទេ ។ កាបទិកមាណព ឆ្លើយថា បពិត្រព្រះគោតម ដ៏ចម្រើន ពុំមានទេ ។ ម្នាលភារទ្វាជៈ ចុះបណ្តាព្រាហ្មណ៍ទាំងឡាយ ព្រាហ្មណ៍ខ្លះ មានអាចារ្យជាមួយគ្នាផង ជាប្រធានលើអាចារ្យជាមួយគ្នាផង តាំងអំពីគូនៃអាចារ្យជាគម្រប់ ៧ មក ពោលយ៉ាងនេះថា អញដឹងហេតុនេះ អញឃើញហេតុនេះ ពាក្យនេះពិត ឯពាក្យដទៃជាមោឃៈ ដូច្នេះមានដែរឬទេ ។ បពិត្រព្រះគោតម ដ៏ចម្រើន ពុំមានទេ ។ ម្នាលភារទ្វាជៈ ចុះបណ្តាព្រាហ្មណ៍ទាំងឡាយ មានពួកព្រាហ្មណ៍ណា ជាឥសីមានក្នុងជាន់មុន ជាអ្នកតាក់តែងនូវមន្ត្រ អ្នកពោលនូវមន្ត្រ បទនៃមន្ត្រចាស់នេះ ដែលពួកព្រាហ្មណ៍ណា បានសូត្រហើយ បានពោលហើយ បានតាំងទុកហើយ ឥឡូវនេះ ពួកព្រាហ្មណ៍ សូត្រតាមមន្ត្រនោះ ពោលតាមមន្ត្រនោះ ពោលតាមមន្ត្រដែលគេពោលហើយ បង្រៀនមន្ត្រដែលគេបង្រៀនហើយ ពួកឥសីទាំងនោះ គឺឥសីឈ្មោះ អដ្ឋកៈ ឈ្មោះវាមកៈ

វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ តេបិ ឯវមាហំសុ មយមេតំ ជានាម មយមេតំ បស្សាម ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ នោ ហិទំ ភោ គោតម ។

[៧១] ឥតិ កិរ ភារទ្វាជ នត្ថិ កោចិ ព្រាហ្មណានំ ឯកព្រាហ្មណោបិ យោ ឯវមាហ អហមេតំ ជានាមិ អហមេតំ បស្សាមិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ នត្ថិ កោចិ ព្រាហ្មណានំ ឯកាចរិយោបិ ឯកាចរិយប្បាចរិយោបិ យាវ សត្តមា អាចរិយមហយុគា យោ ឯវមាហ អហមេតំ ជានាមិ អហមេតំ បស្សាមិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ យេបិ តេ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ

ឈ្មោះវាមទេវៈ ឈ្មោះវេស្សាមិត្តៈ ឈ្មោះយមតគ្គិ ឈ្មោះអង្គីរសៈ ឈ្មោះភារទ្វាជៈ ឈ្មោះវាសេដ្ឋៈ ឈ្មោះកស្សបៈ ឈ្មោះភគុ ក៏ពួកឥសីទាំងនោះ ពោលយ៉ាងនេះថា យើងទាំងឡាយ ដឹងហេតុនេះ យើងទាំងឡាយឃើញហេតុនេះ ពាក្យនេះពិត ឯពាក្យដទៃជាមោឃៈ ដូច្នេះមានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពុំមានទេ ។

[៧១] ព្រះភគវន្តមុនីនាថទ្រង់ត្រាស់ថា ម្នាលភារទ្វាជៈ បានឮមកថា បណ្តាព្រាហ្មណ៍ទាំងឡាយ មិនមានព្រាហ្មណ៍ណាមួយ សូម្បីតែម្នាក់ ពោលយ៉ាងនេះថា អញដឹងហេតុនេះ អញឃើញហេតុនេះ ពាក្យនេះពិត ឯពាក្យដទៃ ជាមោឃៈ បណ្តាព្រាហ្មណ៍ទាំងឡាយ មិនមានព្រាហ្មណ៍ណាមួយ ដែលមានអាចារ្យជាមួយគ្នា ឬមានអាចារ្យជាប្រធានលើអាចារ្យជាមួយគ្នា ដរាបតាំងអំពីគូអាចារ្យជាគម្រប់ ៧ មក ពោលយ៉ាងនេះថា អញដឹងហេតុនេះ អញឃើញហេតុនេះ ពាក្យនេះពិត ឯពាក្យដទៃជាមោឃៈ បណ្តាព្រាហ្មណ៍ទាំងឡាយ ពួកព្រាហ្មណ៍ដែលជាឥសី មានក្នុងជាន់មុន ជាអ្នកតាក់តែងមន្ត អ្នកពោលមន្ត បទនៃមន្តចាស់នេះ ដែលពួកឥសីណា បានសូត្រហើយ បានពោលហើយ បានតាំងទុកហើយ ឥឡូវនេះ ពួកព្រាហ្មណ៍

# ១៣១



តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ តេបិ ន ឯវមាហំសុ មយមេតំ ជានាម មយមេតំ បស្សាម ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សេយ្យថាបិ ភារទ្វាជ អន្ធវេណិ បរម្បរាសំសត្តា បុរិមោបិ ន បស្សតិ មជ្ឈិមោបិ ន បស្សតិ បច្ឆិមោបិ ន បស្សតិ ឯវមេវ ខោ ភារទ្វាជ អន្ធវេណូបមំ មញ្ញេ ព្រាហ្មណានំ ភាសិតំ សម្បជ្ជតិ បុរិមោបិ ន បស្សតិ មជ្ឈិមោបិ ន បស្សតិ បច្ឆិមោបិ ន បស្សតិ តំ កឹ មញ្ញសិ ភារទ្វាជ ននុ ឯវំ សន្តេ ព្រាហ្មណានំ អមូលិកា សទ្ធា សម្បជ្ជតីតិ ។ ន ខ្វេត្ថ[១] ភោ គោតម ព្រាហ្មណា សទ្ធាយេវ បយិរុបាសន្តិ អនុស្សវាបេត្ថ ព្រាហ្មណា បយិរុបាសន្តីតិ ។

---

១ ឱ. ន ខោត្ថ ។

បានសូត្រតាមមន្តនោះ បានពោលតាមមន្តនោះ បានពោលតាមមន្តដែលគេពោលហើយ បានបង្រៀនមន្តដែលគេបង្រៀនហើយ ពួកឥសីទាំងនោះ គឺឥសីឈ្មោះអដ្ឋកៈ ឈ្មោះវាមកៈ ឈ្មោះវាមទេវៈ ឈ្មោះវេស្សាមិត្តៈ ឈ្មោះយមតគ្គិ ឈ្មោះអង្គីរសៈ ឈ្មោះភារទ្វាជៈ ឈ្មោះវាសេដ្ឋៈ ឈ្មោះកស្សបៈ ឈ្មោះភគុ ក៏ពួកឥសីទាំងនោះ មិនពោលថា យើងទាំងឡាយដឹងហេតុនេះ យើងទាំងឡាយឃើញហេតុនេះ ពាក្យនេះពិត ឯពាក្យដទៃជាមោឃៈ ។ ម្នាលភារទ្វាជៈ ដូចបុរសខ្វាក់ទាំងជួរដែលជាប់ត ៗ គ្នា បុរសដែលដើរមុន ក៏មើលមិនឃើញ បុរសដែលដើរកណ្តាលក៏មើលមិនឃើញ បុរសដែលដើរក្រោយ ក៏មើលមិនឃើញ យ៉ាងណាមិញ ម្នាលភារទ្វាជៈ ភាសិតរបស់ពួកព្រាហ្មណ៍ក៏មានទំនងដូចបុរសខ្វាក់ទាំងជួរ បុរសដែលដើរមុន ក៏មើលមិនឃើញ បុរសដែលដើរកណ្តាល ក៏មើលមិនឃើញ បុរសដែលក្រោយក៏មើលមិនឃើញ យ៉ាងនោះដែរ ម្នាលភារទ្វាជៈ អ្នកយល់សេចក្តីនោះដូចម្តេច កាលបើយ៉ាងនេះ តើសទ្ធាដែលគ្មានឫសគល់របស់ពួកព្រាហ្មណ៍សម្រេចបានដែរឬ ។ កាបទិកមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន សម្រេចមិនបានទេ ពួកព្រាហ្មណ៍តែងចូលទៅអង្គុយជិតដោយសទ្ធា ពួកព្រាហ្មណ៍តែងចូលទៅអង្គុយជិតដោយការស្តាប់ត ៗ គ្នាមក ។

[៧២] បុព្វេ ខោ ត្វំ ភារទ្វាជ សទ្ធំ អគ-
មាសិ អនុស្សវំ ឥទានិ វទេសិ បញ្ច ខោ ឥមេ
ភារទ្វាជ ធម្មា ទិដ្ឋេវ ធម្មេ ទ្វិធាវិបាកា កតមេ
បញ្ច សទ្ធា រុចិ អនុស្សវោ អាការបរិវិតក្កោ ទិដ្ឋិ-
និជ្ឈានក្ខន្តិ ឥមេ ខោ ភារទ្វាជ បញ្ច ធម្មា ទិដ្ឋេវ
ធម្មេ ទ្វិធាវិបាកា អបិច ភារទ្វាជ សុសទ្ទ-
ហិតំយេវ ហោតិ តញ្ច ហោតិ រិត្តំ តុច្ឆំ មុសា
ធោ ចេបិ សុសទ្ទហិតំ ហោតិ តញ្ច ហោតិ ភូតំ
តច្ឆំ អនញ្ញថា អបិច ភារទ្វាជ សុរុចិតំយេវ ហោតិ
។ បេ ។ ស្វានុស្សុតំយេវ ហោតិ ។ បេ ។ សុបរិវិ-
តក្កិតំយេវ ហោតិ ។ បេ ។ សុនិជ្ឈាយិតំយេវ ហោតិ
តញ្ច ហោតិ រិត្តំ តុច្ឆំ មុសា ធោ ចេបិ សុនិជ្ឈា-
យិតំ ហោតិ តញ្ច ហោតិ ភូតំ តច្ឆំ អនញ្ញថា
សច្ចំ អនុរក្ខតា ភារទ្វាជ វិញ្ញុនា បុរិសេន នាល-

[៧២] ព្រះបរមគ្រូទ្រង់ត្រាស់ថា ម្នាលភារទ្វាជៈ កាលពីមុន អ្នកជាជឿ ឥឡូវនេះ អ្នកជាឮតាមគេ ម្នាលភារទ្វាជៈ ធម៌ទាំង ៥ យ៉ាងនេះ មានវិបាក ២ យ៉ាង ក្នុងបច្ចុប្បន្ន ធម៌ទាំង ៥ យ៉ាងតើដូចម្តេច ធម៌ទាំង ៥ យ៉ាងគឺ សេចក្តីជឿ ១ សេចក្តីគាប់ចិត្ត ១ ការឮតាមគ្នា ១ ការត្រិះរិះនូវអាការ ១ សេចក្តីចូលចិត្តតាមការយល់ ១ ម្នាលភារទ្វាជៈ ធម៌ទាំង ៥ នេះឯង មានវិបាក ២ យ៉ាង ក្នុងបច្ចុប្បន្ន ម្នាលភារទ្វាជៈ គឺហេតុណា ដែលបុគ្គលជឿស៊ប់ តែហេតុនោះ ជាហេតុសោះសូន្យ ទទេ កុហកសោះក៏មាន ហេតុណា ដែលបុគ្គលមិនជឿស៊ប់ទេ តែហេតុនោះ ជាហេតុពិត ប្រាកដ មិនមែនជាដទៃក៏មាន ម្នាលភារទ្វាជៈ មួយទៀត ហេតុណា ដែលបុគ្គលគាប់ចិត្តស៊ប់ ។ បេ ។ ពាក្យណា ដែលបុគ្គលឮច្បាស់តាមគ្នា ។ បេ ។ ហេតុណា ដែលបុគ្គលត្រិះរិះឃើញជាក់ ។ បេ ។ ហេតុណា ដែលបុគ្គលចូលចិត្តស៊ប់ តែហេតុនោះ ជាហេតុសោះសូន្យ ទទេ កុហកសោះក៏មាន ហេតុណាដែលបុគ្គលមិនចូលចិត្តស៊ប់ទេ តែហេតុនោះជាហេតុពិត ប្រាកដ មិនមែនជាដទៃក៏មាន ម្នាលភារទ្វាជៈ បុរសជាអ្នកប្រាជ្ញ អ្នករក្សាសច្ចៈ មិនគួរ

មេត្ថ ឯកំសេន និដ្ឋំ គន្តុំ ឥទមេវ សច្ចំ មោឃ-មញ្ញន្តិ ។ កិត្តាវតា បន ភោ គោតម សច្ចានុរក្ខណា ហោតិ កិត្តាវតា សច្ចមនុរក្ខតិ សច្ចានុរក្ខណំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។

[៧៣] សទ្ធា ចេបិ ភារទ្វាជ បុរិសស្ស ហោតិ ឯវំ មេ សទ្ធាតិ ឥតិ វទំ(១) សច្ចមនុរក្ខតិ ន ត្វេវ តាវ ឯកំសេន និដ្ឋំ គច្ឆតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯត្តាវតា ខោ ភារទ្វាជ សច្ចមនុរក្ខណា ហោតិ ឯត្តាវតា សច្ចមនុរក្ខតិ ឯត្តាវតា ច មយំ សច្ចានុរក្ខណំ បញ្ញាបេម ន ត្វេវ តាវ សច្ចានុពោធោ ហោតិ រុចិ ចេបិ ភារទ្វាជ បុរិសស្ស ហោតិ...

១ ម. ឯវមេវ សិជ្ឈតីតិ ឥតិ វាតន្តិ ទិស្សន្តិ ។

ចូលចិត្តដោយដាច់ខាត ក្នុងហេតុនេះថា ពាក្យនេះពិត ពាក្យដទៃជាមោឃៈ ដូច្នេះឡើយ ។ កាបទិកមាណពក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ចុះការរក្សាសច្ចៈតើត្រឹមប៉ុន្មាន បុគ្គលរក្សាសច្ចៈតើត្រឹមប៉ុន្មាន យើងខ្ញុំព្រះអង្គ សូមសួរចំពោះការរក្សាសច្ចៈ នឹងព្រះគោតមដ៏ចម្រើន ។

[៧៣] ព្រះលោកនាថត្រាស់ថា ម្នាលភារទ្វាជៈ បើបុរសមានជំនឿថា ជំនឿរបស់អញយ៉ាងនេះ កាលដែលនិយាយតាមគំនិតដូច្នេះ ឈ្មោះថារក្សាសច្ចៈ តែមិនទាន់ដល់នូវសេចក្តីចូលចិត្ត ដោយដាច់ខាតថា ពាក្យនេះពិត ពាក្យដទៃជាមោឃៈ ត្រឹមប៉ុណ្ណោះឡើយ ម្នាលភារទ្វាជៈ ការរក្សាសច្ចៈត្រឹមប៉ុណ្ណោះ បុគ្គលរក្សាសច្ចៈត្រឹមប៉ុណ្ណោះ យើងក៏បញ្ញត្តការរក្សាសច្ចៈត្រឹមប៉ុណ្ណោះ តែការត្រាស់ដឹងសច្ចៈមិនទាន់មានដល់បុរសនោះនៅឡើយទេ ម្នាលភារទ្វាជៈ បើបុរសមានសេចក្តីគាប់ចិត្ត...

អនុស្សវោ ចេបិ ភារទ្វាជ បុរិសស្ស ហោតិ... អាការបរិវិតក្កោ ចេបិ ភារទ្វាជ បុរិសស្ស ហោតិ... ទិដ្ឋិនិជ្ឈានក្ខន្តិ ចេបិ ភារទ្វាជ បុរិសស្ស ហោតិ ឯវំ មេ[១] ទិដ្ឋិនិជ្ឈានក្ខន្តីតិ ឥតិ វទំ[២] សច្ចមនុរក្ខតិ ន ត្វេវ តាវ ឯកំសេន និដ្ឋំ គច្ឆតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯត្តាវតា ខោ ភារទ្វាជ សច្ចមនុរក្ខណា ហោតិ ឯត្តាវតា សច្ចមនុរក្ខតិ ឯត្តាវតា ច មយំ សច្ចានុរក្ខណំ បញ្ញាបេម ន ត្វេវ តាវ សច្ចានុពោធោ ហោតីតិ ។ ឯត្តាវតា ភោ គោតម សច្ចមនុរក្ខណា ហោតិ ឯត្តាវតា សច្ចមនុរក្ខតិ ឯត្តាវតា ច មយំ សច្ចានុរក្ខណំ បញ្ញាបេម កិត្តាវតា បន ភោ គោតម សច្ចានុពោធោ ហោតិ កិត្តាវតា សច្ចមនុពុជ្ឈតិ សច្ចានុពោធំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។

[៧៤] ឥធ កិរ ភារទ្វាជ ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ ។ តមេវ[៣] គហបតិ វា គហបតិបុត្តោ វា ឧបសង្កមិត្វា

១ ម. ឯវមេវ ។ ២ ម. វាតំ ។ ៣ ឱ. ម. តមេនំ ។

ម្នាលភារទ្វាជៈ បើបុរសមានការឮតាម ៗ គ្នា... ម្នាលភារទ្វាជៈ បើបុរសមានសេចក្តីត្រិះរិះនូវអាការ... ម្នាលភារទ្វាជៈ បើបុរសមានសេចក្តីចូលចិត្តដោយការយល់ថា សេចក្តីចូលចិត្ត តាមការយល់របស់អញយ៉ាងនេះ កាលបើនិយាយតាមសេចក្តីចូលចិត្ត ដោយការយល់ដូច្នេះ ឈ្មោះថារក្សាសច្ចៈ តែមិនទាន់ដល់នូវសេចក្តីចូលចិត្តដោយដាច់ខាតថា ពាក្យនេះពិត ឯពាក្យដទៃជាមោឃៈ ត្រឹមប៉ុណ្ណោះឡើយ ម្នាលភារទ្វាជៈ ការរក្សាសច្ចៈត្រឹមប៉ុណ្ណោះ បុគ្គលរក្សាសច្ចៈត្រឹមតែប៉ុណ្ណោះ យើងក៏បញ្ញត្តការរក្សាសច្ចៈត្រឹមប៉ុណ្ណោះ តែការត្រាស់ដឹងសច្ចៈ មិនទាន់មានដល់បុរសនោះនៅឡើយទេ ។ កាបទិកមាណព ក្រាបបង្គំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន ការរក្សាសច្ចៈត្រឹមប៉ុណ្ណោះ បុគ្គលរក្សាសច្ចៈត្រឹមប៉ុណ្ណោះ យើងខ្ញុំទាំងឡាយ ក៏បញ្ញត្តការរក្សាសច្ចៈត្រឹមប៉ុណ្ណោះដែរ បពិត្រព្រះគោតមដ៏ចម្រើន ចុះការត្រាស់ដឹងសច្ចៈត្រឹមប៉ុន្មាន បុគ្គលត្រាស់ដឹងសច្ចៈត្រឹមប៉ុន្មាន យើងខ្ញុំសូមសួរ ចំពោះការត្រាស់ដឹងសច្ចៈ នឹងព្រះគោតមដ៏ចម្រើន ។

[៧៤] ព្រះមានព្រះភាគត្រាស់ថា ម្នាលភារទ្វាជៈ មានសេចក្តីដំណាលថា ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនូវស្រុក ឬនិគមណាមួយ ។ គហបតីក្តី កូនគហបតីក្តី ចូលទៅរកភិក្ខុនោះឯង

តីសុ ធម្មេសុ សមន្នេសតិ លោភនីយេសុ ធម្មេសុ ទោសនីយេសុ ធម្មេសុ មោហនីយេសុ ធម្មេសុ អត្ថិ នុ ខោ ឥមស្ស អាយស្មតោ តថារូបា លោភនីយា ធម្មា យថារូបេហិ លោភនីយេហិ ធម្មេហិ បរិយាទិន្នចិត្តោ អជានំ វា វទេយ្យ ជានាមីតិ អបស្សំ វា វទេយ្យ បស្សាមីតិ បរំ វា តថត្តាយ សមាទបេយ្យ យំ បរេសំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ នត្ថិ ខោ ឥមស្សាយស្មតោ តថារូបា លោភនីយា ធម្មា យថារូបេហិ លោភនីយេហិ ធម្មេហិ បរិយាទិន្នចិត្តោ អជានំ វា វទេយ្យ ជានាមីតិ អបស្សំ វា វទេយ្យ បស្សាមីតិ បរំ វា តថត្តាយ សមាទបេយ្យ យំ បរេសំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ តថា(១) ខោ បនិមស្សាយស្មតោ កាយសមាចារោ តថា(២) វចីសមាចារោ យថាតំ អលុទ្ធស្ស

១-២ ម. តថារូបោ ។

ល្បងមើលក្នុងធម៌ទាំងឡាយ ៣ ប្រការ គឺធម៌ជាទីតាំងនៃលោភៈ ធម៌ជាទីតាំងនៃទោសៈ ធម៌ជាទីតាំងនៃមោហៈ ដោយគំនិតថា បុគ្គលមានចិត្ត ដែលធម៌ជាទីតាំងនៃលោភៈ មានសភាពយ៉ាងណា គ្របសង្កត់ហើយមិនដឹង និយាយថា អាត្មាអញដឹង ឬមិនឃើញ និយាយថា អាត្មាអញឃើញ ឬក៏ហេតុណាដែលប្រព្រឹត្តទៅ ដើម្បីកម្មមិនមែនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរ ដល់បុគ្គលទាំងឡាយដទៃ ក៏បបួលនូវបុគ្គលដទៃ ដើម្បីហេតុនោះ ធម៌ទាំងឡាយដែលជាទីតាំងនៃសេចក្តីលោភ មានសភាពដូច្នោះ តើមានដល់លោកមានអាយុនេះដែរឬហ្ន៎ ។ កាលគហបតី ឬកូនគហបតី ល្បងមើលភិក្ខុនោះ ក៏ដឹងយ៉ាងនេះថា បុគ្គលមានចិត្តដែលធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីលោភ មានសភាពយ៉ាងណាគ្របសង្កត់ហើយ មិនដឹង និយាយថា អាត្មាអញដឹង ឬមិនឃើញ និយាយថា អាត្មាអញឃើញ ឬក៏ហេតុណា ដែលប្រព្រឹត្តទៅ ដើម្បីកម្មមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរ ដល់បុគ្គលទាំងឡាយដទៃ ក៏បបួលនូវបុគ្គលដទៃ ដើម្បីហេតុនោះ ធម៌ទាំងឡាយជាទីតាំងនៃសេចក្តីលោភ មានសភាពដូច្នោះ មិនមានដល់លោកមានអាយុនេះទេ ។ កាយសមាចារ និងវចីសមាចារ របស់លោកមានអាយុនេះ ក៏ដូចជារបស់អ្នកដែលមិនលោភដែរ

យំ ខោ បន អយមាយស្មា ធម្មំ ទេសេតិ គម្ភីរោ សោ ធម្មោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ ធម្មោ និបុណោ បណ្ឌិតវេទនីយោ ន សោ សុទេសិយោ[១] លុទ្ធជាតិ ។ យតោ នំ សមន្វេសមានោ វិសុទ្ធំ លោភនីយេហិ ធម្មេហិ បស្សតិ សមនុបស្សតិ តតោ នំ ឧត្តរឹ សមន្វេសតិ ទោសនីយេសុ ធម្មេសុ អត្ថិ នុ ខោ ឥមស្សាយស្មតោ តថារូបា ទោសនីយា ធម្មា យថារូបេហិ ទោសនីយេហិ ធម្មេហិ បរិយាទិន្នចិត្តោ អជានំ វា វទេយ្យ ជានាមីតិ អបស្សំ វា វទេយ្យ បស្សាមីតិ បរំ វា តថត្តាយ សមាទបេយ្យ យំ បរេសំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ តមេនំ សមន្វេសមានោ ឯវំ ជានាតិ នត្ថិ ខោ ឥមស្សាយស្មតោ តថារូបា ទោសនីយា ធម្មា យថារូបេហិ ទោសនីយេហិ ធម្មេហិ បរិយាទិន្នចិត្តោ អជានំ វា វទេយ្យ

១ ម. សុទេសនីយោ ។

បើលោកមានអាយុនេះ សំដែងធម៌ណា ធម៌នោះជ្រៅ ឃើញបាន ដោយក្រ ត្រាស់ដឹងបានដោយក្រ ជាធម៌ស្ងប់ ជាធម៌ឧត្តម ជាធម៌ ដែលគេស្ទង់មើលដោយការត្រិះរិះពុំបាន ជាធម៌ល្អិត មានតែអ្នកប្រាជ្ញ ទើបដឹងបាន ធម៌នោះបុគ្គលអ្នកមានសេចក្ដីលោភ មិនងាយសំដែងបាន ឡើយ ។ កាលគហបតី ឬកូនគហបតី ល្បងមើលភិក្ខុនោះ បានឃើញ ច្បាស់ថា ជាអ្នកបរិសុទ្ធចាកធម៌ទាំងឡាយដែលជាទីតាំងនៃលោភៈ ដោយ ហេតុណាហើយ ក៏ល្បងមើលភិក្ខុនោះក្នុងធម៌ដែលជាទីតាំងនៃទោសៈ ឲ្យក្រៃលែងជាងហេតុនោះ តទៅទៀតថា បុគ្គលមានចិត្តដែលធម៌ជាទី តាំងនៃទោសៈមានសភាពយ៉ាងណាគ្របសង្កត់ហើយ មិនដឹង និយាយ ថាអាត្មាអញដឹង ឬមិនឃើញ និយាយថា អាត្មាអញឃើញ ឬក៏ហេតុ ណាដែលប្រព្រឹត្តទៅដើម្បីកម្មមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ អស់ កាលយូរ ដល់ជនទាំងឡាយដទៃ ក៏បបួលនូវបុគ្គលដទៃដើម្បីហេតុនោះ ពួកធម៌ដែលជាទីតាំងនៃទោសៈ មានសភាពដូច្នោះ មានដល់លោក មានអាយុនេះ ដែរឬហ្ន៎ ។ កាលគហបតី ឬកូនគហបតី ល្បងមើល ភិក្ខុនោះ ក៏ដឹងយ៉ាងនេះថា បុគ្គលមានចិត្តដែលពួកធម៌ជាទីតាំងនៃ ទោសៈ មានសភាពយ៉ាងណាគ្របសង្កត់ហើយ មិនដឹង និយាយថា

១៣៧



ជានាមីតិ អបស្សំ វា វទេយ្យ បស្សាមីតិ បរំ វា តទត្ថាយ សមាទបេយ្យ យំ បរេសំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ តថា ខោ បនិមស្សា-យស្មតោ កាយសមាចារោ តថា វចីសមាចារោ យថាតំ អទុដ្ឋស្ស យំ ខោ បន អយមាយស្មា ធម្មំ ទេសេតិ គម្ភីរោ សោ ធម្មោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ ន សោ ធម្មោ សុទេសិយោ ទុដ្ឋេនាតិ ។ យតោ នំ សមន្នេសមានោ វិសុទ្ធំ មោហនីយេហិ ធម្មេហិ បស្សតិ សមនុបស្សតិ

អាត្មាអញដឹង ឬមិនឃើញ និយាយថា អាត្មាអញឃើញ ឬក៏ហេតុណា ដែលប្រព្រឹត្តទៅ ដើម្បីកម្មមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលយូរ ដល់ជនទាំងឡាយដទៃ ក៏បបួលជនដទៃ ដើម្បីហេតុនោះ ពួកធម៌ដែលជាទីតាំងនៃទោសៈ មានសភាពដូច្នោះ មិនមានដល់លោកមានអាយុនេះឡើយ ។ កាយសមាចារនិងវចីសមាចារ របស់លោកមានអាយុនេះ ក៏ដូចជារបស់អ្នកដែលមិនមានទោសៈដែរ បើលោកមានអាយុនេះ សំដែងធម៌ណា ធម៌នោះជ្រៅ ឃើញបានដោយក្រ ត្រាស់ដឹងបានដោយក្រ ជាធម៌ស្ងប់ ជាធម៌ឧត្ដម ជាធម៌ដែលគេស្ទង់មើលដោយការត្រិះរិះពុំបាន ជាធម៌ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ធម៌នោះបុគ្គលអ្នកមានទោសៈមិនងាយសំដែងបានឡើយ ។ កាលគហបតី ឬកូនគហបតី ល្បងមើលភិក្ខុនោះបានឃើញច្បាស់ថា ជាអ្នកបរិសុទ្ធចាកធម៌ទាំងឡាយដែលជាទីតាំងនៃទោសៈ ដោយហេតុណាហើយ

តតោ នំ ឧត្តរឹ សមន្នេសតិ មោហនីយេសុ ធម្មេសុ អត្ថិ នុ ខោ ឥមស្សាយស្មតោ តថារូបា មោហនីយា ធម្មា យថារូបេហិ មោហនីយេហិ ធម្មេហិ បរិយាទិន្នចិត្តោ អជានំ វា វទេយ្យ ជានាមីតិ អបស្សំ វា វទេយ្យ បស្សាមីតិ បរំ វា តថត្តាយ សមាទបេយ្យ យំ បរេសំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ តមេនំ សមន្នេសមានោ ឯវំ ជានាតិ នត្ថិ ខោ ឥមស្សាយស្មតោ តថារូបា មោហនីយា ធម្មា យថារូបេហិ មោហនីយេហិ ធម្មេហិ បរិយាទិន្នចិត្តោ អជានំ វា វទេយ្យ ជានាមីតិ អបស្សំ វា វទេយ្យ បស្សាមីតិ បរំ វា តថត្តាយ សមាទបេយ្យ យំ បរេសំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ តថា ខោ បនិមស្សាយស្មតោ កាយសមាចារោ តថា វចីសមាចារោ យថាតំ អមូឡ្ហស្ស យំ ខោ បន អយមាយស្មា ធម្មំ ទេសេតិ គម្ភីរោ សោ ធម្មោ ទុទ្ទសោ

កំល្បងមើលភិក្ខុនោះ ក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃមោហៈឲ្យក្រៃលែងជាងហេតុនោះតទៅទៀតថា បុគ្គលមានចិត្តដែលពួកធម៌ជាទីតាំងនៃមោហៈ មានសភាពយ៉ាងណា គ្របសង្កត់ហើយ មិនដឹង និយាយថា អាត្មាអញដឹង ឬមិនឃើញ និយាយថា អាត្មាអញឃើញ ឬក៏ហេតុណា ដែលប្រព្រឹត្តទៅដើម្បីកម្មមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរ ដល់ជនទាំងឡាយដទៃ ក៏បបួលអ្នកដទៃ ដើម្បីហេតុនោះ ពួកធម៌ដែលជាទីតាំងនៃមោហៈ មានសភាពដូច្នោះ មានដល់លោកមានអាយុនេះ ដែរឬហ្ន៎ ។ កាលគហបតី ឬកូនគហបតី ល្បងមើលភិក្ខុនោះ ក៏ដឹងយ៉ាងនេះថា បុគ្គលមានចិត្តដែលពួកធម៌ជាទីតាំងនៃមោហៈមានសភាពយ៉ាងណាគ្របសង្កត់ហើយ មិនដឹង និយាយថា អាត្មាអញដឹង ឬមិនឃើញ និយាយថា អាត្មាអញឃើញ ឬក៏ហេតុណាដែលប្រព្រឹត្តទៅ ដើម្បីកម្មមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរដល់ជនទាំងឡាយដទៃ ក៏បបួលអ្នកដទៃដើម្បីហេតុនោះ ពួកធម៌ដែលជាទីតាំងនៃមោហៈ មានសភាពដូច្នោះ មិនមានដល់លោកមានអាយុនេះទេ ។ កាយសមាចារ និងវចីសមាចារ របស់លោកមានអាយុនេះ ក៏ដូចជារបស់អ្នកដែលមិនមានមោហៈដែរ បើលោកមានអាយុនេះ សំដែងធម៌ណា ធម៌នោះជ្រៅ ឃើញបានដោយក្រ

១៣៩



ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ ន សោ ធម្មោ សុទេសិយោ លុទ្ធេនាតិ ។ យតោ នំ សមន្នេសមានោ វិសុទ្ធំ មោហនីយេហិ ធម្មេហិ បស្សតិ សមនុបស្សតិ អថ តម្ហិ សទ្ធំ និវេសេតិ សទ្ធាជាតោ ឧបសង្កមតិ ឧបសង្កមន្តោ បយិរុបាសតិ បយិរុបាសន្តោ សោតំ ឱទហតិ ឱហិតសោតោ ធម្មំ សុណាតិ សុត្វា ធម្មំ ធារេតិ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខតិ អត្ថំ ឧបបរិក្ខតោ ធម្មា និជ្ឈានំ ខមន្តិ ធម្មនិជ្ឈានក្ខន្តិយា សតិ ឆន្ទោ ជាយតិ ឆន្ទជាតោ ឧស្សហតិ ឧស្សហិត្វា តុលេតិ តុលយិត្វា បទហតិ បហិតត្តោ សមានោ កាយេន ចេវ បរមត្ថសច្ចំ សច្ឆិករោតិ បញ្ញាយ ច តំ អតិវិជ្ឈ បស្សតិ ។ ឯត្តាវតា ខោ ភារទ្វាជ សច្ចានុពោធោ ហោតិ

ត្រាស់ដឹងបានដោយក្រ ជាធម៌ស្ងប់ ជាធម៌ឧត្តម ជាធម៌ដែលគេស្ទង់មើលដោយការត្រិះរិះពុំបានទេ ជាធម៌ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបានធម៌នោះ បុគ្គលអ្នកមានមោហៈ មិនងាយនឹងសំដែងបានឡើយ ។ កាលគហបតី ឬកូនគហបតី ល្បងមើលនូវភិក្ខុនោះ បានឃើញច្បាស់ថា ជាអ្នកបរិសុទ្ធចាកធម៌ទាំងឡាយជាទីតាំងនៃមោហៈ ដោយហេតុណាហើយ ក៏ញុំាងសទ្ធាឲ្យជ្រួតជ្រាបក្នុងហេតុនោះ ជាអ្នកមានសទ្ធាកើតឡើងក្នុងកាលនោះ ទើបចូលទៅរក (ភិក្ខុនោះ) កាលចូលទៅរក ក៏បានអង្គុយជិត កាលទៅអង្គុយជិត ក៏ដាក់នូវសោតប្បសាទ លុះមានសោតប្បសាទដាក់ចុះហើយ ទើបស្តាប់ធម៌ លុះស្តាប់ហើយ ទើបទ្រទ្រង់នូវធម៌ ពិចារណានូវសេចក្តីនៃធម៌ទាំងឡាយដែលខ្លួនទ្រទ្រង់ហើយ កាលបើពិចារណានូវសេចក្តីហើយ ក៏ចូលចិត្តនូវធម៌នឹងគំនិត កាលមានសេចក្តីចូលចិត្តនូវធម៌នឹងគំនិតហើយ ក៏មានឆន្ទៈកើតឡើង លុះមានឆន្ទៈកើតឡើងហើយ ក៏ប្រឹងប្រែង លុះប្រឹងប្រែងហើយ ក៏ត្រិះរិះ លុះត្រិះរិះហើយ ក៏តម្កល់ (នូវសេចក្តីព្យាយាមដើម្បីមគ្គ) ជាអ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ទើបធ្វើឲ្យជាក់ច្បាស់ នូវបរមត្ថសច្ចៈដោយនាមកាយផង បានចាក់ធ្លុះឃើញច្បាស់នូវបរមត្ថសច្ចៈនោះដោយបញ្ញាផង ។ ម្នាលភារទ្វាជៈ ការត្រាស់ដឹងនូវសច្ចៈត្រឹមប៉ុណ្ណោះ

ឯត្តាវតា សច្ចមនុពុជ្ឈតិ ឯត្តាវតា ច មយំ សច្ចានុពោធំ បញ្ញាបេម ន ត្វេវ សច្ចានុប្បត្តិ ហោតីតិ ។ ឯត្តាវតា ភោ គោតម សច្ចានុពោធោ ហោតិ ឯត្តាវតា សច្ចមនុពុជ្ឈតិ ឯត្តាវតា ច មយំ សច្ចានុពោធំ បញ្ញាបេម កិត្តាវតា បន ភោ គោតម សច្ចានុប្បត្តិ ហោតិ កិត្តាវតា សច្ច-មនុប្បាបុណាតិ សច្ចានុប្បត្តឹ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។

[៧៥] តេសំយេវ ភារទ្វាជ ធម្មានំ អាសេវនា ភាវនា ពហុលីកម្មំ សច្ចានុប្បត្តិ ហោតិ ឯត្តាវតា ខោ ភារទ្វាជ សច្ចានុប្បត្តិ ហោតិ ឯត្តាវតា សច្ច-មនុប្បាបុណាតិ ឯត្តាវតា ច មយំ សច្ចានុប្បត្តឹ បញ្ញាបេមាតិ ។ ឯត្តាវតា ភោ គោតម សច្ចានុប្បត្តិ ហោតិ ឯត្តាវតា សច្ចមនុប្បាបុណាតិ ឯត្តាវតា ច មយំ សច្ចានុប្បត្តឹ បញ្ញាបេម សច្ចានុប្បត្តិយា

បុគ្គលត្រាស់ដឹងនូវសច្ចៈត្រឹមប៉ុណ្ណោះ យើងក៏បញ្ញត្តការត្រាស់ដឹងសច្ចៈត្រឹមប៉ុណ្ណោះ តែមិនទាន់ហៅថា កើតសច្ចធម៌ទេ ។ កាបទិកមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការត្រាស់ដឹងនូវសច្ចៈត្រឹមប៉ុណ្ណោះ បុគ្គលត្រាស់ដឹងនូវសច្ចៈត្រឹមប៉ុណ្ណោះ យើងខ្ញុំក៏បញ្ញត្តការត្រាស់ដឹងសច្ចៈត្រឹមប៉ុណ្ណោះដែរ បពិត្រព្រះគោតមដ៏ចម្រើន ចុះការកើតសច្ចៈតើត្រឹមប៉ុន្មាន បុគ្គលបាននូវសច្ចៈតើត្រឹមប៉ុន្មាន យើងខ្ញុំ សូមសួរនូវការកើតសច្ចៈ ចំពោះព្រះគោតមដ៏ចម្រើន ។

[៧៥] ព្រះបរមគ្រូត្រាស់ថា ម្នាលភារទ្វាជៈ ការធ្វើឲ្យច្រើន ការចម្រើន ការធ្វើរឿយ ៗ នូវធម៌ទាំងនោះឯង ឈ្មោះថា ការកើតសច្ចៈ ម្នាលភារទ្វាជៈ ការកើតសច្ចៈត្រឹមប៉ុណ្ណោះ បុគ្គលបាននូវសច្ចៈត្រឹមប៉ុណ្ណោះ យើងក៏បញ្ញត្តការកើតឡើងនៃសច្ចៈត្រឹមប៉ុណ្ណោះដែរ ។ កាបទិកមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ការកើតសច្ចៈត្រឹមប៉ុណ្ណោះ បុគ្គលបាននូវសច្ចៈត្រឹមប៉ុណ្ណោះ យើងបញ្ញត្តនូវការកើតឡើងនៃសច្ចៈត្រឹមប៉ុណ្ណោះ

បន ភោ គោតម កតមោ ធម្មោ ពហុការោ សច្ចានុប្បត្តិយា ពហុការំ ធម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។

[៧៦] សច្ចានុប្បត្តិយា ខោ ភារទ្វាជ បធានំ ពហុការំ នោ ចេ តំ បទហេយ្យ នយិទំ សច្ចមនុប្បាបុណេយ្យ យស្មា ច ខោ បទហតិ តស្មា សច្ចមនុប្បាបុណាតិ តស្មា សច្ចានុប្បត្តិយា បធានំ ពហុការន្តិ ។ បធានស្ស បន ភោ គោតម កតមោ ធម្មោ ពហុការោ បធានស្ស ពហុការំ ធម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ បធានស្ស ខោ ភារទ្វាជ តុលនា ពហុការា នោ ចេ តំ តុលេយ្យ នយិទំ បទហេយ្យ យស្មា ច ខោ តុលេតិ តស្មា បទហតិ

បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើន ប្រព្រឹត្តទៅដើម្បីឲ្យកើតសច្ចៈតើដូចម្តេច យើងខ្ញុំសូមសួរព្រះគោតមដ៏ចម្រើន នូវធម៌មានឧបការៈច្រើន ដើម្បីឲ្យកើតសច្ចៈ ។

[៧៦] ព្រះសាស្តាត្រាស់ថា ម្នាលភារទ្វាជៈ សេចក្តីព្យាយាមជាធម្មជាតមានឧបការៈច្រើនដល់ការកើតឡើងនៃសច្ចៈ បើបុគ្គលមិនតាំងទុកនូវសេចក្តីព្យាយាមនោះទេ មិនគប្បីបាននូវសច្ចៈនេះឡើយ ព្រោះហេតុនោះ បុគ្គលលុះតែតាំងព្យាយាមទើបបាននូវសច្ចៈ ហេតុនោះបានជាថា សេចក្តីព្យាយាម ជាធម្មជាតមានឧបការៈច្រើនដល់ការកើតឡើងនៃសច្ចៈ ។ កាបទិកមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌ដូចម្តេចដែលជាធម្មជាតមានឧបការៈច្រើនដល់សេចក្តីព្យាយាម យើងខ្ញុំសូមសួរព្រះគោតមដ៏ចម្រើន នូវធម៌ដែលជាធម្មជាតមានឧបការៈច្រើន ដល់សេចក្តីព្យាយាម ។ ព្រះសាស្តាត្រាស់ថា ម្នាលភារទ្វាជៈ ការពិចារណាជាធម្មជាតមានឧបការៈច្រើន ដល់សេចក្តីព្យាយាម បើបុគ្គលមិនថ្លឹងនូវការពិចារណានោះទេ មិនគប្បីតាំងនូវសេចក្តីព្យាយាមនេះបានឡើយ ព្រោះហេតុនោះ បុគ្គលលុះតែពិចារណា ទើបតាំងសេចក្តីព្យាយាមបាន

តស្មា បជានស្ស តុលជា ពហុការាតិ ។ តុលជាយ បង ភោ គោតម កាតមោ ជម្មោ ពហុការោ តុលជាយ ពហុការំ ជម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ តុលជាយ ខោ ភារទ្វាជ ឧស្សាហោ ពហុការោ ជោ ចេ តំ ឧស្សហេយ្យ ជ-យិធំ តុលេយ្យ យស្មា ច ខោ ឧស្សហាតិ តស្មា តុលេតិ តស្មា តុលជាយ ឧស្សាហោ ពហុការោតិ ។ ឧស្សាហស្ស បង ភោ គោតម កាតមោ ជម្មោ ពហុការោ ឧស្សាហស្ស ពហុការំ ជម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ ឧស្សាហស្ស ខោ ភារទ្វាជ ឆន្ទោ ពហុការោ ជោ ចេ តំ ឆន្ទោ ជាយេថ ជយិធំ ឧស្សហេយ្យ យស្មា ច ខោ ឆន្ទោ ជាយតិ តស្មា ឧស្សហាតិ តស្មា ឧស្សាហស្ស ឆន្ទោ ពហុការោតិ ។ ឆន្ទស្ស បង ភោ គោតម កាតមោ ជម្មោ ពហុការោ ឆន្ទស្ស ពហុការំ ជម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ ឆន្ទស្ស ខោ ភារទ្វាជ

ព្រោះហេតុនោះបានជាថា ការពិចារណា ជាធម្មជាតមានឧបការៈច្រើន ដល់សេចក្តីព្យាយាម ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈ ច្រើនដល់ការពិចារណា តើដូចម្តេច យើងខ្ញុំសូមសួរព្រះគោតមដ៏ចម្រើន នូវធម៌មានឧបការៈច្រើន ដល់ការពិចារណា ។ ម្នាលភារទ្វាជៈ ការ ប្រឹងប្រែងជាសភាវៈមានឧបការៈច្រើន ដល់ការពិចារណា បើបុគ្គល មិនផ្គូផ្គងនូវការប្រឹងប្រែងនោះទេ មិនគប្បីថ្លឹងនូវការពិចារណានេះបាន ឡើយ ព្រោះហេតុនោះ បុគ្គលលុះតែផ្គូផ្គងទើបពិចារណាបាន ហេតុ នោះបានជាថា ការប្រឹងប្រែង ជាសភាពមានឧបការៈច្រើនដល់ការពិចា- រណា ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើនដល់ការ ប្រឹងប្រែង តើដូចម្តេច យើងខ្ញុំសូមសួរព្រះគោតមដ៏ចម្រើននូវធម៌មាន ឧបការៈច្រើនដល់ការប្រឹងប្រែង ។ ម្នាលភារទ្វាជៈ ឆន្ទៈមានឧប- ការៈច្រើនដល់ការប្រឹងប្រែង បើឆន្ទៈមិនញុំាងការប្រឹងប្រែងនោះឲ្យកើត ឡើងទេ បុគ្គលមិនគប្បីប្រឹងប្រែងបានឡើយ ព្រោះហេតុនោះ លុះតែ កើតឆន្ទៈទើបបុគ្គលប្រឹងប្រែងបាន ហេតុនោះបានជាថា ឆន្ទៈជាធម៌ មានឧបការៈច្រើន ដល់សេចក្តីប្រឹងប្រែង ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើនដល់ឆន្ទៈ តើដូចម្តេច យើងខ្ញុំសូមសួរព្រះ គោតមដ៏ចម្រើននូវធម៌មានឧបការៈច្រើនដល់ឆន្ទៈ ។ ម្នាលភារទ្វាជៈ

១៤៣



ធម្មនិជ្ឈានក្ខន្តិ ពហុការា នោ ចេ តំ ធម្មា និជ្ឈានំ ខមេយ្យុំ នយិទំ ឆន្ទោ ជាយេថ យស្មា ច ខោ ធម្មា និជ្ឈានំ ខមន្តិ តស្មា ឆន្ទោ ជាយតិ តស្មា ឆន្ទស្ស ធម្មនិជ្ឈានក្ខន្តិ ពហុការាតិ ។ ធម្មនិជ្ឈានក្ខន្តិយា បន ភោ គោតម កតមោ ធម្មោ ពហុការោ ធម្មនិជ្ឈានក្ខន្តិយា ពហុការំ ធម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ ធម្មនិជ្ឈានក្ខន្តិយា ខោ ភារទ្វាជ អត្ថុបបរិក្ខា ពហុការា នោ ចេ តំ អត្ថំ ឧបបរិក្ខេយ្យ នយិទំ ធម្មា និជ្ឈានំ ខមេយ្យុំ យស្មា ច ខោ អត្ថំ ឧបបរិក្ខតិ តស្មា ធម្មា និជ្ឈានំ ខមន្តិ តស្មា ធម្មនិជ្ឈានក្ខន្តិយា អត្ថុបបរិក្ខា ពហុការាតិ ។ អត្ថុបបរិក្ខាយ បន ភោ គោតម កតមោ ធម្មោ ពហុការោ អត្ថុបបរិក្ខាយ ពហុការំ ធម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ អត្ថុបបរិក្ខាយ ខោ ភារទ្វាជ ធម្មធារណា ពហុការា នោ ចេ តំ ធម្មំ ធារេយ្យ នយិទំ អត្ថំ ឧបបរិក្ខេយ្យ យស្មា ច ខោ ធម្មំ ធារេតិ តស្មា

សេចក្តីចូលចិត្តធម៌ក្នុងគំនិត ជាធម្មជាតិមានឧបការៈច្រើនដល់ឆន្ទៈ បើមិនចូលចិត្តធម៌ក្នុងគំនិតនោះទេ ឆន្ទៈក៏កើតឡើងមិនបាន ព្រោះហេតុនោះ លុះតែចូលចិត្តធម៌ក្នុងគំនិត ទើបឆន្ទៈកើតឡើងបាន ហេតុនោះបានជាថា ការចូលចិត្តធម៌ក្នុងគំនិត ជាធម្មជាតិមានឧបការៈច្រើនដល់ឆន្ទៈ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើនដល់ការចូលចិត្តធម៌ក្នុងគំនិត តើដូចម្តេច យើងខ្ញុំសូមសួរនូវធម៌មានឧបការៈច្រើនដល់ការចូលចិត្តធម៌ក្នុងគំនិត ចំពោះព្រះគោតមដ៏ចម្រើន ។ ម្នាលភារទ្វាជៈ ការពិចារណានូវអត្ថ មានឧបការៈច្រើនដល់ការចូលចិត្តធម៌ក្នុងគំនិត បើបុគ្គលមិនពិ-ចារណានូវអត្ថនោះទេ ធម៌ទាំងឡាយ មិនគួរដល់ការចូលចិត្តបានឡើយ ព្រោះហេតុនោះ បុគ្គលលុះតែពិចារណានូវអត្ថ ទើបធម៌ទាំងឡាយគួរដល់ការចូលចិត្តបាន ហេតុនោះបានជាថា ការពិចារណានូវអត្ថ មានឧបការៈច្រើនដល់ការចូលចិត្តធម៌ក្នុងគំនិត ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើនដល់ការពិចារណានូវអត្ថ តើដូចម្តេច យើងខ្ញុំសូមសួរនូវធម៌ មានឧបការៈច្រើនដល់ការពិចារណានូវអត្ថ ចំពោះព្រះគោតមដ៏ចម្រើន ។ ម្នាលភារទ្វាជៈ ការចេះចាំនូវធម៌ មានឧបការៈច្រើនដល់ការពិចារណានូវអត្ថ បើបុគ្គលមិនចេះចាំនូវធម៌នោះទេ ក៏មិនអាចពិចា-រណា នូវអត្ថបានឡើយ ព្រោះហេតុនោះ បុគ្គលលុះតែចេះចាំនូវធម៌

អត្ថំ ឧបបរិក្ខតិ តស្មា អត្ថុបបរិក្ខាយ ជម្មជារណា ពហុការាតិ ។ ជម្មជារណាយ បន ភោ គោតម កតមោ ជម្មោ ពហុការោ ជម្មជារណាយ ពហុការំ ជម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ ជម្មជារណាយ ខោ ភារទ្វាជ ជម្មស្សូវជំ ពហុការំ ជោ ចេ តំ ជម្មំ សុណេយ្យ នយិទំ ជម្មំ ជារេយ្យ យស្មា ច ខោ ជម្មំ សុណាតិ តស្មា ជម្មំ ជារេតិ តស្មា ជម្មជារណាយ ជម្មស្សូវជំ ពហុការន្តិ ។ ជម្មស្សូវជស្ស បន ភោ គោតម កតមោ ជម្មោ ពហុការោ ជម្មស្សូវជស្ស ពហុការំ ជម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ ជម្មស្សូវជស្ស ខោ ភារទ្វាជ សោតាវជានំ ពហុការំ ជោ ចេ តំ សោតំ ឱជហេយ្យ នយិទំ ជម្មំ សុណេយ្យ យស្មា ច ខោ សោតំ ឱជហាតិ តស្មា ជម្មំ សុណាតិ តស្មា ជម្មស្សូវជស្ស សោតាវជានំ ពហុការន្តិ ។ សោតាវជានស្ស បន ភោ គោតម កតមោ ជម្មោ

ទើបពិចារណានូវអត្ថបាន ហេតុនោះបានជាថា ការចេះចាំនូវធម៌ មានឧបការៈច្រើនដល់ការពិចារណានូវអត្ថ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើនដល់ការទ្រទ្រង់នូវធម៌ តើដូចម្តេច យើងខ្ញុំសូមសួរនូវធម៌មានឧបការៈច្រើនដល់ការចេះចាំនូវធម៌ ចំពោះព្រះគោតមដ៏ចម្រើន ។ ម្នាលភារទ្វាជៈ ការស្តាប់ធម៌មានឧបការៈច្រើន ដល់ការចេះចាំនូវធម៌ បើបុគ្គលមិនស្តាប់ធម៌នោះទេ មិនអាចចេះចាំនូវធម៌បានឡើយ ព្រោះហេតុនោះ បុគ្គលលុះតែស្តាប់ធម៌ ទើបចេះចាំនូវធម៌បាន ហេតុនោះបានជាថា ការស្តាប់ធម៌ មានឧបការៈច្រើនដល់ការចេះចាំនូវធម៌ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើនដល់ការស្តាប់ធម៌ តើដូចម្តេច យើងខ្ញុំសូមសួរនូវធម៌ មានឧបការៈច្រើន ដល់ការស្តាប់ធម៌ចំពោះព្រះគោតមដ៏ចម្រើន ។ ម្នាលភារទ្វាជៈ ការផ្ទង់ត្រចៀក មានឧបការៈច្រើនដល់ការស្តាប់នូវធម៌ បើបុគ្គលមិនផ្ទង់ត្រចៀកនោះទេ មិនអាចស្តាប់ធម៌បានឡើយ ព្រោះហេតុនោះ បុគ្គលលុះតែផ្ទង់ត្រចៀក ទើបស្តាប់ធម៌បាន ហេតុនោះបានជាថា ការផ្ទង់ត្រចៀកមានឧបការៈច្រើនដល់ការស្តាប់ធម៌ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើន ដល់

ពហុការោ សោតាវធានស្ស ពហុការំ ធម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ សោតាវធានស្ស ខោ ភារទ្វាជ បយិរុបាសនា ពហុការា នោ ចេ តំ បយិរុបាសេយ្យ នយិទំ សោតំ ឱទហេយ្យ យស្មា ច ខោ បយិរុបាសតិ តស្មា សោតំ ឱទហតិ តស្មា សោតាវធានស្ស បយិរុបាសនា ពហុការាតិ ។ បយិរុបាសនាយ បន ភោ គោតម កតមោ ធម្មោ ពហុការោ បយិរុបាសនាយ ពហុការំ ធម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ បយិរុបាសនាយ ខោ ភារទ្វាជ ឧបសង្កមនំ ពហុការំ នោ ចេ តំ ឧបសង្កមេយ្យ នយិទំ បយិរុបាសេយ្យ យស្មា ច ខោ ឧបសង្កមតិ តស្មា បយិរុបាសតិ តស្មា បយិរុបាសនាយ ឧបសង្កមនំ ពហុការន្តិ ។ ឧបសង្កមនស្ស បន ភោ គោតម កតមោ ធម្មោ ពហុការោ ឧបសង្កមនស្ស ពហុការំ ធម្មំ មយំ ភវន្តំ គោតមំ បុច្ឆាមាតិ ។ ឧបសង្កមនស្ស ខោ ភារទ្វាជ សទ្ធា ពហុការា នោ ចេ តំ សទ្ធា ជាយេថ នយិទំ ឧបសង្កមេយ្យ

ការផ្ទង់ត្រចៀក តើដូចម្តេច យើងខ្ញុំសូមសួរនូវធម៌ មានឧបការៈច្រើន ដល់ការផ្ទង់ត្រចៀក ចំពោះព្រះគោតមដ៏ចម្រើន ។ ម្នាលភារទ្វាជៈ ការចូលទៅអង្គុយជិតមានឧបការៈច្រើន ដល់ការផ្ទង់ត្រចៀក បើបុគ្គលមិនចូលទៅអង្គុយជិតទេ មិនអាចផ្ទង់ត្រចៀកបានឡើយ ព្រោះហេតុនោះ បុគ្គលលុះតែចូលទៅអង្គុយជិត ទើបផ្ទង់ត្រចៀកបាន ហេតុនោះបានជាថា ការចូលទៅអង្គុយជិតមានឧបការៈច្រើន ដល់ការផ្ទង់ត្រចៀក ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើនដល់ការចូលទៅអង្គុយជិត តើដូចម្តេច យើងខ្ញុំសូមសួរនូវធម៌ មានឧបការៈច្រើនដល់ការចូលទៅអង្គុយជិត ចំពោះព្រះគោតមដ៏ចម្រើន ។ ម្នាលភារទ្វាជៈ ការចូលទៅរក មានឧបការៈច្រើនដល់ការចូលទៅអង្គុយជិត បើបុគ្គលមិនចូលទៅរកទេ មិនអាចចូលទៅអង្គុយជិតបានឡើយ ព្រោះហេតុនោះ បុគ្គលលុះតែចូលទៅរក ទើបចូលទៅអង្គុយជិតបាន ហេតុនោះបានជាថា ការចូលទៅរក មានឧបការៈច្រើនដល់ការចូលទៅអង្គុយជិត ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌មានឧបការៈច្រើន ដល់ការចូលទៅរក តើដូចម្តេច យើងខ្ញុំសូមសួរនូវធម៌ មានឧបការៈច្រើន ដល់ការចូលទៅរក ចំពោះព្រះគោតមដ៏ចម្រើន ។ ម្នាលភារទ្វាជៈ សទ្ធាមានឧបការៈច្រើនដល់ការចូលទៅរក បើសទ្ធាមិនកើតទេ គេមិនអាចចូលទៅរកបាន

យស្មា ច ខោ សទ្ធា ជាយតិ តស្មា ឧបសង្កមតិ តស្មា ឧបសង្កមនស្ស សទ្ធា ពហុការាតិ ។

[៧៧] សច្ចានុរក្ខណំ មយំ ភវន្តំ គោតមំ អបុច្ឆិម្ហា[១] សច្ចានុរក្ខណំ ភវំ គោតមោ ព្យាកាសិ តញ្ច បនម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា សច្ចមនុពោធំ មយំ ភវន្តំ គោតមំ អបុច្ឆិម្ហា សច្ចមនុពោធំ ភវំ គោតមោ ព្យាកាសិ តញ្ច បនម្ហា-កំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា សច្ចានុបត្តឹ មយំ ភវន្តំ គោតមំ អបុច្ឆិម្ហា សច្ចានុបត្តឹ ភវំ គោតមោ ព្យាកាសិ តញ្ច បនម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា សច្ចានុបត្តិយា ពហុ-ការំ ធម្មំ មយំ ភវន្តំ គោតមំ អបុច្ឆិម្ហា សច្ចានុ-បត្តិយា ពហុការំ ធម្មំ ភវំ គោតមោ ព្យាកាសិ តញ្ច

១ ឱ. ម. អបុច្ឆិម្ហ ។

ព្រោះហេតុនោះ បុគ្គលលុះតែសទ្ធាកើត ទើបចូលទៅរកបាន ហេតុនោះបានជាថា សទ្ធាមានឧបការៈច្រើនដល់ការចូលទៅរក ។

[៧៧] កាបទិកមាណព ក្រាបបង្គំទូលតបថា យើងខ្ញុំ បានសួរនូវការរក្សាសច្ចធម៌នឹងព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន ក៏បានព្យាករនូវការរក្សាសច្ចៈហើយ ក៏ការព្យាករនោះ គាប់ចិត្តផង គួរផង ដល់យើងខ្ញុំ ទាំងយើងខ្ញុំសោត ក៏មានចិត្តត្រេកអរ ដោយការព្យាករនោះ យើងខ្ញុំបានសួរនូវការត្រាស់ដឹងនូវសច្ចៈ នឹងព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន ក៏បានព្យាករនូវការត្រាស់ដឹងសច្ចៈហើយ ការព្យាករនោះ គាប់ចិត្តផង គួរផង ដល់យើងខ្ញុំ ទាំងយើងខ្ញុំសោត ក៏មានចិត្តត្រេកអរ ដោយការព្យាករនោះ យើងខ្ញុំបានសួរនូវការកើតសច្ចៈ នឹងព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន ក៏បានព្យាករនូវការកើតសច្ចៈហើយ ក៏ការព្យាករនោះ គាប់ចិត្តផង គួរផង ដល់យើងខ្ញុំ ទាំងយើងខ្ញុំសោត ក៏មានចិត្តត្រេកអរ ដោយការព្យាករនោះ យើងខ្ញុំបានសួរនូវធម៌មានឧបការៈច្រើន ដល់ការកើតសច្ចៈ នឹងព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន ក៏បានព្យាករនូវធម៌មានឧបការៈច្រើន ដល់ការកើតសច្ចៈហើយ ក៏ការព្យាករនោះ

អម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា យំ យទេវ ច មយំ ភវន្តំ គោតមំ អបុច្ឆិម្ហា តំ តទេវ ភវំ គោតមោ ព្យាកាសិ តញ្ច អម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា មយំ ហិ ភោ គោតម បុព្វេ ឯវំ ជានាម កេ ច មុណ្ឌកា សមណកា ឥព្ភា កណ្ហា ពន្ធុបាទាបច្ចា កេ ច ធម្មស្ស អញ្ញាតារោតិ អជនេសិ វត មេ ភវំ គោតមោ សមណេសុ សមណប្បេមំ សមណេសុ សមណប្បសាទំ សមណេសុ សមណគារវំ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

ចង្កីសុត្តំ បញ្ចមំ និដ្ឋិតំ ។

គាប់ចិត្តផង គួរផង ដល់យើងខ្ញុំ ទាំងយើងខ្ញុំសោត ក៏មានចិត្តត្រេកអរ ដោយការព្យាករនោះ យើងខ្ញុំបានសួរ នូវប្រស្នាណា ៗ នឹងព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន ក៏បានព្យាករនូវប្រស្នានោះ ៗ ហើយ ក៏ការព្យាករនោះ គាប់ចិត្តផង គួរផង ដល់យើងខ្ញុំ ទាំងយើងខ្ញុំសោត ក៏មានចិត្តត្រេកអរដោយការព្យាករនោះ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថាកាលពីដើមយើងខ្ញុំបានដឹងយ៉ាងនេះថា បុគ្គលពួកណា ជាសមណៈត្រងោល ជាគហបតិជាតិ មានសម្បុរខ្មៅ ជាកូនកើតមកអំពីព្រះបាទនៃមហាព្រហ្ម បុគ្គលពួកណា ជាអ្នកដឹងច្បាស់នូវធម៌ ឱហ្ន៎ (ឥឡូវនេះ) ព្រះគោតមដ៏ចម្រើន បាននាំខ្ញុំឲ្យមានសេចក្ដីស្រឡាញ់ក្នុងពួកសមណៈ ឲ្យមានសេចក្ដីជ្រះថ្លាក្នុងពួកសមណៈ ឲ្យមានសេចក្ដីគោរព ក្នុងពួកសមណៈ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើនទ្រង់ជ្រាប នូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវត្រៃសរណគមន៍ ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមតទៅ ។

ចប់ ចង្កីសូត្រ ទី ៥ ។

# ៦. ឯសុការីសុត្តំ

[៧៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ឯសុការី ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[៧៩] ឯកមន្តំ និសិន្នោ ខោ ឯសុការី ព្រាហ្មណោ ភគវន្តំ ឯតទវោច ព្រាហ្មណា ភោ គោតម ចតស្សោ បារិចរិយា បញ្ញបេន្តិ ព្រាហ្មណស្ស បារិចរិយំ បញ្ញបេន្តិ ខត្តិយស្ស បារិចរិយំ បញ្ញបេន្តិ វេស្សស្ស បារិចរិយំ បញ្ញបេន្តិ សុទ្ទស្ស បារិចរិយំ បញ្ញបេន្តិ ។ តត្រិទំ ភោ គោតម ព្រាហ្មណា ព្រាហ្មណស្ស បារិចរិយំ បញ្ញបេន្តិ ព្រាហ្មណោ វា ព្រាហ្មណំ បរិចរេយ្យ ខត្តិយោ វា ព្រាហ្មណំ បរិចរេយ្យ វេស្សោ វា ព្រាហ្មណំ បរិចរេយ្យ

# ឯសុការីសូត្រ ទី ៦

[៧៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រាហ្មណ៍ឈ្មោះឯសុការី បានចូលទៅគាល់ព្រះមានបុណ្យ លុះចូលទៅដល់ហើយ ក៏រាក់ទាក់ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់និងគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[៧៩] លុះឯសុការីព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានបុញ្ញសិរីយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍តែងបញ្ញត្តការបម្រើ ៤ យ៉ាង គឺបញ្ញត្តការបម្រើសម្រាប់ព្រាហ្មណ៍ ១ បញ្ញត្តការបម្រើសម្រាប់ក្សត្រិយ៍ ១ បញ្ញត្តការបម្រើសម្រាប់វេស្សៈ ១ បញ្ញត្តការបម្រើសម្រាប់សុទ្ទៈ ១ ។ បពិត្រព្រះគោតមដ៏ចម្រើន ក្នុងរឿងនោះ ពួកព្រាហ្មណ៍បញ្ញត្តការបម្រើសម្រាប់ព្រាហ្មណ៍យ៉ាងនេះថា ព្រាហ្មណ៍ត្រូវបម្រើព្រាហ្មណ៍ ឬក្សត្រិយ៍ត្រូវបម្រើព្រាហ្មណ៍ វេស្សៈត្រូវបម្រើព្រាហ្មណ៍

សុទ្ទោ វា ព្រាហ្មណំ បរិចរេយ្យាតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា ព្រាហ្មណស្ស ចារិចរិយំ បញ្ញបេន្តិ ។ តត្រិទំ ភោ គោតម ព្រាហ្មណា ខត្តិយស្ស ចារិចរិយំ បញ្ញបេន្តិ ខត្តិយោ វា ខត្តិយំ បរិចរេយ្យ វេស្សោ វា ខត្តិយំ បរិចរេយ្យ សុទ្ទោ វា ខត្តិយំ បរិចរេយ្យាតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា ខត្តិយស្ស ចារិចរិយំ បញ្ញបេន្តិ ។ តត្រិទំ ភោ គោតម ព្រាហ្មណា វេស្សស្ស ចារិចរិយំ បញ្ញបេន្តិ វេស្សោ វា វេស្សំ បរិចរេយ្យ សុទ្ទោ វា វេស្សំ បរិចរេយ្យាតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា វេស្សស្ស ចារិចរិយំ បញ្ញបេន្តិ ។ តត្រិទំ ភោ គោតម ព្រាហ្មណា សុទ្ទស្ស ចារិចរិយំ បញ្ញបេន្តិ សុទ្ទោវ សុទ្ទំ បរិចរេយ្យ កោ បនញ្ញោ សុទ្ទំ បរិចរិស្សតីតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា សុទ្ទស្ស ចារិចរិយំ បញ្ញបេន្តិ ព្រាហ្មណា ភោ គោតម ឥមា ចតស្សោ ចារិចរិយា បញ្ញបេន្តិ ឥទំ[១] ភវំ គោតមោ កិមាហាតិ ។

១ ឱ. ឥធាតិ ទិស្សតិ ។

សុទ្ទៈត្រូវបម្រើព្រាហ្មណ៍ បពិត្រព្រះគោតម ដ៏ចម្រើន ពួកព្រាហ្មណ៍ បញ្ញត្តការបម្រើនេះឯង សម្រាប់ព្រាហ្មណ៍ ។ បពិត្រព្រះគោតម ដ៏ចម្រើន ក្នុងរឿងនោះ ពួកព្រាហ្មណ៍ បញ្ញត្តការបម្រើសម្រាប់ក្សត្រិយ៍ យ៉ាងនេះថា ក្សត្រិយ៍ត្រូវបម្រើក្សត្រិយ៍ វេស្សៈត្រូវបម្រើក្សត្រិយ៍ សុទ្ទៈ ក៏ត្រូវបម្រើក្សត្រិយ៍ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ បញ្ញត្តការបម្រើនេះឯង សម្រាប់ក្សត្រិយ៍ ។ បពិត្រព្រះគោតម ដ៏ចម្រើន ក្នុងរឿងនោះ ពួកព្រាហ្មណ៍បញ្ញត្តការបម្រើសម្រាប់វេស្សៈ យ៉ាងនេះ ថា វេស្សៈត្រូវបម្រើវេស្សៈ សុទ្ទៈក៏ត្រូវបម្រើវេស្សៈ បពិត្រព្រះគោតម ដ៏ចម្រើន ពួកព្រាហ្មណ៍ បញ្ញត្តការបម្រើនេះឯង សម្រាប់វេស្សៈ ។ បពិត្រព្រះគោតមដ៏ចម្រើន ក្នុងរឿងនោះ ពួកព្រាហ្មណ៍បញ្ញត្តការបម្រើ សម្រាប់សុទ្ទៈ យ៉ាងនេះថា ត្រូវតែសុទ្ទៈបម្រើសុទ្ទៈ តើអ្នកដទៃណាទៅ ទៀតនឹងបម្រើសុទ្ទៈ (នោះ) បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ បញ្ញត្តការបម្រើនេះឯង សម្រាប់សុទ្ទៈ បពិត្រព្រះគោតមដ៏ចម្រើន ពួក ព្រាហ្មណ៍បញ្ញត្តការបម្រើទាំង ៤ យ៉ាងនេះ តើព្រះគោតមដ៏ចម្រើន ទ្រង់ ត្រាស់សំដែងនូវដំណើរនេះ ថាដូចម្តេច ។

[៨០] កឹ បន ព្រាហ្មណ សព្វោ លោកោ ព្រាហ្មណានំ ឯតទព្ភនុជានាតិ ឥមា ចតស្សោ បារិចរិយា បញ្ញបេន្តូតិ[១] ។ នោ ហិទំ ភោ គោតម ។ សេយ្យថាបិ ព្រាហ្មណ បុរិសោ ទឡិទ្ទោ អស្សកោ អនាឡ្ហិយោ តស្ស អកាមស្ស វិសំ[២] ឱលគ្គេយ្យុំ ឥទន្តេ អម្ភោ បុរិស មំសំ ខាទិតព្វំ មូលញ្ច អនុប្បទាតព្វន្តិ ឯវមេវ ខោ ព្រាហ្មណ ព្រាហ្មណា អប្បដិញ្ញាយ[៣] តេសំ សមណព្រាហ្មណានំ អថ ច បនិមា ចតស្សោ បារិចរិយា បញ្ញបេន្តិ ។ នាហំ ព្រាហ្មណ សព្វំ បរិចរិតព្វន្តិ វទាមិ ន បនាហំ ព្រាហ្មណ សព្វំ ន បរិចរិតព្វន្តិ វទាមិ ។ យំ ហិស្ស ព្រាហ្មណ បរិចរតោ បារិចរិយាហេតុ បាបិយោ អស្ស ន សេយ្យោ នាហន្តំ បរិចរិតព្វន្តិ វទាមិ យញ្ច ខ្វស្ស ព្រាហ្មណ បរិចរតោ បារិចរិយាហេតុ សេយ្យោ អស្ស ន បាបិយោ តមហំ បរិចរិតព្វន្តិ វទាមិ ។

---

១ ម. បញ្ញបេន្តីតិ ។ ២ ឱ. ពិលំ ។ ម. ពីលំ ។ ៣ ឱ. អប្បដិញ្ញាយេតេសំ ។

[៨០] ព្រះមានព្រះភាគត្រាស់សួរថា ម្នាលព្រាហ្មណ៍ ចុះលោកទាំងមូលយល់ព្រមដាច់ស្រេច នូវការបញ្ញត្ត របស់ពួកព្រាហ្មណ៍នុ៎ះថា ចូរពួកព្រាហ្មណ៍បញ្ញត្តនូវការបម្រើទាំង ៤ យ៉ាងនេះចុះ ដូច្នេះដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន លោកទាំងមូលមិនយល់ព្រម នូវការបញ្ញត្តនេះទេ ។ ម្នាលព្រាហ្មណ៍ បុរសកំសត់ ឥតយស មិនស្តុកស្តម្ភ ពួកឈ្មួញរទេះ យកចំណែកសាច់ (គោរបស់ខ្លួនដែលស្លាប់តាមផ្លូវ) ផ្តែកវេរឲ្យដល់បុរសកំសត់នោះ ដែលមិនចង់បានដោយបង្ខំថា នែវ៉ឺយបុរស ឯងត្រូវតែស៊ីសាច់នេះ ទាំងត្រូវសងថ្លៃផង សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលព្រាហ្មណ៍ ដោយការដែលពួកសមណព្រាហ្មណ៍នោះ មិនបានយល់ព្រមសោះ ស្រាប់តែពួកព្រាហ្មណ៍ មកបញ្ញត្តការបម្រើទាំង ៤ យ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថាត្រូវតែបម្រើអ្នកទាំងអស់ (នោះ) ទេ ម្នាលព្រាហ្មណ៍ តែតថាគតនឹងបានពោលថាមិនត្រូវបម្រើទាំងអស់ក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ ព្រោះថាកាលបើគេបម្រើបុគ្គលណា ត្រឡប់ជាបានបាបក្រៃពេក មិនបានប្រយោជន៍ ព្រោះហេតុការបម្រើ តថាគតមិនពោលថាត្រូវបម្រើបុគ្គលនោះទេ ម្នាលព្រាហ្មណ៍ តែថាកាលគេបម្រើបុគ្គលណា បានប្រយោជន៍មិនបានបាប ព្រោះហេតុតែការបម្រើទេ តថាគតពោលថាត្រូវបម្រើបុគ្គលនោះចុះ ។

ខត្តិយញ្ចេបិ ព្រាហ្មណ ឯវំ បុច្ឆេយ្យុំ យំ វា តេ បរិចរតោ ចារិចរិយាហេតុ ចាបិយោ អស្ស ន សេយ្យោ យំ វា តេ បរិចរតោ ចារិចរិយាហេតុ សេយ្យោ អស្ស ន ចាបិយោ កាមេត្ត បរិចរេយ្យាសីតិ ។ ខត្តិយោបិ ហិ ព្រាហ្មណ សម្មា ព្យាករមានោ ឯវំ ព្យាករេយ្យ យំ ហិ មេ បរិចរតោ ចារិចរិយា-ហេតុ ចាបិយោ អស្ស ន សេយ្យោ ជាហន្តំ បរិចរេយ្យំ យញ្ច ខោ មេ បរិចរតោ ចារិចរិយា-ហេតុ សេយ្យោ អស្ស ន ចាបិយោ តមហំ បរិចរេយ្យន្តិ ។ ព្រាហ្មណំ ចេបិ ព្រាហ្មណ... វេស្សំ ចេបិ ព្រាហ្មណ... សុទ្ទំ ចេបិ ព្រាហ្មណ ឯវំ បុច្ឆេយ្យុំ យំ វា តេ បរិចរតោ ចារិចរិយាហេតុ ចាបិយោ អស្ស ន សេយ្យោ យំ វា តេ បរិចរតោ ចារិចរិយាហេតុ សេយ្យោ អស្ស ន ចាបិយោ

ម្នាលព្រាហ្មណ៍ ប្រសិនបើគេសួរក្សត្រិយ៍យ៉ាងនេះថា កាលបើព្រះអង្គបម្រើបុគ្គលណា ទ្រង់ក្លាយទៅជាមនុស្សលាមកក្រៃពេក មិនបានជាមនុស្សប្រសើរវិសេស ព្រោះហេតុតែការបម្រើ មួយទៀត កាលបើព្រះអង្គបម្រើបុគ្គលណា បានជាបុគ្គលគាប់ប្រសើរ មិនក្លាយជាបុគ្គលថោកថយ ព្រោះហេតុតែការបម្រើទេ បណ្ដាបុគ្គលទាំងពីរនុ៎ះ តើព្រះអង្គត្រូវបម្រើបុគ្គលណា ។ ម្នាលព្រាហ្មណ៍ កាលបើក្សត្រិយ៍ឆ្លើយតបដោយត្រឹមត្រូវ គួរឆ្លើយតបយ៉ាងនេះថា កាលខ្ញុំបម្រើបុគ្គលណា ក្លាយខ្លួនទៅជាមនុស្សលាមកក្រៃពេក មិនបានជាមនុស្សប្រសើរវិសេស ព្រោះហេតុតែការបម្រើទេ ខ្ញុំមិនត្រូវបម្រើបុគ្គលនោះឡើយ លុះតែខ្ញុំបម្រើបុគ្គលណា បានការគាប់ប្រសើរ មិនបានការអាក្រក់ ព្រោះហេតុតែការបម្រើ ទើបខ្ញុំត្រូវបម្រើបុគ្គលនោះ ។ ម្នាលព្រាហ្មណ៍ បើគេសួរព្រាហ្មណ៍... ម្នាលព្រាហ្មណ៍ បើគេសួរវេស្សៈ... ម្នាលព្រាហ្មណ៍ បើគេសួរសុទ្ទៈយ៉ាងនេះថា កាលបើអ្នកបម្រើបុគ្គលណា ត្រឡប់ជាបានបាប មិនបានការគាប់ប្រសើរ ព្រោះការបម្រើជាហេតុទេ មួយទៀត កាលបើអ្នក បម្រើបុគ្គលណា បានការគាប់ប្រសើរ មិនបានការអាក្រក់ ព្រោះការបម្រើជាហេតុទេ

កាមេត្ថ បរិចរេយ្យាសីតិ ។ សុទ្ទោបិ(១) ព្រាហ្មណ សម្មា ព្យាករមានោ ឯវំ ព្យាករេយ្យ យំ ហិ មេ បរិចរតោ បារិចរិយាហេតុ បាបិយោ អស្ស ន សេយ្យោ នាហន្តំ បរិចរេយ្យំ យញ្ច ខោ មេ បរិចរតោ បរិចរិយាហេតុ សេយ្យោ អស្ស ន បាបិយោ តមហំ បរិចរេយ្យន្តិ ។

[៨១] នាហំ ព្រាហ្មណ ឧច្ចាកុលីនតា សេយ្យសោតិ(២) វទាមិ ន បនាហំ ព្រាហ្មណ ឧច្ចាកុលីនតា បាបិយសោតិ(៣) វទាមិ ។ នាហំ ព្រាហ្មណ ឧឡារវណ្ណតា សេយ្យសោតិ វទាមិ ន បនាហំ ព្រាហ្មណ ឧឡារវណ្ណតា បាបិយសោតិ វទាមិ ។ នាហំ ព្រាហ្មណ ឧឡារភោគតា សេយ្យ-សោតិ វទាមិ ន បនាហំ ព្រាហ្មណ ឧឡារភោគតា បាបិយសោតិ វទាមិ ។ ឧច្ចាកុលីនោបិ ហិ ព្រាហ្ម-ណ ឥធេកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុមិច្ឆាចារី ហោតិ មុសាវាទី ហោតិ

១ ឱ. ម. ឯត្ថន្តរេ ហិសទ្ទោ ទិស្សតិ ។ ២-៣ ឱ. ម. សេយ្យំ សោតិ ។ បាបិយំ សោតិ ។

បណ្តាបុគ្គលទាំងពីរនុ៎ះ តើអ្នកត្រូវបម្រើបុគ្គលណា ។ ម្នាលព្រាហ្មណ៍ កាលបើសុទ្ទៈឆ្លើយតបដោយត្រឹមត្រូវ គប្បីឆ្លើយតបយ៉ាងនេះថា កាលបើខ្ញុំបម្រើបុគ្គលណា បានការអាក្រក់ មិនបានការគាប់ប្រសើរ ព្រោះហេតុតែការបម្រើទេ ខ្ញុំមិនត្រូវបម្រើបុគ្គលនោះឡើយ កាលបើខ្ញុំបម្រើបុគ្គលណា បានការគាប់ប្រសើរ មិនមែនជាការអាក្រក់ ព្រោះហេតុតែការបម្រើទេ ទើបខ្ញុំត្រូវបម្រើបុគ្គលនោះ ។

[៨១] ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលគាប់ប្រសើរ ព្រោះតែមានត្រកូលខ្ពស់ទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបានពោលថាបុគ្គលថោកថយ ព្រោះតែមានត្រកូលខ្ពស់ក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថាបុគ្គលគាប់ប្រសើរ ព្រោះតែមានជាតិថ្លៃថ្លាទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបានពោលថាបុគ្គលថោកទាប ព្រោះតែមានជាតិថ្លៃថ្លាក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលប្រសើរវិសេស ព្រោះតែមានភោគៈលើសលុបទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបានពោលថាបុគ្គលថោកទាប ព្រោះតែមានភោគៈលើសលុបក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ ព្រោះថាបុគ្គលពួកខ្លះ ក្នុងលោកនេះ សូម្បីមានត្រកូលខ្ពង់ខ្ពស់ តែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តកាមេសុមិច្ឆា ប្រព្រឹត្តពោលពាក្យមុសា

១៤៣



បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆា-ទិដ្ឋី ហោតិ តស្មា ន ឧច្ចាកុលីនតា សេយ្យសោតិ វទាមិ ។ ឧច្ចាកុលីនោបិ ហិ ព្រាហ្មណ ឥធេកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ តស្មា ន ឧច្ចាកុលីនតា បាបិយសោតិ វទាមិ ។ ឧឡារវណ្ណោបិ ហិ ព្រាហ្មណ ឥធេកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុមិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណា-វាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋី ហោតិ តស្មា ន ឧឡារវណ្ណតា សេយ្យសោតិ វទាមិ ។

មានវាចាញុះញង់ មានវាចាទ្រគោះ និយាយតែពាក្យឥតប្រយោជន៍ ជាអ្នកមានអភិជ្ឈា មានចិត្តព្យាបាទ ជាមិច្ឆាទិដ្ឋិ ហេតុនោះបានជាតថាគតមិនពោលថា បុគ្គលប្រសើរវិសេស ព្រោះតែមានត្រកូលខ្ពង់ខ្ពស់ទេ ។ ម្នាលព្រាហ្មណ៍ ព្រោះថាបុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ហើយបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ក៏មាន ហេតុនោះ បានជាតថាគតមិនពោលថាបុគ្គលថោកទាប ព្រោះតែមានត្រកូលខ្ពង់ខ្ពស់ទេ ។ ម្នាលព្រាហ្មណ៍ មនុស្សពួកខ្លះក្នុងលោកនេះ ទុកជាមានជាតិថ្លៃថ្នាក៏ដោយតែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តកាមេសុមិច្ឆា ពោលពាក្យមុសា មានវាចាញុះញង់ មានសំដីអាក្រក់ និយាយពាក្យឥតប្រយោជន៍ មានអភិជ្ឈា មានចិត្តព្យាបាទ ជាមិច្ឆាទិដ្ឋិ ហេតុនោះ បានជាតថាគតមិនពោលថា បុគ្គលវិសេសវិសាល ព្រោះតែមានជាតិថ្លៃថ្នាទេ ។

ឧឡារវណ្ណោបិ ហិ ព្រាហ្មណា ឥធេកច្ចោ បា-ណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ តស្មា ន ឧឡារវណ្ណតា បាបិយសោតិ វទាមិ ។ ឧឡារភោគោបិ ហិ ព្រាហ្មណា ឥធេកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេ-សុមិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋី ហោតិ តស្មា ន ឧឡារភោគតា សេយ្យសោតិ វទាមិ ។ ឧឡារភោគោបិ ហិ ព្រាហ្មណា ឥធេកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ

ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានជាតិថ្ងៃថ្លា ហើយបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុ-មិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មា-ទិដ្ឋិក៏មាន ហេតុនោះ បានជាតថាគតមិនពោលថា បុគ្គលថោកទាប ព្រោះតែមានជាតិថ្ងៃថ្លាទេ ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ សូម្បីមានភោគៈលើសលុប តែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តកាមេសុមិច្ឆា និយាយពាក្យមុសា មានវាចាញុះញង់ មានពាក្យអាក្រក់ និយាយពាក្យឥតប្រយោជន៍ មានអភិជ្ឈា មានចិត្តព្យា-បាទ ជាមនុស្សមិច្ឆាទិដ្ឋិ ហេតុនោះ បានជាតថាគតមិនពោលថា បុគ្គលវិសេសវិសាល ព្រោះតែមានភោគៈលើសលុបទេ ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានភោគៈដ៏លើសលុប ហើយបាន វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ

មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ តស្មា ន ឧច្ចាកុលីនតា បាបិយសោតិ វទាមិ ។ នាហំ ព្រាហ្មណ សព្វំ បរិចរិតព្វន្តិ វទាមិ ន បនាហំ ព្រាហ្មណ សព្វំ ន បរិចរិតព្វន្តិ វទាមិ ។ យំ ហិស្ស ព្រាហ្មណ បរិចរតោ បារិចរិយាហេតុ សទ្ធា វឌ្ឍតិ សីលំ វឌ្ឍតិ សុតំ វឌ្ឍតិ ចាគោ វឌ្ឍតិ បញ្ញា វឌ្ឍតិ តមហំ បរិចរិតព្វន្តិ វទាមីតិ ។

[៨២] ឯវំ វុត្តេ ឯសុការី ព្រាហ្មណោ ភគវន្តំ ឯតទវោច ព្រាហ្មណា ភោ គោតម ចត្តារិ ធនានិ បញ្ញបេន្តិ ព្រាហ្មណស្ស សន្ធនំ[១] បញ្ញបេន្តិ ខត្តិយស្ស សន្ធនំ បញ្ញបេន្តិ វេស្សស្ស សន្ធនំ បញ្ញបេន្តិ សុទ្ទស្ស សន្ធនំ បញ្ញបេន្តិ ។

១ ឱ. ម. សន្ធនំ ។

វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិក៏មាន ហេតុនោះបានជាតថាគតមិនពោលថា បុគ្គលថោកទាប ព្រោះតែមានភោគៈលើសលុបទេ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា ត្រូវតែបម្រើអ្នកទាំងអស់ (នោះ) ទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបានពោលថា មិនត្រូវបម្រើអ្នកទាំងអស់ក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ ព្រោះថាកាលបើគេបម្រើបុគ្គលណា សទ្ធាចម្រើន សីលចម្រើន សុតៈចម្រើន ចាគៈចម្រើន ប្រាជ្ញាក៏ចម្រើន ព្រោះការបម្រើ (នោះ) ជាហេតុ តថាគតទើបពោលថា ត្រូវបម្រើបុគ្គលនោះ ។

[៨២] កាលបើព្រះមានបុណ្យ សំដែងយ៉ាងនេះហើយ ឯសុការីព្រាហ្មណ៍ បានក្រាបទូលព្រះមានបុណ្យយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្តទ្រព្យ ៤ យ៉ាង គឺបញ្ញត្តទ្រព្យសម្រាប់ខ្លួនរបស់ព្រាហ្មណ៍ ១ បញ្ញត្តទ្រព្យសម្រាប់ខ្លួនរបស់ក្សត្រិយ៍ ១ បញ្ញត្តទ្រព្យសម្រាប់ខ្លួនរបស់វេស្សៈ ១ បញ្ញត្តទ្រព្យសម្រាប់ខ្លួនរបស់សុទ្ទៈ ១ ។

តត្រិទំ ភោ គោតម ព្រាហ្មណា ព្រាហ្មណស្ស សន្ធនំ បញ្ញបេន្តិ ភិក្ខាចរិយំ ភិក្ខាចរិយញ្ច បន ព្រាហ្មណោ សន្ធនំ អតិមញ្ញមានោ អកិច្ចការី ហោតិ គោបោវ អទិន្នំ អាទិយមានោតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា ព្រាហ្មណស្ស សន្ធនំ បញ្ញបេន្តិ ។ តត្រិទំ ភោ គោតម ព្រាហ្មណា ខត្តិយស្ស សន្ធនំ បញ្ញបេន្តិ ធនុកលាបំ ធនុកលាបញ្ច បន ខត្តិយោ សន្ធនំ អតិមញ្ញមានោ អកិច្ចការី ហោតិ គោបោវ អទិន្នំ អាទិយមានោតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា ខត្តិយស្ស សន្ធនំ បញ្ញបេន្តិ ។ តត្រិទំ ភោ គោតម ព្រាហ្មណោ វេស្សស្ស សន្ធនំ បញ្ញបេន្តិ កសិគោរក្ខំ កសិគោរក្ខញ្ច បន វេស្សោ សន្ធនំ អតិមញ្ញមានោ អកិច្ចការី ហោតិ គោបោវ អទិន្នំ អាទិយមានោតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា វេស្សស្ស សន្ធនំ បញ្ញបេន្តិ ។

បពិត្រព្រះគោតមដ៏ចម្រើន បណ្តាទ្រព្យទាំង ៤ នោះ ពួកព្រាហ្មណ៍បញ្ញត្ត ការប្រព្រឹត្តសូមនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់ព្រាហ្មណ៍ ប្រសិនបើ ព្រាហ្មណ៍មើលងាយនូវការប្រព្រឹត្តសូម ដែលជាទ្រព្យរបស់ខ្លួនហើយ ឈ្មោះថាជាអ្នកមិនធ្វើអំពើដែលខ្លួនត្រូវធ្វើ ដូចអ្នករក្សាទ្រព្យ លួចយក ទ្រព្យដែលគេមិនបានឲ្យ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្ត ការប្រព្រឹត្តសូមនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់ព្រាហ្មណ៍ យ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាទ្រព្យទាំង ៤ នោះ ពួកព្រាហ្មណ៍បញ្ញត្ត ធ្នូនិងបំពង់ព្រួញនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់ក្សត្រិយ៍ ប្រសិនបើ ក្សត្រិយ៍មើលងាយធ្នូនិងបំពង់ព្រួញ ដែលជាទ្រព្យរបស់ខ្លួនហើយ ឈ្មោះ ថាជាអ្នកមិនធ្វើការងារដែលខ្លួនត្រូវធ្វើ ដូចអ្នករក្សាទ្រព្យ លួចទ្រព្យ ដែលគេមិនបានឲ្យ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្តធ្នូនិង បំពង់ព្រួញនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់ក្សត្រិយ៍យ៉ាងនេះឯង ។ បពិត្រ ព្រះគោតមដ៏ចម្រើន បណ្តាទ្រព្យទាំង ៤ នោះ ពួកព្រាហ្មណ៍បញ្ញត្តការភ្ជួរ រាស់និងការរក្សាគោនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់វេស្សៈ ប្រសិនបើ វេស្សៈ មើលងាយការភ្ជួររាស់និងការរក្សាគោដែលជាទ្រព្យរបស់ខ្លួនហើយ ឈ្មោះថាជាអ្នកមិនធ្វើកិច្ចដែលខ្លួនត្រូវធ្វើ ដូចអ្នករក្សាទ្រព្យ លួចទ្រព្យ ដែលគេមិនបានឲ្យ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្តការភ្ជួរ រាស់និងការរក្សាគោនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់វេស្សៈយ៉ាងនេះឯង ។

១៨៧



តត្រិទំ ភោ គោតម ព្រាហ្មណា សុទ្ទស្ស សទ្ធនំ បញ្ញបេន្តិ អសិតព្យាភង្គឹ អសិតព្យាភង្គិញ្ច បន សុទ្ទោ សទ្ធនំ អតិមញ្ញមានោ អកិច្ចការី ហោតិ គោចោវ អទិន្នំ អាទិយមានោតិ ឥទំ ខោ ភោ គោតម ព្រាហ្មណា សុទ្ទស្ស សទ្ធនំ បញ្ញបេន្តិ ។ [១]ឥមានិ ចត្តារិ ធនានិ បញ្ញបេន្តិ ឥធ ភវំ គោតមោ កិមាហាតិ ។

[៨៣] កឹ បន ព្រាហ្មណា សព្វោ លោកោ ព្រាហ្មណានំ ឯតទព្ភនុជានាតិ ឥមានិ ចត្តារិ ធនានិ បញ្ញបេន្តូតិ ។ នោ ហិទំ ភោ គោតម ។ សេយ្យថាបិ ព្រាហ្មណ បុរិសោ ទឡិទ្ទោ អស្សកោ អនាឡ្ហិយោ តស្ស អកាមស្ស វិសំ ឱលគ្គេយ្យុំ ឥទន្តេ អម្ភោ បុរិស មំសំ ខាទិតព្វំ មូលញ្ច អនុប្បទាតព្វន្តិ ឯវមេវ ខោ ព្រាហ្មណ ព្រាហ្មណា អប្បដិញ្ញាយ តេសំ សមណព្រាហ្មណានំ អថ ច បនិមានិ ចត្តារិ ធនានិ បញ្ញបេន្តិ ។ អរិយំ ខោ បន អហំ ព្រាហ្មណ

១ ឱ. ព្រាហ្មណា ភោ គោតមាត្យាទិបយោគេ ទិស្សតិ ។

បពិត្រព្រះគោតមដ៏ចម្រើន បណ្តាទ្រព្យទាំង ៤ នោះ ពួកព្រាហ្មណ៍ បញ្ញត្ត កណ្តៀវនិងអម្រែកនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់សុទ្ទៈ ប្រសិនបើសុទ្ទៈ មើលងាយកណ្តៀវនិងអម្រែក ដែលជាទ្រព្យរបស់ខ្លួនហើយ ឈ្មោះថា ជាអ្នកមិនធ្វើការងារដែលខ្លួនត្រូវធ្វើ ដូចអ្នករក្សាទ្រព្យ លួចយកទ្រព្យ ដែលគេមិនបានឲ្យ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ បញ្ញត្ត កណ្តៀវនិងអម្រែកនេះ ថាជាទ្រព្យសម្រាប់ខ្លួនរបស់សុទ្ទៈយ៉ាងនេះឯង ។ ពួកព្រាហ្មណ៍ បញ្ញត្តទ្រព្យ ៤ យ៉ាងនេះ តើព្រះគោតមដ៏ចម្រើន សំដែង ថាដូចម្តេច ត្រង់រឿងនេះ ។

[៨៣] ម្នាលព្រាហ្មណ៍ ចុះលោកទាំងមូល យល់ព្រមនូវការ បញ្ញត្តរបស់ពួកព្រាហ្មណ៍នេះថា ពួកព្រាហ្មណ៍ ចូរបញ្ញត្តទ្រព្យ ៤ យ៉ាង នេះចុះ ដូច្នេះដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន រឿងនេះលោកទាំង មូលមិនយល់ព្រមទេ ។ ម្នាលព្រាហ្មណ៍ បុរសកំសត់ ឥតយស ក្រីក្រ ពួកឈ្មួញរទេះយកចំណែកសាច់ (គោរបស់ខ្លួន ដែលស្លាប់តាមផ្លូវ) ផ្តែកវេរឲ្យដល់បុរសកំសត់នោះ ដែលមិនចង់បាន ដោយការបង្ខំថា នែ វ៉ឺយបុរស ឯងត្រូវស៊ីសាច់នេះ ទាំងត្រូវសងថ្លៃផង សេចក្តីនេះមាន ឧបមាយ៉ាងណា ម្នាលព្រាហ្មណ៍ កាលបើពួកសមណព្រាហ្មណ៍ទាំង នោះមិនបានយល់ព្រម ស្រាប់តែពួកព្រាហ្មណ៍បញ្ញត្តទ្រព្យទាំង ៤ នេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ ឯតថាគតបញ្ញត្ត

លោកុត្តរំ ធម្មំ បុរិសស្ស សន្ធនំ បញ្ញបេមិ ។ បោរាណំ ខោ បនស្ស មាតាបេត្តិកំ កុលវំសំ អនុស្សរតោ យត្ថ យត្ថេវ អត្តភាវស្ស អភិនិព្វត្តិ ហោតិ តេន តេនេវ សំខ្យំ[១] គច្ឆតិ ខត្តិយកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ ខត្តិយោត្វេវ សំខ្យំ គច្ឆតិ ព្រាហ្មណកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ ព្រាហ្មណោត្វេវ សំខ្យំ គច្ឆតិ វេស្សកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ វេស្សោត្វេវ សំខ្យំ គច្ឆតិ សុទ្ទកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ សុទ្ទោត្វេវ សំខ្យំ គច្ឆតិ ។ សេយ្យថាបិ ព្រាហ្មណ យំ យទេវ បច្ចយំ បដិច្ច អគ្គិ ជលតិ តេន តេនេវ សំខ្យំ គច្ឆតិ ។ កដ្ឋញ្ចេ បដិច្ច អគ្គិ ជលតិ កដ្ឋគ្គិត្វេវ សំខ្យំ គច្ឆតិ សកលិកញ្ចេ បដិច្ច អគ្គិ ជលតិ សកលិកគ្គិត្វេវ សំខ្យំ គច្ឆតិ តិណញ្ចេ បដិច្ច អគ្គិ ជលតិ តិណគ្គិត្វេវ សំខ្យំ គច្ឆតិ គោមយញ្ចេ បដិច្ច អគ្គិ ជលតិ គោមយគ្គិត្វេវ សំខ្យំ គច្ឆតិ

១ ឱ. សង្ខំ ។

លោកុត្តរធម៌ដ៏ប្រសើរតែម្យ៉ាង ថាជាទ្រព្យសម្រាប់ខ្លួនរបស់បុរសស្ត្រី ចំ-ណែកបុរសស្ត្រីនោះ ដែលអន្ទោលតាមវង្សត្រកូល ជាចំណែកខាងមាតាបិតាមកពីដើម បានកើតអត្តភាពក្នុងត្រកូលណា ៗ ក៏ដល់នូវការរាប់តាមត្រកូលនោះ ៗ បើបានកើតអត្តភាពក្នុងត្រកូលក្សត្រិយ៍ ក៏ដល់នូវការរាប់ថាជាក្សត្រិយ៍ បើបានកើតអត្តភាពក្នុងត្រកូលព្រាហ្មណ៍ ក៏ដល់នូវការរាប់ថាជាព្រាហ្មណ៍ បើបានកើតអត្តភាពក្នុងត្រកូលវេស្សៈ ក៏ដល់នូវការរាប់ថាជាវេស្សៈ បើបានកើតអត្តភាពក្នុងត្រកូលសុទ្ទៈ ក៏ដល់នូវការរាប់ថាជាសុទ្ទៈ ។ ម្នាលព្រាហ្មណ៍ ភ្លើងឆេះព្រោះអាស្រ័យរបស់ណា ៗ ជាបច្ច័យ ក៏ដល់នូវការរាប់តាមរបស់នោះ ៗ ។ បើភ្លើងឆេះអាស្រ័យនឹងឧស ក៏ដល់នូវការរាប់ថា ភ្លើងឧស បើភ្លើងឆេះអាស្រ័យនឹងចំណាំងឈើ ក៏ដល់នូវការរាប់ថា ភ្លើងចំណាំងឈើ បើភ្លើងឆេះអាស្រ័យនឹងស្មៅ ក៏ដល់នូវការរាប់ថា ភ្លើងស្មៅ បើភ្លើងឆេះអាស្រ័យនឹងអាចម៍គោ ក៏ដល់នូវការរាប់ថា ភ្លើងអាចម៍គោ សេចក្តីទាំងនេះមានឧបមាយ៉ាងណា

ឯវមេវ ខោ អហំ ព្រាហ្មណ អរិយំ លោកុត្តរំ ធម្មំ បុរិសស្ស សន្ធនំ បញ្ញបេមិ បោរាណំ ខោ បនស្ស មាតាបេត្តិកំ កុលវំសំ អនុស្សរតោ យត្ថ យត្ថេវ អត្តភាវស្ស អភិនិព្វត្តិ ហោតិ តេន តេនេវ សំខ្យំ គច្ឆតិ ខត្តិយកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ ខត្តិយោត្វេវ សំខ្យំ គច្ឆតិ ព្រាហ្មណកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ ព្រាហ្មណោត្វេវ សំខ្យំ គច្ឆតិ វេស្សកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ វេស្សោត្វេវ សំខ្យំ គច្ឆតិ សុទ្ទកុលេ ចេ អត្តភាវស្ស អភិនិព្វត្តិ ហោតិ សុទ្ទោត្វេវ សំខ្យំ គច្ឆតិ ។

[៨៤] ខត្តិយកុលា ចេបិ ព្រាហ្មណ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ

ម្នាលព្រាហ្មណ៍ តថាគតបញ្ញត្តលោកុត្តរធម៌ដ៏ប្រសើរ ថាជាទ្រព្យសម្រាប់ខ្លួននៃបុរសស្ត្រី កាលបើបុគ្គលរលឹកនូវវង្សត្រកូល ជាចំណែកខាងមាតាបិតាដែលមានមកពីបូរាណ ហើយបានកើតអត្តភាពក្នុងត្រកូលណា ៗ ក៏ដល់នូវការរាប់តាមត្រកូលនោះ ៗ ដែរ បើបានកើតអត្តភាពក្នុងត្រកូលក្សត្រិយ៍ ក៏ដល់នូវការរាប់ថាជាក្សត្រិយ៍ បើបានកើតអត្តភាពក្នុងត្រកូលព្រាហ្មណ៍ ក៏ដល់នូវការរាប់ថាជាព្រាហ្មណ៍ បើបានកើតអត្តភាពក្នុងត្រកូលវេស្សៈ ក៏ដល់នូវការរាប់ថា វេស្សៈ បើបានកើតអត្តភាពក្នុងត្រកូលសុទ្ទៈ ក៏ដល់នូវការរាប់ថា សុទ្ទៈ ក៏មានឧបមេយ្យដូច្នោះដែរ ។

[៨៤] ម្នាលព្រាហ្មណ៍ បើបុគ្គលចេញចាកផ្ទះអំពីខត្តិយត្រកូល ហើយចូលទៅកាន់ផ្នួស ក៏អ្នកបួសនោះ បានអាស្រ័យធម៌វិន័យ ដែលតថាគតសំដែងហើយ ជាបុគ្គលបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ វៀរចាកបិសុ-

ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ ព្រាហ្មណកុលា ចេបិ ព្រាហ្មណា អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ វេស្សកុលា ចេបិ ព្រាហ្មណា អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ

ណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្ដីយល់ត្រូវ ជាបុគ្គលត្រេកអរនឹងកុសលធម៌ដែលជាតួហេតុ ។ ម្នាលព្រាហ្មណ៍ បើកុលបុត្រចេញចាកផ្ទះអំពីត្រកូលព្រាហ្មណ៍ ហើយចូលទៅកាន់ផ្នួស កុលបុត្រនោះសោត អាស្រ័យធម៌វិន័យដែលតថាគតសំដែងហើយ ជាបុគ្គលបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ ។ បេ ។ ជាសម្មាទិដ្ឋិ ជាបុគ្គលត្រេកអរនឹងកុសលធម៌ ដែលជាតួហេតុ ។ ម្នាលព្រាហ្មណ៍ បើកុលបុត្របានចេញចាកផ្ទះអំពីត្រកូលវេស្សៈហើយចូលទៅកាន់ផ្នួស កុលបុត្រនោះសោត អាស្រ័យធម៌វិន័យ ដែលតថាគតសំដែងហើយ ជាបុគ្គលវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ ។ បេ ។ ជាសម្មាទិដ្ឋិ ជាបុគ្គលត្រេកអរ

ញាយំ ធម្មំ កុសលំ ។ សុទ្ទកុលា ចេបិ ព្រាហ្មណ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម ចាណាតិចាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាចា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ តំ កឹ មញ្ញសិ ព្រាហ្មណ ព្រាហ្មណោវ នុ ខោ បហោតិ អស្មឹ បទេសេ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតុំ នោ ខត្តិយោ នោ វេស្សោ នោ សុទ្ទោតិ ។ នោ ហិទំ ភោ គោតម ខត្តិយោបិ ហិ ភោ គោតម បហោតិ អស្មឹ បទេសេ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតុំ ព្រាហ្មណោបិ ហិ ភោ គោតម... វេស្សោបិ ហិ ភោ គោតម...

នឹងកុសលធម៌ ដែលជាតួហេតុ ។ ម្នាលព្រាហ្មណ៍ បើកុលបុត្រ បានចេញចាកផ្ទះអំពីត្រកូលសុទ្ទៈហើយចូលទៅកាន់ផ្នួស កុលបុត្រនោះ សោត អាស្រ័យធម៌វិន័យ ដែលតថាគតបានសំដែងហើយ ជាបុគ្គល បានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរ ចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មា-ទិដ្ឋិ ជាបុគ្គលត្រេកអរនឹងកុសលធម៌ ដែលជាតួហេតុ ។ ម្នាល ព្រាហ្មណ៍ អ្នកយល់នូវហេតុនោះដូចម្ដេច មានតែព្រាហ្មណ៍ទើបអាច ចម្រើនមេត្តចិត្ត ជាចិត្តមិនមានពៀរ មិនមានព្យាបាទ ក្នុងប្រទេសនេះ ក្សត្រិយ៍ចម្រើនមិនបាន វេស្សៈចម្រើនមិនបាន សុទ្ទៈចម្រើនមិនបានទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនមែនដូច្នោះទេ បពិត្រព្រះ គោតមដ៏ចម្រើន ទោះក្សត្រិយ៍អាចចម្រើនមេត្តចិត្ត ដែលមិនមានពៀរ មិនមានព្យាបាទ ក្នុងប្រទេសនេះបាន បពិត្រព្រះគោតមដ៏ចម្រើន ទោះជាព្រាហ្មណ៍... បពិត្រព្រះគោតមដ៏ចម្រើន ទោះជាវេស្សៈ...

សុទ្ទោបិ ហិ ភោ គោតម... សព្វេបិ ហិ ភោ គោតម ចត្តារោ វណ្ណា បហោន្តិ អស្មឹ បទេសេ អវេរំ អព្យាបជ្ឈំ មេត្តចិត្តំ ភាវេតុន្តិ ។

[៨៥] ឯវមេវ ខោ ព្រាហ្មណ ខត្តិយកុលា ចេបិ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ ព្រាហ្មណកុលា ចេបិ ព្រាហ្មណ... វេស្សកុលា ចេបិ ព្រាហ្មណ... សុទ្ទកុលា ចេបិ ព្រាហ្មណ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម

បពិត្រព្រះគោតមដ៏ចម្រើន ទោះជាសុទ្ទ... បពិត្រព្រះគោតមដ៏ចម្រើន វណ្ណៈទាំង ៤ សុទ្ធតែអាចចម្រើនមេត្តចិត្ត ដែលមិនមានពៀរ មិនមានព្យាបាទ ក្នុងប្រទេសនេះ បានទាំងអស់ ។

[៨៥] ម្នាលព្រាហ្មណ៍ យ៉ាងហ្នឹងហើយ បើកុលបុត្រចេញចាកផ្ទះអំពីត្រកូលក្សត្រិយ៍ហើយចូលទៅកាន់ផ្នួស កុលបុត្រនោះឯង អាស្រ័យធម៌វិន័យ ដែលតថាគតបានសំដែងហើយ ជាបុគ្គលបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ជាបុគ្គលត្រេកអរនឹងកុសលធម៌ ដែលជាតួហេតុ ។ ម្នាលព្រាហ្មណ៍ បើចេញអំពីត្រកូលព្រាហ្មណ៍... ម្នាលព្រាហ្មណ៍ បើចេញអំពីត្រកូលវេស្សៈ... ម្នាលព្រាហ្មណ៍ បើកុលបុត្រចេញចាកផ្ទះអំពីត្រកូលសុទ្ទៈហើយចូលទៅកាន់ផ្នួស កុលបុត្រនោះឯងអាស្រ័យធម៌វិន័យ ដែលតថាគតបានសំដែងហើយ

ចាណាតិចាតា បដិវិរតោ ហោតិ អចិន្នាជាដា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ជប្បលាចា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អាភាដកោ ហោតិ ញាយំ ជម្មំ កុសលំ ។ តំ កឹ មញ្ញសិ ព្រាហ្មណា ព្រាហ្មណោវ នុ ខោ បហោតិ សោត្ថឹ សិដានំ អាបាយ ងជឹ គន្ត្វា រដោជល្វំ បរាហេតុំ ដោ ខត្តិយោ ដោ វេស្សោ ដោ សុទ្ទោតិ ។ ដោ ហិទំ ភោ គោតម ខត្តិយោបិ ហិ ភោ គោតម បហោសិ សោត្ថឹ សិដានំ អាបាយ ងជឹ គន្ត្វា រដោជល្វំ បរាហេតុំ ព្រាហ្មណោបិ ហិ ភោ គោត-ម... វេស្សោបិ ហិ ភោ គោតម... សុទ្ទោបិ ហិ ភោ គោតម... សព្វេបិ ហិ ភោ គោតម ចត្តារោ វណ្ណា បហោន្តិ សោត្ថឹ សិដានំ អាបាយ ងជឹ គន្ត្វា រដោជល្វំ បរាហេតុន្តិ ។

ជាបុគ្គលបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ជាបុគ្គលត្រេកអរនឹងកុសលធម៌ ដែលជាតួហេតុ ។ ម្នាលព្រាហ្មណ៍ អ្នកយល់នូវហេតុនោះដូចម្តេច មានតែព្រាហ្មណ៍ទើបអាចនាំយកនូវកញ្ចប់លំអិតសម្រាប់ងូត ទៅកាន់ស្ទឹង ដុសជម្រះក្អែលបាន ក្សត្រិយ៍ជម្រះមិនបាន វេស្សៈជម្រះមិនបាន សុទ្ទៈជម្រះមិនបានទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន សូម្បីក្សត្រិយ៍ក៏អាចយកកញ្ចប់លំអិតសម្រាប់ងូតទៅកាន់ស្ទឹង ជម្រះក្អែលបានដែរ បពិត្រព្រះគោតមដ៏ចម្រើន សូម្បីព្រាហ្មណ៍... បពិត្រព្រះគោតមដ៏ចម្រើន សូម្បីវេស្សៈ បពិត្រព្រះគោតមដ៏ចម្រើន សូម្បីសុទ្ទៈ... បពិត្រព្រះគោតមដ៏ចម្រើន ពួកវណ្ណៈទាំង ៤ សុទ្ធតែអាចយកកញ្ចប់លំអិតសម្រាប់ងូត ទៅកាន់ស្ទឹងជម្រះក្អែលបានទាំងអស់ ។

[៨៦] ឯវមេវ ខោ ព្រាហ្មណា ខត្តិយកុលា ចេបិ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ ព្រាហ្មណកុលា ចេបិ ព្រាហ្ម-ណា... វេស្សកុលា ចេបិ ព្រាហ្មណា... សុទ្ទកុលា ចេបិ ព្រាហ្មណា អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ

[៨៦] ម្នាលព្រាហ្មណ៍ បើកុលបុត្រចេញចាកផ្ទះអំពីត្រកូលក្សត្រិយ៍ហើយចូលទៅកាន់ផ្នួស ក៏កុលបុត្រនោះ អាស្រ័យធម៌វិន័យដែលតថាគតបានសំដែងហើយ ជាបុគ្គលវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ វៀរចាកបិ-សុណវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ជាបុគ្គលត្រេកអរនឹងកុសលធម៌ ដែលជាតួហេតុ ។ ម្នាលព្រាហ្មណ៍ បើចេញអំពីត្រកូលព្រាហ្មណ៍... ម្នាលព្រាហ្មណ៍ បើចេញអំពីត្រកូលវេស្សៈ... ម្នាលព្រាហ្មណ៍ បើកុលបុត្រចេញចាកផ្ទះអំពីត្រកូលសុទ្ទៈហើយចូលទៅកាន់ផ្នួស ក៏កុលបុត្រនោះ អាស្រ័យធម៌វិន័យ ដែលតថាគតបានសំដែងហើយជាបុគ្គលវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្ម-ចរិយៈ វៀរចាកមុសាវាទ វៀរចាកបិសុណវាចា វៀរចាកផរុសវាចា

សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ តំ កឹ មញ្ញសិ ព្រាហ្មណ ឥធ រាជា ខត្តិយោ មុទ្ធាវសិត្តោ នានាជច្ចានំ បុរិសានំ បុរិសសតំ សន្និបាតេយ្យ អាយន្តុ ភោន្តោ យេ តត្ថ ខត្តិយកុលា ព្រាហ្មណកុលា រាជញ្ញកុលា ឧប្បន្នា សាកស្ស វា សាលស្ស វា សលឡស្ស វា ចន្ទនស្ស វា បទុមកស្ស វា ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេន្តុ តេជោ បាតុករោន្តុ អាយន្តុ បន ភោន្តោ យេ ច តត្ថ ចណ្ឌាលកុលា នេសាទកុលា វេណុកុលា រថការកុលា បុក្កុសកុលា ឧប្បន្នា សាបានទោណិយា វា សូករទោណិយា វា រជកទោណិយា វា ឯលណ្ឌកដ្ឋស្ស វា ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេន្តុ តេជោ បាតុករោន្តូតិ ។ តំ កឹ មញ្ញសិ ព្រាហ្មណ

វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ជាបុគ្គលត្រេកអរនឹងកុសលធម៌ ដែលជាតួហេតុ ក៏ដូចគ្នាយ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ អ្នកយល់នូវហេតុនោះថាដូចម្ដេច ក្សត្រិយ៍ជារាជាដែលបានមុទ្ធាភិសេកហើយ ក្នុងលោកនេះ ប្រជុំពួកបុរស ១០០ នាក់ ដែលមានជាតិផ្សេង ៗ គ្នាថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមក បណ្ដាបុរសទាំងនោះ ពួកបុរសណាដែលកើតអំពីខត្តិយត្រកូល អំពីព្រាហ្មណត្រកូល អំពីរាជញ្ញត្រកូល[១] ពួកបុរសនោះ ចូរកាន់យកនូវឈើពំនួតខាងលើ (កូនពំនួតជាវិការៈ) នៃឈើស្រាយ ឬឈើខ្លឹម ស្រល់ ខ្លឹមចន្ទន៍ ឬឈូក ពួតបង្កាត់ភ្លើង ឲ្យភ្លើងឆេះប្រាកដឡើង មួយទៀត អ្នកដ៏ចម្រើនទាំងឡាយ ចូរមក បណ្ដាបុរសទាំងនោះ ពួកបុរសណា ដែលកើត អំពីត្រកូលចណ្ឌាល អំពីត្រកូលនេសាទ អំពីវេណុត្រកូល (ត្រកូលត្បាញផែង) អំពីរថការត្រកូល (ត្រកូលអ្នកធ្វើរថ) អំពីបុក្កុសត្រកូល (ត្រកូលអ្នកកើបសំរាម) ពួកបុរសទាំងនោះ ចូរយកឈើពំនួតខាងលើ (ជាវិការៈ) នៃស្នូកឆ្កែឬស្នូកជ្រូក ស្នូកជាងជ្រលក់ ឬដើមល្ហុងប្រេង ពួតបង្កាត់ភ្លើង ឲ្យភ្លើងឆេះប្រាកដឡើង ។ ម្នាលព្រាហ្មណ៍ អ្នកយល់នូវហេតុនោះថាដូចម្ដេច

---

១ ស្ដេចដែលមិនទាន់បានរាជាភិសេក ។

យោ ឯវ នុ ខោ សោ ខត្តិយកុលា ព្រាហ្មណកុលា រាជញ្ញកុលា ឧប្បន្នេហិ សាកស្ស វា សាលស្ស វា សលឡស្ស វា ចន្ទនស្ស វា បទុមកស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ បាតុកតោ ស្វេវ នុ ខ្វស្ស អគ្គិ អច្ចិមា ចេវ វណ្ណិមា ច បភស្សរោ ច តេន សក្កា អគ្គិនា អគ្គិករណីយំ កាតុំ យោ បន សោ ចណ្ឌាលកុលា នេសាទកុលា វេណុកុលា រថការកុលា បុក្កុសកុ-លា ឧប្បន្នេហិ សាបានទោណិយា វា សូករទោណិយា វា រជកទោណិយា វា ឯលណ្ឌកដ្ឋស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ បាតុកតោ ស្វាស្ស អគ្គិ ន ចេវ អច្ចិមា ន ច វណ្ណិមា ន ច បភស្សរោ ន ច តេន សក្កា អគ្គិនា អគ្គិករណីយំ កាតុន្តិ ។ នោ ហិទំ ភោ គោតម យោបិ សោ ភោ គោតម ខត្តិយកុលា ព្រាហ្មណកុលា រាជញ្ញ-កុលា ឧប្បន្នេហិ សាកស្ស វា សាលស្ស វា

ភ្លើងណា ដែលពួកបុរសកើតអំពីខត្តិយត្រកូល អំពីព្រាហ្មណត្រកូល អំពីរាជញ្ញត្រកូល យកពំនួតភ្លើងខាងលើ (ជាវិការៈ) នៃឈើស្រាយក្តី ឈើខ្ទឹមក្តី ដើមស្រល់ក្តី ដើមចន្ទន៍ក្តី ដើមឈូកក្រហមក្តី មកពួតបង្កាត់ ភ្លើងក៏ឆេះប្រាកដឡើង ភ្លើងនោះមានអណ្តាតផង មានពណ៌ផង មានពន្លឺផង គេអាចធ្វើការដែលត្រូវធ្វើដោយភ្លើង នឹងភ្លើងនោះបាន ចំណែកភ្លើងណាដែលពួកបុរសកើតអំពីចណ្ឌាលត្រកូល នេសាទត្រកូល វេណុត្រកូល រថការត្រកូល បុក្កុសត្រកូល យកពំនួតភ្លើងខាងលើ (ជាវិការៈ) នៃស្នូកឆ្កែក្តី ស្នូកជ្រូកក្តី ស្នូកជាងជ្រលក់ក្តី ដើមល្ហុងប្រេងក្តី មកពួតបង្កាត់ ភ្លើងក៏ឆេះប្រាកដឡើងដែរ តែភ្លើងនោះ មិនមានអណ្តាតផង មិនមានពណ៌ផង មិនមានពន្លឺផង គេមិនអាចធ្វើការដែលត្រូវធ្វើដោយភ្លើង នឹងភ្លើងនោះ បានទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន ភ្លើងណាដែលពួកបុរសកើតអំពីខត្តិយត្រកូល អំពីព្រាហ្មណត្រកូល អំពីរាជញ្ញត្រកូល យកពំនួតភ្លើងខាងលើ (ជាវិការៈ) នៃឈើស្រាយក្តី ឈើខ្ទឹមក្តី

សលឡស្ស វា ចន្ទនស្ស វា បទុមកស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ ចាតុកតោ ស្វាស្ស អគ្គិ អច្ចិមា ចេវ វណ្ណិមា ច បភស្សរោ ច តេន ច សក្កា អគ្គិនា អគ្គិករ-ណីយំ កាតុំ យោបិ សោ ចណ្ឌាលកុលា នេសា-ទកុលា វេណុកុលា រថការកុលា បុក្កុសកុលា ឧប្បន្នេហិ សាចានទោណិយា វា សូករទោណិយា វា រជកទោណិយា វា ឯលណ្ឌកដ្ឋស្ស វា ឧត្តរារណឹ អាទាយ អគ្គិ អភិនិព្វត្តោ តេជោ ចាតុកតោ សោ-បិស្ស អគ្គិ អច្ចិមា ចេវ វណ្ណិមា ច បភស្សរោ ច តេនបិ ច សក្កា អគ្គិនា អគ្គិករណីយំ កាតុំ សព្វោបិ ហិ ភោ គោតម អគ្គិ អច្ចិមា ចេវ វណ្ណិមា ច បភស្សរោ ច សព្វេនបិ ច សក្កា អគ្គិនា អគ្គិករណីយំ កាតុន្តិ ។

ដើមស្រល់ក្តី ដើមចន្ទន៍ក្តី ឬដើមឈូកក្រហមក្តី មកពួតបង្កាត់ ភ្លើងក៏ឆេះប្រាកដឡើង ភ្លើងនោះ មានអណ្តាតផង មានពណ៌ផង មានពន្លឺផង គេអាចធ្វើការដែលត្រូវធ្វើដោយភ្លើង នឹងភ្លើងនោះក៏បាន ចំណែកភ្លើងណា ដែលពួកបុរសកើតអំពីចណ្ឌាលត្រកូល អំពីនេសាទ-ត្រកូល អំពីវេណុត្រកូល អំពីរថការត្រកូល អំពីបុក្កុសត្រកូល កាន់យកនូវពំនួតភ្លើងខាងលើ (ជាវិការៈ) នៃស្នូកឆ្កែក្តី ស្នូកជ្រូកក្តី ស្នូកជាងជ្រលក់ក្តី ដើមល្ហុងប្រេងក្តី មកពួតបង្កាត់ ភ្លើងក៏ឆេះប្រាកដឡើង ភ្លើងនោះសោត ក៏មានអណ្តាតដូចគ្នា មានពណ៌ដូចគ្នា មានពន្លឺក៏ដូចគ្នាដែរ ទាំងគេអាចធ្វើការដែលត្រូវធ្វើដោយភ្លើង នឹងភ្លើងនោះក៏បាន បពិត្រព្រះគោតមដ៏ចម្រើន ដ្បិតភ្លើងទាំងអស់ សុទ្ធតែមានអណ្តាតផង មានពណ៌ផង មានពន្លឺផង ទាំងគេអាចធ្វើការដែលត្រូវធ្វើដោយភ្លើង នឹងភ្លើងនោះបាន ទាំងអស់ ។

[៨៧] ឯវមេវ ខោ ព្រាហ្មណា ខត្តិយកុលា ចេបិ អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្ន-ចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ ព្រាហ្ម-ណកុលា ចេបិ ព្រាហ្មណា... វេស្សកុលា ចេបិ ព្រាហ្មណា... សុទ្ទកុលា ចេបិ ព្រាហ្មណា អគារស្មា អនគារិយំ បព្វជិតោ ហោតិ សោ ច តថាគតប្បវេទិតំ ធម្មវិនយំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ

[៨៧] ម្នាលព្រាហ្មណ៍ បើកុលបុត្រចេញចាកផ្ទះ អំពីខត្តិយត្រកូលហើយចូលទៅកាន់ផ្នួស កុលបុត្រនោះបានអាស្រ័យធម៌វិន័យដែលតថាគតបានសំដែងហើយ ជាបុគ្គលវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ជាអ្នកត្រេកអរនឹងកុសលធម៌ដែលជាតួហេតុ ។ ម្នាលព្រាហ្មណ៍ បើកុលបុត្រ ចេញចាកផ្ទះអំពីព្រាហ្មណត្រកូល... ម្នាលព្រាហ្មណ៍ បើកុលបុត្រ ចេញចាកផ្ទះអំពីវេស្សត្រកូល... ម្នាលព្រាហ្មណ៍ បើកុលបុត្រ ចេញចាកផ្ទះអំពីសុទ្ទត្រកូល ហើយចូលទៅកាន់ផ្នួស កុលបុត្រនោះឯង បានអាស្រ័យធម៌វិន័យ ដែលតថាគតបានសំដែងហើយ ជាបុគ្គលវៀរចាកបាណាតិបាត

អនិជ្ឈាធាជា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ អាវាដកោ ហោតិ ញាយំ ធម្មំ កុសលន្តិ ។

[៨៨] ឯវំ វុត្តេ ឯសុការី ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។ បេ ។ ឧ-ចាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ ចាណុបេតំ សរណាគ្គតន្តិ ។

ឯសុការីសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

វៀរចាកអទិន្នាទាន វៀរចាកអព្រហ្មចរិយៈ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ជាអ្នកត្រេកអរនឹងកុសលធម៌ ដែលជាតួហេតុ ក៏ដូចគ្នានឹងរឿងបង្កាត់ភ្លើងយ៉ាងនោះដែរ ។

[៨៨] កាលបើព្រះសព្វញ្ញូ ទ្រង់ត្រាស់យ៉ាងនេះហើយ ឯសុការីព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ តាំងពីថ្ងៃនេះតទៅ សូមព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត ។

ចប់ ឯសុការីសូត្រ ទី ៦ ។

# សត្តមំ ធនញ្ជានិសុត្តំ(១)

[៨៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ទក្ខិណាគិរិស្មឹ ចារិកញ្ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ អថខោ អញ្ញតរោ ភិក្ខុ រាជគហេ វស្សំ វុត្ថោ យេន ទក្ខិណាគិរិ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[៩០] ឯកមន្តំ និសិន្នំ ខោ តំ ភិក្ខុំ អាយស្មា សារីបុត្តោ ឯតទវោច កច្ចាវុសោ ភគវា អរោគោ ច ពលវា ចាតិ ។ អរោគោ ចាវុសោ ភគវា ពលវា ចាតិ ។ កច្ចិ បនាវុសោ ភិក្ខុសង្ឃោ អរោគោ ច ពលវា ចាតិ ។

១ ឱ. ធានញ្ជានិសុត្តំ ។ ២ ម. ធនញ្ជានីសុត្តំ ។

# ធនញ្ជានិសូត្រ ទី ៧

[៨៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសារីបុត្រមានអាយុ ត្រាច់ទៅកាន់ចារិក ក្នុងទក្ខិណាគិរិជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ គ្រានោះ មានភិក្ខុមួយរូបនៅចាំវស្សាក្នុងក្រុងរាជគ្រឹះ រួចហើយក៏ចូលទៅរកព្រះសារីបុត្រមានអាយុ ឯទក្ខិណាគិរិជនបទ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់ជាមួយនឹងព្រះសារីបុត្រមានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់និងគួររីករាយហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[៩០] ព្រះសារីបុត្រមានអាយុ បានសួរភិក្ខុនោះ ដែលអង្គុយក្នុងទីដ៏សមគួរយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ មិនមានអាពាធ ទាំងមានព្រះកាយពលទេឬ ។ ម្នាលអាវុសោ ព្រះមានព្រះភាគមិនមានអាពាធ ទាំងមានព្រះកាយពលទេ ។ ម្នាលអាវុសោ ចំណែកខាងភិក្ខុសង្ឃ មិនមានរោគ ទាំងមានកម្លាំងទេឬ ។

១៧១

ភិក្ខុសង្ឃោបិ ខោ អាវុសោ អរោគោ ច ពលវា ចាតិ ។ ឯត្ថ អាវុសោ តណ្ឌុលបាលទ្វារាយំ ធនញ្ជានិ នាម ព្រាហ្មណោ អត្ថិ កច្ចាវុសោ ធនញ្ជានិ[១] ព្រាហ្មណោ អរោគោ ច ពលវា ចាតិ ។ ធនញ្ជានិបិ ខោ អាវុសោ ព្រាហ្មណោ អរោគោ ច ពលវា ចាតិ ។ កច្ចិ បនាវុសោ ធនញ្ជានិ ព្រាហ្មណោ អប្បមត្តោតិ ។ កុតោ[២] នោ អាវុសោ ធនញ្ជានិស្ស ព្រាហ្មណស្ស អប្បមាទោ ធនញ្ជានិ អាវុសោ ព្រាហ្មណោ រាជានំ និស្សាយ ព្រាហ្មណគហបតិកេ វិលុម្បតិ ព្រាហ្មណគហបតិកេ និស្សាយ រាជានំ វិលុម្បតិ យាបិស្ស ភរិយា សទ្ធា សទ្ធា កុលា អានីតា សាបិ[៣] កាលកតា អញ្ញស្ស ភរិយា

១ ឱ. ម. ឯត្ថន្តរេ នាមាតិ ទិស្សតិ ។ ២ ម. កុតោ បនាវុសោ ។ ៣ ឱ. សាបិស្ស ។

ម្នាលអាវុសោ ភិក្ខុសង្ឃ មិនមានរោគ ទាំងមានកម្លាំង ដែរ ។ ម្នាលអាវុសោ ក្នុងស្រុកតណ្ឌុលបាលទ្វារ[១] ក្នុងក្រុងរាជគ្រឹះនុ៎ះ មាន ព្រាហ្មណ៍ឈ្មោះធនញ្ជានិ ម្នាលអាវុសោ ធនញ្ជានិព្រាហ្មណ៍ (នោះ) មិនមានរោគ ទាំងមានកម្លាំង ដែរឬ ។ ម្នាលអាវុសោ ឯធនញ្ជានិ-ព្រាហ្មណ៍មិនមានរោគ ទាំងមានកម្លាំង ដែរ ។ ម្នាលអាវុសោ ចុះធនញ្ជានិព្រាហ្មណ៍ មិនប្រហែសធ្វេសទេឬ ។ ម្នាលអាវុសោ សេចក្ដីមិនធ្វេសប្រហែល របស់ធនញ្ជានិព្រាហ្មណ៍ មានពីណា ម្នាល អាវុសោ ព្រោះធនញ្ជានិព្រាហ្មណ៍ អាងព្រះរាជាក៏រឹបជាន់ពួកព្រាហ្មណ៍ និងគហបតី អាងពួកព្រាហ្មណ៍និងគហបតី ក៏បោកប្រាស់ព្រះរាជា ឯភរិយារបស់គាត់ មានសទ្ធា ដែលគាត់នាំមកអំពីត្រកូលមានសទ្ធា នាងនោះ ក៏ធ្វើកាលកិរិយាទៅហើយ ភរិយាឯទៀត ដែលគាត់

---

១ ក្នុងអដ្ឋកថា ថា ក្នុងក្រុងរាជគ្រឹះ មានទ្វារធំៗ ៣២ មានទ្វារតូចៗ ៦៤ ។ ក្នុងទ្វារទាំងធំទាំងតូចនោះ មានទ្វារ ១ នេះ ឈ្មោះតណ្ឌុលបាលទ្វារ ។

អស្សទ្ធា អស្សទ្ធា កុលា អានីតាតិ ។ ទុស្សុតំ វតាវុសោ អស្សុម្ហា យេ មយំ ធនញ្ជានឹ ព្រាហ្មណំ បមត្តំ អស្សុម្ហា អប្បេវ នាម មយំ កទាចិ ករហចិ ធនញ្ជានិនា ព្រាហ្មណេន សទ្ធឹ សមាគច្ឆេយ្យាម អប្បេវ នាម សិយា កោចិទេវ កថាសល្លាបោតិ ។ អថខោ អាយស្មា សារីបុត្តោ ទក្ខិណាគិរិស្មឹ យថាភិរន្តំ វិហរិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកញ្ចរមានោ យេន រាជ-គហំ តទវសរិ ។

[៩១] តត្រ សុទំ អាយស្មា សារីបុត្តោ រាជ-គហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថ-ខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បាវិសិ ។ តេន ខោ បន សមយេន ធនញ្ជានិ ព្រាហ្មណោ ពហិនគរេ គាវោ គោដ្ឋេ ទុហាបេតិ ។ អថខោ អាយស្មា សារីបុត្តោ

នាំមកអំពីត្រកូល មិនមានសទ្ធា ក៏ជាស្ត្រីមិនមានសទ្ធា ។ ម្នាលអាវុសោ យើងបានឮថា ធនញ្ជានិព្រាហ្មណ៍មានសេចក្តីប្រហែសធ្វេស ឈ្មោះថាបានឮដំណឹងមិនល្អហើយ ធ្វើដូចម្តេចហ្ន៎ យើងនឹងបានចួបធនញ្ជានិព្រាហ្មណ៍ម្តងទៅអេះ ធ្វើម្តេចហ្ន៎ នឹងបាននិយាយចរចាម្តងទៅអេះ ។ ទើបព្រះសារីបុត្រមានអាយុ នៅតាមសប្បាយក្នុងទក្ខិណាគិរី ហើយចេញទៅកាន់ចារិកសំដៅទៅត្រង់ក្រុងរាជគ្រឹះ កាលត្រាច់ទៅកាន់ចារិកតាមលំដាប់ ក៏បានដល់ទៅក្រុងរាជគ្រឹះនោះ ។

[៩១] សេចក្តីដំណាលថា ព្រះសារីបុត្រមានអាយុ នៅអាស្រ័យក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះនោះ ។ គ្រានោះ ព្រះសារីបុត្រមានអាយុ ស្លៀកស្បង់ ទ្រង់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងរាជគ្រឹះ ។ ចួនសម័យនោះឯង ធនញ្ជានិព្រាហ្មណ៍ ឲ្យពួកមនុស្សរឹតទឹកដោះគោទាំងឡាយ ក្នុងឃ្នងគោ នាខាងក្រៅនគរ ។ គ្រានោះ ព្រះសារីបុត្រ មានអាយុ

រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌ-ចាតប្បដិក្កន្តោ យេន ធនញ្ជានិ ព្រាហ្មណោ តេនុបសង្កមិ ។ អទ្ទសា ខោ ធនញ្ជានិ ព្រាហ្មណោ អាយស្មន្តំ សារីបុត្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ ឯតទវោច ឥតោ ភោ សារីបុត្ត បយោ បីយតំ តាវ ភត្តស្ស កាលោ ភវិស្សតីតិ ។ អលំ ព្រាហ្មណ កតំ មេ អជ្ជ ភត្តកិច្ចំ អមុ-កស្មឹ មេ រុក្ខមូលេ ទិវាវិហារោ ភវិស្សតិ តត្រ អាគច្ឆេយ្យាសីតិ ។ ឯវំ ភោតិ ខោ ធនញ្ជានិ ព្រា-ហ្មណោ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសិ ។ អថខោ ធនញ្ជានិ ព្រាហ្មណោ បច្ឆាភត្តំ ភុត្ត-ចាតរាសោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ កាលត្រឡប់ពីបិណ្ឌបាត ក្នុងពេលខាងក្រោយនៃភត្ត ក៏ចូលទៅរកធនញ្ជានិព្រាហ្មណ៍ ។ ធនញ្ជានិ-ព្រាហ្មណ៍ បានឃើញព្រះសារីបុត្រ មានអាយុ កំពុងនិមន្តមកអំពីចម្ងាយ ក៏ដើរចូលទៅរកព្រះសារីបុត្រ មានអាយុ លុះចូលទៅដល់ហើយ និយាយនឹងព្រះសារីបុត្រ មានអាយុ យ៉ាងនេះថា បពិត្រព្រះសារីបុត្រដ៏ចម្រើន សូមលោកនិមន្តមកណេះបន្តិច សូមព្រះសារីបុត្រឆាន់ទឹកដោះសិន ទម្រាំដល់ភត្តកាល ។ ម្នាលព្រាហ្មណ៍ កុំឡើយថ្ងៃនេះ អាត្មាធ្វើភត្តកិច្ចរួចហើយ អាត្មានឹងទៅនៅសម្រាកក្នុងវេលាថ្ងៃឯម្លប់ឈើឯណោះ អ្នកត្រូវមកក្នុងទីនោះ ។ ឯធនញ្ជានិព្រាហ្មណ៍ក៏ទទួលស្តាប់ព្រះសារីបុត្រមានអាយុថា ករុណា លោកដ៏ចម្រើន ។ ពេលនោះ ធនញ្ជានិព្រាហ្មណ៍ បរិភោគក្នុងវេលាព្រឹករួចហើយដល់ពេលជាខាងក្រោយនៃភត្ត ក៏ចូលទៅរកព្រះសារីបុត្រ មានអាយុលុះចូលទៅដល់ហើយ ក៏រាក់ទាក់ជាមួយព្រះសារីបុត្រ មានអាយុលុះបញ្ចប់ពាក្យគួររាក់ទាក់និងគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។

[៩២] ឯកមន្តំ និសិន្នំ ខោ ធនញ្ជានឹ ព្រាហ្មណំ អាយស្មា សារីបុត្តោ ឯតទវោច កច្ចិសិ ធនញ្ជានិ អប្បមត្តោតិ ។ កុតោ ភោ សារីបុត្ត អម្ហាកំ អប្បមាទោ យេសន្នោ មាតាបិតរោ បោសេតព្វា បុត្តទារោ បោសេតព្វោ ទាសកម្មករបោរិសំ បោសេតព្វំ មិត្តាមច្ចានំ មិត្តាមច្ចករណីយំ កាតព្វំ ញាតិសាលោហិតានំ ញាតិសាលោហិតករណីយំ កាតព្វំ អតិថីនំ អតិថិករណីយំ កាតព្វំ បុព្វបេតានំ បុព្វបេតករណីយំ កាតព្វំ ទេវតានំ ទេវតាករណីយំ កាតព្វំ រញ្ញោ រាជករណីយំ កាតព្វំ អយម្បិ កាយោ បិណេតព្វោ ព្រូហេតព្វោតិ ។

[៩៣] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ មាតាបិតូនំ ហេតុ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចរិយវិសមចរិយាហេតុ[១] និរយំ និរយបាលា ឧបកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ

១ ឱ. ម. អធម្មចរិយាវិសមចរិយាហេតុ ។

[៩២] ព្រះសារីបុត្រមានអាយុ បាននិយាយនឹងធនញ្ជានិព្រាហ្មណ៍ ដែលអង្គុយក្នុងទីសមគួរហើយយ៉ាងនេះថា ម្នាលធនញ្ជានិ អ្នកជាបុគ្គលមិនប្រហែសធ្វេសទេឬ ។ បពិត្រព្រះសារីបុត្រ ដ៏ចម្រើន សេចក្តីមិនប្រហែសធ្វេសរបស់យើង នឹងមានមកពីណា ព្រោះយើងត្រូវចិញ្ចឹមមាតាបិតា ត្រូវចិញ្ចឹមកូនប្រពន្ធ ត្រូវចិញ្ចឹមខ្ញុំនិងបុរសអ្នកធ្វើការ ត្រូវធ្វើកិច្ចរបស់មិត្រអាមាត្យ ដល់ពួកមិត្រអាមាត្យ ត្រូវធ្វើកិច្ចរបស់ញាតិសាលោហិត ដល់ពួកញាតិសាលោហិត ត្រូវធ្វើកិច្ចរបស់ភ្ញៀវ ដល់ពួកភ្ញៀវ ត្រូវធ្វើកិច្ចរបស់បុព្វបេត ដល់ពួកបុព្វបេត ត្រូវធ្វើកិច្ចរបស់ទេវតា ដល់ពួកទេវតា ត្រូវធ្វើរាជកិច្ចដល់ព្រះរាជា សូម្បីកាយនេះ យើងក៏ត្រូវចិញ្ចឹមឲ្យធាត់ធំចម្រើន ។

[៩៣] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តខុសគន្លងធម៌[១] ប្រព្រឹត្តមិនស្មើ ព្រោះហេតុមាតាបិតា ពួកនិរយបាល ទង់ទាញបុគ្គលនោះទៅទម្លាក់ក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ តើបុគ្គលនោះគួរអង្វរថា

១ សំដៅយកមនុស្សទ្រុស្តសីល ៥ ឬទ្រុស្តសីល ១០ ។ អដ្ឋកថា ។

អហំ ខោ មាតាបិតូនំ ហេតុ អធម្មចារី វិសមចារី
អហោសឹ មា មំ និរយំ និរយបាលាតិ មាតាបិតរោ
វា បនស្ស លភេយ្យុំ ឯសោ ខោ អម្ហាកំ ហេតុ
អធម្មចារី វិសមចារី អហោសិ មា នំ និរយំ
និរយបាលាតិ ។ នោ ហិទំ ភោ សារីបុត្ត
អថខោ នំ វិក្កន្ទន្តំយេវ និរយេ និរយបាលា
បក្ខិបេយ្យុំ ។

[៩៤] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ
បុត្តទារស្ស ហេតុ អធម្មចារី វិសមចារី អស្ស
តមេនំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយ-
បាលា ឧបកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ
អហំ ខោ បុត្តទារស្ស ហេតុ អធម្មចារី
វិសមចារី អហោសឹ មា មំ និរយំ និរយបា-
លាតិ បុត្តទារោ វា បនស្ស លភេយ្យ
ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិសមចារី
អហោសិ មា នំ និរយំ និរយបាលាតិ ។

ខ្ញុំបានជាអ្នកប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុមាតាបិតា សូមកុំឲ្យពួកនិរយបាល ទង់ទាញខ្ញុំទៅនរកឡើយ ដូច្នេះបានដែរឬ ឬក៏មាតាបិតា អង្វរដើម្បីអ្នកនោះថា កូននោះបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុយើងទាំងឡាយ សូមកុំឲ្យពួកនិរយបាលនាំយកវាទៅទម្លាក់ក្នុងនរកឡើយ ដូច្នេះបានដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ក៏ពួកនិរយបាលនៅតែទម្លាក់បុគ្គលកំពុងកន្ទក់កន្ទេញនោះទៅក្នុងនរកពុំខាន ។

[៩២] ម្នាលធនញ្ជានិ អ្នកយល់សេចក្ដីនោះដូចម្ដេច បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុកូនប្រពន្ធ ពួកនិរយបាលទង់ទាញបុគ្គលនុ៎ះ ទៅទម្លាក់ក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ អ្នកនោះគួរអង្វរថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែកូនប្រពន្ធ សូមកុំឲ្យពួកនិរយបាល ទង់ទាញខ្ញុំទៅទម្លាក់ក្នុងនរកឡើយ ដូច្នេះបានដែរឬ ឬក៏កូននិងប្រពន្ធអ្នកនោះអង្វរថា អ្នកនុ៎ះបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុយើងទាំងឡាយ សូមកុំឲ្យពួកនិរយ-បាល ទង់ទាញអ្នកនោះទៅទម្លាក់ក្នុងនរកឡើយ ដូច្នេះបានដែរឬ ។

ជោ ហិទំ ភោ សារីបុត្ត អជទោ នំ វិកាឌ្ឍន្តំយេវ និរយេ និរយបាលា បក្ខិបេយ្យុំ ។

[៩៥] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ ទាសកម្មករចោរិសស្ស ហេតុ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយបាលា ឧបកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ អហំ ខោ ទាសកម្មករចោរិសស្ស ហេតុ អធម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយបាលាតិ ទាសកម្មករចោរិសំ វា បនស្ស លភេយ្យ ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិសមចារី អហោសិ មា នំ និរយំ និរយបាលាតិ ។ ជោ ហិទំ ភោ សារីបុត្ត អជទោ នំ វិកាឌ្ឍន្តំយេវ និរយេ និរយបាលា បក្ខិបេយ្យុំ ។

បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះក៏គង់តែពួកនិរយបាល ទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះទៅក្នុងនរកពុំខាន ។

[៩៥] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុទាសៈនិងបុរសជាកម្មករ ពួកនិរយបាលទង់ទាញបុគ្គលនោះទម្លាក់ទៅក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ បុគ្គលនោះគួរអង្វរថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែទាសៈនិងបុរសជាកម្មករ សូមកុំឲ្យពួកនិរយបាល ទង់ទាញខ្ញុំទៅទម្លាក់ក្នុងនរកឡើយ ដូច្នេះបានដែរឬ ឬក៏ទាសៈនិងបុរសជាកម្មកររបស់បុគ្គលនោះគួរអង្វរថា ចៅហ្វាយខ្ញុំនុ៎ះបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែយើងទាំងឡាយ សូមកុំឲ្យពួកនិរយបាល ទម្លាក់ចៅហ្វាយខ្ញុំនោះទៅក្នុងនរកឡើយ ដូច្នេះបានដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះមិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ពួកនិរយបាលក៏នៅតែទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះទៅក្នុងនរកពុំខាន ។

[៩៦] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ មិត្តាមច្ចានំ ហេតុ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយបាលា ឧ-បកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ អហំ ខោ មិត្តាមច្ចានំ ហេតុ អធម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយបាលាតិ មិត្តាមច្ចា វា បនស្ស លភេយ្យុំ ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិស-មចារី អហោសិ មា នំ និរយំ និរយបាលាតិ ។ នោ ហិទំ ភោ សារីបុត្ត អថខោ នំ វិកន្ទន្តំយេវ និរយេ និរយបាលា បក្ខិបេយ្យុំ ។

[៩៦] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុមិត្រអាមាត្យទាំងឡាយ ពួកនិរយបាលទង់ទាញបុគ្គលនោះទម្លាក់ទៅក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ បុគ្គលនោះគួរអង្វរថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុមិត្រអាមាត្យទាំងឡាយ សូមកុំឲ្យពួកនិរយបាល ទម្លាក់ខ្ញុំទៅក្នុងនរកឡើយ យ៉ាងនេះបានដែរឬ ឬក៏ពួកមិត្រអាមាត្យរបស់បុគ្គលនោះគួរអង្វរថា អ្នកនុ៎ះបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុយើងទាំងឡាយ សូមកុំឲ្យពួកនិរយបាលទម្លាក់អ្នកនោះទៅក្នុងនរកឡើយ យ៉ាងនេះបានដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ពួកនិរយបាលក៏នៅតែទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះទៅក្នុងនរកពុំខាន ។

[៩៧] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ ញាតិសាលោហិតានំ ហេតុ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយបាលា ឧបកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ អហំ ខោ ញាតិសាលោហិតានំ ហេតុ អធម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយបាលាតិ ញាតិសាលោហិតា វា បនស្ស លភេយ្យុំ ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិសមចារី អហោសិ មា នំ និរយំ និរយបាលាតិ ។ នោ ហិទំ ភោ សារីបុត្ត អថខោ នំ វិក្កន្ទន្តំយេវ និរយេ និរយបាលា បក្ខិបេយ្យុំ ។

[៩៧] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុញាតិសាលោហិតទាំងឡាយ ពួកនិរយបាលទង់ទាញអ្នកនោះទម្លាក់ទៅក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ អ្នកនោះគួរអង្វរថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុញាតិសាលោហិតទាំងឡាយ សូមកុំឲ្យពួកនិរយបាល ទម្លាក់ខ្ញុំក្នុងនរកឡើយ ដូច្នេះបានដែរឬ ឬក៏ពួកញាតិសាលោហិតរបស់អ្នកនោះគួរអង្វរថា អ្នកនុ៎ះបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែយើងទាំងឡាយ សូមកុំឲ្យពួកនិរយបាល ទម្លាក់អ្នកនុ៎ះក្នុងនរកឡើយ យ៉ាងនេះបានដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះមិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ក៏គង់តែពួកនិរយបាលទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះ ទៅក្នុងនរកដែរ ។

[៩៨] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ អតិថីនំ ហេតុ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយបាលា ឧបកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ អហំ ខោ អតិថីនំ ហេតុ អធម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយបាលាតិ អតិថិយោ វា បនស្ស លភេយ្យុំ ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិសមចារី អហោសិ មា នំ និរយំ និរយបាលាតិ ។ នោ ហិទំ ភោ សារីបុត្ត អថខោ នំ វិក្កន្ទន្តំយេវ និរយេ និរយបាលា បក្ខិបេយ្យុំ ។

[៩៩] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ បុព្វបេតានំ ហេតុ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយបាលា ឧបកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ

[៩៨] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុភ្ញៀវទាំងឡាយ ពួកនិរយបាល ទង់ទាញអ្នកនោះទៅទម្លាក់ក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ អ្នកនោះគួរអង្វរថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែភ្ញៀវទាំងឡាយ សូមកុំឲ្យពួកនិរយបាលទម្លាក់ខ្ញុំទៅក្នុងនរកឡើយ ដូច្នេះបានដែរឬ ឬក៏ពួកភ្ញៀវរបស់អ្នកនោះគួរអង្វរថា អ្នកនុ៎ះឯងបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែយើងទាំងឡាយ សូមកុំឲ្យពួកនិរយបាលទម្លាក់អ្នកនោះទៅក្នុងនរកឡើយ ដូច្នេះបានដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ពួកនិរយ-បាលក៏នៅតែទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះទៅក្នុងនរកពុំខាន ។

[៩៩] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុបុព្វបេតៈទាំងឡាយ ពួកនិរយបាល ទង់ទាញមនុស្សនោះទម្លាក់ទៅក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ បុគ្គលនោះគួរអង្វរថា

អហំ ខោ បុព្វេ បេតានំ ហេតុ អធម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយបាលាតិ បុព្វេ បេតា វា បនស្ស លភេយ្យុំ ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិសមចារី អហោសិ មា នំ និរយំ និរយបាលាតិ ។ តោ ហិនំ កោ សារីបុត្ត អថខោ នំ វិការន្តុំ យេវ និរយេ និរយបាលា បក្ខិបេយ្យុំ ។

[១០០] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកច្ចោ ទេវតានំ ហេតុ អធម្មចារី វិសមចារី អស្ស តមេនំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយបាលា ឧបកឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ អហំ ខោ ទេវតានំ ហេតុ អធម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយបាលាតិ ទេវតា វា បនស្ស លភេយ្យុំ ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិសមចារី អហោសិ មា នំ និរយំ និរយបាលាតិ ។

ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុបុព្វបេតៈទាំងឡាយ សូមកុំឲ្យពួកនិរយបាលទម្លាក់ខ្ញុំទៅក្នុងនរកឡើយ ដូច្នេះបានដែរឬ ឬក៏ពួកបុព្វបេតៈរបស់អ្នកនោះ អង្វរថា មនុស្សនោះ បានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែយើងទាំងឡាយ សូមកុំឲ្យពួកនិរយបាលទម្លាក់អ្នកនោះទៅក្នុងនរកឡើយ ដូច្នេះបានដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ពួកនិរយបាល ក៏នៅតែទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះ ទៅក្នុងនរកដែរ ។

[១០០] ម្នាលធនញ្ជានិ អ្នកយល់សេចក្ដីនោះដូចម្ដេច បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុទេវតាទាំងឡាយ ពួកនិរយបាល ទង់ទាញអ្នកនោះទម្លាក់ទៅក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ បុគ្គលនោះគួរអង្វរថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែទេវតាទាំង-ឡាយ សូមកុំឲ្យពួកនិរយបាល ទម្លាក់ខ្ញុំទៅក្នុងនរកឡើយ ដូច្នេះបានដែរឬ ឬក៏ពួកទេវតារបស់អ្នកនោះ គួរអង្វរថា បុគ្គលនុ៎ះ បានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែយើងទាំងឡាយ សូមកុំឲ្យពួកនិរយបាលទម្លាក់អ្នកនោះទៅក្នុងនរកឡើយ ដូច្នេះបានដែរឬ ។

ឆោ ហិធំ ភោ សារីបុត្ត អថខោ ធំ វិកាន្ធគ្គំយេវ និរយេ និរយចាលា បក្ខិបេយ្យុំ ។

[១០១] តំ កឹ មញ្ញសិ ធនញ្ជានិ ឥធេកាច្ចោ រញ្ញោ ហេតុ អធម្មចារី វិសមចារី អស្ស តមេធំ អធម្មចរិយវិសមចរិយាហេតុ និរយំ និរយចាលា ឧប-កឌ្ឍេយ្យុំ លភេយ្យ នុ ខោ សោ អហំ ខោ រញ្ញោ ហេតុ អធម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយចាលាតិ រាជា វា បនស្ស លភេយ្យ ឯសោ ខោ អម្ហាកំ ហេតុ អធម្មចារី វិសមចារី អហោសិ មា ធំ និរយំ និរយចាលាតិ ។ ឆោ ហិធំ ភោ សារីបុត្ត អថខោ ធំ វិកាន្ធគ្គំយេវ និរយេ និរយចា-លា បក្ខិបេយ្យុំ ។

បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះពួកនិរយបាល ក៏នៅតែទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះទៅក្នុងនរកដែរ ។

[១០១] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច មនុស្សពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែព្រះរាជា ពួកនិរយបាលក៏ទង់ទាញយកមនុស្សនោះ ទម្លាក់ទៅក្នុងនរកព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ មនុស្សនោះត្រូវបានពាក្យប្រកែកថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែព្រះរាជា សូមកុំឲ្យពួកនិរយបាលទម្លាក់ខ្ញុំក្នុងនរកឡើយ ដូច្នេះដែរឬ ឬក៏ព្រះរាជារបស់អ្នកនោះ ត្រូវបានសេចក្តីហាមប្រាមថា មនុស្សនោះបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែយើង សូមកុំឲ្យពួកនិរយបាល ទម្លាក់អ្នកនោះក្នុងនរកឡើយ ដូច្នេះដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ពួកនិរយបាល ក៏នៅតែទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះទៅក្នុងនរកដែរ ។

[១០២] តំ កឹ មញ្ញសិ ជនញ្ជានិ ឥដេកច្ចោ កាយស្ស បិណាជាហេតុ ព្រូហាជាហេតុ អជម្មចារី វិសមចារី អស្ស តមេជំ អជម្មចរិយវិសមចរិយាហេតុ និរយំ និរយបាលា ឧបកឌ្ឍេយ្យុំ លភេយ្យ ជុ ខោ សោ អហំ ខោ កាយស្ស បិណាជាហេតុ ព្រូហាជាហេតុ អជម្មចារី វិសមចារី អហោសឹ មា មំ និរយំ និរយបាលាតិ បរេ វា បជស្ស លភេយ្យុំ ឯសោ ខោ កាយស្ស បិណាជាហេតុ ព្រូហាជាហេតុ អជម្មចារី វិសមចារី អហោសិ មា ជំ និរយំ និរយបាលាតិ ។ ជោ ហិជំ ភោ សារីបុត្ត អថខោ ជំ វិក្កន្ទន្តំយេវ និរយេ និរយបាលា បក្ខិបេយ្យុំ ។

[១០៣] តំ កឹ មញ្ញសិ ជនញ្ជានិ យោ វា មាតាបិតូជំ ហេតុ អជម្មចារី វិសមចារី អស្ស យោ វា មាតាបិតូជំ ហេតុ ជម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។

[១០២] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច មនុស្សពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែចិញ្ចឹមកាយ ឲ្យជាត់ធំចម្រើន ពួកនិរយបាល ចាប់ទាញមនុស្សនោះទម្លាក់ក្នុងនរក ព្រោះហេតុតែការប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ មនុស្សនោះត្រូវបានសេចក្តីអង្វរថា ខ្ញុំបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែការចិញ្ចឹមកាយឲ្យជាត់ធំចម្រើន សូមកុំឲ្យពួកនិរយបាល ទម្លាក់ខ្ញុំក្នុងនរកឡើយ ឬក៏ពួកមនុស្សឯទៀតរបស់អ្នកនោះ ត្រូវបានសេចក្តីជួយអង្វរថា មនុស្សនោះបានជាប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែការចិញ្ចឹមកាយ ឲ្យជាត់ធំចម្រើន សូមកុំឲ្យពួកនិរយបាល ទម្លាក់អ្នកនោះក្នុងនរកឡើយ ដូច្នេះបានដែរឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ដំណើរនេះ មិនបានជាដាច់ខាត បើទុកជាយ៉ាងនោះ ពួកនិរយបាល ក៏នៅតែទម្លាក់អ្នកដែលកំពុងកន្ទក់កន្ទេញនោះក្នុងនរកដែរ ។

[១០៣] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះ ដូចម្តេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុមាតានិងបិតាទាំងឡាយក្តី មនុស្សដែលប្រព្រឹត្តត្រូវធម៌[១] ប្រព្រឹត្តស្មើ ព្រោះហេតុតែមាតានិងបិតាទាំងឡាយក្តី អំពើណាប្រសើរជាង ។

១ អដ្ឋកថា ថាបានដល់ការងារទាំងឡាយមានភ្ជួររាស់និងជំនួញដែលប្រកដោយធម៌ជាដើម ។

យោ ហិ ភោ សារីបុត្ត មាតាបិតូនំ ហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សារីបុត្ត មាតាបិតូនំ ហេតុ ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិសមចរិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។ អត្ថិ ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា មាតាបិតរោ ចេវ បោសេតុំ ន ច បាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុំ ។

[១០៤] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា បុត្តទារស្ស ហេតុ អធម្មចារី វិសមចារី អស្ស យោ វា បុត្តទារស្ស ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ សារីបុត្ត បុត្តទារស្ស ហេតុ អធម្មចារី វិសមចារី

បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុមាតាបិតា អំពើនោះមិនប្រសើរទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុមាតាបិតា អំពើនោះឯង ទើបឈ្មោះថា ប្រសើរក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តត្រូវធម៌ និងការប្រព្រឹត្តស្មើ ប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយដទៃ ដែលត្រូវធម៌ ប្រកបដោយហេតុ ដែលពួកមនុស្សអាចចិញ្ចឹមមាតាបិតាបានផង មិនធ្វើបាបកម្មផង អាចប្រតិបត្តិនូវបដិបទាជាហេតុឲ្យកើតបុណ្យផង មានដែរតើ ។

[១០៤] ម្នាលធនញ្ជានិ អ្នកយល់សេចក្ដីនោះ ដូចម្ដេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះតែកូននិងប្រពន្ធក្ដី មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែកូននិងប្រពន្ធក្ដី អំពើណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែកូននិងប្រពន្ធ

អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សា-
រីបុត្ត បុត្តទារស្ស ហេតុ ធម្មចារី សមចារី អស្ស
តទេវេត្ថ សេយ្យោ អធម្មចរិយវិសមចរិយាហិ ភោ
សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។ អត្ថិ
ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា
យេហិ សក្កា បុត្តទារេ ចេវ ចោសេតុំ ន ច
ចាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុំ ។

[១០៥] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា ទាស-
កម្មករចោរិសស្ស ហេតុ អធម្មចារី វិសមចារី អស្ស
យោ វា ទាសកម្មករចោរិសស្ស ហេតុ ធម្មចារី
សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ
សារីបុត្ត ទាសកម្មករចោរិសស្ស ហេតុ អធម្មចារី
វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ
ភោ សារីបុត្ត ទាសកម្មករចោរិសស្ស ហេតុ
ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ

អំពើនោះមិនប្រសើរទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន ចំណែកឯមនុស្ស ដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែកូននិងប្រពន្ធ អំពើនោះឯង ទើបប្រសើរក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយដទៃដែលត្រូវធម៌ ប្រកបដោយហេតុ ដែលពួកមនុស្សអាចចិញ្ចឹមកូននិងប្រពន្ធបានផង មិនបាច់ធ្វើបាបកម្មផង អាចប្រតិបត្តិនូវបដិបទាជាហេតុឲ្យកើតបុណ្យបានផង មានដែរតើ ។

[១០៥] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះ ដូចម្តេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែទាសៈ និងបុរសជាកម្មករក្តី មនុស្សដែលប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែទាសៈ និងបុរសជាកម្មករក្តី តើអំពើណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែទាសៈ និងបុរសជាកម្មករ អំពើនោះមិនប្រសើរឡើយ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែទាសៈ និងបុរសជាកម្មករ អំពើនោះឯង ទើបឈ្មោះថា ប្រសើរ ក្នុងហេតុនុ៎ះ

អធម្មចរិយវិសមចរិយាហិ ភោ សារីបុត្ត ធម្មចរិយ-សមចរិយា សេយ្យោតិ ។ អត្ថិ ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា ឋាសកម្មករចោរិសំ ចេវ ចោសេតុំ ន ច ចាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុំ ។

[១០៦] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា មិត្តាមច្ចានំ ហេតុ អធម្មចារី វិសមចារី អស្ស យោ វា មិត្តាមច្ចានំ ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ សារីបុត្ត មិត្តាមច្ចានំ ហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សា-រីបុត្ត មិត្តាមច្ចានំ ហេតុ ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិសមចរិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។

បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ដែលត្រូវតាមធម៌ ប្រកបដោយហេតុ ដែលពួកមនុស្សអាចចិញ្ចឹមទាសៈ និងបុរសជាកម្មករបានផង មិនបាច់ធ្វើនូវបាបកម្មផង អាចប្រតិបត្តិនូវបដិបទាជាហេតុឲ្យបានបុណ្យផង មានដែរតើ ។

[១០៦] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែមិត្រអាមាត្យទាំង-ឡាយក្តី មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែមិត្រអាមាត្យទាំងឡាយក្តី អំពើណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែមិត្រអាមាត្យទាំងឡាយ អំពើនោះមិនប្រសើរទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែមិត្រអាមាត្យទាំងឡាយ អំពើនោះឯង ទើបបានឈ្មោះថាប្រសើរ ក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន ព្រោះថាការប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។

អត្ថិ ខោ ជនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា មិត្តាមច្ចានញ្ចេវ មិត្តាមច្ចករណីយំ កាតុំ ន ច បាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុំ ។

[១០៧] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា ញាតិសាលោហិតានំ ហេតុ អធម្មចារី វិសមចារី អស្ស យោ វា ញាតិសាលោហិតានំ ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ សារីបុត្ត ញាតិសាលោហិតានំ ហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សារីបុត្ត ញាតិសាលោហិតានំ ហេតុ ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិសមចរិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។ អត្ថិ ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា

ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ដែលត្រូវធម៌ ប្រកបដោយហេតុ ដែលមនុស្សទាំងឡាយអាចធ្វើកិច្ចរបស់មិត្រអាមាត្យ ដល់មិត្រអាមាត្យបានផង មិនបាច់ធ្វើបាបកម្មផង អាចប្រតិបត្តិនូវបដិបទាជាហេតុឲ្យកើតបុណ្យផង មានដែរតើ ។

[១០៧] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែញាតិសាលោហិតទាំងឡាយក្តី មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែញាតិសាលោហិតទាំងឡាយក្តី អំពើណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែញាតិសាលោហិតទាំងឡាយ អំពើនោះ មិនប្រសើរទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែញាតិសាលោហិតទាំងឡាយ អំពើនោះឯង ទើបឈ្មោះថា ប្រសើរក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ដែលត្រូវធម៌ ប្រកបដោយហេតុ ដែលមនុស្សទាំងឡាយ អាច

ញាតិសាលោហិតានញ្ចេវ ញាតិសាលោហិតការណា យំ កាតុំ ន ច ចាបកម្មំ កាតុំ បុញ្ញញ្ច បដិបជ្ជំ បដិបជ្ជិតុំ ។

[១០៨] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា អតិថីនំ ហេតុ អធម្មចារី វិសមចារី អស្ស យោ វា អតិថីនំ ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ សារីបុត្ត អតិថីនំ ហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សារីបុត្ត អតិថីនំ ហេតុ ធម្មចារី សម-ចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិសមច-រិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោ-តិ ។ អត្ថិ ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិ-កា កម្មន្តា យេហិ សក្កា អតិថីនញ្ចេវ អតិ-ថិការណា យំ កាតុំ ន ច ចាបកម្មំ កាតុំ បុញ្ញញ្ច បដិបជ្ជំ បដិបជ្ជិតុំ ។

ធ្វើនូវកិច្ចការ របស់ញាតិសាលោហិត ដល់ញាតិសាលោហិតបានផង មិនបាច់ធ្វើនូវបាបកម្មផង អាចប្រតិបត្តិនូវបដិបទា ជាហេតុឲ្យបានបុណ្យផង មានដែរតើ ។

[១០៨] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះ ដូចម្តេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែភ្ញៀវទាំងឡាយក្តី មនុស្ស ដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែភ្ញៀវទាំង-ឡាយក្តី អំពើណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែភ្ញៀវទាំងឡាយ អំពើនោះ មិនប្រសើរទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែភ្ញៀវទាំងឡាយ អំពើនោះ ទើបឈ្មោះថា ប្រសើរ ក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ដែលត្រូវធម៌ ប្រកបដោយហេតុ ដែលមនុស្សទាំងឡាយ អាចធ្វើនូវកិច្ចការរបស់ភ្ញៀវ ដល់ភ្ញៀវទាំងឡាយបានផង មិនបាច់ធ្វើនូវបាបកម្មផង អាចប្រតិបត្តិនូវបដិបទា ដែលជាហេតុឲ្យកើតបុណ្យបានផង មានដែរតើ ។

[១០៩] តំ កឹ មញ្ញសិ ជនញ្ហានិ យោ វា បុព្វបេតានំ ហេតុ អធម្មចារី វិសមចារី អស្ស យោ វា បុព្វបេតានំ ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ សារីបុត្ត បុព្វបេតានំ ហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សារីបុត្ត បុព្វបេតានំ ហេតុ ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិសមចរិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។ អត្ថិ ខោ ជនញ្ហានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា បុព្វបេតានញ្ចេវ បុព្វបេតករណីយំ កាតុំ ន ច បាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុំ ។

[១០៩] ម្នាលធនញ្ជានិ អ្នកយល់សេចក្ដីនោះ ដូចម្ដេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែបុព្វបេតៈទាំង-ឡាយក្ដី មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែបុព្វបេតៈទាំងឡាយក្ដី អំពើណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែបុព្វបេតៈទាំងឡាយ អំពើនោះ មិនប្រសើរទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែបុព្វ-បេតៈទាំងឡាយ អំពើនោះ ទើបឈ្មោះថា ប្រសើរ ក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ដែលត្រូវតាមធម៌ ប្រកបដោយហេតុ ដែលមនុស្សទាំងឡាយ អាចធ្វើនូវកិច្ចការរបស់បុព្វបេតៈ ដល់បុព្វបេតៈទាំងឡាយបានផង មិនបាច់ធ្វើបាបកម្មផង អាចប្រតិបត្តិនូវបដិ-បទា ដែលជាហេតុឲ្យកើតបុណ្យបានផង មានដែរតើ ។

[១១០] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា ទេវតានំ ហេតុ អធម្មចារី វិសមចារី អស្ស យោ វា ទេវតានំ ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ សារីបុត្ត ទេវតានំ ហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សារីបុត្ត ទេវតានំ ហេតុ ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិស-មចរិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។ អត្ថិ ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា ទេវតានញ្ចេវ ទេវតា-ករណីយំ កាតុំ ន ច បាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុំ ។

[១១០] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះ ដូចម្តេច មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែទេវតាទាំងឡាយក្តី មនុស្សដែលប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែទេវតាទាំងឡាយក្តី អំពើណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែទេវតាទាំងឡាយ អំពើនោះ មិនប្រសើរឡើយ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែទេវតាទាំងឡាយ អំពើនោះឯង ទើបឈ្មោះថា ប្រសើរក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ ការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ដែលត្រូវតាមធម៌ ប្រកបដោយហេតុ ដែលមនុស្សទាំងឡាយ អាចធ្វើនូវកិច្ចការរបស់ទេវតាដល់ទេវតាទាំងឡាយបានផង មិនបាច់ធ្វើបាបកម្មផង អាចប្រតិបត្តិនូវបដិបទាដែលជាហេតុឲ្យកើតបុណ្យបានផង មានដែរតើ ។

[១១១] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា រញ្ញោ ហេតុ អធម្មចារី វិសមចារី អស្ស យោ វា រញ្ញោ ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។ យោ ហិ ភោ សារីបុត្ត រញ្ញោ ហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សារីបុត្ត រញ្ញោ ហេតុ ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិសមចរិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។ អត្ថិ ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា រញ្ញោ ចេវ រាជករណីយំ កាតុំ ន ច បាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុំ ។

[១១២] តំ កឹ មញ្ញសិ ធនញ្ជានិ យោ វា កា-យស្ស បិណនាហេតុ ព្រូហនាហេតុ អធម្មចារី វិសម-ចារី អស្ស យោ វា កាយស្ស បិណនាហេតុ ព្រូហនា-ហេតុ ធម្មចារី សមចារី អស្ស កតមំ សេយ្យោតិ ។

[១១១] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច មនុស្ស ដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែព្រះរាជាក្តី មនុស្ស ដែលប្រព្រឹត្តតាមធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែព្រះរាជាក្តី តើអំពើ ណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្ស ដែល ប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែព្រះរាជា អំពើនោះ មិន ប្រសើរឡើយ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែព្រះរាជា អំពើនោះឯង ទើបឈ្មោះថា ប្រសើរក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការ ប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ដែលត្រូវតាមធម៌ ប្រកបដោយហេតុ ដែលមនុស្សទាំងឡាយ អាចធ្វើ រាជការរបស់ព្រះរាជាបានផង មិនបាច់ធ្វើបាបកម្មផង អាចប្រតិបត្តិនូវ បដិបទា ជាហេតុឲ្យកើតបុណ្យបានផង មានដែរតើ ។

[១១២] ម្នាលធនញ្ជានិ អ្នកយល់សេចក្តីនោះដូចម្តេច មនុស្ស ដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែការចិញ្ចឹមកាយ ឲ្យធាត់ធំចម្រើន មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះ ហេតុតែការចិញ្ចឹមកាយឲ្យធាត់ធំចម្រើន តើអំពើណាប្រសើរជាង ។

យោ ហិ ភោ សារីបុត្ត កាយស្ស បិណ្ឌជាហេតុ ព្យូហជាហេតុ អធម្មចារី វិសមចារី អស្ស ន តំ សេយ្យោ យោ ច ខោ ភោ សារីបុត្ត កាយស្ស បិណ្ឌជាហេតុ ព្យូហជាហេតុ ធម្មចារី សមចារី អស្ស តទេវេត្ថ សេយ្យោ អធម្មចរិយវិសមចរិយាហិ ភោ សារីបុត្ត ធម្មចរិយសមចរិយា សេយ្យោតិ ។ អត្ថិ ខោ ធនញ្ជានិ អញ្ញេ សហេតុកា ធម្មិកា កម្មន្តា យេហិ សក្កា កាយស្ស ចេវ បិណ្ឌេតុំ ព្យូហេតុំ ន ច បាបកម្មំ កាតុំ បុញ្ញញ្ច បដិបទំ បដិបជ្ជិតុន្តិ ។ អថខោ ធនញ្ជានិ ព្រាហ្មណោ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។

[១១៣] អថខោ ធនញ្ជានិ ព្រាហ្មណោ អបរេន សមយេន អាពាធិកោ ហោតិ[១] ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ ធនញ្ជានិ ព្រាហ្មណោ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស

១ ឱ. ម. អហោសិ ។

បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តខុសធម៌ ប្រព្រឹត្តមិនស្មើ ព្រោះហេតុតែចិញ្ចឹមកាយឲ្យជាត់ជំចម្រើន អំពើនោះមិនប្រសើរ បពិត្រព្រះសារីបុត្រដ៏ចម្រើន មនុស្សដែលប្រព្រឹត្តត្រូវធម៌ ប្រព្រឹត្តស្មើ ព្រោះហេតុតែការចិញ្ចឹមកាយឲ្យជាត់ជំចម្រើន អំពើនោះឯង ទើបឈ្មោះថាប្រសើរក្នុងហេតុនុ៎ះ បពិត្រព្រះសារីបុត្រដ៏ចម្រើន (ព្រោះថា) ការប្រព្រឹត្តត្រូវធម៌ ការប្រព្រឹត្តស្មើ ត្រូវតែប្រសើរវិសេសជាងការប្រព្រឹត្តខុសធម៌ និងការប្រព្រឹត្តមិនស្មើ ។ ម្នាលធនញ្ជានិ ការងារទាំងឡាយឯទៀត ត្រូវតាមធម៌ ប្រកបដោយហេតុ ដែលមនុស្សទាំងឡាយ អាចចិញ្ចឹមកាយឲ្យជាត់ជំចម្រើនបានផង មិនបាច់ធ្វើនូវបាបកម្មផង អាចប្រតិបត្តិនូវបដិបទា ដែលជាហេតុឲ្យកើតបុណ្យបានផង មានដែរតើ ។ គ្រានោះ ធនញ្ជានិព្រាហ្មណ៍ ត្រេកអរអនុមោទនានូវភាសិតរបស់ព្រះសារីបុត្រមានអាយុ រួចក្រោកចាកអាសនៈ ហើយក៏ចៀសចេញទៅ ។

[១១៣] លុះចំណេរកាលតមក ធនញ្ជានិព្រាហ្មណ៍ មានអាពាធ ដល់នូវទុក្ខវេទនា មានជំងឺជាទម្ងន់ ។ ទើបធនញ្ជានិព្រាហ្មណ៍ ហៅបុរសម្នាក់ មកនិយាយបង្គាប់ថា នែបុរសដ៏ចម្រើន ចូរអ្នកមកនេះ

យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ ជនញ្ជានិ ភន្តេ ព្រាហ្មណោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ យេន ចាយស្មា សារីបុត្តោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទាហិ ជនញ្ជានិ ភន្តេ ព្រាហ្មណោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេហិ សាធុ កិរ ភន្តេ អាយស្មា សារីបុត្តោ យេន ជនញ្ជានិស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។

[១១៤] ឯវំ ភន្តេតិ ខោ សោ បុរិសោ ធនញ្ជានិស្ស ព្រាហ្មណស្ស[១] បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ

១ ឱ. ឯត្តន្តរេ វចនន្តីតិ ទិស្សតិ ។

ចូរអ្នកទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះបាទានៃព្រះមានបុណ្យ ហើយក្រាបបង្គំទូល តាមពាក្យអញថា បពិត្រព្រះអង្គដ៏ចម្រើន ធនញ្ជានិព្រាហ្មណ៍ មានអាពាធ ដល់នូវទុក្ខ-វេទនា មានជំងឺជាទម្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយត្បូង ដូច្នេះរួច ឯងចូរទៅរកព្រះសារីបុត្រមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំបាទាព្រះសារីបុត្រមានអាយុ តាមពាក្យអញថា បពិត្រលោកដ៏ចម្រើន ធនញ្ជានិព្រាហ្មណ៍ មានអាពាធ ដល់នូវទុក្ខវេទ-នា មានជំងឺជាទម្ងន់ គាត់ថ្វាយបង្គំបាទាព្រះសារីបុត្រមានអាយុដោយត្បូង ដូច្នេះរួចហើយ ឯងទូលលោកយ៉ាងនេះថា បពិត្រព្រះថេរៈដ៏ចម្រើន យើងខ្ញុំសូមអង្វរ សូមព្រះសារីបុត្រមានអាយុ និមន្តទៅនិវេសនដ្ឋានរបស់ធនញ្ជានិព្រាហ្មណ៍ អាស្រ័យសេចក្ដីអនុគ្រោះ ។

[១១៤] បុរសនោះ ក៏ទទួលពាក្យ របស់ធនញ្ជានិព្រាហ្មណ៍ថា បាទអ្នកដ៏ចម្រើន យ៉ាងនេះហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ

### ព្រាហ្មណវគ្គស្ស ធនញ្ជានិសុត្តេ ពាឡ្ហទុក្ខារោចនំ

ភគវន្តំ ឯតទវោច ធនញ្ជានិ ភន្តេ ព្រាហ្មណោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ យេនាយស្មា[១] សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ សារីបុត្តំ ឯតទវោច ធនញ្ជានិ ភន្តេ ព្រាហ្មណោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ អាយស្មា សារីបុត្តោ យេន ធនញ្ជានិស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា សារីបុត្តោ តុណ្ហីភាវេន ។

---

១ ឱ. ម. យេន ចាយស្មា ។

ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គ ដ៏ចម្រើន ធនញ្ជានិព្រាហ្មណ៍ មានអាពាធ ដល់នូវទុក្ខវេទនា មានជំងឺជាទម្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទាព្រះមានបុណ្យ ដោយត្បូង ដូច្នេះរួចហើយ ចូលទៅរកព្រះសារីបុត្រមានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ ព្រះសារីបុត្រមានអាយុ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយនឹងព្រះសារីបុត្រ មានអាយុថា បពិត្រលោកដ៏ចម្រើន ធនញ្ជានិព្រាហ្មណ៍ មានអាពាធ ដល់នូវទុក្ខ-វេទនា មានជំងឺជាទម្ងន់ គាត់ថ្វាយបង្គំបាទាព្រះសារីបុត្រមានអាយុ ដោយត្បូង មួយទៀត គាត់មានប្រសាសន៍យ៉ាងនេះថា សូមឱកាស បពិត្រលោកដ៏ចម្រើន សូមព្រះសារីបុត្រ មានអាយុ និមន្តចូលទៅ និវេសនដ្ឋានរបស់ធនញ្ជានិព្រាហ្មណ៍ អាស្រ័យសេចក្តីអនុគ្រោះ ។ ព្រះសារីបុត្រមានអាយុ ក៏ទទួលដោយតុណ្ហីភាព ។

[១១៥] អថខោ អាយស្មា សារីបុត្តោ និវាសេត្វា បត្តចីវរមាទាយ យេន ធនញ្ជានិស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ អាយស្មា សារីបុត្តោ ធនញ្ជានឹ ព្រាហ្មណំ ឯតទវោច កច្ចិ តេ ធនញ្ជានិ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។

[១១៦] ន មេ ភោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ សេយ្យថាបិ ភោ សារីបុត្ត ពលវា បុរិសោ តិណ្ហេន សិខរេន មុទ្ធានំ[១] អភិមត្ថេយ្យ ឯវមេវ ខោ មេ ភោ សារីបុត្ត អធិមត្តា វាតា មុទ្ធានំ[២] ឱហនន្តិ ន មេ ភោ សារីបុត្ត ខមនីយំ ន យាបនីយំ

---

១ ម. មុទ្ធនឹ ។ ២ ម. មុទ្ធនិញ្ច ។

[១១៥] លំដាប់នោះ ព្រះសារីបុត្រមានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ចូលទៅនិវេសនដ្ឋានរបស់ធនញ្ជានិព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកប្រគេន ។ លុះព្រះសារីបុត្រមានអាយុគង់ហើយ ក៏និយាយនឹងធនញ្ជានិព្រាហ្មណ៍យ៉ាងនេះថា នែធនញ្ជានិ (យន្តគឺសរីរៈដែលមានចក្រ ៤ មានទ្វារ ៩) អ្នកអត់សង្កត់បានទេឬ អ្នកឲ្យប្រព្រឹត្តទៅបានស្រួលបួលឬទេ ទុក្ខវេទនាស្រាកស្រាន្ត មិនរឹតឡើងទេឬ ប្រាកដជាសះស្បើយ មិនរឹតចម្រើនឡើងទេឬ ។

[១១៦] ធនញ្ជានិព្រាហ្មណ៍ទូលថា បពិត្រព្រះសារីបុត្រដ៏ចម្រើន សរីរយន្តដែលមានចក្រ ៤ មានទ្វារ ៩ ខ្ញុំព្រះករុណាអត់សង្កត់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនា របស់ខ្ញុំព្រះករុណារឹតតែចម្រើនឡើង មិនស្រាកស្រាន្តទេ មានតែចម្រើនឡើង មិនប្រាកដជាស្រាកស្រាន្តទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន ប្រៀបដូចបុរសមានកម្លាំង ចាក់ក្បាលដោយដែកស្រួចដ៏មុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ទាំងឡាយដ៏ខ្លាំងហួសប្រមាណ ចាក់ដោតនូវក្បាលខ្ញុំព្រះករុណា ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន សរីរយន្តខ្ញុំព្រះករុណា អត់សង្កត់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ

១៩៤

ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ សេយ្យថាបិ ភោ សារីបុត្ត ពលវា បុរិសោ ទឡ្ហេន វរត្តក្ខណ្ឌេន សីសេ សីសវេឋនំ ទទេយ្យ ឯវមេវ ខោ មេ ភោ សារីបុត្ត អធិមត្តា សីសេ សីសវេទនា ន មេ ភោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ សេយ្យថាបិ ភោ សារីបុត្ត ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា តិណ្ហេន គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ មេ ភោ សារីបុត្ត អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ន មេ ភោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ សេយ្យថាបិ ភោ សារីបុត្ត ទ្វេ ពលវន្តោ បុរិសា

ទុក្ខវេទនារបស់ខ្ញុំព្រះករុណា រឹតតែចម្រើនឡើង មិនមានធូរថយទេ ចេះតែចម្រើនឡើង មិនមានស្រាកស្រាន្តទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន ប្រៀបដូចបុរសមានកម្លាំង យកព្រ័ត្រដ៏មាំមកត្របែងក្បាល យ៉ាងណា បពិត្រព្រះសារីបុត្រដ៏ចម្រើន សីសវេទនាក្នុងក្បាលខ្ញុំខ្លាំងហួសប្រមាណ ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន សរីរយន្តខ្ញុំព្រះករុណា អត់សង្កត់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះករុណា រឹតតែចម្រើនឡើង មិនធូរថយទេ មានតែចម្រើនឡើង មិនស្រាកស្រាន្តទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន ប្រៀបដូចអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោ ដ៏ឈ្លាសវៃ វះពោះគោនឹងកាំបិតសម្រាប់អារគោដ៏មុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ទាំងឡាយខ្លាំងហួសប្រមាណ ក៏អារពោះខ្ញុំព្រះករុណា យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន សរីរយន្ត ខ្ញុំព្រះករុណាអត់សង្កត់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានស្រួលបួលទេ ទុក្ខវេទនារបស់ខ្ញុំព្រះករុណា រឹតតែចម្រើនឡើង មិនបានធូរថយទេ មានតែចម្រើនឡើង មិនស្រាកស្រាន្តទេ បពិត្រព្រះសារីបុត្រដ៏ចម្រើន ប្រៀបដូចបុរសមានកម្លាំង ពីរនាក់

ទុព្វលតរំ បុរិសំ ធាធាពាហាសុ គហេត្វា អង្គារ-កាសុយា សន្តាបេយ្យុំ សម្បរិតាបេយ្យុំ ឯវមេវ ខោ មេ ភោ សារីបុត្ត អធិមត្តោ កាយស្មឹ ឌាហោ ន មេ ភោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[១១៧] តំ កឹ មញ្ញសិ ធនញ្ជានិ កាតមំ សេយ្យោ និរយោ វា តិរច្ឆានយោនិ វាតិ ។ និរយា ភោ សារីបុត្ត តិរច្ឆានយោនិ សេ-យ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កាតមំ សេយ្យោ តិរច្ឆានយោនិ វា បិត្តិវិសយោ វាតិ ។ តិរច្ឆានយោនិយា ភោ សារីបុត្ត បិត្តិវិសយោ សេយ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ

ចាប់បុរសខ្សោយជាង ត្រង់ដើមដៃទាំងពីរ ហើយផ្ទើរពាលកម្តៅលើរងើកភ្លើង យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន សេចក្តីក្តៅអន្ទះអន្ទែងក្នុងកាយ របស់ខ្ញុំព្រះករុណា ក៏ហួសប្រមាណ យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន សរីរយន្ត ខ្ញុំព្រះករុណាអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះករុណា រឹតតែចម្រើនឡើង មិនអន់ថយសោះ មានតែចម្រើនខ្លាំងឡើង ឥតស្រាកស្រាន្តទេ ។

[១១៧] ម្នាលធនញ្ជានិ អ្នកសំគាល់នូវហេតុនោះ ដូចម្តេច នរកក្តី កំណើតតិរច្ឆានក្តី ណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន កំណើតតិរច្ឆាន ប្រសើរជាងនរក ។ ម្នាលធនញ្ជានិ អ្នកសំគាល់ហេតុនោះ ដូចម្តេច កំណើតតិរច្ឆានក្តី បិត្តិវិស័យក្តី ណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បិត្តិវិស័យប្រសើរជាងកំណើតតិរច្ឆាន ។ ម្នាលធនញ្ជានិ អ្នកសំគាល់ហេតុនោះ ដូចម្តេច

១៩៧



កតមំ សេយ្យោ បិត្តិវិសយោ វា មនុស្សា វាតិ ។ បិត្តិវិសយា ភោ សារីបុត្ត មនុស្សា សេយ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កតមំ សេយ្យោ មនុស្សា វា ចាតុម្មហារាជិកា ទេវា វាតិ ។ មនុស្សេហិ ភោ សារីបុត្ត ចាតុម្មហារាជិកា ទេវា សេយ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កតមំ សេយ្យោ ចាតុម្មហារាជិកា ទេវា វា តាវត្តឹសា ទេវា វាតិ ។ ចាតុម្មហារាជិកេហិ ភោ សារីបុត្ត ទេវេហិ តាវត្តឹសា ទេវា សេ-យ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កតមំ សេយ្យោ តាវត្តឹសា ទេវា វា យាមា ទេវា វាតិ ។ តាវត្តឹសេហិ ភោ សារីបុត្ត ទេវេហិ យាមា ទេវា សេយ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កតមំ សេយ្យោ យាមា ទេវា វា តុសិតា ទេវា វាតិ ។ យាមេហិ ភោ សារីបុត្ត

បិត្តិវិស័យក្តី ពួកមនុស្សក្តី ណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ពួកមនុស្សប្រសើរជាងបិត្តិវិស័យ ។ ម្នាលធនញ្ជានិ អ្នកសំគាល់នូវហេតុនោះ ដូចម្តេច ពួកមនុស្សក្តី ពួកទេវតាដែលនៅក្នុងឋានចាតុម្មហារាជិកៈក្តី ណាប្រសើរជាងណា ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ពួកចាតុម្មហារាជិកទេវតា ប្រសើរជាងពួកមនុស្ស ។ ម្នាលធន-ញ្ជានិ អ្នកសំគាល់នូវហេតុនោះ ដូចម្តេច ពួកចាតុម្មហារាជិកទេវតាក្តី ពួកតាវត្តឹសទេវតាក្តី ណាប្រសើរជាងណា ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ពួកតាវត្តឹសទេវតា ប្រសើរជាងពួកចាតុម្មហារាជិកទេវតា ។ ម្នាលធនញ្ជានិ អ្នកសំគាល់ហេតុនោះ ដូចម្តេច ពួកតាវត្តឹសទេវតាក្តី ពួកយាមទេវតាក្តី ណាប្រសើរជាងណា ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ពួកយាមទេវតា ប្រសើរជាងពួកតាវត្តឹសទេវតា ។ ម្នាលធនញ្ជានិ អ្នកសំគាល់នូវហេតុនោះ ដូចម្តេច ពួកយាមទេវតាក្តី ពួកតុសិតទេវតាក្តី ណាប្រសើរជាងណា ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន

ទេវេហិ តុសិតា ទេវា សេយ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កតមំ សេយ្យោ តុសិតា ទេវា វា និម្មានរតី ទេវា វាតិ ។ តុសិតេហិ ភោ សារីបុត្ត ទេវេហិ និម្មានរតី ទេវា សេយ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កតមំ សេយ្យោ និម្មានរតី ទេវា វា បរនិម្មិតវសវត្តី ទេវា វាតិ ។ និម្មានរតីហិ ភោ សារីបុត្ត ទេវេហិ បរនិម្មិតវសវត្តី ទេវា សេយ្យោតិ ។ តំ កឹ មញ្ញសិ ធនញ្ជានិ កតមំ សេយ្យោ បរនិម្មិតវសវត្តី ទេវា វា ព្រហ្មលោកោ វាតិ ។ ព្រហ្មលោកោតិ ភវំ សារីបុត្តោ អាហ ព្រហ្មលោកោតិ ភវំ សារីបុត្តោ អាហាតិ ។ អថខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ ឥមេ ខោ ព្រាហ្មណា ព្រហ្មលោកាធិមុត្តា យន្នូនាហំ ធនញ្ជានិស្ស ព្រាហ្មណស្ស ព្រហ្មានំ សហាព្យតាយ មគ្គំ ទេសេយ្យន្តិ ។ ព្រហ្មានំ[១] ធនញ្ជានិ សហាព្យតាយ មគ្គំ ទេសេស្សាមិ តំ សុណាហិ សាធុកំ មនសិករោហិ

---

១ ឱ. ម. ឯត្ថន្តរេ តេតិ បទំ អត្ថិ ។

ពួកតុសិតទេវតា ប្រសើរជាងពួកយាមទេវតា ។ ម្នាលធនញ្ជានិ អ្នកសំគាល់នូវហេតុនោះដូចម្តេច ពួកតុសិតទេវតាក្តី ពួកនិម្មានរតិទេវតាក្តី ណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ពួកនិម្មានរតិទេវតា ប្រសើរជាងពួកតុសិតទេវតា ។ ម្នាលធនញ្ជានិ អ្នកសំគាល់នូវហេតុនោះដូចម្តេច ពួកនិម្មានរតិទេវតាក្តី ពួកបរនិម្មិតវសវត្តិទេវតាក្តី ណាប្រសើរជាង ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ពួកបរនិម្មិតវសវត្តិ-ទេវតា ប្រសើរជាងពួកនិម្មានរតិទេវតា ។ ម្នាលធនញ្ជានិ អ្នកសំគាល់នូវហេតុនោះដូចម្តេច ពួកបរនិម្មិតវសវត្តិទេវតាក្តី ព្រហ្មលោកក្តី ណាប្រសើរជាង ។ ព្រះសារីបុត្រដ៏ចម្រើន សំដែងថាព្រហ្មលោក ព្រះសារីបុត្រដ៏ចម្រើន សំដែងថាព្រហ្មលោក ។ គ្រានោះ ព្រះសារី-បុត្រមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកព្រាហ្មណ៍ទាំងនេះចុះចិត្តស៊ប់តែនឹងព្រហ្មលោក បើដូច្នោះ គួរតែអញសំដែងផ្លូវដើម្បីឲ្យបានកើតរួមនឹងព្រហ្មទាំងឡាយ ដល់ធនញ្ជានិព្រាហ្មណ៍ចុះ ។ ទើបព្រះថេរៈសំដែងថា នែធនញ្ជានិ អាត្មានឹងសំដែងផ្លូវដើម្បីបានកើតរួមនឹងព្រហ្មទាំងឡាយ អ្នកចូរស្តាប់រឿងនោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យស្រួលចុះ

ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ ធនញ្ជានិ ព្រាហ្មណោ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសិ ។

[១១៨] អាយស្មា សារីបុត្តោ ឯតទវោច ក-តមោ ច ធនញ្ជានិ ព្រហ្មានំ សហព្យតាយ មគ្គោ ឥធ ធនញ្ជានិ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ អយម្បិ ខោ ធនញ្ជានិ ព្រហ្មានំ សហព្យតាយ មគ្គោ បុន ចបរំ ធនញ្ជានិ ភិក្ខុ ករុណាសហ-គតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ

អាត្មានឹងសំដែងប្រាប់ ។ ធនញ្ជានិព្រាហ្មណ៍ ទទួលស្ដាប់ព្រះសារីបុត្រមានអាយុថា ព្រះករុណា លោកដ៏ចម្រើន ។

[១១៨] ព្រះសារីបុត្រ មានអាយុ ក៏សំដែងយ៉ាងនេះថា ម្នាលធនញ្ជានិ ផ្លូវប្រព្រឹត្តទៅ ដើម្បីកើតរួមនឹងព្រហ្មទាំងឡាយ តើដូចម្ដេច ម្នាលធនញ្ជានិ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា ទិសខាងលើ ទិសខាងក្រោម ទិសទទឹងក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសទាំងពួង ដោយយកខ្លួនប្រៀបនឹងសត្វទាំងពួង ម្នាលធនញ្ជានិ នេះឯងជាផ្លូវប្រព្រឹត្តទៅ ដើម្បីកើតរួមនឹងព្រហ្មទាំងឡាយ ម្នាលធនញ្ជានិមួយទៀត ភិក្ខុមានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា.... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២

តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ អយំ ខោ ធនញ្ជានិ ព្រហ្មានំ សហាព្យតាយ មគ្គោតិ ។ តេនហិ ភោ សារីបុត្ត មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ ធនញ្ជានិ ភន្តេ ព្រាហ្មណោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ ។

[១១៩] អថខោ អាយស្មា សារីបុត្តោ ធនញ្ជានឹ ព្រាហ្មណំ សតិ ឧត្តរិករណីយេ ហីនេ ព្រហ្មលោកេ បតិដ្ឋាបេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ ធនញ្ជានិ ព្រាហ្មណោ អចិរ-បក្កន្តេ អាយស្មន្តេ សារីបុត្តេ កាលមកាសិ

ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ក្នុងទិសទាំងពួង ដោយយកខ្លួនទៅប្រៀបនឹងសត្វទាំងពួង ម្នាលធនញ្ជានិ នេះឯងក៏ជាផ្លូវប្រព្រឹត្តដើម្បីកើតរួមនឹងពួកព្រហ្ម ។ ធនញ្ជានិផ្តាំថា បពិត្រព្រះសារីបុត្រដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់ក្រាបថ្វាយបង្គំព្រះបាទាព្រះមានបុណ្យដោយត្បូង តាមពាក្យរបស់ខ្ញុំព្រះករុណាថា បពិត្រព្រះអង្គដ៏ចម្រើន ធនញ្ជានិព្រាហ្មណ៍ មានអាពាធ ដល់នូវទុក្ខវេទនា មានជំងឺជាទម្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទា នៃព្រះមានបុណ្យដោយត្បូង ។

[១១៩] គ្រានោះ ព្រះសារីបុត្រ មានអាយុ កាលបើមានកិច្ច ដែលលោកត្រូវធ្វើតទៅទៀត ក៏ញុំាងធនញ្ជានិព្រាហ្មណ៍ឲ្យតម្កល់នៅត្រឹមព្រហ្មលោកថោកទាប រួចក្រោកចាកអាសនៈ ហើយក៏ចេញទៅ ។ គ្រានោះឯង ធនញ្ជានិព្រាហ្មណ៍ កាលបើព្រះសារីបុត្រមានអាយុ និមន្តចេញទៅ មិនយូរប៉ុន្មាន ក៏ធ្វើមរណកាល

ព្រហ្មលោកំ ឧបបជ្ជិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ឯសោ ភិក្ខវេ សារីបុត្តោ ធនញ្ជានិ ព្រាហ្មណំ សតិ ឧត្តរិករណីយេ ហីនេ ព្រហ្មលោកេ បតិដ្ឋាបេត្វា ឧដ្ឋាយាសនា បក្កន្តោតិ ។

[១២០] អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ធនញ្ជានិ ភន្តេ ព្រាហ្មណោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ កឹ បន ត្វំ សារីបុត្ត ធនញ្ជានឹ ព្រាហ្មណំ សតិ ឧត្តរិករណីយេ ហីនេ ព្រហ្មលោកេ បតិដ្ឋាបេត្វា

ហើយទៅកើត ឯព្រហ្មលោក ។ គ្រានោះ ព្រះមានបុណ្យ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រនុ៎ះ កាលបើមានកិច្ចដែលខ្លួនត្រូវធ្វើតទៅទៀត ក៏ញុំាងធនញ្ជានិព្រាហ្មណ៍ ឲ្យតម្កល់នៅត្រឹមព្រហ្មលោកថោកទាប រួចក្រោកចាកអាសនៈ ចេញមក ។

[១២០] គ្រានោះ ព្រះសារីបុត្រមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏អង្គុយ ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធនញ្ជានិព្រាហ្មណ៍ មានអាពាធដល់នូវទុក្ខវេទនា មានជំងឺជាទម្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទានៃព្រះមានព្រះភាគដោយត្បូង ។ ព្រះមានព្រះភាគត្រាស់សួរថា ហែសារីបុត្រ កាលបើកិច្ចដែលអ្នកត្រូវធ្វើតទៅទៀតនៅមាន ហេតុម្តេចក៏អ្នកញុំាងធនញ្ជានិព្រាហ្មណ៍ ឲ្យតម្កល់នៅត្រឹមព្រហ្មលោកថោកទាប

២០២



ឧដ្ឋាយាសនា បក្កាមេតិ ។ មយ្ហំ ខោ ភន្តេ ឯវំ អហោសិ ឥមេ ខោ ព្រាហ្មណា ព្រហ្មលោកាធិមុត្តា យន្នូនាហំ ធនញ្ជានិស្ស ព្រាហ្មណស្ស ព្រហ្មានំ សហព្យតាយ មគ្គំ ទេសេយ្យន្តិ ។ កាលកតោ វ សារីបុត្ត ធនញ្ជានិ ព្រាហ្មណោ ព្រហ្មលោកេ ឧបបន្នោតិ ។

ធនញ្ជានិសុត្តំ សត្តមំ និដ្ឋិតំ ។

រួចក្រោកចាកអាសនៈចេញមក ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកព្រាហ្មណ៍ទាំងនេះ មានចិត្តជឿស៊ប់នឹងព្រហ្មលោក បើដូច្នោះ គួរតែខ្ញុំព្រះអង្គសំដែងផ្លូវប្រព្រឹត្តទៅដើម្បីកើតរួមនឹងពួកព្រហ្ម ដល់ធនញ្ជានិព្រាហ្មណ៍ចុះ ។ ហែសារីបុត្រ ធនញ្ជានិព្រាហ្មណ៍ស្លាប់ហើយ ទៅកើតឯព្រហ្មលោកហើយ ។

ចប់ ធនញ្ជានិសូត្រ ទី ៧ ។

# អដ្ឋមំ វាសេដ្ឋសុត្តំ

[១៦១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា ព្រាហ្មណមហាសាលា ឥច្ឆានង្គលេ បដិវសន្តិ សេយ្យថីទំ ចង្កី ព្រាហ្មណោ តារុក្ខោ ព្រាហ្មណោ បោក្ខរសាតិ ព្រាហ្មណោ ជាណុស្សោណិ ព្រាហ្មណោ តោទេយ្យោ ព្រាហ្មណោ អញ្ញេ ច អភិញ្ញាតា អភិញ្ញាតា ព្រាហ្មណមហាសាលា ។ អថ ខោ វាសេដ្ឋភារទ្វាជានំ មាណវានំ ជង្ឃាវិហារំ អនុចង្កមន្តានំ អនុវិចរន្តានំ អយមន្តរាកថា ឧទបាទិ កថម្ភោ ព្រាហ្មណោ ហោតីតិ ។ ភារទ្វាជោ មាណវោ ឯវមាហ

# វាសេដ្ឋសូត្រ ទី ៨

[១២១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈ ។ សម័យនោះឯង មានព្រាហ្មណមហាសាលជាច្រើនសុទ្ធតែជាអ្នកមានកេរ្តិ៍ឈ្មោះ ល្បីល្បាញ អាស្រ័យនៅក្នុងស្រុកឥច្ឆានង្គលៈ គឺ ចង្កីព្រាហ្មណ៍ ១ តារុក្ខព្រាហ្មណ៍ ១ បោក្ខរសាតិព្រាហ្មណ៍ ១ ជាណុស្សោណិព្រាហ្មណ៍ ១ តោទេយ្យព្រាហ្មណ៍ ១ មិនតែប៉ុណ្ណោះសោត មានទាំងពួកព្រាហ្មណមហាសាលដទៃទៀត ក៏សឹងជាអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញដែរ ។ វេលានោះ វាសេដ្ឋមាណពនិងភារទ្វាជមាណពទាំងពីរនាក់ កំពុងដើរទៅដើរមក ដើម្បីសម្រួលស្មងក៏ផ្តើមនូវអន្តរាកថានេះថា ម្នាលអ្នកដ៏ចម្រើន មនុស្សឈ្មោះថាព្រាហ្មណ៍តើដោយហេតុដូចម្តេច ។ ភារទ្វាជមាណព បានឆ្លើយយ៉ាងនេះថា

យតោ ខោ ភោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឯត្តាវតា ខោ ភោ ព្រាហ្មណោ ហោតីតិ ។ វាសេដ្ឋមាណវោ ឯវមាហ យតោ ខោ ភោ សីលវា ច ហោតិ វត្តសម្បន្នោ ច ឯត្តាវតា ខោ ភោ ព្រាហ្មណោ ហោតីតិ ។ នេវ ខោ អសក្ខិ ភារទ្វាជោ មាណវោ វាសេដ្ឋំ មាណវំ សញ្ញាបេតុំ ន បនាសក្ខិ វាសេដ្ឋោ មាណវោ ភារទ្វាជំ មាណវំ សញ្ញាបេតុំ ។

[១៦២] អថខោ វាសេដ្ឋោ មាណវោ ភារទ្វាជំ មាណវំ អាមន្តេសិ អយំ ខោ ភោ ភារទ្វាជ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ

ម្នាលអ្នកដ៏ចម្រើន បើកាលណាបុគ្គលមានជាតិល្អទាំងពីរចំណែក គឺ ទាំងខាងមាតានិងខាងបិតា ប្រសូតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីគូនៃជីតាជាគម្រប់ ៧ មក មិនមានអ្នកណា តិះដៀលចំអកចំអន់ដោយការពោលដល់ជាតិបាន ម្នាលអ្នកដ៏ចម្រើន ដោយហេតុប៉ុណ្ណោះឯង មនុស្សទើបឈ្មោះថាព្រាហ្មណ៍ ។ វាសេដ្ឋមាណព បានពោលយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើកាលណាបុគ្គលមានសីលផង បរិបូណ៌ដោយវត្តផង ដោយហេតុប៉ុណ្ណោះ មនុស្សទើបឈ្មោះថាជាព្រាហ្មណ៍បាន ។ ភារទ្វាជមាណពមិនអាចដើម្បីពន្យល់វាសេដ្ឋមាណពបាន ចំណែកខាងវាសេដ្ឋមាណពក៏មិនអាចដើម្បីនឹងពន្យល់ភារទ្វាជមាណពបានដែរ ។

[១៤៤] លំដាប់នោះ វាសេដ្ឋមាណព និយាយនឹងភារទ្វាជមាណពថា ម្នាលភារទ្វាជៈ ដ៏ចម្រើន ព្រះសមណគោតមនេះឯងជាសក្យបុត្រ ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ឥឡូវមកគង់នៅក្នុងដងព្រៃ ឈ្មោះឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈ កិត្តិសព្ទដ៏ល្អ នៃព្រះគោតមដ៏ចម្រើននោះ ល្បីឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកកិលេសហើយ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ

២០៨

ព្រាហ្មណវគ្គស្ស វាសេដ្ឋសុត្តេ ភគវន្តូបសង្កមនំ

វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិស-
ទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ
អាយាម ភោ ភារទ្វាជ យេន សមណោ គោតមោ
តេនុបសង្កមិស្សាម ឧបសង្កមិត្វា សមណំ គោតមំ
ឯតមត្ថំ បុច្ឆិស្សាម យថា នោ សមណោ គោតមោ
ព្យាករិស្សតិ តថា នំ ធារេស្សាមាតិ ។ ឯវំ ភោតិ
ខោ ភារទ្វាជោ មាណវោ វាសេដ្ឋស្ស មាណវស្ស
បច្ចស្សោសិ ។ អថខោ វាសេដ្ឋភារទ្វាជមាណវា
យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា
សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ
វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។

ព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះដឹងនិងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្ត្រាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ម្នាលភារទ្វាជៈដ៏ចម្រើន មក យើងនឹងនាំគ្នាចូលទៅគាល់ព្រះសមណគោតម លុះចូលទៅដល់ហើយ យើងនឹងទូលសួរសេចក្ដីនុ៎ះនឹងព្រះសមណគោតម ព្រះសមណគោតមនឹងដោះស្រាយ ដល់យើងទាំងពីរនាក់ យ៉ាងណា យើងនឹងចាំទុកសេចក្ដីនោះយ៉ាងនោះ ។ ឯភារទ្វាជមាណព ក៏បានទទួលពាក្យរបស់វាសេដ្ឋមាណពថា យ៉ាងហ្នឹងហើយ អ្នកដ៏ចម្រើន ។ គ្រានោះ វាសេដ្ឋមាណពនិងភារទ្វាជមាណព បាននាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលរាក់ទាក់ សំណេះសំណាលទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[១៦៣] ឯកមន្តំ និសិន្នោ ខោ វាសេដ្ឋោ មាណវោ ភគវន្តំ គាថាហិ អជ្ឈភាសិ

អនុញ្ញាតប្បដិញ្ញាតា
តេវិជ្ជា មយមស្មុភោ
អហំ បោក្ខរសាតិស្ស
តារុក្ខស្សាយំ មាណវោ
តេវិជ្ជានំ យទក្ខាតំ
តត្រ កេវលិនោស្ម សេ
បទកស្មា វេយ្យាករណា
ជប្បេ[១] អាចរិយសាទិសា
តេសន្នោ ជាតិវាទស្មឹ
វិវាទោ អត្ថិ គោតម
ជាតិយា ព្រាហ្មណោ ហោតិ
ភារទ្វាជោ ឥតិ ភាសតិ

១ ម. ជប្បេ ។

[១២៣] លុះវាសេដ្ឋមាណព អង្គុយក្នុងទីដ៏សមគួរហើយ បាន ពោលនឹងព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា

ខ្ញុំព្រះអង្គទាំងពីរនាក់ បានទទួលអនុញ្ញាត អំពីអាចារ្យ ដែលបានឲ្យរៀនសូត្រស្រេចហើយ ទាំងបានប្តេជ្ញាខ្លួនឯង ថា បានរៀនសូត្រចេះចាំនូវវេទទាំង ៣ ខ្ញុំព្រះអង្គជាសិស្ស ច្បងរបស់បោក្ខរសាតិព្រាហ្មណ៍ ឯមាណពនេះ ជាសិស្ស ច្បង របស់តារុក្ខព្រាហ្មណ៍ បទណាដែលពួកព្រាហ្មណ៍ ចេះនូវវេទទាំង ៣ បានប្រាប់ ដោយអត្ថក្តី ដោយ ព្យញ្ជនៈក្តី ខ្ញុំព្រះអង្គទាំងពីរនាក់ ក៏បានចូលចិត្តក្នុងបទ នោះទាំងអស់ ទាំងសេចក្តីព្យាករនូវបទរបស់ខ្ញុំព្រះអង្គ ទាំងពីរនាក់ ក៏ប្រាកដស្មើនឹងអាចារ្យ ត្រង់កន្លែងជាទី ពោលមន្ត្ត បពិត្រព្រះគោតម ខ្ញុំព្រះអង្គទាំងពីរនាក់ មានសេចក្តីវិវាទ ក្នុងការពោលអំពីជាតិ ភារទ្វាជមាណព ពោលថា បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះជាតិ

២០៧



អហញ្ច កម្មុនា ព្រូមិ
ឯវំ ជានាហិ ចក្ខុម
តេ ន សក្កោម ញាបេតុំ
អញ្ញមញ្ញំ មយំ ឧភោ
ភគវន្តំ បុដ្ឋុំ អាគម្ម[១]
សម្ពុទ្ធំ ឥតិ វិស្សុតំ
ចន្ទំ យថា ខយាតីតំ
បេច្ច បញ្ជលិកា ជនា
វន្ទមានា នមស្សន្តិ
ឯវំ លោកស្មិំ គោតមំ
ចក្ខុំ លោកេ សមុប្បន្នំ
មយំ បុច្ឆាម គោតមំ
ជាតិយា ព្រាហ្មណោ ហោតិ
ឧទាហុ ភវតិ កម្មុនា
អជានតំ នោ ច ព្រូហិ
យថា ជានេមុ ព្រាហ្មណំ ។

---

១ ម. បុដ្ឋុមាគម្មា ។

ចំណែកខ្ញុំព្រះអង្គពោលថា ព្រោះកម្ម បពិត្រព្រះអង្គអ្នកមានចក្ខុ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះ ដោយហេតុនោះហើយ បានជាខ្ញុំព្រះអង្គទាំងពីរនាក់ មិនអាចញុំាំងគ្នានិងគ្នាឲ្យដឹងបាន ទើបនាំគ្នាមកក្រាបទូលសួរព្រះមានព្រះភាគដែលប្រាកដថាជាព្រះសម្ពុទ្ធ ពួកជនតាំងអញ្ជលីកម្មថ្វាយបង្គំ ចំពោះទៅរកព្រះចន្ទពេញវង់ យ៉ាងណា គេក៏ថ្វាយបង្គំចំពោះព្រះគោតមក្នុងលោក យ៉ាងនោះដែរ ខ្ញុំព្រះអង្គទាំងពីរនាក់ សូមទូលសួរព្រះគោតម ដែលមានដួងចក្ខុកើតឡើងបរិសុទ្ធស្អាតក្នុងលោកថា បុគ្គលដែលជាព្រាហ្មណ៍នោះ តើព្រះជាតិឬព្រោះកម្ម ដ្បិតខ្ញុំព្រះអង្គទាំងពីរនាក់មិនស្គាល់ សូមព្រះអង្គទ្រង់សំដែង ល្មមឲ្យខ្ញុំព្រះអង្គទាំងពីរនាក់ ស្គាល់ថាព្រាហ្មណ៍បានផង ។

[១២៤] តេសំ វោហំ ព្យាចិក្ខិស្សំ (វាសេដ្ឋាតិ ភគវា)
អនុបុព្វំ យថាតថំ
ជាតិវិភង្គំ បាណានំ
អញ្ញមញ្ញា ហិ ជាតិយោ
តិណរុក្ខេបិ ជានាថ
ន វាបិ បដិជានរេ
លិង្គំ ជាតិមយំ តេសំ
អញ្ញមញ្ញា ហិ ជាតិយោ
តតោ កីដេ បដង្គេ ច
យាវ កុន្ថកិបិល្លិកេ
លិង្គំ ជាតិមយំ តេសំ
អញ្ញមញ្ញា ហិ ជាតិយោ
ចតុប្បទេបិ ជានាថ

[១២៤] (ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ) តថាគតនឹងចែករំលែកជាតិ នៃសត្វទាំងឡាយនោះ តាមលំដាប់ ប្រាប់អ្នកទាំងឡាយ ដ្បិតជាតិរបស់សត្វទាំងឡាយផ្សេងៗគ្នា អ្នកទាំងឡាយស្គាល់តិណជាតិនិងរុក្ខជាតិហើយ ចំណែកតិណជាតិនិងរុក្ខជាតិនោះ មិនស្គាល់ខ្លួនវាថា យើងជាតិណជាតិ ជារុក្ខជាតិដូច្នេះឡើយ សណ្ឋានក៏សម្រេចមកអំពីជាតិ ព្រោះជាតិរបស់វាទីទៃ ៗ ពីគ្នា តាំងពីកណ្ដូប កន្ទុំរុយ រហូតដល់ស្រមោចខ្មៅស្រមោចក្រហម សណ្ឋានក៏សម្រេចមកអំពីជាតិ ព្រោះជាតិរបស់វា ទីទៃ ៗ ពីគ្នា មួយទៀត អ្នកទាំងឡាយចូរដឹងសត្វជើង ៤ ទាំងឡាយ

ព្រាហ្មណវគ្គស្ស វាសេដ្ឋសុត្តេ ព្រាហ្មណព្យាករណំ

ខុទ្ទកោ ច មហល្លកោ
លិង្គំ ជាតិមយំ តេសំ
អញ្ញមញ្ញា ហិ ជាតិយោ
ចាតុប្បទេបិ ជាជាថ
ឧរគេ ទីឃបិដ្ឋិកោ
លិង្គំ ជាតិមយំ តេសំ
អញ្ញមញ្ញា ហិ ជាតិយោ
តតោ មច្ឆេបិ ជាជាថ
ឧទកោ វារិគោចរេ
លិង្គំ ជាតិមយំ តេសំ
អញ្ញមញ្ញា ហិ ជាតិយោ
តតោ បក្ខីបិ ជាជាថ
បត្តយានេ វិហង្គមេ
លិង្គំ ជាតិមយំ តេសំ

ទាំងតូចទាំងធំ សណ្ឋានក៏សម្រេចមកអំពីជាតិ ព្រោះជាតិរបស់វា ទីទៃ ៗ ពីគ្នា មួយទៀត អ្នកទាំងឡាយចូរដឹងពួកសត្វដែលមានពោះជាជើង ដូចជាឧរគជាតិ ដែលមានខ្នងវែង សណ្ឋានក៏សម្រេចមកអំពីជាតិ ព្រោះជាតិរបស់វាទីទៃ ៗ ពីគ្នា មួយទៀត អ្នកទាំងឡាយចូរដឹងពួកមច្ឆជាតិដែលនៅក្នុងទឹក មានទឹកជាទីគោចរ សណ្ឋានក៏សម្រេចមកអំពីជាតិ ព្រោះជាតិរបស់វា ទីទៃ ៗ ពីគ្នា មួយទៀត អ្នកទាំងឡាយចូរដឹងពួកសត្វបក្សី ដែលមានស្លាបជាយានហើរទៅក្នុងអាកាស សណ្ឋានក៏សម្រេចមក អំពីជាតិ

អញ្ញមញ្ញា ហិ ជាតិយោ
យថា ឯតាសុ ជាតីសុ
លិង្គំ ជាតិមយំ បុថុ
ឯវំ នត្ថិ មនុស្សេសុ
លិង្គំ ជាតិមយំ បុថុ
ន កេសេហិ ន សីសេន
ន កណ្ណេហិ ន អក្ខិភិ
ន មុខេន ន នាសាយ
ន ឱដ្ឋេហិ ភមូហិ វា
ន គីវាយ ន អំសេហិ
ន ឧទរេន ន បិដ្ឋិយា
ន សោណិយា ន ឧរស្មា
ន សម្ពាធេ ន មេថុនេ[១]
ន ហត្ថេហិ ន បាទេហិ

១ ម. មេថុនា ។

ព្រោះជាតិរបស់វា ទីទៃ ៗ ពីគ្នា សណ្ឋានដែលសម្រេច អំពីជាតិក្នុងជាតិទាំងនុ៎ះច្រើន ដូចម្ដេចមិញ សណ្ឋានដែលសម្រេចមកអំពីជាតិ ក្នុងមនុស្សទាំងឡាយ មិនមានច្រើនដូច្នោះទេ ព្រោះមិនបាននិយមដោយសក់ទាំងឡាយ មិនបាននិយមដោយក្បាល មិនបាននិយមដោយត្រចៀកទាំងពីរ មិនបាននិយមដោយភ្នែកទាំងពីរ មិនបាននិយមដោយមាត់ មិនបាននិយមដោយច្រមុះ មិនបាននិយមដោយបបូរមាត់ទាំងពីរ មិនបាននិយមដោយចិញ្ចើមទាំងពីរ មិនបាននិយមដោយ-ក មិនបាននិយមដោយស្មាទាំងសងខាង មិនបាននិយមដោយពោះ មិនបាននិយមដោយខ្នង មិនបាននិយមដោយត្រគាក មិនបាននិយមដោយទ្រូង មិនបាននិយមដោយទីចង្អៀត មិនបាននិយមដោយមេថុន មិនបាននិយមដោយដៃទាំងពីរ មិនបាននិយមដោយជើង

ន អង្គុលីហិ[១] នខេហិ វា
ន ជង្ឃាហិ ន ឩរូហិ
ន វណ្ណេន សរេន វា
លិង្គំ ជាតិមយំ នេវ
យថា អញ្ញាសុ ជាតិសុ
បច្ចត្តញ្ច សរីរេសុ
មនុស្សេស្វេតំ ន វិជ្ជតិ
វោការំ ច មនុស្សេសុ
សមញ្ញាយ បវុច្ចតិ
យោ ហិ កោចិ មនុស្សេសុ
គោរក្ខំ ឧបជីវតិ
ឯវំ វាសេដ្ឋ ជានាហិ
កស្សកោ សោ ន ព្រាហ្មណោ
យោ ហិ កោចិ មនុស្សេសុ
បុថុសិប្បេន ជីវតិ

១ ម. នង្គុលីហិ ។

ទាំងពីរ មិនបាននិយមដោយម្រាមដៃទាំង ១០ មិនបាននិយមដោយក្រចកទាំង ១០ មិនបាននិយមដោយស្មងទាំងពីរ មិនបាននិយមដោយភ្លៅទាំងពីរ មិនបាននិយមដោយសម្បុរ មិនបាននិយមដោយសំឡេង ជាសណ្ឋានសម្រេចមកអំពីជាតិ ដូចជាក្នុងជាតិពួកសត្វដទៃក៏ទេ មួយទៀតរបស់ដែលអាស្រ័យចំពោះខ្លួន ក្នុងសរីរៈរបស់មនុស្ស នឹងបានដូច្នោះក៏ទេ ឯការផ្សេងគ្នារបស់មនុស្សទាំងឡាយ គេហៅតាមឈ្មោះ ព្រោះថាបណ្តាមនុស្សទាំងឡាយ មនុស្សណាមួយចិញ្ចឹមជីវិតដោយការភ្ជួររាស់ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាអ្នកភ្ជួររាស់ មិនមែនជាព្រាហ្មណ៍ទេ បណ្តាមនុស្សទាំងឡាយ មនុស្សណាចិញ្ចឹមជីវិតដោយសិប្បៈផ្សេង ៗ (មានការត្បាញជាដើម)

ឯវំ វាសេដ្ឋ ជានាហិ
សិប្បិកោ សោ ន ព្រាហ្មណោ
យោ ហិ កោចិ មនុស្សេសុ
វោហារំ ឧបជីវតិ
ឯវំ វាសេដ្ឋ ជានាហិ
វាណិជោ សោ ន ព្រាហ្មណោ
យោ ហិ កោចិ មនុស្សេសុ
បរបេស្សេន ជីវតិ
ឯវំ វាសេដ្ឋ ជានាហិ
បេស្សិកោ សោ ន ព្រាហ្មណោ
យោ ហិ កោចិ មនុស្សេសុ
អទិន្នំ ឧបជីវតិ
ឯវំ វាសេដ្ឋ ជានាហិ
ចោរោ ឯសោ ន ព្រាហ្មណោ
យោ ហិ កោចិ មនុស្សេសុ
ឥស្សត្ថំ ឧបជីវតិ

ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះឈ្មោះថាជាអ្នកមានសិប្បៈ មិនមែនព្រាហ្មណ៍ទេ បណ្តាមនុស្សទាំង-ឡាយ មនុស្សណាមួយចិញ្ចឹមជីវិតដោយការជួញ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាពាណិជ មិនមែនព្រាហ្មណ៍ទេ បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយចិញ្ចឹមជីវិតដោយការបម្រើអ្នកដទៃ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាអ្នកបម្រើគេ មិនមែនព្រាហ្មណ៍ទេ បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយ ចិញ្ចឹមជីវិតដោយការលួច ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនុ៎ះជាចោរ មិនមែនព្រាហ្មណ៍ទេ បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយចិញ្ចឹមជីវិត ដោយការកាន់គ្រឿងសស្ត្រាវុធ

ព្រាហ្មណវគ្គស្ស វាសេដ្ឋសុត្តេ ព្រាហ្មណព្យាករណំ

ឯវំ វាសេដ្ឋ ជានាហិ
យោធាជីវោ ន ព្រាហ្មណោ
យោ ហិ កោចិ មនុស្សេសុ
ចោរោហិច្ចេន ជីវតិ
ឯវំ វាសេដ្ឋ ជានាហិ
យាជកោ សោ ន ព្រាហ្មណោ
យោ ហិ កោចិ មនុស្សេសុ
គាមំ រដ្ឋញ្ច ភុញ្ជតិ
ឯវំ វាសេដ្ឋ ជានាហិ
រាជា ឯសោ ន ព្រាហ្មណោ
ន ចាហំ ព្រាហ្មណំ ព្រូមិ
យោនិជំ មត្តិសម្ភវំ
ភោវាទី នាម សោ ហោតិ
សចេ ហោតិ សកិញ្ចនោ
អកិញ្ចនំ អនាទានំ
តមហំ ព្រូមិ ព្រាហ្មណំ

ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនុ៎ះជាទាហាន មិនមែនព្រាហ្មណ៍ទេ បណ្ដាមនុស្សទាំងឡាយ មនុស្សណាមួយចិញ្ចឹមជីវិតដោយនាទីជាបុរោហិត ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនុ៎ះជាអ្នកបូជា មិនមែនព្រាហ្មណ៍ទេ បណ្ដាមនុស្សទាំងឡាយ មនុស្សណាមួយបរិភោគស្រុកឬដែន ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនុ៎ះជាព្រះរាជា មិនមែនព្រាហ្មណ៍ទេ មួយទៀត តថាគតមិនបានពោលបុគ្គលដែលកើតអំពីកំណើត ឬកើតអំពីសំណាក់នៃមាតាថាជាព្រាហ្មណ៍ទេ បុគ្គលនោះ គ្រាន់តែឈ្មោះថាភោវាទី (អ្នកពោលថាភោភោ) ព្រោះបុគ្គលនោះឯងនៅមានកង្វល់គឺកិលេស លុះតែបុគ្គលមិនមានកង្វល់ មិនមានសេចក្ដីប្រកាន់មាំ ទើបតថាគតពោលថាជាព្រាហ្មណ៍

សព្វំ សញ្ញោជនំ ឆេត្វា
យោ វេ ន បរិតស្សតិ
សង្គាតីតំ[១] វិសំយុត្តំ
តមហំ ព្រូមិ ព្រាហ្មណំ
ឆេត្វា នន្ទឹ វរត្តញ្ច
សន្ទានំ សហនុក្កមំ
ឧក្ខិត្តបលិឃំ ពុទ្ធំ
តមហំ ព្រូមិ ព្រាហ្មណំ
អក្កោសំ វធពន្ធញ្ច
អទុដ្ឋោ យោ តិតិក្ខតិ
ខន្តិពលំ ពលានីកំ
តមហំ ព្រូមិ ព្រាហ្មណំ
អក្កោធនំ វតវន្តំ
សីលវន្តំ អនុស្សុទំ
ទន្តំ អន្តិមសារីរំ
តមហំ ព្រូមិ ព្រាហ្មណំ

១ សង្គាតិគន្តិប្បត្តិ ។

បុគ្គលណាកាត់បង់នូវសំយោជនៈទាំងអស់ ហើយមិនបាន តក់ស្លុតដោយតណ្ហា តថាគតពោលនូវបុគ្គលនោះ ដែល ជាអ្នកកន្លងបង់នូវសេចក្តីចំពាក់ ជាអ្នកប្រាសចាកកិលេស ថាជាព្រាហ្មណ៍ បុគ្គលណាកាត់បង់នូវខ្សែរឹត គឺការចង គំនុំ និងព្រ័ត្រគឺតណ្ហា និងទី-តគឺកិលេស គ្រឿងស្នាក់គឺទិដ្ឋិ ព្រមទាំងទិដ្ឋានុស័យចេញបាន តថាគតពោលនូវបុគ្គលនោះ ដែលមានបង្គោលគឺអវិជ្ជាដកចេញហើយ អ្នកត្រាស់ដឹងនូវ ចតុរារិយសច្ច ថាជាព្រាហ្មណ៍ បុគ្គលណាមិនបានប្រទូស្ត អត់សង្កត់នូវពាក្យជេរ និងការវាយដំ និងចំណងបាន តថា-គតពោលនូវបុគ្គលនោះ ដែលមានអធិវាសនក្ខន្តីជាកម្លាំង មានពួកពលគឺខន្តី ថាជាព្រាហ្មណ៍ បុគ្គលណាមិនមាន សេចក្តីក្រោធ មានធុតង្គវត្ត មានសីលគុណ មិនប៉ោង ដោយរាគាទិក្កិលេស មិនមានពុតត្បុត មានសរីរៈតាំងនៅ ក្នុងទីបំផុត តថាគតពោលនូវបុគ្គលនោះ ថាជាព្រាហ្មណ៍

វារិបោក្ខរបត្តេវ
អារគ្គេរិវ សាសបោ
យោ ន លិម្បតិ កាមេសុ
តមហំ ព្រូមិ ព្រាហ្មណំ
យោ ទុក្ខស្ស បជានាតិ
ឥធេវ ខយមត្តនោ
បន្នភារំ វិសំយុត្តំ
តមហំ ព្រូមិ ព្រាហ្មណំ
គម្ភីរបញ្ញំ មេធាវឹ
មគ្គាមគ្គស្ស កោវិទំ
ឧត្តមត្ថំ អនុបត្តំ
តមហំ ព្រូមិ ព្រាហ្មណំ
អសំសដ្ឋំ គហដ្ឋេហិ
អនាគារេហិ ចូភយំ
អនោកសារឹ អប្បិច្ឆំ
តមហំ ព្រូមិ ព្រាហ្មណំ
និធាយ ទណ្ឌំ ភូតេសុ

បុគ្គលណាមិនជាប់ ក្នុងកាមទាំងឡាយ ដូចទឹកមិនជាប់លើស្លឹកឈូក ឬដូចគ្រាប់ស្ពៃ មិនជាប់លើចុងនៃដែកស្រួច តថាគតពោលនូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាក្នុងលោកនេះ ដឹងច្បាស់នូវការអស់ទៅនៃទុក្ខរបស់ខ្លួន តថាគតពោលនូវបុគ្គលនោះ ដែលមានភារៈដាក់ចុះហើយ ប្រាសចាកកិលេសហើយ ថាជាព្រាហ្មណ៍ បុគ្គលណាជាអ្នកប្រាជ្ញមានប្រាជ្ញាជ្រាលជ្រៅឈ្លាសវៃ ក្នុងមគ្គនិងមិនមែនមគ្គ មានប្រយោជន៍ដ៏ខ្ពស់សម្រេចហើយ តថាគតពោល នូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាមិនច្រឡំដោយបុគ្គលទាំងពីរពួក គឺគ្រហស្ថនិងបព្វជិត មិនបានជាប់នៅក្នុងអាល័យគឺកាមគុណ ទាំងមិនមានសេចក្ដីប្រាថ្នា តថាគតពោល នូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាដាក់ចុះនូវអាជ្ញាក្នុង

តសេសុ ថាវរេសុ ច
យោ ន ហន្តិ ន ឃាតេតិ
តមហំ ព្រូមិ ព្រាហ្មណំ
អវិរុទ្ធំ វិរុទ្ធេសុ
អត្តទណ្ឌេសុ និព្វុតំ
សាទានេសុ អនាទានំ
តមហំ ព្រូមិ ព្រាហ្មណំ
យស្ស រាគោ ច ទោសោ ច
មានោ មក្ខោ ច ចាតិតោ
សាសបោរិវ អារគ្គា
តមហំ ព្រូមិ ព្រាហ្មណំ
អកក្កសំ វិញ្ញាបនឹ
គិរំ សច្ចំ ឧទីរយេ
យាយ នាភិសជេ កិញ្ចិ
តមហំ ព្រូមិ ព្រាហ្មណំ
យោបិ ទីឃំ វ រស្សំ វា

ពួកសត្វ អ្នកដែលនៅមានសេចក្តីតក់ស្លុតគឺតណ្ហា មានសេចក្តីខ្ជាប់ខ្ជួនគឺមិនមានតណ្ហា មិនសម្លាប់ដោយខ្លួនឯង មិនប្រើអ្នកដទៃឲ្យសម្លាប់ តថាគតពោល នូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាមិនខឹង ក្នុងពួកសត្វដែលខឹង មានសេចក្តីត្រជាក់ទៅលើពួកសត្វ ដែលមានអាជ្ញាក្នុងខ្លួន ជាអ្នកមិនមានសេចក្តីប្រកាន់ក្នុងពួកបុគ្គល ដែលមានសេចក្តីប្រកាន់ តថាគតពោល នូវបុគ្គលនោះ ថាជាព្រាហ្មណ៍ រាគៈ ទោសៈ មានៈ និងសេចក្តីលុបគុណរបស់បុគ្គលណាជ្រុះចេញហើយ បីដូចជាគ្រាប់ស្ពៃធ្លាក់អំពីចុងនៃដែកស្រួច តថាគតពោលនូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាពោលវាចាឥតទោស ជាវាចាញ៉ាំងបុគ្គលឲ្យស្គាល់ប្រយោជន៍ ជាវាចាពិត ទាំងមិនបានធ្វើបុគ្គលណាមួយឲ្យចំពាក់ដោយវាចាណាឡើយ តថាគតពោលនូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាមិនបានបង្អោន របស់វែងឬខ្លី

ព្រាហ្មណវគ្គស្ស វាសេដ្ឋសុត្តេ ព្រាហ្មណព្យាករណំ

អណុំ ថូលំ សុភាសុភំ

លោកេ អទិន្នំ នាទេតិ

តមហំ ព្រូមិ ព្រាហ្មណំ

អាសា យស្ស ន វិជ្ជន្តិ

អស្មឹ លោកេ បរម្ហិ ច

និរាសាសំ វិសំយុត្តំ

តមហំ ព្រូមិ ព្រាហ្មណំ

យស្សាលយា ន វិជ្ជន្តិ

អញ្ញាយ អកថំកថី

អមតោគធំ អនុប្បត្តំ

តមហំ ព្រូមិ ព្រាហ្មណំ

យោធ បុញ្ញញ្ច បាបញ្ច

ឧភោ សង្គំ ឧបច្ចគា

អសោកំ វិរជំ សុទ្ធំ

តូចឬធំ ល្អឬអាក្រក់ ដែលគេមិនបានឲ្យ ក្នុងលោកនេះ តថាគតពោល នូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាមិនមានសេចក្តីប្រាថ្នា ក្នុងលោកនេះ និងលោកខាងមុខ តថាគតពោល នូវបុគ្គល ដែលមិនមានសេចក្តីប្រាថ្នា ជាអ្នកប្រាសចាកកិលេសនោះ ថាជាព្រាហ្មណ៍ បុគ្គលណាមិនមានសេចក្តីអាល័យ ជាអ្នកដឹងច្បាស់ មិនមានសេចក្តីសង្ស័យ តថាគតពោលនូវបុគ្គល ដែលបានសម្រេចនូវល្វែងនៃព្រះនិព្វាននោះ ថាជាព្រាហ្មណ៍ បុគ្គលណាក្នុងលោកនេះ កន្លងបង់នូវសេចក្តីចំពាក់ទាំងពីរគឺបុណ្យនិងបាបចេញបានហើយ តថាគតពោលនូវបុគ្គលដែលមិនមានសោក ប្រាសចាកធូលីគឺកិលេស ជាអ្នកបរិសុទ្ធស្អាត

តមហំ ព្រូមិ ព្រាហ្មណំ
ចន្ទំវ វិមលំ សុទ្ធំ
វិប្បសន្នំ អនាវិលំ
នន្ទិភវបរិក្ខីណំ
តមហំ ព្រូមិ ព្រាហ្មណំ
យោ ឥមំ បលិបថំ ទុគ្គំ
សំសារំ មោហមច្ចគា
តិណ្ណោ ចារំ គតោ ឈាយី
អនេជោ អកថំកថី
អនុបាទាយ និព្វុតោ
តមហំ ព្រូមិ ព្រាហ្មណំ
យោធ កាមេ[១] បហត្វាន
អនាគារោ បរិព្វជេ

១ ម. តណ្ហំ ។

នោះ ថាជាព្រាហ្មណ៍ បុគ្គលណាឥតមានមន្ទិលសៅហ្មង ជាបុគ្គលស្អាតផូរផង់ មិនល្អក់ដោយកិលេស មានតម្រេកក្នុងភពអស់ហើយ ដូចព្រះចន្ទប្រាសចាកមន្ទិល តថាគតពោលនូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាឆ្លងផុតនូវផ្លូវវៀចផ្លូវផុង ដែលនាំសត្វឲ្យអន្ទោលទៅ នាំសត្វឲ្យវង្វេងនេះ បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកដុតបង់នូវកិលេស ឥតមានតណ្ហា ឥតមានសេចក្តីសង្ស័យ ឥតមានប្រកាន់អ្វីបន្តិចបន្តួចហើយបរិនិព្វាន តថាគតពោលនូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាក្នុងលោកនេះ លះបង់នូវកាមទាំងឡាយចេញបាន ហើយបួសជាបុគ្គលមិនមានផ្ទះ

២១៩

ព្រាហ្មណវគ្គស្ស វាសេដ្ឋសុត្តេ ព្រាហ្មណព្យាករណំ

កាមភវបរិក្ខីណំ[(១)]

តមហំ ព្រូមិ ព្រាហ្មណំ

យោធ តណ្ហំ បហន្ត្វាន

អនាគារោ បរិព្វជេ

កាមភវបរិក្ខីណំ[(២)]

តមហំ ព្រូមិ ព្រាហ្មណំ

ហិត្វា មានុសកំ យោគំ

ទិព្វយោគំ ឧបច្ចគា

សព្វយោគវិសំយុត្តំ

តមហំ ព្រូមិ ព្រាហ្មណំ

ហិត្វា រតឹ អរតិញ្ច

---

១-២ ម. តណ្ហាភវបរិក្ខីណំ ។

តថាគតពោលនូវបុគ្គល ដែលមានកាមនិងភពអស់ហើយនោះ ថាជាព្រាហ្មណ៍ បុគ្គលណា ក្នុងលោកនេះ លះបង់នូវតណ្ហាចេញបាន ហើយបួស ជាបុគ្គលមិនមានផ្ទះ តថាគតពោលនូវបុគ្គលដែលមានកាម[១]និងភពអស់ហើយនោះ ថាជាព្រាហ្មណ៍ បុគ្គលណាលះបង់ នូវធម៌ជាគ្រឿងប្រកប គឺកាមគុណ ៥ ជារបស់មនុស្ស និងធម៌ជាគ្រឿងប្រកប គឺកាមគុណ ៥ ជារបស់ទិព្វ តថា-គតពោល នូវបុគ្គល ដែលប្រាសចាកធម៌ជាគ្រឿងប្រកបទាំងអស់នោះ ថាជាព្រាហ្មណ៍ បុគ្គលណា លះបង់នូវតម្រេក (ក្នុងកាមគុណ ៥ ផង) នូវសេចក្តីអផ្សុកផង

---

១ បើជា តណ្ហា ទើបគួរ ។

សីតីភូតំ និរូបធឹ
សព្វលោកាភិភុំ វីរំ
តមហំ ព្រូមិ ព្រាហ្មណំ
ចុតឹ យោ វេទិ សត្តានំ
ឧបបត្តិញ្ច សព្វសោ
អសត្តំ សុគតំ ពុទ្ធំ
តមហំ ព្រូមិ ព្រាហ្មណំ
យស្ស គតឹ ន ជានន្តិ
ទេវា គន្ធព្វមានុសា
ខីណាសវំ អរហន្តំ
តមហំ ព្រូមិ ព្រាហ្មណំ
យស្ស បុរេ ច បច្ឆា ច
មជ្ឈេ ច នត្ថិ កិញ្ចនំ
អកិញ្ចនំ អនាទានំ
តមហំ ព្រូមិ ព្រាហ្មណំ
ឧសភំ បវរំ វីរំ

ជាអ្នកត្រជាក់ត្រជុំ មិនមានកិលេស គ្របសង្កត់នូវខន្ធ-លោកទាំងអស់បាន ជាអ្នកមានព្យាយាម តថាគតពោលនូវបុគ្គលនោះ ថាជាព្រាហ្មណ៍ បុគ្គលណាដឹងនូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ដោយប្រការទាំងពួង តថា-គតពោលនូវបុគ្គលដែលមិនចំពាក់ (ក្នុងអារម្មណ៍) មានដំណើរល្អ អ្នកត្រាស់ដឹងនូវចតុរារិយសច្ចនោះ ថាជាព្រាហ្មណ៍ ទេវតា គន្ធព និងមនុស្សទាំងឡាយ មិនដឹងនូវគតិរបស់បុគ្គលណា តថាគតពោលនូវបុគ្គលនោះ ដែលជាអ្នកមានអាសវៈអស់ហើយ ជាអរហន្ត ថាជាព្រាហ្មណ៍ បុគ្គលណាមិនមានកង្វល់គឺកិលេសក្នុងអតីត អនាគតនិងបច្ចុ-ប្បន្នទេ តថាគតពោលនូវបុគ្គលដែលមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ បុគ្គលណាជាឧសភៈ (អង់អាច) ជាអ្នកប្រសើរ អ្នកមានសេចក្តីព្យាយាម

២២១

ព្រាហ្មណវគ្គស្ស វាសេដ្ឋសុត្តេ ព្រាហ្មណព្យាករណំ

មហេសឹ វិជិតាវិនំ
អនេជំ ន្ហាតកំ ពុទ្ធំ
តមហំ ព្រូមិ ព្រាហ្មណំ
បុព្វេនិវាសំ យោ វេទិ
សគ្គាបាយញ្ច បស្សសិ[១]
អថោ ជាតិក្ខយំ បត្តោ
តមហំ ព្រូមិ ព្រាហ្មណំ
សមញ្ញា ហេសា លោកស្មឹ
នាមគោត្តំ បកប្បិតំ
សមុច្ច សមុនាគតំ
តត្ថ តត្ថ បកប្បិតំ
ទីឃរត្តមនុសយិតំ
ទិដ្ឋិគតមជានតំ
អជានន្តា នោ ច ព្រូហន្តិ
ជាតិយា ហោតិ ព្រាហ្មណោ

១ ម. បស្សតិ ។

អ្នកស្វែងរកគុណដ៏ធំ  អ្នកមានជ័យជម្នះ  អ្នកមិនមានសេចក្តីញាប់ញ័រ (ដោយតណ្ហា) អ្នកលាងបង់នូវកិលេស  អ្នកត្រាស់ដឹងនូវចតុរារិយសច្ច  តថាគតពោលនូវបុគ្គលនោះ  ថាជាព្រាហ្មណ៍  បុគ្គលណាដឹងនូវខន្ធ  ដែលខ្លួនអាស្រ័យនៅក្នុងភពមុនផង  ឃើញសួគ៌និងអបាយផង  ដល់នូវការអស់ទៅនៃជាតិផង  តថាគតពោលនូវបុគ្គលនោះ  ថាជាព្រាហ្មណ៍  នាមនិងគោត្រដែលគេបានកំណត់តាំងទុក  ហៅត ៗ  គ្នាមកឈ្មោះនេះ  គ្រាន់តែជាវោហារក្នុងលោក  ដែលពួកញាតិនិងសាលោហិត  បានកំណត់តាំងទុក  ក្នុងកាលព្រាហ្មណ៍កើតហើយ  ក្នុងទីនោះ ៗ  ក៏កើតជាទិដ្ឋិដេកត្រាំនៅក្នុងពួកជនដែលមិនដឹងអស់កាលជាយូរអង្វែង  កាលបើពួកជនទាំងនោះមិនដឹង  ក៏នាំគ្នានិយាយថា  បុគ្គលជាព្រាហ្មណ៍ព្រោះជាតិ

ន ជច្ចា វសលោ ហោតិ
ន ជច្ចា ហោតិ ព្រាហ្មណោ
កម្មុនា វសលោ ហោតិ
កម្មុនា ហោតិ ព្រាហ្មណោ
កស្សកោ កម្មុនា ហោតិ
សិប្បិកោ ហោតិ កម្មុនា
វាណិជោ កម្មុនា ហោតិ
បេស្សិកោ ហោតិ កម្មុនា
ចោរោបិ កម្មុនា ហោតិ
យោធាជីវោបិ កម្មុនា
យាជកោ កម្មុនា ហោតិ
រាជាបិ ហោតិ កម្មុនា
ឯវមេតំ យថាភូតំ
កម្មំ បស្សន្តិ បណ្ឌិតា
បដិច្ចសមុប្បាទទសា
កម្មវិបាកកោវិទា

ឯបុគ្គលខូចកាច មិនមែនព្រោះជាតិទេ បុគ្គលដែលជាព្រាហ្មណ៍ ក៏មិនមែនព្រោះជាតិដែរ បុគ្គលដែលខូចកាចព្រោះកម្ម គឺការងារដែលធ្វើក្នុងបច្ចុប្បន្ន បុគ្គលដែលជាព្រាហ្មណ៍ក៏ព្រោះកម្ម ជាអ្នកស្រែក៏ព្រោះកម្ម ជាអ្នកមានសិប្បៈក៏ព្រោះកម្ម ជាពាណិជក៏ព្រោះកម្ម ជាអ្នកបម្រើគេក៏ព្រោះកម្ម ទោះបីជាចោរក៏ព្រោះកម្ម ជាទាហានក៏ព្រោះកម្ម ជាអ្នកបូជាក៏ព្រោះកម្ម ជាព្រះរាជាក៏ព្រោះកម្ម អ្នកប្រាជ្ញទាំងឡាយ អ្នកឃើញច្បាស់នូវធម៌ជាបច្ច័យអាស្រ័យកើតត ៗ គ្នា អ្នកឈ្លាសក្នុងវិបាករបស់កម្ម តែងឃើញកម្មនេះ តាមសេចក្ដីពិតយ៉ាងនេះថា

កម្មុនា វត្តតិ លោកោ

កម្មុនា វត្តតិ បជា

កម្មនិ ពន្ធនា សត្តា

រថស្សាណីវ យាយតោ

តបេន ព្រហ្មចរិយេន

សំយមេន ទមេន ច

ឯតេន ព្រាហ្មណោ ហោតិ

ឯតំ ព្រាហ្មណមុត្តមំ

តីហិ វិជ្ជាហិ សម្បន្នោ

សន្តោ ខីណបុនព្ភវោ

ឯវំ វាសេដ្ឋ ជានាហិ

ព្រហ្មា សក្កោ វិជានតន្តិ ។

[១២៤] ឯវំ វុត្តេ វាសេដ្ឋភារទ្វាជមាណវា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម

លោកតែងប្រព្រឹត្តទៅតាមកម្ម ប្រជាជន តែងប្រព្រឹត្តទៅតាមកម្ម សត្វទាំងឡាយ ដែលជាប់នៅក្នុងកម្ម ទើបប្រព្រឹត្តទៅបាន ដូចជារទេះដែលមានភ្លៅ ទើបបរទៅបាន បុគ្គលដែលជាព្រាហ្មណ៍ព្រោះកម្ម ៤ យ៉ាងនេះ គឺតបៈ ១ ព្រហ្មចរិយៈ ១ សំយមៈ ១ ទមៈ ១ កម្ម ៤ យ៉ាង ដ៏ប្រសើរបំផុតនេះ ជាគុណរបស់ព្រហ្មទាំងឡាយ សប្បុរសដែលបរិបូណ៌ដោយវិជ្ជា ៣ មានភពថ្មីអស់ហើយ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះហៅថាព្រហ្មក៏បាន ហៅថាឥន្ទក៏បាន សម្រាប់ពួកបណ្ឌិតជាអ្នកដឹង ។

[១២៥] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វាសេដ្ឋមាណព និងភារទ្វាជមាណព បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះ

អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណង្គតេតិ ។

វាសេដ្ឋសុត្តំ អដ្ឋមំ និដ្ឋិតំ ។

គោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយនេះ ដូចគេផ្ងាររបស់ដែលផ្កាប់ចុះ ឬដូចជាគេបើកបង្ហាញរបស់ដែលបិទបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចគេកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សមានចក្ខុមើលឃើញរូបទាំងឡាយបាន យើងខ្ញុំទាំងឡាយនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវយើងខ្ញុំទាំងឡាយ ថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិត ។

ចប់ វាសេដ្ឋសូត្រ ទី ៨ ។

# នវមំ សុភសុត្តំ

[១២៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សុភោ មាណវោ តោទេយ្យបុត្តោ សាវត្ថិយំ បដិវសតិ អញ្ញតរស្ស គហបតិស្ស និវេសនេ កេនចិទេវ ករណីយេន ។ អថខោ សុភោ មាណវោ តោទេយ្យបុត្តោ យស្ស គហបតិស្ស និវេសនេ បដិវសតិ តំ គហបតឹ ឯតទវោច សុតមេតំ គហបតិ អវិវិត្តា សាវត្ថី អរហន្តេហិ កំ នុ ខ្វជ្ជ[១] សមណំ វា ព្រាហ្មណំ វា បយិរុបាសេយ្យាមាតិ ។ អយំ ភន្តេ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ តំ ភន្តេ ភគវន្តំ បយិរូបាសស្សូតិ ។

១ ឱ. កន្នុ ខជ្ជ ។

# សុភសូត្រ ទី ៩

[១២៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង សុភមាណព ជាបុត្រតោទេយ្យ-ព្រាហ្មណ៍ អាស្រ័យនៅក្នុងនិវេសន៍របស់គហបតីម្នាក់ ក្នុងក្រុងសាវត្ថី ដោយកិច្ចដែលត្រូវធ្វើណានីមួយ ។ កាលដែលសុភមាណព ជាបុត្ររបស់តោទេយ្យព្រាហ្មណ៍ អាស្រ័យនៅក្នុងនិវេសន៍ របស់គហបតីណាក៏ពោលពាក្យនេះ នឹងគហបតីនោះថា ម្នាលគហបតី ខ្ញុំបានឮពាក្យនេះថា ក្រុងសាវត្ថីមិនស្ងាត់ចាកព្រះអរហន្តទាំងឡាយឡើយ ក្នុងថ្ងៃនេះ គួរយើងទាំងពីរនាក់ ចូលទៅអង្គុយជិតសមណៈ ឬព្រាហ្មណ៍ណាហ្ន៎ ។ គហបតីឆ្លើយថា បពិត្រអ្នកដ៏ចម្រើន ព្រះមានព្រះភាគនេះ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី បពិត្រអ្នកដ៏ចម្រើន សូមអ្នកចូលទៅអង្គុយជិត ព្រះមានព្រះភាគនោះចុះ ។

[១២៧] អថខោ សុភោ មាណវោ តោទេយ្យ-បុត្តោ តស្ស គហបតិស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុភោ មាណវោ តោទេយ្យបុត្តោ ភគវន្តំ ឯតទវោច ព្រាហ្មណា ភោ គោតម ឯវមាហំសុ គហដ្ឋោ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ន បព្វជិតោ អារាធកោ ហោតិ ញាយំ ធម្មំ កុសលន្តិ ឥធ ភវំ គោតមោ កិមាហាតិ ។ វិភជ្ជវាទោ ខោ អហមេត្ថ មាណវ នាហមេត្ថ ឯកំសវាទោ គិហិស្ស វាហំ មាណវ បព្វជិតស្ស វា មិច្ឆាបដិបត្តឹ វណ្ណេមិ[១] គិហី វា ហិ មាណវ បព្វជិតោ វា មិច្ឆាបដិបន្នោ

១ ឱ. ម. ន វណ្ណេមិ ។

[១២៧] លុះសុភមាណព ជាបុត្រតោទេយ្យព្រាហ្មណ៍ ទទួលពាក្យរបស់គហបតីនោះហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសុភមាណព ជាបុត្រតោទេយ្យ-ព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ច្រើននិយាយគ្នាយ៉ាងនេះថា គ្រហស្ថទើបជាអ្នកបំពេញនូវហេតុគឺកុសលធម៌បាន ឯបព្វជិតបំពេញនូវហេតុគឺកុសលធម៌មិនបានឡើយ ដូច្នេះ តើក្នុងសេចក្តីនេះ ព្រះគោតមដ៏ចម្រើននឹងទ្រង់ត្រាស់ថាដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាណព ក្នុងសេចក្តីនេះ តថាគតជាអ្នកពោលញែក ក្នុងសេចក្តីនេះ តថាគតមិនបានពោលដោយចំណែកមួយទេ ម្នាលមាណព តថាគតពណ៌នានូវសេចក្តីប្រតិបត្តិខុសរបស់គ្រហស្ថខ្វះ របស់បព្វជិតខ្វះ ម្នាលមាណព ព្រោះថា គ្រហស្ថក្តី បព្វជិតក្តី តែប្រតិបត្តិខុសហើយ

មិច្ឆាបដិបត្តាធិករណហេតុ ន អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ គិហិស្ស វាហំ មាណវ បព្វជិតស្ស វា សម្មាបដិបត្តឹ វណ្ណេមិ គិហី វា ហិ មាណវ បព្វជិតោ វា សម្មាបដិបន្នោ សម្មាបដិបត្តាធិករណហេតុ អារាធកោ ហោតិ ញាយំ ធម្មំ កុសលន្តិ ។

[១២៨] ព្រាហ្មណា ភោ គោតម ឯវមាហំសុ មហត្ថមិទំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ ឃរាវាសកម្មដ្ឋានំ មហប្ផលំ ហោតិ អប្បត្ថមិទំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ បព្វជ្ជាកម្ម-ដ្ឋានំ អប្បប្ផលំ ហោតីតិ ឥធ ភវំ គោតមោ កិមាហាតិ ។ ឯត្ថបិ ខោ អហំ មាណវ វិភជ្ជវាទោ ណាហមេត្ថ ឯកំសវាទោ អត្ថិ មាណវ កម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ

នឹងហៅថាជាអ្នកបំពេញនូវហេតុគឺកុសលធម៌ ព្រោះហេតុប្រតិបត្តិខុស មិនបានឡើយ ម្នាលមាណព តថាគតពណ៌នានូវសេចក្តីប្រតិបត្តិត្រូវរបស់គ្រហស្ថខ្លះ របស់បព្វជិតខ្លះ ព្រោះថា គ្រហស្ថក្តី បព្វជិតក្តី តែប្រតិបត្តិត្រូវហើយ ហៅថាជាអ្នកបំពេញនូវហេតុគឺកុសលធម៌ ព្រោះហេតុប្រតិបត្តិត្រូវនោះបាន ។

[១២៨] សុភមាណព ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ និយាយយ៉ាងនេះថា ហេតុជាទីតាំងនៃការងារ របស់ឃរាវាសនេះ មានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន ទើបមានផលច្រើន ឯហេតុជាទីតាំងនៃការងាររបស់បព្វជ្ជានេះ មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រុងប្រៀបតិច ទើបមានផលតិច ដូច្នេះ តើក្នុងសេចក្តីនេះ ព្រះគោតមដ៏ចម្រើន ទ្រង់ត្រាស់ថាដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព ក្នុងសេចក្តីនេះ តថាគតជាបុគ្គលពោលញែក ក្នុងសេចក្តីនេះ តថាគតមិនបានពោលដោយចំណែកមួយឡើយ ម្នាលមាណព ហេតុជាទីតាំងនៃការងារមានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន

មហាសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ អត្ថិ មាណវ កម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ អត្ថិ មាណវ កម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ អត្ថិ មាណវ កម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ ។

[១២៩] កតមំ[១] មាណវ កម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ ឃរាវាសកម្មដ្ឋានំ ខោ មាណវ កម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ

១ ឱ. ម. កតមញ្ច ។

មានសេចក្តីប្រុងប្រៀបច្រើន កាលបើមិនសម្រេច មានផលតិចក៏មាន ម្នាលមាណព ហេតុជាទីតាំងនៃការងារ មានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន កាលបើបានសម្រេច មានផលច្រើនក៏មាន ម្នាលមាណព ហេតុជាទីតាំងនៃការងារ មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រុងប្រៀបតិច កាលបើមិនសម្រេច បានផលតិចក៏មាន ម្នាលមាណព ហេតុជាទីតាំងនៃការងារ មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រុងប្រៀបតិច កាលបើបានសម្រេច បានផលច្រើនក៏មាន ។

[១២៩] ម្នាលមាណព ហេតុជាទីតាំងនៃការងារ មានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន កាលបើមិនសម្រេច បានផលតិចក៏មាន តើដូចម្តេចខ្លះ ម្នាលមាណព ហេតុជាទីតាំងនៃការងារ គឺការភ្ជួររាស់ មានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន

វិបជ្ជមានំ អប្បប្ផលំ ហោតិ ។ កតមញ្ច មាណវ កម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ កសិយេវ ខោ មាណវ កម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ ។ កតមញ្ច មាណវ កម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ វណិជ្ជា ខោ មាណវ កម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ ។ កតមញ្ច មាណវ កម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ វណិជ្ជាយេវ ខោ មាណវ កម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ ។

កាលបើមិនសម្រេច តែងមានផលតិច ។ ម្នាលមាណព ហេតុជាទីតាំងនៃការងារ មានសេចក្ដីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្ដីប្រុងប្រៀបច្រើន កាលបើបានសម្រេច តែងមានផលច្រើន តើដូចម្ដេច ម្នាលមាណព ហេតុជាទីតាំងនៃការងារ គឺការភ្ជួររាស់នេះឯង មានសេចក្ដីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្ដីប្រុងប្រៀបច្រើន កាលបើបានសម្រេច តែងមានផលច្រើន ។ ម្នាលមាណព ហេតុជាទីតាំងនៃការងារ មានសេចក្ដីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្ដីប្រុងប្រៀបតិច កាលបើមិនសម្រេច តែងមានផលតិច តើដូចម្ដេច ម្នាលមាណព ហេតុជាទីតាំងនៃការងារ គឺការលក់ដូរនេះឯង មានសេចក្ដីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្ដីប្រុងប្រៀបតិច កាលបើមិនសម្រេច តែងមានផលតិច ។ ម្នាលមាណព ហេតុជាទីតាំងនៃការងារ មានសេចក្ដីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្ដីប្រុងប្រៀបតិច កាលបើបានសម្រេច តែងមានផលច្រើន តើដូចម្ដេច ម្នាលមាណព ហេតុជាទីតាំងនៃការងារ គឺការលក់ដូរនេះឯង មានសេចក្ដីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្ដីប្រុងប្រៀបតិច កាលបើបានសម្រេច តែងមានផលច្រើន ។

[១៣០] សេយ្យថាបិ មាណវ កសិកម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ ឯវមេវ ខោ មាណវ ឃរាវាសកម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ ។ សេយ្យថាបិ មាណវ កសិយេវ កម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិករណំ មហាសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ ឯវមេវ ខោ មាណវ ឃរាវាសកម្មដ្ឋានំ មហត្ថំ មហាកិច្ចំ មហាធិ-ករណំ មហាសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ ។ សេយ្យថាបិ មាណវ វណិជ្ជាកម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ ឯវមេវ ខោ មាណវ បព្វជ្ជាកម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ វិបជ្ជមានំ អប្បប្ផលំ ហោតិ ។

[១៣០] ម្នាលមាណព ហេតុជាទីតាំងនៃការងាររបស់ឃរាវាស មានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន កាលបើមិនសម្រេច តែងមានផលតិច ដូចហេតុជាទីតាំងនៃកសិកម្ម គឺការភ្ជួររាស់ មានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន កាលបើមិនសម្រេច តែងមានផលតិចដូច្នោះឯង ។ ម្នាលមាណព ហេតុជាទីតាំងនៃការងារ របស់ឃរាវាស មានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន កាលបើបានសម្រេច តែងមានផលច្រើន ដូចហេតុជាទីតាំងនៃកសិកម្ម ដែលមានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រុងប្រៀបច្រើន កាលបើបានសម្រេច តែងមានផលច្រើនដូច្នោះឯង ។ ម្នាលមាណព ហេតុជាទីតាំងនៃបព្វជ្ជាកម្មគឺការបួស មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រុងប្រៀបតិច កាលបើមិនសម្រេច តែងមានផលតិច ដូចហេតុជាទីតាំងនៃពាណិជ្ជកម្ម គឺការលក់ដូរ មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រុងប្រៀបតិច កាលបើមិនសម្រេច តែងមានផលតិចដូច្នោះឯង ។

សេយ្យថាបិ មាណវ វណិជ្ជាយេវ កម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតិ ឯវមេវ ខោ មាណវ បព្វជ្ជាកម្មដ្ឋានំ អប្បត្ថំ អប្បកិច្ចំ អប្បាធិករណំ អប្បសមារម្ភំ សម្បជ្ជមានំ មហប្ផលំ ហោតីតិ ។

[១៣១] ព្រាហ្មណា ភោ គោតម បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធ-នាយាតិ ។ យេ តេ មាណវ ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនា-យ សចេ តេ អគរុ សាធុ តេ បញ្ច ធម្មេ ឥមស្មឹ[១] បរិសតិ[២] ភាសស្សូតិ ។ ន ខោ[៣] ភោ គោតម គរុ យត្ថស្សុ ភវន្តោ វា និសិន្នា ភវន្តរូបា វាតិ ។ តេនហិ មាណវ ភាសស្សូតិ ។

១ ឥមិស្សន្តិ បាឋេន ភវិតព្វំ ។ ២ ឱ. បរិសតី ។ ៣ ឱ. ម. ន ខោ មេតិ ទិស្សតិ ។

ម្នាលមាណព ហេតុជាទីតាំង នៃបព្វជ្ជាកម្ម មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រុងប្រៀបតិច កាលបើបានសម្រេច តែងមានផលច្រើន ដូចហេតុជាទីតាំងនៃពាណិជ្ជកម្ម ដែលមានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រុងប្រៀបតិច កាលបើបានសម្រេច តែងមានផលច្រើន ដូច្នោះឯង ។

[១៣១] សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ នាំគ្នាបញ្ញត្តធម៌ ៥ យ៉ាង ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមាណព ពួកព្រាហ្មណ៍នាំគ្នាបញ្ញត្តធម៌ ៥ ណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បើអ្នកមិនទើសទាល់ទេ ចូរអ្នកពោលធម៌ទាំង ៥ នោះ ក្នុងបរិស័ទនេះ មកមើល ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គក្តី អ្នកប្រាជ្ញប្រហែលនឹងព្រះអង្គក្តី គង់ក្នុងទីណា ទីនោះឈ្មោះថា មិនទើសទាល់ (ដល់ខ្ញុំព្រះអង្គ) ។ ម្នាលមាណព បើដូច្នោះ អ្នកចូរពោលចុះ ។

[១៣២] សច្ចំ ខោ ភោ គោតម ព្រាហ្មណោ បឋមំ ធម្មំ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ តបំ(១) ខោ ភោ គោតម ព្រាហ្មណា ទុតិយំ ធម្មំ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ព្រហ្មចរិយំ ខោ ភោ គោតម ព្រាហ្មណា តតិយំ ធម្មំ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ អជ្ឈេនំ ខោ ភោ គោតម ព្រាហ្មណា ចតុត្ថំ ធម្មំ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ចាគំ ខោ ភោ គោតម ព្រាហ្មណា បញ្ចមំ ធម្មំ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុស-លស្ស អារាធនាយ ព្រាហ្មណោ ភោ គោតម ឥមេ បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយាតិ ឥធ ភវំ គោតមោ កិមាហាតិ ។

១ ម. តបញ្ច ។

[១៣២] សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាបញ្ញត្តធម៌ទី ១ គឺវចីសច្ចៈ ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាបញ្ញត្តធម៌ទី ២ គឺតបៈ ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាបញ្ញត្តធម៌ទី ៣ គឺព្រហ្មចរិយៈ ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាបញ្ញត្តធម៌ទី ៤ គឺការបង្រៀនមន្ត ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាបញ្ញត្តធម៌ទី ៥ គឺចាគៈ ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍នាំគ្នាបញ្ញត្តធម៌ទាំង ៥ នេះ ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល ដូច្នេះ តើក្នុងសេចក្ដីនេះ ព្រះគោតមដ៏ចម្រើន ទ្រង់ត្រាស់ថាដូចម្ដេច ។

ព្រាហ្មណវគ្គស្ស សុភសុត្តេ បញ្ចធម្មប្បញ្ញត្តិ

[១៣៣] កឹ បន មាណវ អត្ថិ កោចិ ព្រាហ្មណានំ ឯកព្រាហ្មណោបិ យោ ឯវមាហ អហំ ឥមេសំ បញ្ចន្នំ ធម្មានំ សយំ អភិញ្ញា សច្ឆិកត្វា វិបាកំ បវេទេមីតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន មាណវ អត្ថិ កោចិ ព្រាហ្មណានំ ឯកាចរិយោបិ ឯកាចរិយប្បាចរិយោបិ យាវ សត្តមា អាចរិយមហាយុគា យោ ឯវមាហ អហំ ឥមេសំ បញ្ចន្នំ ធម្មានំ សយំ អភិញ្ញា សច្ឆិកត្វា វិបាកំ បវេទេមីតិ ។ នោ ហិទំ ភោ គោតម ។ កឹ បន មាណវ យេបិ តេ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណានំ ចោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ

ព្រាហ្មណវគ្គ សុភសូត្រ ការបញ្ញត្តធម៌ ៥ យ៉ាង

[១៣៣] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព បណ្ដាព្រាហ្មណ៍ទាំងឡាយ ចុះមានព្រាហ្មណ៍ណាមួយ សូម្បីតែព្រាហ្មណ៍ម្នាក់ បាននិយាយយ៉ាងនេះថា យើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា នូវធម៌ទាំង ៥ យ៉ាងនេះ ដោយខ្លួនឯង ទើបប្រកាសផល ដូច្នេះ មានដែរឬទេ ។ សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន មិនមានទេ ។ ម្នាលមាណព បណ្ដាព្រាហ្មណ៍ទាំងឡាយ ចុះមានព្រាហ្មណ៍ណាមួយ ជាអាចារ្យម្នាក់ក្ដី ជាអាចារ្យប្រធានលើអាចារ្យម្នាក់ក្ដី ដរាបអំពីជួរនៃអាចារ្យជាគម្រប់ ៧ មក បាននិយាយយ៉ាងនេះថា យើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា នូវធម៌ទាំង ៥ យ៉ាងនេះ ដោយខ្លួនឯង ទើបប្រកាសផល ដូច្នេះ មានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានទេ ។ ម្នាលមាណព ចុះពួកឥសីជាន់មុន ៗ ដែលជាអ្នកតែងមន្ត ជាអ្នកពាយមន្តដល់ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ឥឡូវនេះ តែងស្វាធ្យាយតាមបទមន្ត ជារបស់ចាស់ ដែលធ្លាប់ច្រៀង ធ្លាប់ប្រព្រឹត្ត ធ្លាប់ផ្សំមកនោះ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលពួកឥសីពោលមកហើយ តែងបង្រៀនតាមបទមន្តដែលពួកឥសីបង្រៀនមកហើយ ដូចជាឥសីឈ្មោះអដ្ឋកៈ ១ ឈ្មោះវាមកៈ ១

វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ តេបិ ឯវមាហំសុ មយំ ឥមេសំ បញ្ចន្នំ សយំ អភិញ្ញា សច្ឆិកត្វា វិចាកំ បវេទេមាតិ ។ នោ ហិទំ ភោ គោតម ។

[១៣៤] ឥតិ កិរ មាណវ នត្ថិ កោចិ ព្រាហ្មណានំ ឯកព្រាហ្មណោបិ យោ ឯវមាហ អហំ ឥមេសំ បញ្ចន្នំ ធម្មានំ សយំ អភិញ្ញា សច្ឆិកត្វា វិចាកំ បវេទេមីតិ នត្ថិ កោចិ ព្រាហ្មណានំ ឯកាចរិយោបិ ឯកាចរិយប្បាចរិយោបិ យាវ សត្តមា អាចរិយមហាយុគា យោ ឯវមាហ អហំ ឥមេសំ បញ្ចន្នំ ធម្មានំ សយំ អភិញ្ញា សច្ឆិកត្វា វិចាកំ បវេទេមីតិ

ឈ្មោះវាមទេវៈ ១ ឈ្មោះវេស្សាមិត្រ ១ ឈ្មោះយមតគ្គិ ១ ឈ្មោះអង្គីរសៈ ១ ឈ្មោះភារទ្វាជៈ ១ ឈ្មោះវាសេដ្ឋៈ ១ ឈ្មោះកស្សបៈ ១ ឈ្មោះភគុ ១ ឥសីទាំងនោះបានពោលហើយយ៉ាងនេះថា ពួកយើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា នូវធម៌ទាំង ៥ យ៉ាងនេះ ដោយខ្លួនឯង ទើបប្រកាសផល ដូច្នេះ មានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនមានទេ ។

[១៣៤] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព បណ្តាព្រាហ្មណ៍ទាំងឡាយ មិនមានព្រាហ្មណ៍ណាមួយ សូម្បីតែព្រាហ្មណ៍ម្នាក់ បាននិយាយយ៉ាងនេះថា យើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា នូវធម៌ទាំង ៥ នេះ ដោយខ្លួនឯង ទើបប្រកាសផល ដូច្នេះទេ បណ្តាព្រាហ្មណ៍ទាំងឡាយ មិនមានព្រាហ្មណ៍ណាមួយ ជាអាចារ្យម្នាក់ក្តី ជាអាចារ្យប្រធានលើអាចារ្យម្នាក់ក្តី ដរាបអំពីជួរនៃអាចារ្យជាគម្រប់ ៧ មក បាននិយាយយ៉ាងនេះថា យើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា នូវធម៌ទាំង ៥ យ៉ាងនេះ ដោយខ្លួនឯង ទើបប្រកាសផល ដូច្នេះទេ

យេបិ តេ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ តេបិ ន ឯវមាហំសុ មយំ ឥមេសំ បញ្ចន្នំ ធម្មានំ សយំ អភិញ្ញា សច្ឆិកត្វា វិបាកំ បវេទេមាតិ សេយ្យថាបិ មាណវ អន្ធវេណិ បរំបរាសំសត្តា បុរិមោបិ ន បស្សតិ មជ្ឈិមោបិ ន បស្សតិ បច្ឆិមោបិ ន បស្សតិ ឯវមេវ ខោ មាណវ អន្ធវេណូបមំ មញ្ញេ ព្រាហ្មណានំ ភាសិតំ សម្បជ្ជតិ បុរិមោបិ ន បស្សតិ មជ្ឈិមោបិ ន បស្សតិ បច្ឆិមោបិ ន បស្សតីតិ ។

ពួកឥសីជាន់មុន ។ ដែលជាអ្នកតែងមន្ត ជាអ្នករាយមន្តដល់ពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ ឥឡូវនេះ តែងស្វាធ្យាយតាមបទមន្ត ជារបស់ចាស់ ដែលធ្លាប់ច្រៀងមក ធ្លាប់ប្រព្រឹត្តមក ធ្លាប់ផ្សំមកនោះ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្តដែលពួកឥសីពោលមកហើយ តែងបង្រៀនតាមបទមន្ត ដែលពួកឥសីបង្រៀនមកហើយ ដូចជាឥសីឈ្មោះអដ្ឋកៈ ១ ឈ្មោះវាមកៈ ១ ឈ្មោះវាមទេវៈ ១ ឈ្មោះវេស្សាមិត្រ ១ ឈ្មោះយមតគ្គិ ១ ឈ្មោះអង្គីរសៈ ១ ឈ្មោះភារទ្វាជៈ ១ ឈ្មោះវាសេដ្ឋៈ ១ ឈ្មោះកស្សប ១ ឈ្មោះភគុ ១ ពួកឥសីទាំងនោះ ក៏មិនបានពោលយ៉ាងនេះថា ពួកយើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា នូវធម៌ទាំង ៥ នេះ ដោយខ្លួនឯង ទើបប្រកាសផល ដូច្នេះទេ ម្នាលមាណព មនុស្សខ្វាក់ទាំងជួរដើរដឹកដៃគ្នា អ្នកមុខក៏មើលមិនឃើញ អ្នកកណ្តាលក៏មើលមិនឃើញ អ្នកក្រោយក៏មើលមិនឃើញ យ៉ាងណា ម្នាលមាណព ភាសិតសម្រេចដល់ពួកព្រាហ្មណ៍ ក៏មានទំនង ប្រៀបដូចមនុស្សខ្វាក់ទាំងជួរ អ្នកមុខក៏មើលមិនឃើញ អ្នកកណ្តាលក៏មើលមិនឃើញ អ្នកក្រោយក៏មើលមិនឃើញ យ៉ាងនោះឯង ។

[១៣៥] ឯវំ វុត្តេ សុភោ មាណវោ តោទេយ្យ-បុត្តោ ភគវតោ[១] អង្គវេណ្ហាបម្ហេន វុច្ចមានោ កុបិតោ អនត្តមនោ ភគវន្តំយេវ ខុំសេន្តោ ភគវន្តំយេវ វម្ភេន្តោ ភគវន្តំយេវ វទមានោ សមណោ គោតមោ បាបិតោ ភវិស្សតីតិ ភគវន្តំ ឯតទវោច ព្រាហ្មណោ ភោ គោតម បោក្ខរសាតិ ឱបម្មញ្ញោ សុភគវនិកោ ឯវមាហ ឯវមេវ ខោ[២] បនិមេ ភោ សមណព្រាហ្មណា ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ បដិជានន្តិ តេសមិទំ ភាសិតំ ហស្សកំយេវ សម្បជ្ជតិ នាមកំយេវ សម្បជ្ជតិ រិត្តកំយេវ សម្បជ្ជតិ តុច្ឆកំយេវ សម្បជ្ជតិ កថំ ហិ នាម មនុស្សភូតោ ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ ញស្សតិ វា ទក្ខិតិ វា សច្ឆិ វា ករិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។

---

១ ឱ. ម. ភគវតា ។ ២ ឱ. ម. ខោសទ្ទោ នត្ថិ ។

[១៣៥] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សុភមាណព ជាបុត្ររបស់តោទេយ្យព្រាហ្មណ៍ ដែលត្រូវព្រះមានព្រះភាគត្រាស់ឧបមាថាដូចជាមនុស្សខ្វាក់ទាំងជួរ ក៏ខឹង អាក់អន់ចិត្ត ជេរព្រះមានព្រះភាគ ប្រទេចព្រះមានព្រះភាគ និយាយនឹងព្រះមានព្រះភាគថា ព្រះសមណគោតម ធ្វើអាត្មាអញឲ្យមានសេចក្តីអាក្រក់ដូច្នេះហើយ ក៏និយាយនឹងព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ឈ្មោះបោក្ខរសាតិ ជាឱបម្មញ្ញគោត្រ ជាធំក្នុងសុភគវនជនបទ (ក្នុងស្រុកឧកដ្ឋា) បានពោលយ៉ាងនេះថា សមណ-ព្រាហ្មណ៍ពួកខ្លះ ប្តេជ្ញានូវឧត្តរិមនុស្សធម៌ដែលជាគុណវិសេសគួរឃើញដោយញាណដ៏ប្រសើរយ៉ាងនេះឯង ភាសិតរបស់សមណព្រាហ្មណ៍ទាំងនោះ នាំឲ្យតែគេសើចលេង នាំឲ្យតែអាក្រក់ឈ្មោះ ជារបស់នាំឲ្យឥតប្រយោជន៍សោះសូន្យទទេ ព្រោះថា ធម្មតាមនុស្សនឹងដឹង ឬនឹងឃើញ ឬនឹងធ្វើឲ្យច្បាស់ នូវឧត្តរិមនុស្សធម៌ ដែលជាគុណវិសេសគួរឃើញដោយញាណដ៏ប្រសើរ ដូចម្តេចបាន ការណ៍ដូច្នេះនេះមិនមានឡើយ ។

កឹ បន មាណវ ព្រាហ្មណោ ចោក្ខរសាតិ ឱបម្មញ្ញោ សុភគវនិកោ សព្វេសំយេវ សមណព្រាហ្មណានំ ចេតសា ចេតោ បរិច្ច បជានាតីតិ ។ សកាយបិ ហិ ភោ គោតម បុណ្ណិកាយ ទាសិយា ព្រាហ្មណោ ចោក្ខរសាតិ ឱបម្មញ្ញោ សុភគវនិកោ[១] ចេតសា ចេតោ បរិច្ច បជានាតិ កុតោ បន សព្វេសំយេវ សមណព្រាហ្មណានំ ចេតសា ចេតោ បរិច្ច បជានិស្សតីតិ ។

[១៣៦] សេយ្យថាបិ មាណវ ជច្ចន្ធោ បុរិសោ សោ[២] ន បស្សេយ្យ កណ្ហសុក្កានិ រូបានិ ន បស្សេយ្យ នីលកានិ រូបានិ ន បស្សេយ្យ បីតកានិ រូបានិ ន បស្សេយ្យ លោហិតកានិ រូបានិ ន បស្សេយ្យ មញ្ជេដ្ឋកានិ រូបានិ ន បស្សេយ្យ សមវិសមានិ ន បស្សេយ្យ តារករូបានិ ន បស្សេយ្យ ចន្ទិមសុរិយេ សោ ឯវំ វទេយ្យ នត្ថិ កណ្ហសុក្កានិ រូបានិ នត្ថិ កណ្ហសុក្កានំ រូបានំ ទស្សាវី

១ ឱ. ឯត្តន្តរេ នសទ្ទោ ទិស្សតិ ។ ២ ឱ. សោតិ នត្ថិ ។

ម្នាលមាណព ចុះបោក្ខរសាតិព្រាហ្មណ៍ ជាឱបម្មញ្ញគោត្រ ជាធំក្នុងសុភគវនេជនបទ (ក្នុងស្រុកឧកដ្ឋា) នឹងកំណត់ដឹងចិត្តរបស់ពួកសមណ-ព្រាហ្មណ៍ទាំងអស់ ដោយចិត្តរបស់ខ្លួនបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន អម្បាលនាងបុណ្ណាជាទាសីរបស់គាត់ ក៏បោក្ខរសាតិព្រាហ្មណ៍ជាឱបម្មញ្ញគោត្រ ជាធំក្នុងសុភគវនេជនបទ (ក្នុងស្រុកឧកដ្ឋា) កំណត់ដឹងចិត្តដោយចិត្តរបស់ខ្លួនមិនបានទៅហើយ នឹងកំណត់ដឹងចិត្ត របស់សមណព្រាហ្មណ៍ទាំងអស់ ដោយចិត្តខ្លួនឯង ឯណាបាន ។

[១៣៦] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព ដូចបុរសខ្វាក់អំពីកំណើត មិនធ្លាប់ឃើញរូបខ្មៅឬស មិនធ្លាប់ឃើញរូបខៀវ មិនធ្លាប់ឃើញរូបលឿង មិនធ្លាប់ឃើញរូបក្រហម មិនធ្លាប់ឃើញរូបហង្សបាទ មិនធ្លាប់ឃើញទីស្មើនិងមិនស្មើ មិនធ្លាប់ឃើញរូបផ្កាយនិងព្រះចន្ទព្រះអាទិត្យទាំងឡាយ ក៏និយាយយ៉ាងនេះថា រូបខ្មៅនិងស ក៏មិនមាន បុគ្គលដែលជាអ្នកឃើញរូបខ្មៅនិងស ក៏មិនមាន

នត្ថិ នីលកានិ រូបានិ នត្ថិ នីលកានំ រូបានំ ទស្សាវី នត្ថិ បីតកានិ រូបានិ នត្ថិ បីតកានំ រូបានំ ទស្សាវី នត្ថិ លោហិតកានិ រូបានិ នត្ថិ លោហិតកានំ រូបានំ ទស្សាវី នត្ថិ មញ្ជេដ្ឋកានិ រូបានិ នត្ថិ មញ្ជេដ្ឋកានំ រូបានំ ទស្សាវី នត្ថិ សមវិសមំ នត្ថិ សមវិសមស្ស ទស្សាវី នត្ថិ តារក-រូបានិ នត្ថិ តារករូបានំ ទស្សាវី នត្ថិ ចន្ទិមសុរិយា នត្ថិ ចន្ទិមសុរិយានំ ទស្សាវី អហមេតំ ន ជានាមិ អហមេតំ ន បស្សាមិ តស្មា តំ[១] នត្ថីតិ សម្មា នុ ខោ សោ មាណវ វទមានោ វទេយ្យាតិ ។ នោ ហិទំ ភោ គោតម នត្ថិ កណ្ហាសុក្កានិ រូបានិ អត្ថិ កណ្ហាសុក្កានំ រូបានំ ទស្សាវី អត្ថិ នីលកានិ រូបានិ

---

១ ឱ. តន្តិ ន ទិស្សតិ ។

រូបខៀវក៏មិនមាន បុគ្គលដែលជាអ្នកឃើញរូបខៀវក៏មិនមាន រូបលឿងក៏មិនមាន បុគ្គលដែលជាអ្នកឃើញរូបលឿងក៏មិនមាន រូបក្រហមក៏មិនមាន បុគ្គលដែលជាអ្នកឃើញរូបក្រហមក៏មិនមាន រូបហង្សបាទក៏មិនមាន បុគ្គលដែលជាអ្នកឃើញរូបហង្សបាទក៏មិនមាន ទីដែលស្មើនិងមិនស្មើក៏មិនមាន បុគ្គលដែលជាអ្នកឃើញទីស្មើនិងមិនស្មើក៏មិនមាន រូបផ្កាយក៏មិនមាន បុគ្គលដែលជាអ្នកឃើញរូបផ្កាយក៏មិនមាន ព្រះចន្ទព្រះអាទិត្យក៏មិនមាន បុគ្គលដែលជាអ្នកឃើញព្រះចន្ទព្រះអាទិត្យក៏មិនមាន អាត្មាអញមិនស្គាល់របស់នុ៎ះ អាត្មាអញមិនឃើញរបស់នុ៎ះ ព្រោះហេតុនុ៎ះរបស់នោះមិនមានឡើយ ម្នាលមាណព បុរសនោះកាលនិយាយដូច្នេះ តើឈ្មោះថា និយាយត្រូវដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើនមិនត្រូវទេ ព្រោះថា រូបខ្មៅនិងសក៏មាន បុគ្គលដែលជាអ្នកឃើញរូបខ្មៅនិងសក៏មាន រូបខៀវក៏មាន បុគ្គលដែលជាអ្នកឃើញរូបខៀវក៏មាន

អត្ថិ នីលកានំ រូបានំ ទស្សាវី អត្ថិ បីតកានិ រូបានិ អត្ថិ បីតកានំ រូបានំ ទស្សាវី អត្ថិ លោហិតកានិ រូបានិ អត្ថិ លោហិតកានំ រូបានំ ទស្សាវី អត្ថិ មញ្ជេដ្ឋកានិ រូបានិ អត្ថិ មញ្ជេដ្ឋកានំ រូបានំ ទស្សាវី អត្ថិ សមវិសមំ អត្ថិ សមវិសមស្ស ទស្សាវី អត្ថិ តារការូបានិ អត្ថិ តារការូបានំ ទស្សាវី អត្ថិ ចន្ទិមសុរិយា អត្ថិ ចន្ទិមសុរិយានំ ទស្សាវី អហមេតំ ន ជានាមិ អហមេតំ ន បស្សាមិ តស្មា តំ នត្ថីតិ ន ហិ កោ គោតម សម្មា វទមានោ វទេយ្យាតិ ។ ឯវមេវ ខោ មាណវ ព្រាហ្មណោ បោក្ខរសាតិ ឱបមញ្ញោ សុភគវនិកោ អន្ធោ អចក្ខុកោ សោ វត ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ ញស្សតិ វា ទក្ខិតិ វា សច្ឆិ វា ករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

រូបលឿងក៏មាន បុគ្គលដែលជាអ្នកឃើញរូបលឿងក៏មាន រូបក្រហមក៏មាន បុគ្គលដែលជាអ្នកឃើញរូបក្រហមក៏មាន រូបហង្សបាទក៏មាន បុគ្គលដែលជាអ្នកឃើញរូបហង្សបាទក៏មាន ទីដែលស្មើនិងមិនស្មើក៏មាន បុគ្គលដែលជាអ្នកឃើញទីដែលស្មើនិងមិនស្មើ ក៏មាន រូបផ្កាយក៏មាន បុគ្គលដែលជាអ្នកឃើញរូបផ្កាយ ក៏មាន ព្រះចន្ទព្រះអាទិត្យ ក៏មាន បុគ្គលដែលជាអ្នកឃើញព្រះចន្ទនិងព្រះអាទិត្យក៏មាន បពិត្រព្រះគោតមដ៏ចម្រើន បុរសនោះ កាលពោលដោយត្រឹមត្រូវ មិនគប្បីពោលថា ខ្ញុំមិនស្គាល់របស់នោះ ខ្ញុំមិនឃើញនូវរបស់នោះ ព្រោះហេតុដូច្នោះ របស់នោះមិនមានឡើយ ដូច្នេះទេ ។ ម្នាលមាណព សេចក្តីនេះមានឧបមេយ្យដូចបោក្ខរសាតិព្រាហ្មណ៍ ជាឱបម្មញ្ញគោត្រ ជាធំក្នុងសុភគវនជនបទ (ក្នុងស្រុកឧកដ្ឋា) ជាបុគ្គលខ្វាក់ មិនមានចក្ខុយ៉ាងនោះឯង គាត់នឹងដឹង ឬនឹងឃើញ ឬនឹងធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ដែលជាគុណវិសេសគួរឃើញដោយញាណដ៏ប្រសើរបាន ការណ៍ដូច្នេះនេះ មិនមានឡើយ ។

[១៣៧] តំ កឹ មញ្ញសិ មាណវ យេ បន[១] តេ កោសលិកា ព្រាហ្មណមហាសាលា សេយ្យថីទំ ចង្កី ព្រាហ្មណោ តារុក្ខោ ព្រាហ្មណោ បោក្ខរសាតិ ព្រាហ្មណោ ជាណុស្សោណិ ព្រាហ្មណោ បិតា វា[២] តេ តោទេយ្យោ កតមា នេសំ សេយ្យា[៣] យំ វា តេ សំមុច្ចា[៤] វាចំ ភាសេយ្យុំ យំ វា អសំមុច្ចា-តិ ។ សំមុច្ចា ភោ គោតម ។ កតមា តេសំ សេយ្យា យំ វា តេ មន្តា វាចំ ភាសេយ្យុំ យំ វា អមន្តាតិ ។ មន្តា ភោ គោតម ។ កតមា តេសំ សេយ្យា យំ វា តេ បដិសង្ខាយ វាចំ ភាសេយ្យុំ យំ វា អប្បដិសង្ខាយាតិ ។ បដិសង្ខាយ ភោ គោតម ។

១ ឱ. បនសទ្ទោ នត្ថិ ។ ២ ម. ច ។ ៣ ឱ. ម. សេយ្យោ ។ ៤ ឱ. សម្មុសា ។ ម. សមុច្ចា ។

[១៣៧] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព អ្នកសំគាល់នូវហេតុនោះដូចម្ដេច បើព្រាហ្មណមហាសាលណាមួយ ដែលនៅក្នុងកោសលជនបទ ដូចជាចង្កីព្រាហ្មណ៍ តារុក្ខព្រាហ្មណ៍ បោក្ខរសាតិព្រាហ្មណ៍ ជាណុស្សោណិព្រាហ្មណ៍ ឬតោទេយ្យព្រាហ្មណ៍ ជាបិតារបស់អ្នកឯង គប្បីពោលវាចាណា តាមលោកវោហារក្ដី ពោលវាចាណាមិនតាមលោកវោហារក្ដី តើវាចាដូចម្ដេច របស់ព្រាហ្មណមហាសាលទាំងនោះ ដែលជាវាចាប្រសើរជាងគេ ។ បពិត្រព្រះគោតមដ៏ចម្រើន វាចាដែលពោលតាមលោកវោហារជាវាចាប្រសើរ ។ ព្រាហ្មណ៍ទាំងនោះ ត្រិះរិះហើយពោលវាចាក្ដី មិនបានត្រិះរិះហើយពោលវាចាក្ដី តើវាចារបស់ពួកព្រាហ្មណ៍ទាំងនោះ ណាប្រសើរជាង ។ បពិត្រព្រះគោតមដ៏ចម្រើន វាចាដែលត្រិះរិះហើយពោល ប្រសើរជាង ។ ព្រាហ្មណ៍ទាំងនោះ ដឹងហើយពោលវាចាណាក្ដី មិនដឹងហើយពោលវាចាណាក្ដី តើវាចារបស់ព្រាហ្មណ៍ទាំងនោះ ណាប្រសើរជាង ។ បពិត្រព្រះគោតមដ៏ចម្រើន វាចាដែលព្រាហ្មណ៍ទាំងនោះ ដឹងហើយពោល ប្រសើរជាង ។

កតមា តេសំ សេយ្យា យំ វា តេ អត្ថសញ្ហិតំ វាចំ ភាសេយ្យុំ យំ វា អនត្ថសញ្ហិតន្តិ ។ អត្ថសញ្ហិតំ ភោ គោតម ។

[១៣៨] តំ កឹ មញ្ញសិ មាណវ យទិ ឯវំ សន្តេ ព្រាហ្មណោ ពោក្ខរសាតិជា ឱបម្មញ្ញេន សុភគវនិកោន សំមុច្ចា វាចា ភាសិតា អសំ-មុច្ចាតិ ។ សំមុច្ចា ភោ គោតម ។ មន្តា វាចា ភាសិតា អមន្តា វាចាតិ ។ អមន្តា ភោ គោតម ។ បដិសង្ខាយ ភាសិតា វាចា អប្ប-ដិសង្ខាយាតិ ។ អប្បដិសង្ខាយ ភោ គោតម ។ អត្ថសញ្ហិតា វាចា ភាសិតា អនត្ថសញ្ហិតាតិ ។ អនត្ថសញ្ហិតា ភោ គោតម ។

ព្រាហ្មណ៍ទាំងនោះ ពោលវាចាណា ដែលប្រកបដោយប្រយោជន៍ក្តី មិនប្រកបដោយប្រយោជន៍ក្តី តើវាចារបស់ព្រាហ្មណ៍ទាំងនោះ ណាប្រសើរជាង ។ បពិត្រព្រះគោតមដ៏ចម្រើន វាចាដែលព្រាហ្មណ៍ទាំងនោះ ពោលប្រកបដោយប្រយោជន៍ (ប្រសើរជាង) ។

[១៣៨] ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមាណព អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមាន វាចាដែលបោក្ខរសាតិព្រាហ្មណ៍ ជាឱបម្មញ្ញគោត្រ ជាធំក្នុងសុភគវនជនបទ (ក្នុងស្រុកឧកដ្ឋា) ពោលតាមលោកវោហារ ឬមិនពោលតាមលោកវោហារទេ ។ សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន បោក្ខរសាតិព្រាហ្មណ៍ ពោលតាមលោកវោហារ ។ បោក្ខរសាតិព្រាហ្មណ៍ ពិចារណាហើយពោលវាចា ឬមិនបានពិចារណា ហើយពោលវាចា ។ បពិត្រព្រះគោតមដ៏ចម្រើន បោក្ខរសាតិព្រាហ្មណ៍មិនបានពិចារណាទេ ។ បោក្ខរសាតិព្រាហ្មណ៍ដឹងហើយពោលវាចា ឬមិនបានដឹងហើយពោលវាចា ។ បពិត្រព្រះគោតមដ៏ចម្រើន បោក្ខរសាតិព្រាហ្មណ៍ មិនបានដឹងទេ ។ បោក្ខរសាតិព្រាហ្មណ៍ ពោលវាចាប្រកបដោយប្រយោជន៍ ឬមិនបានប្រកបដោយប្រយោជន៍ទេ ។ បពិត្រព្រះគោតម ដ៏ចម្រើន បោក្ខរសាតិព្រាហ្មណ៍ ពោលវាចាមិនប្រកបដោយប្រយោជន៍ទេ ។

[១៣៩] បញ្ច ខោ ឥមេ មាណវ នីវរណា កតមេ បញ្ច កាមច្ឆន្ទនីវរណំ ព្យាបាទនីវរណំ ថីនមិទ្ធនីវរណំ ឧទ្ធច្ចកុក្កុច្ចនីវរណំ វិចិកិច្ឆានីវរណំ ឥមេ ខោ មាណវ បញ្ច នីវរណា ។ ឥមេហិ ខោ មាណវ បញ្ចហិ នីវរណេហិ ព្រាហ្មណោ ចោក្ខរសាតិ ឱប-ម្មញ្ញោ សុភគវនិកោ អាវុតោ និវុតោ ឱផុតោ បរិយោនទ្ធោ សោ វត ឧត្តរឹ មនុស្សធម្មា អលមរិ-យញ្ញាណទស្សនវិសេសំ ញស្សតិ វា ទក្ខិតិ វា សច្ឆិ វា ករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

[១៤០] បញ្ច ខោ ឥមេ មាណវ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា

[១៣៩] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព នីវរណធម៌ទាំងនេះ មាន ៥ ប្រការ នីវរណធម៌ ៥ ប្រការនោះ ដូចម្តេចខ្លះ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ម្នាលមាណព នីវរណធម៌មាន ៥ ប្រការនេះឯង ។ ម្នាលមាណព បោក្ខរសាតិព្រាហ្មណ៍ ជាឱបម្មញ្ញគោត្រ ជាធំក្នុងសុភគវនជនបទ (ក្នុងស្រុកឧកដ្ឋា) ត្រូវនីវរណធម៌ ៥ ប្រការនេះឯង មកបិទបាំងរាំងរា ព័ទ្ធព័ទ្ធ រួបរឹតហើយ គាត់នឹងដឹង ឬនឹងឃើញ ឬនឹងធ្វើឲ្យជាក់ច្បាស់ នូវឧត្តរិមនុស្សធម៌ ដែលជាគុណវិសេសគួរឃើញដោយញាណដ៏ប្រសើរ ការណ៍ ដូច្នេះនេះ មិនមានឡើយ ។

[១៤០] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព កាមគុណទាំងឡាយនេះ មាន ៥ ប្រការ កាមគុណ ៥ ប្រការនោះ ដូចម្តេចខ្លះ គឺរូបារម្មណ៍គប្បីដឹងដោយចក្ខុបសាទ ជាទីប្រាថ្នា ជាទីត្រេកអរ

ព្រាហ្មណវគ្គស្ស សុភសុត្តេ កាមគុណកថា

មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោ-តវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ មាណវ បញ្ច កាមគុណា ។ ឥមេហិ ខោ មាណវ បញ្ចហិ កាមគុណេហិ ព្រាហ្មណោ បោក្ខរសាតិ ឱបម្មញ្ញោ សុភគវនិកោ គធិតោ មុច្ឆិតោ អជ្ឈាបន្នោ[១] អនាទីនវទស្សាវី អនិស្សរ-ណប្បញ្ញោ បរិភុញ្ជតិ សោ វត ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ ញស្សតិ វា ទក្ខិតិ វា សច្ឆិ វា ករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

១ ឱ. ម. អជ្ឈោបន្នោ ។

ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេក ១ សទ្ទារម្មណ៍ដែលគប្បីដឹងដោយសោតបសាទ ១ ។ បេ ។ គន្ធារម្មណ៍ដែលគប្បីដឹង ដោយឃានបសាទ... ១ រសារម្មណ៍ដែលគប្បីដឹងដោយជិវ្ហាបសាទ... ១ ផោដ្ឋព្វារម្មណ៍ដែលគប្បីដឹងដោយកាយ-បសាទ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេក ១ ម្នាលមាណព កាម-គុណមាន ៥ ប្រការនេះឯង ។ ម្នាលមាណព បោក្ខរសាតិព្រាហ្មណ៍ ជាឱបម្មញ្ញគោត្រ ជាធំក្នុងស្រុកគវនេជនបទ (ក្នុងស្រុកឧកដ្ឋា) ចំពាក់ចិត្ត ងប់ចិត្ត លង់គំនិត ដោយកាមគុណទាំង ៥ ប្រការនេះឯង ជាអ្នកមិនឃើញទោស មិនមានបញ្ញាជាគ្រឿងរលាស់ចេញ (ចាកភព) តែងបរិភោគ (នូវកាមគុណនោះ) គាត់នឹងដឹង ឬនឹងឃើញ ឬនឹងធ្វើឲ្យជាក់ច្បាស់ នូវឧត្តរិមនុស្សធម៌ ដែលជាគុណវិសេសគួរឃើញដោយញាណដ៏ប្រសើរ ការណ៍ដូច្នេះនេះ មិនមានឡើយ ។

[១៤១] តំ កឹ មញ្ញសិ មាណវ យំ វា តិណ-
កដ្ឋុបាទានំ បដិច្ច អគ្គិ ជាលេយ្យ យំ វា និស្សដ្ឋតិ-
ណកដ្ឋុបាទានំ អគ្គិ ជាលេយ្យ កតមោ នុ ខោ
អស្ស អគ្គិ អច្ចិមា ចេវ[១] វណ្ណិមា ច បភស្សរោ
ចាតិ ។ សចេ តំ ភោ គោតម ឋានំ និស្សដ្ឋតិណ-
កដ្ឋុបាទានំ អគ្គិ ជលិតុំ ស្វាស្ស អគ្គិ អច្ចិមា ចេវ
វណ្ណិមា ច បភស្សរោ ចាតិ ។ អដ្ឋានំ ខោ ឯតំ
មាណវ អនវកាសោ យំ និស្សដ្ឋតិណកដ្ឋុបាទានំ
អគ្គិ ជាលេយ្យ អញ្ញត្រ ឥទ្ធិមតា សេយ្យថាបិ
មាណវ តិណកដ្ឋុបាទានំ បដិច្ច អគ្គិ ជលតិ

១ ឱ. ច ។

[១៤១] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព អ្នកសំគាល់ហេតុនោះដូចម្តេច បុគ្គលបង្កាត់ភ្លើងឲ្យឆេះឡើង ព្រោះអាស្រ័យស្មៅនិងឧស ជាកំញមណាក្តី បង្កាត់ភ្លើងឲ្យឆេះឡើង ព្រោះមិនអាស្រ័យស្មៅនិងឧស ជាកំញមណាក្តី ភ្លើងណាហ្ន៎ ដែលមានអណ្តាត មានពណ៌ មានពន្លឺ ។ សុភមាណព ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន បើហេតុនោះមានទំនងដើម្បីនឹងឲ្យភ្លើងដែលមិនអាស្រ័យស្មៅនិងឧសឆេះឡើងបាន ភ្លើងនោះ ទើបមានអណ្តាត មានពណ៌ មានពន្លឺ ។ ម្នាលមាណព ឥតមានហេតុ ឥតមានបច្ច័យណា ឲ្យបុគ្គលបង្កាត់ភ្លើង ដែលមិនអាស្រ័យស្មៅនិងឧស ជាកំញម ឲ្យឆេះឡើងបានឡើយ វៀរលែងតែបុគ្គលមានឫទ្ធិ ម្នាលមាណព ភ្លើងអាស្រ័យស្មៅនិងឧសជាកំញម ទើបឆេះឡើងបាន ដូចម្តេចមិញ

តថូបមាហំ មាណវ ឥមំ បីតឹ វទាមិ យាយំ បីតិ បញ្ច កាមគុណេ បដិច្ច ។ សេយ្យថាបិ មាណវ និស្សជ្ជតិណកដ្ឋុបាទានោ អគ្គិ ជលតិ តថូបមាហំ មាណវ ឥមំ បីតឹ វទាមិ យាយំ បីតិ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ កតមា ច មាណវ បីតិ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ ឥធ មាណវ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ អយម្បិ ខោ មាណវ បីតិ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ ។ បុន ចបរំ មាណវ[១] វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ អយម្បិ ខោ មាណវ បីតិ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុស-លេហិ ធម្មេហិ ។

១ ឱ. ម. ឯត្ថន្តរេ ភិក្ខូតិ ទិស្សតិ ។

ម្នាលមាណព តថាគតពោលបីតិ ដែលអាស្រ័យនូវកាមគុណទាំង ៥ ថាមានឧបមេយ្យដូច្នោះដែរ ម្នាលមាណព មួយទៀត ភ្លើងមិនអាស្រ័យស្មៅនិងឧសជាកំញម ឆេះឡើងបាន ដូចម្តេចមិញ ម្នាលមាណព តថាគតពោលបីតិ ដែលប្រាសចាកកាមទាំងឡាយផង ប្រាសចាកអកុសលធម៌ទាំងឡាយផង ថាមានឧបមេយ្យដូច្នោះដែរ ម្នាលមាណព ចុះបីតិដែលប្រាសចាកកាមទាំងឡាយផង ប្រាសចាកអកុសលធម៌ទាំង-ឡាយផង ដូចម្តេចខ្លះ ម្នាលមាណព ភិក្ខុក្នុងធម្មវិន័យនេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ។ បេ ។ ក៏ចូលបឋមជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលមាណព នេះឯងឈ្មោះថា បីតីដែលប្រាសចាកកាមទាំងឡាយ ប្រាសចាកអកុសលធម៌ទាំងឡាយ ។ ម្នាលមាណព មួយទៀត ភិក្ខុនោះព្រោះរម្ងាប់វិតក្កៈវិចារៈរួចហើយ ។ បេ ។ ចូលទុតិយជ្ឈានសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលមាណព នេះឯងឈ្មោះថា បីតិដែលប្រាសចាកកាមទាំងឡាយ ប្រាសចាកអកុសលធម៌ទាំងឡាយ ។

[១៤២] យេ តេ មាណវ ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ កតមេត្ថ ព្រាហ្មណា ធម្មំ មហប្ផលតរំ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយាតិ ។ យេមេ ភោ គោតម ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ចាគមេត្ថ ព្រាហ្មណា ធម្មំ មហប្ផលតរំ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយាតិ ។

[១៤៣] តំ កឹ មញ្ញសិ មាណវ ឥធ អញ្ញតរស្ស ព្រាហ្មណស្ស មហាយញ្ញោ បច្ចុបដ្ឋិតោ អស្ស ។ អថ ទ្វេ ព្រាហ្មណា អាគច្ឆេយ្យុំ ឥត្ថន្នាមស្ស ព្រាហ្មណស្ស មហាយញ្ញំ អនុភវិស្សាមាតិ ។ តត្រ

[១៤២] ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមាណព ព្រាហ្មណ៍ទាំងឡាយ នាំគ្នាបញ្ញត្តធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បណ្ដាធម៌ទាំង ៥ ប្រការនុ៎ះ ព្រាហ្មណ៍ទាំងឡាយ នាំគ្នាបញ្ញត្តធម៌ណា ថាជាធម៌មានផលច្រើនជាង ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល ។ សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ នាំគ្នាបញ្ញត្តធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល បណ្ដាធម៌ទាំងនុ៎ះ ព្រាហ្មណ៍ទាំងឡាយ នាំគ្នាបញ្ញត្តធម៌គឺចាគៈ ថាជាធម៌មានផលច្រើនជាង ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល ។

[១៤៣] ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមាណព អ្នកសំគាល់សេចក្ដីនោះដូចម្ដេច បើមហាយ័ញ្ញប្រាកដឡើង ចំពោះមុខព្រាហ្មណ៍ម្នាក់ក្នុងលោកនេះ ។ វេលានោះ ស្រាប់តែមានព្រាហ្មណ៍ពីរនាក់មកគិតគ្នាថា យើងទាំងពីរនាក់ មុខជានឹងបានបរិភោគនូវមហាយ័ញ្ញរបស់ព្រាហ្មណ៍ឈ្មោះនេះ ។ បណ្ដាព្រាហ្មណ៍ទាំងពីរនាក់នោះ

២៤៧



ឯកស្ស[១] ព្រាហ្មណស្ស ឯវមស្ស អហោ វតាហមេវ លភេយ្យំ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ន អញ្ញេ ព្រាហ្មណា លភេយ្យុំ[២] ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ។ ឋានំ ខោ បនេតំ មាណវ វិជ្ជតិ យំ អញ្ញោ ព្រាហ្មណោ លភេយ្យ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ន សោ ព្រាហ្មណោ លភេយ្យ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ។ អញ្ញេ ព្រាហ្មណា លភន្តិ[៣] ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ នាហំ លភាមិ ភត្តគ្គេ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌន្តិ ឥតិ សោ កុបិតោ អនត្តមនោ ឥមស្ស បន មាណវ ព្រាហ្មណា កឹ វិបាកំ បញ្ញបេន្តីតិ ។ ន ខ្វេត្ថ ភោ គោតម ព្រាហ្មណា ឯវំ ទានំ ទេន្តិ

---

១ ឱ. តត្ថេកស្ស ។ ២ ឱ. ម. អញ្ញោ ព្រាហ្មណោ លភេយ្យាតិ ទិស្សតិ ។ ៣ ឱ. អញ្ញោ ព្រាហ្មណោ លភតីតិ ទិស្សតិ ។

ព្រាហ្មណ៍ម្នាក់ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ក្នុងរោងកត្ត (តែម្នាក់ឯង) កុំឲ្យពួកព្រាហ្មណ៍ដទៃ បានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរក្នុងរោងកត្តឡើយ ។ ម្នាលមាណព បើព្រាហ្មណ៍ដទៃ បានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ក្នុងរោងកត្ត ឯព្រាហ្មណ៍នោះ ត្រឡប់ជាមិនបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរក្នុងរោងកត្តវិញ ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ព្រាហ្មណ៍ទាំងឡាយដទៃ បានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ក្នុងរោងកត្ត ឯព្រាហ្មណ៍នោះ ក៏ខឹងក្រោធអាក់អន់ចិត្តដោយគិតថា អាត្មាអញមិនបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ក្នុងរោងកត្ត ដូច្នេះ ម្នាលមាណព តើពួកព្រាហ្មណ៍បញ្ញត្ត នូវវិបាករបស់មហាយ័ញ្ញនេះដូចម្តេចខ្លះ ។ សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ក្នុងសេចក្តីនេះ ព្រាហ្មណ៍ទាំងឡាយឲ្យទានយ៉ាងនេះ

ឥមិនា ច ភោ[១] កុបិតោ អនត្តមនោតិ អថខ្វេត្ថ ព្រាហ្មណា អនុកម្បជាតិកាំយេវ ជានំ ចេន្តីតិ ។ ឯវំ សន្តេ ខោ មាណវ ព្រាហ្មណានំ ឥទំ ឆដ្ឋំ បុញ្ញកិរិយាវត្ថុំ ហោតិ យទិទំ អនុកម្បជាតិកន្តិ ។ ឯវំ សន្តេ ភោ គោតម ព្រាហ្មណានំ ឥទំ ឆដ្ឋំ បុញ្ញកិរិយាវត្ថុំ ហោតិ យទិទំ អនុកម្បជាតិកន្តិ ។

[១៤៤] យេ តេ មាណវ ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ឯតេ កត្ថ ពហុលំ សមនុ-បស្សសីតិ[២] ។ យេមេ ភោ គោតម ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ឥមាហំ បញ្ច ធម្មេ បព្វជិតេសុ ពហុលំ សមនុបស្សាមិ អប្បំ គហដ្ឋេសុ គហដ្ឋោ ហិ ភោ គោតម មហដ្ឋោ មហាកិច្ចោ

១ ឱ. ម. ឥមិនា បរោ កុបិតោ ហោតូតិ ទិស្សតិ ។ ២ ឱ. ម. ឥមេ ត្វំ បញ្ច ធម្មេ កត្ថ ពហុលំ សមនុបស្សិ គហដ្ឋេសុ វា បព្វជិតេសុ វាតិ ទិស្សន្តិ ។

ដោយគិតថា នឹងឲ្យព្រាហ្មណ៍នេះក្រោធអាក់អន់ចិត្តទៅរកបុគ្គលដទៃក៏ទេ តែថាក្នុងសេចក្តីនេះ ព្រាហ្មណ៍ទាំងឡាយ ឲ្យទានគ្រាន់តែជារបស់សង្គ្រោះប៉ុណ្ណោះ ។ ម្នាលមាណព កាលបើហេតុយ៉ាងនេះមាន បុញ្ញកិរិយាវត្ថុទី ៦ នេះ ជាការសង្គ្រោះរបស់ពួកព្រាហ្មណ៍ឬ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលបើហេតុយ៉ាងនេះមាន បុញ្ញកិរិយាវត្ថុទី ៦ នេះ ក៏ទៅជាការសង្គ្រោះរបស់ព្រាហ្មណ៍ទាំងឡាយ ។

[១៤២] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព ព្រាហ្មណ៍ទាំងឡាយ បញ្ញត្តធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល អ្នកពិចារណានូវធម៌ទាំង ៥ ប្រការនុ៎ះ តើមានច្រើនក្នុងបរិស័ទណា ។ សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ បញ្ញត្តធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល ខ្ញុំព្រះអង្គពិចារណាឃើញធម៌ទាំង ៥ ប្រការនេះ មានច្រើនក្នុងពួកបព្វជិត មានតិចក្នុងពួកគ្រហស្ថ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា គ្រហស្ថមានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន

ព្រាហ្មណវគ្គស្ស  សុភសុត្តេ  សុភមាណវវិសជ្ជនា

មហាធិករណោ មហាសមារម្ភោ ន សតតំ សមិតំ សច្ចវាទី ហោតិ បព្វជិតោ ខោ បន ភោ គោតម អប្បដ្ឋោ អប្បកិច្ចោ អប្បាធិករណោ អប្បសមារម្ភោ សតតំ សមិតំ សច្ចវាទី ហោតិ គហដ្ឋោ ហិ ភោ គោតម មហដ្ឋោ មហាកិច្ចោ មហាធិករណោ មហាសមារម្ភោ ន សតតំ សមិតំ តបស្សី ហោតិ... ព្រហ្មចារី ហោតិ... សជ្ឈាយពហុលោ ហោតិ... ចាគពហុលោ ហោតិ បព្វជិតោ ខោ បន ភោ គោតម អប្បដ្ឋោ អប្បកិច្ចោ អប្បាធិករណោ អប្បសមារម្ភោ សតតំ សមិតំ តបស្សី ហោតិ... ព្រហ្មចារី ហោតិ... សជ្ឈាយពហុលោ ហោតិ... ចាគពហុលោ ហោតិ ។ យេមេ ភោ គោតម ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ឥមាហំ បញ្ច ធម្មេ បព្វជិតេសុ ពហុលំ សមនុបស្សាមិ អប្បំ គហដ្ឋេសូតិ ។

មានអធិករណ៍ច្រើន មានសេចក្តីប្រារព្ធច្រើន នឹងនិយាយពាក្យពិតទៀងទាត់រឿយ ៗ ពុំបាន បពិត្រព្រះគោតមដ៏ចម្រើន ចំណែកខាងបព្វជិត មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រារព្ធតិច និយាយពាក្យពិតទៀងទាត់រឿយ ៗ បាន បពិត្រព្រះគោតមដ៏ចម្រើន ឯគ្រហស្ថមានសេចក្តីត្រូវការច្រើន មានកិច្ចច្រើន មានអធិករណ៍ច្រើន មានសេចក្តីប្រារព្ធច្រើន នឹងប្រព្រឹត្តដុតកម្តៅកិលេសទៀងទាត់រឿយ ៗ ពុំបាន... ប្រព្រឹត្តធម៌ដ៏ប្រសើរ... ច្រើនដោយការស្វាធ្យាយ... ច្រើនដោយការបរិច្ចាគទាន បពិត្រព្រះគោតមដ៏ចម្រើន ចំណែកខាងបព្វជិត មានសេចក្តីត្រូវការតិច មានកិច្ចតិច មានអធិករណ៍តិច មានសេចក្តីប្រារព្ធតិច ប្រព្រឹត្តព្យាយាមដុតកម្តៅកិលេសទៀងទាត់រឿយ ៗ បាន... ប្រព្រឹត្តធម៌ដ៏ប្រសើរ... ច្រើនដោយការស្វាធ្យាយ... ច្រើនដោយការបរិច្ចាគទាន ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ បញ្ញត្តធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល ខ្ញុំព្រះអង្គពិចារណាឃើញធម៌ទាំង ៥ ប្រការនេះ មានច្រើនក្នុងពួកបព្វជិត មានតិចក្នុងពួកគ្រហស្ថ ។

[១៤៥] យេ តេ មាណវ ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ចិត្តស្សាហំ ឯតេ បរិក្ខារេ វទាមិ យទិទំ ចិត្តំ អវេរំ អព្យាបជ្ឈំ តស្ស ភាវនាយ ។ ឥធ មាណវ ភិក្ខុ សច្ចវាទី ហោតិ សោ សច្ចវាទិម្ហីតិ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ យន្តំ កុសលូបសញ្ហិតំ បាមុជ្ជំ ចិត្តស្សាហំ ឯតំ បរិក្ខារំ វទាមិ យទិទំ ចិត្តំ អវេរំ អព្យាបជ្ឈំ តស្ស ភាវនាយ ។ ឥធ មាណវ ភិក្ខុ តបស្សី ហោតិ... ព្រហ្មចារី ហោតិ... សជ្ឈាយពហុលោ ហោតិ... ចាគពហុលោ ហោតិ សោ ចាគពហុលោម្ហីតិ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ

[១៤៥] ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមាណព ព្រាហ្មណ៍ទាំងឡាយ បញ្ញត្តធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល តថាគតពោលនូវធម៌ទាំង ៥ ប្រការនុ៎ះថាជាបរិក្ខាររបស់ចិត្ត ដែលមិនមានពៀរ មិនមានព្យាបាទ ដើម្បីការអប់រំចិត្តនោះ ។ ម្នាលមាណព ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកនិយាយពិត ភិក្ខុនោះគិតថា អាត្មាអញនិយាយពិត ដូច្នេះហើយ តែងបាននូវការដឹងក្នុងអត្ថ បាននូវការដឹងក្នុងធម៌ បាននូវបាមោជ្ជៈដែលអាស្រ័យនឹងធម៌ បាមោជ្ជៈណាអាស្រ័យនឹងកុសលធម៌ តថាគតពោលនូវបាមោជ្ជៈនុ៎ះថាជាបរិក្ខាររបស់ចិត្ត ដែលមិនមានពៀរ មិនមានព្យាបាទ ដើម្បីការអប់រំចិត្តនោះ ។ ម្នាលមាណព ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកប្រព្រឹត្តព្យាយាមដុតកម្តៅកិលេស... ប្រព្រឹត្តធម៌ដ៏ប្រសើរ... ច្រើនដោយការស្វាធ្យាយ... ច្រើនដោយការបរិច្ចាគទាន ភិក្ខុនោះគិតថា អាត្មាអញជាអ្នកច្រើនដោយការបរិច្ចាគទាន ដូច្នេះហើយ ទើបបាននូវការដឹងក្នុងអត្ថ បាននូវការដឹងក្នុងធម៌ បាននូវបាមោជ្ជៈដែលអាស្រ័យនឹងធម៌

យន្តំ កុសលូបសញ្ហិតំ ចាមុជ្ជំ ចិត្តស្សាហំ ឯតំ បរិក្ខារំ វទាមិ យទិទំ ចិត្តំ អវេរំ អព្យាបជ្ឈំ តស្ស ភាវនាយ ។ យេ តេ មាណវ ព្រាហ្មណា បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ចិត្តស្សាហំ ឯតេ បរិក្ខារេ វទាមិ យទិទំ ចិត្តំ អវេរំ អព្យាបជ្ឈំ តស្ស ភាវនាយាតិ ។ ឯវំ វុត្តេ សុភោ មាណវោ តោទេយ្យបុត្តោ ភគវន្តំ ឯតទវោច សុតំ មេតំ ភោ គោតម សមណោ គោតមោ ព្រហ្មានំ សហាព្យតាយ មគ្គំ ទេសេតីតិ ។

[១៤៦] តំ កឹ មញ្ញសិ មាណវ អាសន្នេ ឥតោ នឡការគាមោ នយិតោ ទូរេ នឡការគាមោតិ ។ ឯវំ ភោ គោតម អាសន្នេ ឥតោ នឡការគាមោ នយិតោ ទូរេ នឡការគាមោតិ ។ តំ កឹ មញ្ញសិ មាណវ ឥធ ខ្វស្ស[១] បុរិសោ នឡការគាមេ ជាតវឌ្ឍោ

១ ឱ. ម. ឥធស្ស ។

បាមោជ្ជៈណាដែលអាស្រ័យនូវកុសលធម៌ តថាគតពោលនូវបាមោជ្ជៈនុ៎ះ ថាជាបរិក្ខាររបស់ចិត្ត ដែលមិនមានពៀរ មិនមានព្យាបាទ ដើម្បីការអប់រំចិត្តនោះ ។ ម្នាលមាណព ព្រាហ្មណ៍ទាំងឡាយ បញ្ញត្តធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល តថាគតពោលនូវធម៌ទាំង ៥ ប្រការនុ៎ះ ថាជាបរិក្ខាររបស់ចិត្ត ដែលមិនមានពៀរ មិនមានព្យាបាទ ដើម្បីការអប់រំចិត្តនោះ ។ កាលដែលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ សុភមាណពជាបុត្រតោទេយ្យព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន រឿងនេះ ខ្ញុំព្រះអង្គបានឮមកហើយថា ព្រះសមណគោតមទ្រង់ជ្រាបច្បាស់ នូវផ្លូវប្រព្រឹត្តទៅមួយអន្លើដោយពួកព្រហ្ម ។

[១៤៦] ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព អ្នកសំគាល់សេចក្តីនោះដូចម្តេច នឡការគ្រាមនៅជិតទីនេះ នឡការគ្រាមនៅមិនឆ្ងាយអំពីទីនេះទេឬ ។ សុភមាណពក្រាបទូលថា ព្រះករុណា ព្រះគោតមដ៏ចម្រើន នឡការគ្រាមនៅជិតទីនេះ នឡការគ្រាមនៅមិនឆ្ងាយអំពីទីនេះប៉ុន្មានទេ ។ ម្នាលមាណព អ្នកសំគាល់សេចក្តីនោះ ដូចម្តេច បើបុរសកើតចម្រើនធំឡើង ក្នុងនឡការគ្រាមនេះ

តមេនំ នឡការគាមតោ តាវទេវ អបសក្កំ[១] នឡ-ការគាមស្ស មគ្គំ បុច្ឆេយ្យ សិយា នុ ខោ មាណវ តស្ស បុរិសស្ស នឡការគាមេ ជាតវឌ្ឍស្ស នឡ-ការគាមស្ស មគ្គំ បុដ្ឋស្ស ទន្ធាយិតត្តំ វា វិត្ថាយិតត្តំ វាតិ ។ នោ ហិទំ ភោ គោតម តំ កិស្ស ហេតុ អស្ស ហិ ភោ គោតម បុរិសស្ស នឡការគាមេ ជាតវឌ្ឍស្ស[២] សព្វានេវ នឡការគាមស្ស មគ្គានិ សុវិទិតានីតិ ។ សិយា នុ ខោ មាណវ តស្ស បុរិសស្ស នឡការគាមេ ជាតវឌ្ឍស្ស នឡការគា-មស្ស មគ្គំ បុដ្ឋស្ស ទន្ធាយិតត្តំ វា វិត្ថាយិតត្តំ វា ន ត្វេវ តថាគតស្ស ព្រហ្មលោកំ វា ព្រហ្ម-លោកគាមិនឹ វា បដិបទំ បុដ្ឋស្ស ទន្ធាយិតត្តំ វា វិត្ថាយិតត្តំ វា ព្រហ្មានញ្ចាហំ មាណវ បជានាមិ ព្រហ្មលោកញ្ច ព្រហ្មលោកគាមិនិញ្ច បដិបទំ

១ ឱ. អវដំ ។ ២ ឱ. ម. អមុ ហិ ភោ គោតម បុរិសោ នឡការគាមេ ជាតវឌ្ឍោ តស្សាតិ ទិស្សន្តិ ។

បើគេសួររកផ្លូវនឡការគ្រាម នឹងបុរសដែលទើបចេញអំពីនឡការគ្រាម មួយរំពេចនោះ ម្នាលមាណព តើបុរសដែលកើតចម្រើនធំឡើងក្នុងនឡ-ការគ្រាមនេះ ដែលគេសួររកផ្លូវរបស់នឡការគ្រាម នឹងមានសេចក្ដីយឺតយូរអឹមអៀមដែរឬ ។ សុភមាណពក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនេះមិនដូច្នោះទេ បពិត្រព្រះគោតមដ៏ចម្រើន ដំណើរនោះព្រោះហេតុអ្វី ព្រោះថាផ្លូវរបស់នឡការគ្រាមសព្វអន្លើ បុរសដែលកើតចម្រើនធំឡើងក្នុងនឡការគ្រាមនោះស្គាល់ច្បាស់ហើយ ។ ម្នាលមាណព បុរសដែលកើតចម្រើនធំឡើងក្នុងនឡការគ្រាម ដែលគេសួររកផ្លូវរបស់នឡការគ្រាម មានសេចក្ដីយឺតយូរអឹមអៀមខ្លះ ឯតថាគតកាលបើមានគេសួររកព្រហ្មលោក ឬការប្រតិបត្តិទៅកាន់ព្រហ្មលោក ក៏ឥតមានសេចក្ដីយឺតយូរអឹមអៀមឡើយ ម្នាលមាណព ព្រោះតថាគតស្គាល់ច្បាស់នូវព្រហ្មផង នូវព្រហ្មលោកផង នូវបដិបទាទៅកាន់ព្រហ្មលោកផង

យថាបដិបន្នោ ច ព្រហ្មលោកំ ឧបបន្នោ តញ្ច បជានាមីតិ ។ សុតំ មេតំ ភោ គោតម សមណោ គោតមោ ព្រហ្មានំ សហព្យតាយ មគ្គំ ទេសេតីតិ សាធុ មេ ភវំ គោតមោ ព្រហ្មានំ សហព្យតាយ មគ្គំ ទេសេតូតិ ។ តេនហិ មាណវ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សុភោ មាណវោ តោទេយ្យបុត្តោ ភគវតោ បច្ចស្សោសិ ។

[១៨៧] ភគវា ឯតទវោច កតមោ ច មាណវ ព្រហ្មានំ សហព្យតាយ មគ្គោ ឥធ មាណវ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន

បុគ្គលប្រតិបត្តិយ៉ាងណា ហើយបានទៅកាន់ព្រហ្មលោក តថាគតដឹងច្បាស់នូវបដិបទានោះផង ។ បពិត្រព្រះគោតមដ៏ចម្រើន រឿងនេះ ខ្ញុំព្រះអង្គបានស្តាប់មកហើយថា ព្រះសមណគោតម ទ្រង់សំដែងនូវផ្លូវប្រព្រឹត្តទៅមួយអន្លើដោយពួកព្រហ្ម សូមព្រះគោតមដ៏ចម្រើន ទ្រង់ព្រះមេត្តាប្រោសប្រាប់ផ្លូវប្រព្រឹត្តទៅមួយអន្លើ ដោយពួកព្រហ្ម ដល់ខ្ញុំព្រះអង្គ ។ ម្នាលមាណព បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ សុភមាណពជាបុត្រតោទេយ្យព្រាហ្មណ៍ ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១៤៧] ព្រះមានព្រះភាគទ្រង់ត្រាស់ ដូច្នេះថា ម្នាលមាណព ផ្លូវប្រព្រឹត្តទៅមួយអន្លើដោយពួកព្រហ្ម នោះដូចម្តេចខ្លះ ម្នាលមាណព ភិក្ខុក្នុងធម្មវិន័យនេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តាធំទូលាយ មានសភាពជាចិត្តធំ ប្រមាណមិនបាន

អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ឯវំ ភាវិតាយ ខោ មាណវ មេត្តាយ ចេតោវិមុត្តិយា យំ បមាណកតំ កម្មំ ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតិ សេយ្យថាបិ មាណវ ពលវា សង្ខធមោ អប្បកសិរេនេវ ចាតុទ្ទិសា វិញ្ញាបេយ្យ ឯវមេវ ខោ មាណវ ឯវំ ភាវិតាយ មេត្តាយ ចេតោវិមុត្តិយា យំ បមាណកតំ កម្មំ ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតិ អយម្បិ ខោ មាណវ ព្រហ្មានំ សហព្យតាយ មគ្គោ ។ បុន ចបរំ មាណវ ភិក្ខុ ករុណាសហគតេន ចេតសា . . . មុទិតាសហគតេន ចេតសា . . .

មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ដោយប្រការទាំងពួង ក្នុងទីទាំងពួង ទាំងទិសខាងលើខាងក្រោម និងទិសទទឹងដោយប្រការដូច្នេះ ម្នាលមាណព មេត្តាចេតោវិមុត្តិ ដែលភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនហើយដោយប្រការយ៉ាងនេះ កម្មណាជាកម្មដែលភិក្ខុនោះធ្វើហើយល្មមប្រមាណ កម្មនោះនឹងមិនឈប់នៅក្នុងទីនោះ កម្មនោះមិនបិតនៅក្នុងទីនោះ ម្នាលមាណព បុរសមានកម្លាំង ជាអ្នកផ្លុំស័ង្ខ នឹងញ៉ាំងទិសទាំង ៤ ឲ្យឮខ្ទរខ្ទារទៅបានមិនលំបាក ដូចម្តេចមិញ ម្នាលមាណព កាលបើមេត្តាចេតោវិមុត្តិ ដែលភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនហើយដោយប្រការយ៉ាងនេះ កម្មណា ជាកម្មដែលភិក្ខុនោះធ្វើហើយល្មមប្រមាណ កម្មនោះនឹងមិនឈប់នៅក្នុងទីនោះ កម្មនោះមិនបិតនៅក្នុងទីនោះ ដូច្នោះឯង ម្នាលមាណព នេះឯងឈ្មោះថាផ្លូវប្រព្រឹត្តទៅមួយអន្លើដោយពួកព្រហ្ម ។ ម្នាលមាណព មួយទៀត ភិក្ខុមានចិត្តប្រកប ដោយករុណា... មានចិត្តប្រកប ដោយមុទិតា...

ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ឯវំ ភាវិតាយ ខោ មាណវ ឧបេក្ខាយ ចេតោវិមុត្តិយា យំ បមាណកតំ កម្មំ ន តំ តត្រាវសិស្សតិ ន តំ តត្រាវតិដ្ឋតិ សេយ្យថាបិ មាណវ ពលវា សង្ខ-ធមោ អប្បកសិរេនេវ ចាតុទ្ទិសា វិញ្ញាបេយ្យ ឯវមេវ ខោ មាណវ ឯវំ ភាវិតាយ ឧបេក្ខាយ ចេតោវិមុត្តិ-យា យំ បមាណកតំ កម្មំ ន តំ តត្រាវសិស្សតិ

មានចិត្តប្រកបដោយឧបេក្ខាផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្ត នៅដោយឥរិយាបថទាំង ៤ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ធំទូលាយ មានសភាពជាចិត្តធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកទាំងមូល ដោយប្រការទាំងពួង ក្នុងទីទាំងពួង គឺទិសខាងលើទិសខាងក្រោម និងទិសទទឹងដោយប្រការដូច្នេះ ម្នាលមាណព កាលបើឧបេក្ខាចេតោវិមុត្តិ ដែលភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនហើយ ដោយប្រការយ៉ាងនេះ កម្មណា ជាកម្មដែលភិក្ខុនោះធ្វើហើយ ល្មមប្រមាណ កម្មនោះនឹងមិនឈប់នៅក្នុងទីនោះ កម្មនោះមិនឋិតនៅក្នុងទីនោះទេ ម្នាលមាណព បុរសដែលមានកម្លាំងជាអ្នកផ្លុំស័ង្ខ នឹងញុំាងទិសទាំង ៤ ឲ្យឮខ្ទរខ្ទារទៅបាន ដោយមិនលំបាក ដូចម្តេចមិញ ម្នាលមាណព កាលបើឧបេក្ខាចេតោវិមុត្តិ ដែលភិក្ខុក្នុងធម្មវិន័យនេះ ចម្រើនហើយ ដោយប្រការយ៉ាងនេះ កម្មណាជាកម្មដែលភិក្ខុនោះធ្វើហើយល្មមប្រមាណ កម្មនោះនឹងមិនឈប់នៅក្នុងទីនោះ

ន តំ តត្រាវតិដ្ឋតិ អយម្បិ ខោ មាណវ ព្រហ្មានំ សហព្យតាយ មគ្គោតិ ។

[១៤៨] ឯវំ វុត្តេ សុភោ មាណវោ តោទេយ្យបុត្តោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតំ ហន្ទ ចទានិ មយំ ភោ គោតម គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ មាណវ កាលំ មញ្ញសីតិ ។ អថខោ សុភោ មាណវោ

កម្មនោះមិនឋិតនៅក្នុងទីនោះទេ ដូច្នោះឯង ម្នាលមាណព នេះឯង ឈ្មោះថា ផ្លូវប្រព្រឹត្តទៅមួយអន្លើដោយពួកព្រហ្ម ។

[១៤៨] កាលដែលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ សុភមាណព ជាបុត្តតោទេយ្យព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់ប្រកាសហើយ ដោយអនេកបរិយាយ យ៉ាងនេះ ដូចគេផ្ងាររបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញរបស់ ដែលគេបិទបាំងពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សមានចក្ខុរមែងមើលឃើញរូបទាំងឡាយបានដូច្នោះ ខ្ញុំព្រះអង្គនេះ សូមដល់ព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចម្រើន ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ បពិត្រព្រះគោតមដ៏ចម្រើន ណ្ហើយចុះខ្ញុំព្រះអង្គ សូមលាទៅឥឡូវនេះ ព្រោះខ្ញុំព្រះអង្គមានកិច្ចច្រើន មានការដែលគប្បីធ្វើច្រើន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព អ្នកចូរសំគាល់កាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។ សុភមាណព

តោទេយ្យបុត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា ឧដ្ឋាយា-សនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[១៤៩] តេន ខោ បន សមយេន ជា-ណុស្សោណិ ព្រាហ្មណោ សព្វសេតេន វឡវាភិរថេន សាវត្ថិយា និយ្យាតិ ទិវាទិវស្ស ។ អទ្ទសា ខោ ជាណុស្សោណិ ព្រាហ្មណោ សុភំ មាណវំ តោ-ទេយ្យបុត្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន សុភំ មាណវំ តោទេយ្យបុត្តំ ឯតទវោច ហន្ទ[១] ភវំ ភារទ្វាជោ អាគច្ឆតិ ទិវាទិវស្សាតិ ។ ឥតោ ហិ ខោ អហំ ភោ អាគច្ឆាមិ សមណស្ស គោតមស្ស សន្តិកា-តិ ។ តំ កឹ មញ្ញសិ ភវំ ភារទ្វាជោ សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ បណ្ឌិតោ មញ្ញេតិ ភោ ចាហម្ភោ កោ ច សមណស្ស គោតមស្ស បញ្ញា-វេយ្យត្តិយំ ជានិស្សាមិ សោបិ នូនស្ស តាទិសោវ យោ សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានេយ្យាតិ ។ ឧឡារាយ ខលុ ភវំ ភារទ្វាជោ

---

១ ឱ. ហន្ទ កុតោ នុ ។

ជាបុត្តតោទេយ្យព្រាហ្មណ៍ ក៏ត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ហើយក្រោកអំពីទីអង្គុយ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។

[១៨៩] សម័យនោះឯង ជាណុស្សោណិព្រាហ្មណ៍ ចេញអំពីក្រុងសាវត្ថី ដោយរថដែលទឹមដោយមេសេះសសុទ្ធ ទាំងថ្ងៃត្រង់ ។ ជាណុស្សោណិព្រាហ្មណ៍ បានឃើញសុភមាណព ជាបុត្តតោទេយ្យ-ព្រាហ្មណ៍ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ទើបនិយាយនឹងសុភមាណព ជាបុត្តតោទេយ្យព្រាហ្មណ៍ដូច្នេះថា ចុះភារទ្វាជៈដ៏ចម្រើនទើបមកអំពីណា ទាំងថ្ងៃត្រង់ ។ សុភមាណព ឆ្លើយថា នៃលោកដ៏ចម្រើន ខ្ញុំទើបនឹងមកអំពីសំណាក់ព្រះសមណគោតម ។ ជាណុស្សោណិ-ព្រាហ្មណ៍ពោលថា អ្នកសំគាល់សេចក្តីនោះ ដូចម្តេច ភារទ្វាជៈដ៏ចម្រើនជាបណ្ឌិតដឹងនូវប្រាជ្ញានិងសេចក្តីឈ្លាសវៃ របស់ព្រះសមណគោតមឬទេ នៃអ្នកដ៏ចម្រើន ខ្ញុំ ឬនរណា នរណា ក៏គង់ដឹងនូវប្រាជ្ញានិងសេចក្តីឈ្លាសវៃរបស់ព្រះសមណគោតមដែរ បុគ្គលណាដឹងនូវប្រាជ្ញានិងសេច-ក្តីឈ្លាសវៃ របស់ព្រះសមណគោតមបាន បុគ្គលនោះស្មើនឹងអ្នកដោយពិត ។ ជាណុស្សោណិព្រាហ្មណ៍ពោលទៀតថា ឮថា ភារទ្វាជៈដ៏ចម្រើន

សមណំ គោតមំ បសំសាយ បសំសតីតិ ។ កោ ចាហម្ភោ កោ ច សមណំ គោតមំ បសំសិស្សាមិ បសត្ថប្បសត្ថោ ច ភវំ គោតមោ សេដ្ឋោ ទេវមនុស្សានំ យេ ចិមេ ភោ ព្រាហ្មណោ បញ្ច ធម្មេ បញ្ញបេន្តិ បុញ្ញស្ស កិរិយាយ កុសលស្ស អារាធនាយ ចិត្តស្សេវ សមណោ គោតមោ ឯតេ បរិក្ខារេ វទេតិ យទិទំ ចិត្តំ អវេរំ អព្យាបជ្ឈំ តស្ស ភាវ-នាយាតិ ។

[១៤០] ឯវំ វុត្តេ ជាណុស្សោណិ ព្រាហ្មណោ សព្វសេតា វឡវាភិរថា ឱរោហិត្វា ឯកំសំ ឧត្តរា-សង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ឧទានំ ឧទានេសិ លាភា រញ្ញោ បសេនទិស្ស កោ-សលស្ស សុលទ្ធំ រញ្ញោ បសេនទិស្ស កោស-លស្ស យស្ស វិជិតេ តថាគតោ វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។

សុភសុត្តំ នវមំ និដ្ឋិតំ ។

តែងសរសើរព្រះសមណគោតម ដោយវាចាជាគ្រឿងសរសើរ យ៉ាងក្រៃពេក ។ សុភមាណពពោលថា ឱលោកដ៏ចម្រើន ខ្ញុំនុំ ឬនរណានរណាក៏គង់សរសើរព្រះសមណគោតមដែរ ព្រោះព្រះសមណគោតមដ៏ចម្រើន ជាបុគ្គលប្រសើរក្រៃលែង គឺប្រសើរជាងទេវតានិងមនុស្សទាំងឡាយ នៃលោកដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្តនូវធម៌ទាំង ៥ ប្រការណា ក្នុងការធ្វើបុណ្យ ក្នុងការបំពេញកុសល ឯព្រះសមណគោតមក៏សំដែងនូវធម៌ទាំង ៥ ប្រការនុ៎ះថាជាបរិក្ខាររបស់ចិត្ត ដែលមិនមានពៀរមិនមានព្យាបាទ ដើម្បីអប់រំចិត្តនោះប៉ុណ្ណោះ ។

[១៥០] កាលសុភមាណពពោលយ៉ាងនេះហើយ ជាណុស្សោណិព្រាហ្មណ៍ ក៏ចុះអំពីរថទឹមដោយមេសេះសសុទ្ធ ធ្វើនូវសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីទៅត្រង់ទី ដែលព្រះមានព្រះភាគគង់ បន្លឺឧទានថា ព្រះបាទបសេនទិកោសលហៅពេញជាមានលាភភាពជាមនុស្ស ព្រះបាទបសេនទិកោសលបានដោយប្រពៃហើយ ព្រោះទ្រង់បានព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ គង់ក្នុងដែនរបស់ព្រះអង្គ ។

ចប់សុភសូត្រ ទី ៩ ។

# ទសមំ សគារវសុត្តំ

[១៨១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ តេន ខោ បន សមយេន ធនញ្ជានី នាម ព្រាហ្មណី បច្ចលកប្បេ[១] បដិវសតិ អភិប្បសន្នា ពុទ្ធេ ច ធម្មេ ច សង្ឃេ ច ។ អថខោ ធនញ្ជានី ព្រាហ្មណី ឧបក្ខលិត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស... នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

[១៨២] តេន ខោ បន សមយេន សគារវោ នាម[២] មាណវោ បច្ចលកប្បេ បដិវសតិ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ ។

១ ឱ. ចណ្ឌលកប្បេ ។ ម. បញ្ចលិកប្បេ ។ ២ ឱ. ម. សំគារវោ នាម ។

# សគារវសូត្រ ទី ១០

[១៩១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃជាច្រើន ។ ក៏សម័យនោះឯង ព្រាហ្មណីឈ្មោះនាងធនញ្ជានី នៅអាស្រ័យក្នុងស្រុកបច្ចលកប្ប ជាស្រ្តីមានសេចក្តីជ្រះថ្លាមាំមួន ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ គ្រានោះ នាងធនញ្ជានីព្រាហ្មណី ភ្ញាត់មាត់បន្លឺឧទានវាចា អស់វារៈ ៣ ដងថា សូមនមស្ការ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ... សូមនមស្ការ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។

[១៩២] សម័យនោះឯង មាណពឈ្មោះសគារវៈនៅអាស្រ័យក្នុងបច្ចលកប្បគ្រាម ជាអ្នកចេះចប់នូវត្រៃវេទ ព្រមទាំងគម្ពីរឈ្មោះនិឃណ្ឌុនិងគម្ពីរឈ្មោះកេដុភៈ ព្រមទាំងអក្ខរប្បភេទ មានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥ ជាអ្នកដឹងនូវបទនៃវេទ ជាអ្នកដឹងនូវវេយ្យាករណ៍ មិនទើសទាល់ក្នុងគម្ពីរលោកាយតៈ និងគម្ពីរមហាបុរិសលក្ខណៈ ។

អស្សោសិ ខោ សង្គារវោ មាណវោ ធនញ្ជានិយា ព្រាហ្មណិយា ឯវំ វាចំ ភាសមានាយ សុត្វាន(១) ធនញ្ជានឹ ព្រាហ្មណឹ ឯតទវោច អវភូតា ច យំ ធនញ្ជានី ព្រាហ្មណី បរាភូតា ច យំ ធនញ្ជានី ព្រាហ្មណី វិជ្ជមានានំ តេវិជ្ជានំ(២) ព្រាហ្មណានំ អថ ច បន តស្ស មុណ្ឌកស្ស សមណស្ស វណ្ណំ ភាសតី-តិ ។ ន ហិ បន ត្វំ តាត ភទ្រមុខ តស្ស ភគវតោ សីលប្បញ្ញាណំ(៣) ជានាសិ សចេ ត្វំ តាត ភទ្រមុខ តស្ស ភគវតោ សីលប្បញ្ញាណំ ជានេយ្យាសិ ន ត្វំ តាត ភទ្រមុខ តំ ភគវន្តំ អក្កោសិតព្វំ បរិ-ភាសិតព្វំ មញ្ញេយ្យាសីតិ ។ តេនហិ ភោតិ យទា សមណោ គោតមោ បច្ចលកប្បំ អនុប្បត្តោ ហោតិ អថ(៤) មេ អារោចេយ្យាសីតិ ។ ឯវំ ភទ្រមុខាតិ ខោ ធនញ្ជានី ព្រាហ្មណី សង្គារវស្ស មាណវស្ស បច្ចស្សោសិ ។

---

១ ឱ. ម. នសទ្ទោ នត្ថិ ។ ២ ឱ. តេវិជ្ជានន្តិ ន ទិស្សតិ ។ ៣ ឱ. សីលប្បញ្ញំ ។ ៤ ឱ. អថខោ ។

សគារវមាណព បានឮនាងធនញ្ជានីព្រាហ្មណីពោលវាចាយ៉ាងនេះ លុះឮហើយ ក៏ពោលទៅនឹងនាងធនញ្ជានីព្រាហ្មណីដូច្នេះថា នាងធនញ្ជានីព្រាហ្មណីនេះជាស្ត្រីគម្រក់ផង នាងធនញ្ជានីព្រាហ្មណីនេះជាស្ត្រីដល់នូវសេចក្តីវិនាសផង ព្រោះថា ពួកព្រាហ្មណ៍ដែលបាននូវវិជ្ជាបីក៏មានដែរ ហេតុអ្វីក៏នៅតែពោលសរសើរគុណសមណ:ត្រងោលនោះទៀត ។ នាងធនញ្ជានីព្រាហ្មណីពោលថា នែអ្នកមានមុខស្រស់បស់ ហេតុតែអ្នកមិនស្គាល់សីលនិងបញ្ញា របស់ព្រះមានព្រះភាគអង្គនោះ នែអ្នកមានមុខស្រស់បស់ ប្រសិនបើអ្នកស្គាល់សីលនិងបញ្ញា របស់ព្រះមានព្រះភាគអង្គនោះ នែអ្នកមានមុខស្រស់បស់ អ្នកមិនគួរសំគាល់នូវព្រះមានព្រះភាគអង្គនោះថា ជាបុគ្គលគួរជេរ គួរប្រទេចសោះឡើយ ។ សគារវមាណពតបថា ម្នាលនាងដ៏ចម្រើន បើដូច្នោះ ព្រះសមណគោតម ស្តេចមកដល់បច្ចលកប្បគ្រាមក្នុងកាលណា នាងត្រូវប្រាប់ដល់យើងក្នុងកាលនោះផង ។ នាងធនញ្ជានីព្រាហ្មណីទទួលពាក្យរបស់សគារវមាណពថា ចាស អ្នកមានមុខស្រស់បស់ ។

ព្រាហ្មណវគ្គស្ស សគារវសុត្តេ សគារវូបសង្កមនំ

[១៨៣] អថខោ ភគវា កោសលេសុ អនុបុព្វេន ចារិកំ ចរមានោ យេន បច្ចលកប្បំ តទវសរិ ។ តត្រ សុទំ ភគវា បច្ចលកប្បេ វិហរតិ តោទេយ្យានំ ព្រាហ្មណានំ អម្ពវនេ ។ អស្សោសិ ខោ ធនញ្ជានី ព្រាហ្មណី ភគវា កិរ បច្ចលកប្បំ អនុប្បត្តោ បច្ចលកប្បេ វិហរតិ តោទេយ្យានំ ព្រាហ្មណានំ អម្ពវនេតិ ។ អថខោ ធនញ្ជានី ព្រាហ្មណី យេន សគារវោ មាណវោ តេនុបសង្កមិ ឧបសង្កមិត្វា សគារវំ មាណវំ ឯតទវោច អយំ តាត ភទ្រមុខ សោ ភគវា បច្ចលកប្បំ អនុប្បត្តោ បច្ចលកប្បេ វិហរតិ តោទេយ្យានំ ព្រាហ្មណានំ អម្ពវនេ យស្សទានិ ត្វំ តាត ភទ្រមុខ កាលំ មញ្ញសីតិ ។ ឯវំ ភោតីតិ ខោ សគារវោ មាណវោ ធនញ្ជានិយា ព្រាហ្មណិយា បដិស្សុត្វា

[១៥៣] គ្រានោះឯង កាលព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនកោសលដោយលំដាប់ ក៏បានដល់បច្ចលកប្បគ្រាម ។ បានឮថា ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអម្ពវ័ន (ព្រៃស្វាយ) របស់ពួកតោទេយ្យព្រាហ្មណ៍ ជិតបច្ចលកប្បគ្រាមនោះ ។ នាងធនញ្ជានីព្រាហ្មណីបានឮថា ព្រះមានព្រះភាគស្តេចដល់បច្ចលកប្បគ្រាម ឥឡូវគង់នៅក្នុងអម្ពវ័ន របស់ពួកតោទេយ្យព្រាហ្មណ៍ ជិតស្រុកបច្ចលកប្បគ្រាម ។ ទើបនាងធនញ្ជានីព្រាហ្មណី ចូលទៅរកសគារវមាណព លុះចូលទៅដល់ហើយ ក៏និយាយនឹងសគារវមាណព ដូច្នេះថា នៃអ្នកមានមុខស្រស់បស់ ព្រះមានព្រះភាគអង្គនោះ ស្តេចមកដល់បច្ចលកប្បគ្រាមហើយ ទ្រង់គង់នៅក្នុងអម្ពវ័ន របស់ពួកតោទេយ្យព្រាហ្មណ៍ ជិតបច្ចលកប្បគ្រាម នៃអ្នកមានមុខស្រស់បស់ ចូរអ្នកសំគាល់នូវកាលគួរនឹងទៅឥឡូវនេះចុះ ។ សគារវមាណពទទួលពាក្យ នៃនាងធនញ្ជានីព្រាហ្មណីថា អើ នាងដ៏ចម្រើន

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សគារវោ មាណវោ ភគវន្តំ ឯតទវោច សន្តិ ខោ ភោ គោតម ឯកេ សមណព្រាហ្មណា ទិដ្ឋធម្មាភិញ្ញាវោសានបារមិប្បត្តា អាទិព្រហ្មចរិយំ បដិជានន្តិ តត្រ ភោ គោតម យេ តេ សមណព្រាហ្មណា ទិដ្ឋធម្មាភិញ្ញាវោសានបារមិប្បត្តា អាទិព្រហ្មចរិយំ បដិជានន្តិ តេសំ ភវំ គោតមោ កតមោតិ ។

[១៤៨] ទិដ្ឋធម្មាភិញ្ញាវោសានបារមិប្បត្តានំ អាទិព្រហ្មចរិយំ បដិជានន្តានំបិ ខោ អហំ ភារទ្វាជ វេមត្តំ វទាមិ សន្តិ ភារទ្វាជ ឯកេ សមណព្រាហ្មណា

ហើយក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយនិងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះសគារវ-មាណព អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកដល់នូវទីបំផុតគឺព្រះនិព្វាន ជាគុណជាតដ៏ក្រៃលែងព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន តែងដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ បពិត្រព្រះគោតមដ៏ចម្រើន ក្នុងពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកដល់នូវទីបំផុត គឺព្រះនិព្វានជាគុណ-ជាតដ៏ក្រៃលែង ព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន តែងដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ តើព្រះគោតមដ៏ចម្រើន ជាសមណៈបែបណា ។

[១៩៤] ព្រះអង្គត្រាស់ថា ម្នាលភារទ្វាជៈ តថាគតនឹងពោលអំពីដំណើរខុសគ្នា នៃបុគ្គលអ្នកដល់នូវទីបំផុតគឺព្រះនិព្វាន ជាគុណ-ជាតដ៏ក្រៃលែង ព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន ហើយដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ ម្នាលភារទ្វាជៈ មានសមណព្រាហ្មណ៍ពួកមួយ

អនុស្សវិកា តេន[១] អនុស្សវេន ទិដ្ឋធម្មាភិញ្ញាវោសាន-ចារមិប្បត្តា អាទិព្រហ្មចរិយំ បដិជានន្តិ សេយ្យថាបិ ព្រាហ្មណា តេវិជ្ជា ។ សន្តិ បន ភារទ្វាជ ឯកេ សមណព្រាហ្មណា កេវលំ សទ្ធាមត្តកេន ទិដ្ឋធម្មា-ភិញ្ញាវោសានចារមិប្បត្តា អាទិព្រហ្មចរិយំ បដិជានន្តិ សេយ្យថាបិ តក្កី វីមំសី ។ សន្តិ ភារទ្វាជ ឯកេ សមណព្រាហ្មណា បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំយេវ ធម្មំ អភិញ្ញាយ ទិដ្ឋធម្មាភិញ្ញាវោសានចារ-មិប្បត្តា អាទិព្រហ្មចរិយំ បដិជានន្តិ តត្រ ភារទ្វាជ យេ តេ សមណព្រាហ្មណា បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំយេវ ធម្មំ អភិញ្ញាយ ទិដ្ឋធម្មាភិញ្ញា-វោសានចារមិប្បត្តា អាទិព្រហ្មចរិយំ បដិជានន្តិ

១ ឱ. តេ ។

ជាអ្នកឮតាម ៗ គ្នា ជាអ្នកដល់នូវទីបំផុត គឺព្រះនិព្វាន ជាគុណជាតដ៏ក្រៃលែង ព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន ដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ ដោយការឮតាម ៗ គ្នានោះ ដូចយ៉ាងពួកព្រាហ្មណ៍អ្នកបានត្រៃវិជ្ជា ។ ម្នាលភារទ្វាជៈ មានសមណព្រាហ្មណ៍ពួកមួយជាអ្នកដល់នូវទីបំផុតគឺព្រះនិព្វាន ជាគុណជាតដ៏ក្រៃលែង ព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន ក៏ដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ ដោយត្រឹមតែសទ្ធាប៉ុណ្ណោះ ដូចយ៉ាងបុគ្គលអ្នកត្រិះរិះពិចារណាជាប្រក្រតី ។ ម្នាលភារទ្វាជៈ មានសមណព្រាហ្មណ៍ពួកមួយ ដឹងច្បាស់នូវធម៌ដោយខ្លួនឯង ក្នុងពួកធម៌ដែលខ្លួនមិនដែលបានស្តាប់ក្នុងកាលមុន ហើយជាអ្នកដល់នូវទីបំផុតគឺព្រះនិព្វាន ជាគុណជាតដ៏ក្រៃលែង ព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន ក៏ដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ ម្នាលភារទ្វាជៈ ក្នុងសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ដឹងច្បាស់នូវធម៌ដោយខ្លួនឯង ក្នុងពួកធម៌ដែលខ្លួនមិនដែលបានស្តាប់ ក្នុងកាលមុន ហើយជាអ្នកដល់នូវទីបំផុតគឺព្រះនិព្វាន ជាគុណជាតដ៏ក្រៃលែង ព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន ក៏ដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយៈ

តេសាហមស្មិ តទិមិនាបេតំ ភារទ្វាជ បរិយាយេន វេទិតព្វំ ។ យថា យេ តេ សមណព្រាហ្មណា បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំយេវ ធម្មំ អភិញ្ញាយ ទិដ្ឋធម្មាភិញ្ញាវោសានបារមិប្បត្តា អាទិព្រហ្មចរិយំ បដិជានន្តិ តេសាហមស្មិ ។

[១៨៥] ឥធ មេ ភារទ្វាជ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា

បណ្ដាសមណព្រាហ្មណ៍ទាំងនោះ តថាគតជាសមណ:មួយដែរ ម្នាលភារទ្វាជ: ដំណើរដែលខុសគ្នានោះ អ្នកគប្បីដឹងដោយបរិយាយនេះឯង ។ ពួកសមណព្រាហ្មណ៍ណា ដឹងច្បាស់នូវធម៌ដោយខ្លួនឯងក្នុងពួកធម៌ដែលខ្លួនមិនដែលបានស្ដាប់ក្នុងកាលមុន ហើយជាអ្នកដល់នូវទីបំផុតគឺព្រះនិព្វាន ជាគុណជាតដ៏ក្រៃលែង ព្រោះប្រាជ្ញាក្នុងបច្ចុប្បន្ន ដឹងច្បាស់នូវធម៌ជាខាងដើមនៃព្រហ្មចរិយ: យ៉ាងណា បណ្ដាសមណ-ព្រាហ្មណ៍ទាំងនោះ តថាគត ក៏ជាសមណ: យ៉ាងនោះដែរ ។

[១៩៥] ម្នាលភារទ្វាជ: ក្នុងកាលមុនអំពីការត្រាស់ដឹង កាលតថា-គតនៅជាពោធិសត្វមិនទាន់បានត្រាស់ដឹងនៅឡើយ មានសេចក្ដីត្រិះរិះដូច្នេះក្នុងទីឯណោះថា ឃរាវាស ជាភេទចង្អៀតពេកណាស់ ជាផ្លូវនៃធូលីឯបព្វជ្ជាទើបជាភេទទំនេរ បើអាត្មាអញនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រ-ព្រឹត្តព្រហ្មចរិយធម៌នេះ ឲ្យបរិបូណ៌ក្រៃលែង ឲ្យបរិសុទ្ធក្រៃលែង ឲ្យផូរផង់ ដូចជាស័ង្ខដែលគេដុសខាត់បានឡើយ បើដូច្នោះ មានតែអាត្មាអញកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយ:ទាំងឡាយ

អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ ខោ
អហំ ភារទ្វាជ អបរេន សមយេន ទហរោ វ សមានោ
សុសុកាឡកេសោ ភទ្រេន យោព្វនេន សមន្នា-
គតោ បឋមេន វយសា អកាមកានំ មាតាបិតូនំ
អស្សុមុខានំ រុទន្តានំ កេសមស្សុំ ឱហារេត្វា
កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ
បព្វជឹ ។ សោ ឯវំ បព្វជិតោ សមានោ កឹកុស-
លគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ យេន
អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា
អាឡារំ កាលាមំ ឯតទវោចំ ឥច្ឆាមហំ អាវុសោ កា-
លាម ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ ឯវំ
វុត្តេ ភារទ្វាជ អាឡារោ កាលាមោ មំ ឯតទវោច វិហ-
រតាយស្មា តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ

ចេញចាកផ្ទះចូលទៅកាន់ផ្នួសវិញ ។ ម្នាលភារទ្វាជៈ សម័យខាងក្រោយមក កាលតថាគតនៅក្មេងកំលោះ មានសក់ខ្មៅស្រិល ប្រកបដោយវ័យល្អ គឺបឋមវ័យ ទុកជាមាតាបិតាមិនប្រាថ្នា (នឹងឲ្យបួស) មានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ក៏នៅតែកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លុះតថាគតនោះ បួសយ៉ាងនេះហើយ ក៏ស្វែងរកនូវកឹកុសលគឺសព្វញ្ញុតញ្ញាណ ស្វែងរកនូវសន្តិវរបទគឺព្រះនិព្វាន រកគុណជាតដទៃក្រៃលែងជាងគ្មាន ក៏ចូលទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ ទើបពោលនឹងអាឡារតាបស កាលាមគោត្រ យ៉ាងនេះថា ម្នាលកាលាមៈ មានអាយុ យើងប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះដែរ ។ ម្នាលភារទ្វាជៈ កាលបើតថាគតពោលយ៉ាងនេះហើយ អាឡារតាបស កាលាមគោត្រ ក៏ពោលតបមកតថាគតវិញយ៉ាងនេះថា ចូរអ្នកមានអាយុនៅចុះ នេះធម៌ប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌ដែលវិញ្ញូបុរស

នចិរស្សេវ សកំ អាចរិយកំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ ខោ អហំ ភារទ្វាជ នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ ។ សោ ខោ អហំ ភារទ្វាជ តាវតកេនេវ ឱដ្ឋបហតមត្តេន លបិតលាបនមត្តេន ញាណវាទញ្ច វទាមិ ថេរវាទញ្ច ជានាមិ បស្សាមីតិ ច បដិជានាមិ អហញ្ចេវ អញ្ញេ ច ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ ន ខោ អាឡារោ កាលាមោ ឥមំ ធម្មំ កេវលំ សទ្ធាមត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា អាឡារោ កាលាមោ ឥមំ ធម្មំ ជានំ បស្សំ វិហរតីតិ ។ អថខ្វាហំ ភារទ្វាជ យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ កិត្តាវតា នោ អាវុសោ កាលាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯវំ វុត្តេ ភារទ្វាជ

គប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា នូវលទ្ធិអាចារ្យជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅបាន ដោយកាលមិនយូរប៉ុន្មាន ។ ម្នាលភារទ្វាជៈ មិនយូរប៉ុន្មាន តថាគតក៏រៀនធម៌នោះចប់ភ្លាម ។ ម្នាលភារទ្វាជៈ តថាគតពោលនូវញាណវាទផង ថេរវាទផង ដោយគ្រាន់តែបង្ហើបបបូរមាត់ ដោយគ្រាន់តែហាមាត់និយាយប៉ុណ្ណោះ ទាំងតថាគតទាំងអ្នកដទៃក៏អាចប្ដេជ្ញាថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះបាន ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាឡារតាបស កាលាមគោត្រ មិនហ៊ានប្រកាសថា ខ្ញុំធ្វើឲ្យជាក់ច្បាស់នូវធម៌នេះដោយប្រាជ្ញាខ្លួនឯង ដោយត្រឹមតែសទ្ធាប៉ុណ្ណោះ ហើយសម្រេចសម្រាន្តនៅដូច្នេះឡើយ តាមពិត អាឡារតាបស កាលាមគោត្រ គ្រាន់តែយល់ឃើញនូវធម៌នេះប៉ុណ្ណោះ ។ ម្នាលភារទ្វាជៈ ក្នុងកាលជាខាងក្រោយមក តថាគត ចូលទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ ទើបពោលនឹងអាឡារតាបស កាលាមគោត្រ យ៉ាងនេះថា ម្នាលកាលាមៈ មានអាយុ អ្នកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបាន ដោយចំណែកមានប៉ុន្មានខ្វះឬទេ ។ ម្នាលភារទ្វាជៈ កាលបើតថាគតពោលយ៉ាងនេះហើយ

២៦៧



អាឡារោ កាលាមោ អាកិញ្ចញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សទ្ធា មយ្ហំបត្ថិ សទ្ធា ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ វិរិយំ មយ្ហំបត្ថិ វិរិយំ សតិ... សមាធិ... បញ្ញា មយ្ហំបត្ថិ បញ្ញា យន្នូនាហំ យំ ធម្មំ អាឡារោ កាលាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ តស្ស ធម្មស្ស សច្ឆិកិរិយាយ បទហេយ្យន្តិ ។ សោ ខោ អហំ ភារទ្វាជ នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ។ អថខ្វាហំ ភារទ្វាជ យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ

អាឡារតាបស កាលាមគោត្រ ក៏សំដែងនូវអាកិញ្ចញ្ញាយតនជ្ឈាន ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា សទ្ធារបស់អាឡារតាបស កាលាមគោត្រ គ្មានទេ សទ្ធារបស់អាត្មាអញ ទើបមាន វីរិយៈរបស់អាឡារតាបសកាលាមគោត្រគ្មានទេ វីរិយៈរបស់អាត្មាអញ ទើបមាន សតិ... សមាធិ... បញ្ញារបស់អាឡារតាបសកាលាមគោត្រ គ្មានទេ បញ្ញារបស់អាត្មាអញទើបមាន បើដូច្នោះ គួរតែអាត្មាអញ តាំងសេចក្តីព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលអាឡារតាបស កាលាមគោត្រប្រកាសថា ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ ។ ម្នាលភារទ្វាជៈ មិនយូរប៉ុន្មាន តថាគតក៏បានធ្វើឲ្យជាក់ច្បាស់ នូវធម៌នោះ ដោយប្រាជ្ញាខ្លួនឯងភ្លាម ហើយសម្រេចសម្រាន្តនៅ ។ ម្នាលភារទ្វាជៈ ក្នុងកាលខាងក្រោយមកទៀត តថាគតចូលទៅរកអាឡារតាបស កាលាមគោត្រ លុះចូលទៅដល់ហើយ ក៏ពោលនឹងអាឡារតាបស កាលាមគោត្រយ៉ាងនេះថា

ឯត្តាវតា នោ អាវុសោ កាលាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯត្តាវតា ខោ អហំ អាវុសោ ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ អហម្បិ ខោ អាវុសោ ឯត្តាវតា ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហារាមីតិ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ បស្សាម ឥតិ យាហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ តមហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ ឥតិ យាហំ ធម្មំ ជានាមិ តំ ត្វំ ធម្មំ ជានាសិ

ម្នាលកាលាមៈ មានអាយុ អ្នកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះ ដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបានដោយចំណែកមានប្រមាណតែប៉ុណ្ណេះទេឬ ។ អាឡារតាបសតបថា ម្នាលអាវុសោ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះ ដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបាន ដោយចំណែកមានប្រមាណប៉ុណ្ណេះឯង ម្នាលអាវុសោ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះ ដោយប្រាជ្ញាខ្លួនឯង ដោយចំណែកមានប្រមាណប៉ុណ្ណេះឯង ហើយសម្រាន្តនៅ ម្នាលអាវុសោ យើងពេញជាមានលាភ ម្នាលអាវុសោ អត្តភាពជាមនុស្ស យើងពេញជាបានដោយល្អហើយ ដ្បិតយើងបានឃើញនូវសព្រហ្មចារី ប្រាកដដូចជាអ្នកមានអាយុ ព្រោះថាខ្ញុំបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌ណាដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបាន អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នោះ ដោយប្រាជ្ញាខ្លួនឯង ហើយសម្រាន្តនៅដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌ណា ដោយប្រាជ្ញាខ្លួនឯង ហើយសម្រាន្តនៅ ខ្ញុំក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នោះ ដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបានដែរ ខ្ញុំដឹងនូវធម៌ណា អ្នកក៏ដឹងនូវធម៌នោះដែរ

យំ ត្វំ ធម្មំ ជានាសិ តមហំ ធម្មំ ជានាមិ ឥតិ យាទិសោ អហំ តាទិសោ តុវំ យាទិសោ តុវំ តាទិសោ អហំ ឯហិទានិ អាវុសោ ឧភោ វសន្តា ឥមំ គណំ បរិហរាមាតិ ។ ឥតិ ខោ ភារទ្វាជ អាឡារោ កាលាមោ អាចរិយោ មេ សមានោ អន្តេវាសឹ មំ សមានំ អត្តនោ សមសមំ ឋបេសិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ នាយំ ធម្មោ និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ យាវទេវ អាកិញ្ចញ្ញាយតនូបបត្តិយាតិ ។ សោ ខោ អហំ ភារទ្វាជ តំ[១] ធម្មំ អនលង្ករិត្វា តស្មា ធម្មា និព្វិជ្ជ បក្កាមឹ ។

[១៨៦] សោ ខោ អហំ ភារទ្វាជ កឹកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្ក-

១ ម. ឯតំ ។

អ្នកដឹងនូវធម៌ណា ខ្ញុំក៏ដឹងនូវធម៌នោះដែរ ខ្ញុំប្រាកដយ៉ាងណា អ្នកក៏ប្រាកដយ៉ាងនោះដែរ អ្នកប្រាកដយ៉ាងណា ខ្ញុំក៏ប្រាកដយ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះ អ្នកចូរមក យើងទាំងពីរនាក់នឹងនៅគ្រប់គ្រងគណៈនេះ ។ ម្នាលភារទ្វាជៈ ឯអាឡារតាបស កាលាមគោត្រ ជាអាចារ្យរបស់តថាគត តាំងតថាគតដែលជាកូនសិស្សឲ្យត្រឹមស្មើនឹងខ្លួន ទាំងបូជាតថាគតដោយគ្រឿងបូជាដ៏លើសលុប ដោយប្រការដូច្នេះ ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌នេះមិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ប្រព្រឹត្តទៅបានត្រឹមតែកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះ ។ ម្នាលភារទ្វាជៈ តថាគតមិនទាន់ល្មមចិត្តនឹងធម៌នោះទេ នឿយណាយចាកធម៌នោះ ហើយចៀសចេញទៅ ។

[១៥៦] ម្នាលភារទ្វាជៈ តថាគតក៏ស្វែងរកនូវកឹកុសល គឺសព្វញ្ញុតញ្ញាណ ស្វែងរកនូវសន្តិវរបទគឺព្រះនិព្វាន រកគុណជាតដទៃក្រៃលែងជាងគ្មាន បានចូលទៅរកឧទ្ទកតាបស រាមបុត្ត លុះចូលទៅ

មិត្វា ឧទកំ រាមបុត្តំ ឯតទវោចំ ឥច្ឆាមហំ អាវុសោ រាម ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ ឯវំ វុត្តេ ភារទ្វាជ ឧទកោ រាមបុត្តោ មំ ឯតទវោច វិហរតាយស្មា តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ នចិរស្សេវ សកំ អាចរិយកំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ ខោ អហំ ភារទ្វាជ នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ ។ សោ ខោ អហំ ភារទ្វាជ តាវតកេនេវ ឱដ្ឋបហតមត្តេន លបិតលាបនមត្តេន ញាណវាទញ្ច វទាមិ ថេរវាទញ្ច ជានាមិ បស្សាមីតិ ច បដិជានាមិ អហញ្ចេវ អញ្ញេ ច ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ ន ខោ រាមោ ឥមំ ធម្មំ កេវលំ សទ្ធាមត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា រាមោ ឥមំ ធម្មំ ជានំ បស្សំ វិហរតីតិ ។

ដល់ហើយ ក៏ពោលនឹងឧទ្ទកតាបស រាមបុត្ត យ៉ាងនេះថា ម្នាលរាមៈមានអាយុ ខ្ញុំប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយៈ ក្នុងធម្មវិន័យនេះ ។ ម្នាលភារទ្វាជៈ កាលបើតថាគតពោលយ៉ាងនេះហើយ ឧទ្ទកតាបស រាមបុត្ត ក៏ពោលតបនឹងតថាគតយ៉ាងនេះវិញថា ចូរអ្នកមានអាយុនៅចុះ នេះធម៌ប្រាកដដូចជាអ្នកត្រូវការនោះ ជាធម៌ដែលវិញ្ញូបុរសគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញា នូវលទ្ធិអាចារ្យជារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅបាន ដោយកាលមិនយូរប៉ុន្មាន ។ ម្នាលភារទ្វាជៈ មិនយូរប៉ុន្មាន តថាគតឯងក៏បានរៀននូវធម៌នោះចប់ភ្លាម ។ ម្នាលភារទ្វាជៈ តថាគតពោលនូវញាណវាទផង ថេរវាទផង ដោយគ្រាន់តែបង្ហើបបបូរមាត់ ដោយគ្រាន់តែហាមាត់និយាយប៉ុណ្ណោះ ទាំងតថាគតទាំងអ្នកដទៃ ក៏អាចប្តេជ្ញាថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះបាន ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា រាមៈមិនហ៊ានប្រកាសថា ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះ ដោយប្រាជ្ញាខ្លួនឯង ដោយត្រឹមតែសទ្ធាប៉ុណ្ណោះ ដូច្នេះឡើយ តាមពិត រាមៈគ្រាន់តែយល់ឃើញនូវធម៌នេះប៉ុណ្ណោះ ។

អថខ្វាហំ ភារទ្វាជ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ កិត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯវំ វុត្តេ ភារទ្វាជ ឧទ្ទកោ រាមបុត្តោ នេវ-សញ្ញានាសញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ ន ខោ រាមស្សេវ អហោសិ សទ្ធា មយ្ហំបត្ថិ សទ្ធា ន ខោ រាមស្សេវ អហោសិ វីរិយំ ។ បេ ។ សតិ សមាធិ... បញ្ញា មយ្ហំបត្ថិ បញ្ញា យន្នូនាហំ យំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេសិ តស្ស ធម្មស្ស សច្ឆិកិរិយាយ បទហេយ្យន្តិ ។

ម្នាលភារទ្វាជៈ ក្នុងកាលដទៃទៀត តថាគតចូលទៅរកឧទ្ទកតាបស រាមបុត្ត លុះចូលទៅដល់ហើយ ក៏ពោលនឹងឧទ្ទកតាបស រាមបុត្ត យ៉ាងនេះថា ម្នាលរាមៈមានអាយុ អ្នកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបាន ដោយចំ-ណែកខ្លះឬទេ ។ ម្នាលភារទ្វាជៈ កាលបើតថាគតពោលយ៉ាងនេះហើយ ឧទ្ទកតាបស រាមបុត្ត ក៏សំដែងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្ដីត្រិះរិះយ៉ាងនេះថា សទ្ធារបស់រាមៈមិនមានទេ សទ្ធារបស់អាត្មាអញទើបមាន វីរិយៈរបស់រាមៈមិនមានទេ ។ បេ ។ សតិ... សមាធិ... បញ្ញារបស់រាមៈមិនមានទេ បញ្ញារបស់អាត្មាអញទើបមាន បើដូច្នោះ គួរតែអាត្មាអញតាំងសេចក្ដីព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលរាមៈប្រកាសថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយប្រាជ្ញាខ្លួនឯង ហើយសម្រេចសម្រាន្តនៅ ។

សោ ខោ អហំ ភារទ្វាជ នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ។ អថខ្វាហំ ភារទ្វាជ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ កិត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯត្តាវតា ខោ អហំ អាវុសោ ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ អហម្បិ ខោ អាវុសោ ឯត្តាវតា ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ បស្សាម

ម្នាលភារទ្វាជៈ មិនយូរប៉ុន្មាន តថាគតក៏បានធ្វើឲ្យជាក់ច្បាស់ បាន សម្រេចនូវធម៌នោះភ្លាម ដោយប្រាជ្ញាខ្លួនឯង ។ ម្នាលភារទ្វាជៈ ក្នុងកាលខាងក្រោយមកទៀត តថាគតចូលទៅរកឧទ្ទកតាបស រាមបុត្ត លុះចូលទៅដល់ហើយ ក៏ពោលនឹងឧទ្ទកតាបស រាមបុត្ត យ៉ាងនេះ ថា ម្នាលរាមៈមានអាយុ អ្នកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេច នូវធម៌នេះដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបាន ដោយ ចំណែកខ្លះឬទេ ។ ឧទ្ទកតាបសរាមបុត្តតបថា ម្នាលអាវុសោ ខ្ញុំ បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះ ដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបាន ដោយចំណែកមានប្រមាណប៉ុណ្ណោះឯង ម្នាល អាវុសោ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នេះ ដោយ ប្រាជ្ញាខ្លួនឯង ដោយចំណែកមានប្រមាណប៉ុណ្ណោះឯង ម្នាលអាវុសោ យើងពេញជាមានលាភ អត្តភាពជាមនុស្ស យើងពេញជាបានដោយ ល្អ ត្រង់ដែលយើងបានឃើញនូវសព្រហ្មចារីប្រាកដដូចជាអ្នកមានអាយុ

ឥតិ យំ ធម្មំ អហំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ តំ ធម្មំ អហំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ ឥតិ យំ ធម្មំ អហំ អភិញ្ញាសិ តំ ត្វំ ធម្មំ ជានាសិ យំ ត្វំ ធម្មំ ជានាសិ តំ ធម្មំ អហំ អភិញ្ញាសិ ឥតិ យាទិសោ អហំ អហោសិ តាទិសោ តុវំ យាទិសោ តុវំ តាទិសោ អហំ អហោសិ ឯហិទានិ អាវុសោ តុវំ ឥមំ គណំ បរិហរាតិ ។ ឥតិ ខោ ភារទ្វាជ ឧទ្ទកោ រាមបុត្តោ សព្រហ្មចារី មេ សមានោ អាចរិយដ្ឋានេ មំ ឋបេសិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ នាយំ ធម្មោ និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ

ព្រោះថា រាមៈ បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌ណា ដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបាន អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នោះ ដោយប្រាជ្ញាខ្លួនឯងដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌ណា ដោយប្រាជ្ញាខ្លួនឯង រាមៈក៏បានធ្វើឲ្យជាក់ច្បាស់ បានសម្រេចនូវធម៌នោះ ដោយប្រាជ្ញាខ្លួនឯង ហើយអាចសំដែងបានដែរ រាមៈដឹងច្បាស់នូវធម៌ណា អ្នកក៏ដឹងច្បាស់នូវធម៌នោះដែរ អ្នកដឹងច្បាស់នូវធម៌ណា រាមៈក៏ដឹងច្បាស់នូវធម៌នោះដែរ រាមៈប្រាកដយ៉ាងណា អ្នកក៏ប្រាកដយ៉ាងនោះដែរ អ្នកប្រាកដយ៉ាងណា រាមៈក៏ប្រាកដយ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះអ្នកចូរមក អ្នកចូរគ្រប់គ្រងគណៈនេះចុះ ។ ម្នាលភារទ្វាជៈ ឯឧទ្ទកតាបស រាមបុត្ត ជាសព្រហ្មចារីរបស់តថាគត តាំងតថាគតក្នុងទីជាអាចារ្យ ទាំងបូជាតថាគតដោយគ្រឿងបូជាដ៏លើសលុបដោយប្រការដូច្នេះ ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្តីត្រិះរិះ យ៉ាងនេះថា ធម៌នេះមិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីរំលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន

យាវទេវ នេវសញ្ញានាសញ្ញាយតនូបបត្តិយាតិ ។ សោ ខោ អហំ ភារទ្វាជ តំ ធម្មំ អនលង្ករិត្វា តស្មា ធម្មា និព្វិជ្ជ បក្កាមឹ ។

[១៩៧] សោ ខោ អហំ ភារទ្វាជ កឹកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ មគធេសុ អនុបុព្វេន ចារិកំ ចរមានោ យេន ឧរុវេលា សេនានិគមោ តទវសរិ ។ តត្ថទ្ទសំ រមណីយំ ភូមិភាគំ បាសាទិកញ្ច វនសណ្ឌំ នទិញ្ច សន្ទន្តឹ សេតកំ សុប្បតិត្ថំ រមណីយំ សមន្តា គោចរគាមំ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ រមណីយោ វត ភូមិភាគោ បាសាទិកោ ច វនសណ្ឌោ នទី ច សន្ទន្តី សេតកា សុប្បតិត្ថា រមណីយា សមន្តា ច គោចរគាមោ អលំ វតិទំ កុលបុត្តស្ស បធានត្ថិកស្ស បធានាយាតិ ។ សោ ខោ អហំ ភារទ្វាជ តត្ថេវ និសីទឹ អលមិទំ បធានាយាតិ ។

ប្រព្រឹត្តទៅបាន ត្រឹមតែទៅកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះឯង ។ ម្នាលភារទ្វាជៈ តថាគតឯងមិនល្មមចិត្តនឹងធម៌នោះ នឿយណាយចាកធម៌នោះ ហើយក៏ចៀសចេញទៅ ។

[១៩៧] ម្នាលភារទ្វាជៈ តថាគតស្វែងរកនូវកុសល ស្វែងរកនូវសន្តិវរបទ រកគុណជាតដទៃក្រៃលែងជាងគ្មាន ត្រាច់ទៅកាន់ចារិកក្នុងដែនមគធៈតាមលំដាប់ ក៏បានដល់សេនានិគមក្នុងឧរុវេលាប្រទេស ។ ក្នុងទីនោះ តថាគតបានឃើញភូមិភាគ (ចំណែកផែនដី) ជាទីគួរត្រេកអរផង នូវដងព្រៃជាទីនាំមកនូវសេចក្តីជ្រះថ្លាផង នូវស្ទឹងកំពុងហូរទៅ មានទឹកត្រជាក់ មានកំពង់ដ៏ល្អ ជាទីគួរត្រេកអរផង នូវស្រុកជាទីគោចរជុំវិញផង ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ភូមិភាគនេះជាទីគួរត្រេកអរផង ដងព្រៃជាទីនាំមកនូវសេចក្តីជ្រះថ្លាផង ស្ទឹងកំពុងហូរទៅ មានទឹកត្រជាក់ មានកំពង់ដ៏ល្អ ជាទីគួរត្រេកអរផង ស្រុកជាទីគោចរជុំវិញផង ទីនេះជាទីគួរតាំងសេចក្តីព្យាយាម របស់កុលបុត្តអ្នកត្រូវការដោយសេចក្តីព្យាយាម ។ ម្នាលភារទ្វាជៈ តថាគតអង្គុយក្នុងទីនោះដោយគិតថា ទីនេះជាទីគួរដល់សេចក្តីព្យាយាម ។

[១៨៨] អបិស្សុ មំ ភារទ្វាជ តិស្សោ ឧបមា បដិភំសុ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ ភារទ្វាជ អល្លំ កដ្ឋំ សស្នេហំ ឧទកេ និក្ខិត្តំ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ[១] តំ កឹ មញ្ញសិ ភារទ្វាជ អបិ នុ សោ បុរិសោ អមុំ អល្លំ កដ្ឋំ សស្នេហំ ឧទកេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមន្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ នោ ហិទំ ភោ គោតម តំ កិស្ស ហេតុ អទុញ្ហិ ភោ គោតម អល្លំ កដ្ឋំ សស្នេហំ តញ្ច បន ឧទកេ និក្ខិត្តំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។

---

១ ម. តេជោធាតុំ ករិស្សាមីតីតិ ទិស្សតិ ។

ព្រាហ្មណវគ្គ សគារវសូត្រ ឧបមាទីមួយ

[១៥៨] ម្នាលភារទ្វាជៈ សេចក្តីឧបមា ៣ យ៉ាង មិនជាទីអស្ចារ្យ ប៉ុន្មាន ដែលតថាគតមិនធ្លាប់បានស្តាប់ក្នុងកាលមុន ក៏ប្រាកដឡើង ដល់តថាគត ។ ម្នាលភារទ្វាជៈ ដូចកំណាត់ឈើស្រស់មានជ័រ ដែល ត្រាំទឹក មានបុរសកាន់យកនូវឈើពំនួតភ្លើងខាងលើដើរមក ដោយ គិតថា អាត្មាអញនឹងធ្វើភ្លើងឲ្យកើតឡើង នឹងធ្វើភ្លើងឲ្យឆេះឡើង ម្នាលភារទ្វាជៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសនោះ អាចកាន់ យកនូវពំនួតភ្លើងខាងលើ មកពួតគ្នានឹងកំណាត់ឈើស្រស់ នៅមានជ័រ ដែលត្រាំទឹក តើធ្វើភ្លើងឲ្យកើតឡើង ធ្វើភ្លើងឲ្យឆេះឡើងបានដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនធ្លាប់មានទេ ដំណើរនោះព្រោះ ហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា កំណាត់ឈើឯណោះ នៅ ស្រស់មានជ័រ មួយទៀត កំណាត់ឈើនោះត្រាំទឹកផង ឯបុរសនោះ ឯង គ្រាន់តែមានចំណែកនៃសេចក្តីលំបាកកាយលំបាកចិត្តប៉ុណ្ណោះ ។

ឯវមេវ ខោ ភារទ្វាជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ អវូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ ន សុប្បហីនោ ហោតិ ន សុប្បដិប្បស្សទ្ធោ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិប្បា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ នោ ចេបិ តេ ភោន្តោ សមណព្រាហ្មណា ឱបក្កមិកា ទុក្ខា តិប្បា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ អយំ ខោ មំ ភារទ្វាជ បឋមា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

ម្នាលភារទ្វាជៈ សេចក្តីនុ៎ះមានឧបមេយ្យដូចសមណៈឬព្រាហ្មណ៍ណាមួយ មិនស្ងប់ស្ងាត់ចាកកាមទាំងឡាយដោយកាយផង សេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជ្រុលជ្រប់ក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីក្តៅក្រហាយក្នុងកាមទាំងឡាយណា របស់សមណព្រាហ្មណ៍ទាំងនោះ សេចក្តីប្រាថ្នាក្នុងកាមជាដើមនោះ មិនបានសាបសូន្យដោយងាយ មិនបានស្ងប់រម្ងាប់ដោយងាយ ក្នុងចិត្តផង បើទុកជាសមណព្រាហ្មណ៍ ដ៏ចម្រើនទាំងនោះ ទទួលវេទនាជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាម សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង ដ៏ប្រសើរឡើយ បើទុកជា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនបានទទួលនូវវេទនាជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាមទេ សមណព្រាហ្មណ៍ទាំងនោះ ក៏នៅតែមិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងដ៏ប្រសើរទេ ។ ម្នាលភារទ្វាជៈ នេះសេចក្តីឧបមាទី ១ មិនជាទីអស្ចារ្យប៉ុន្មាន ដែលតថាគតមិនធ្លាប់បានស្តាប់មកក្នុងកាលមុន ក៏ប្រាកដឡើងដល់តថាគត ។

ព្រាហ្មណវគ្គស្ស សគារវសុត្តេ ទុតិយូបមា

[១៨៩] អបរាបិ ខោ មំ ភារទ្វាជ ទុតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ ភារទ្វាជ អល្លំ កដ្ឋំ សស្នេហំ អារកា ឧទកា ថលេ និក្ខិត្តំ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ តំ កឹ មញ្ញសិ ភារទ្វាជ អបិ នុ សោ បុរិសោ អមុំ អល្លំ កដ្ឋំ សស្នេហំ អារកា ឧទកា ថលេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមន្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុក-រេយ្យាតិ ។ នោ ហិទំ ភោ គោតម តំ កិស្ស ហេតុ អទុញ្ហិ ភោ គោតម អល្លំ កដ្ឋំ សស្នេហំ កិញ្ចាបិ អារកា ឧទកា ថលេ និក្ខិត្តំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។

ព្រាហ្មណវគ្គ សគារវសូត្រ ឧបមាទីពីរ

[១៥៩] ម្នាលភារទ្វាជៈ សេចក្តីឧបមាទី ២ ដទៃទៀត មិនជាទីអស្ចារ្យប៉ុន្នាន ដែលតថាគតមិនធ្លាប់បានស្តាប់មកក្នុងកាលមុន ក៏ប្រាកដឡើងដល់តថាគត ។ ម្នាលភារទ្វាជៈ ដូចកំណាត់ឈើស្រស់មានជ័រ នៅលើគោកឆ្ងាយអំពីទឹក មានបុរសកាន់យកឈើពំនួតភ្លើងខាងលើដើរមក ដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឲ្យកើតឡើង នឹងធ្វើភ្លើងឲ្យឆេះឡើង ម្នាលភារទ្វាជៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសនោះអាចកាន់យកពំនួតភ្លើងខាងលើ មកពួតគ្នានឹងកំណាត់ឈើស្រស់ឯណោះ ដែលមានជ័រ នៅលើគោកឆ្ងាយអំពីទឹក តើធ្វើភ្លើងឲ្យកើតឡើង ធ្វើភ្លើងឲ្យឆេះឡើងបានឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុនេះមិនធ្លាប់មានទេ សេចក្តីនោះព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា កំណាត់ឈើឯណោះ ជាឈើស្រស់នៅមានជ័រ ទោះបីនៅលើគោកឆ្ងាយអំពីទឹកក៏ដោយ ឯបុរសនោះគ្រាន់តែមានចំណែកនៃសេចក្តីលំបាកកាយ លំបាកចិត្តប៉ុណ្ណោះឯង ។

ឯវមេវ ខោ ភារទ្វាជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ វូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ ន សុប្បហីនោ ហោតិ ន សុប្បដិប្បស្សទ្ធោ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិប្បា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ នោ ចេបិ តេ ភោន្តោ សមណព្រាហ្មណា ឱបក្កមិកា ទុក្ខា តិប្បា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ ភារទ្វាជ ទុតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

ម្នាលភារទ្វាជៈ សេចក្តីនុ៎ះមានឧបមេយ្យដូច សមណៈឬព្រាហ្មណ៍ឯណានីមួយ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ដោយកាយពិតមែនហើយ តែសេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជ្រុលជ្រប់ក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីក្តៅក្រហាយក្នុងកាមទាំងឡាយណា របស់សមណព្រាហ្មណ៍ទាំងនោះ សេចក្តីប្រាថ្នាក្នុងកាមជាដើមនោះ មិនបានសាបសូន្យស្រឡះ មិនបានស្ងប់រម្ងាប់ស្រឡះក្នុងចិត្តនៅឡើយ បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ សោយនូវវេទនា ជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាម សមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងដ៏ប្រសើរឡើយ បើទុកជាសមណព្រាហ្មណ៍ទាំងនោះ មិនបានទទួលនូវវេទនា ជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាមទេ សមណព្រាហ្មណ៍ទាំងនោះ ក៏គង់តែមិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងដ៏ប្រសើរដែរ ។ ម្នាលភារទ្វាជៈ នេះជាសេចក្តីឧបមាទី ២ មិនជាទីអស្ចារ្យប៉ុន្មាន ដែលតថាគតមិនធ្លាប់បានស្តាប់មកក្នុងកាលមុន ក៏ប្រាកដឡើងដល់តថាគត ។

ព្រាហ្មណវគ្គស្ស សគារវសុត្តេ តតិយូបមា

[១៦០] អបរាបិ ខោ មំ ភារទ្វាជ តតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ ភារទ្វាជ សុក្ខំ កដ្ឋំ កោឡាបំ អារកា ឧទកា ថលេ និក្ខិត្តំ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ តំ កឹ មញ្ញសិ ភារទ្វាជ អបិ នុ សោ បុរិសោ អមុំ សុក្ខំ កដ្ឋំ កោឡាបំ អារកា ឧទកា ថលេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមត្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ ឯវំ ភោ គោតម តំ កិស្ស ហេតុ អទុញ្ហិ ភោ គោតម សុក្ខំ កដ្ឋំ កោឡាបំ តញ្ច បន អារកា ឧទកា ថលេ និក្ខិត្តន្តិ ។ ឯវមេវ ខោ ភារទ្វាជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ វូបកដ្ឋា វិហរន្តិ

[១៦០] ម្នាលភារទ្វាជៈ សេចក្តីឧបមាទី ៣ ដទៃទៀត មិនជាទីអស្ចារ្យប៉ុន្មាន ដែលតថាគតមិនធ្លាប់បានស្តាប់មកក្នុងកាលមុន ក៏ប្រាកដឡើងដល់តថាគត ។ ម្នាលភារទ្វាជៈ ដូចកំណាត់ឈើស្ងួតអស់សម្ងួតនៅលើគោក ឆ្ងាយអំពីទឹក មានបុរសកាន់យកឈើពំនួតភ្លើងខាងលើដើរមក ដោយគិតថា អាត្មាអញនឹងធ្វើភ្លើងឲ្យកើតឡើង ធ្វើភ្លើងឲ្យឆេះឡើង ម្នាលភារទ្វាជៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសនោះអាចកាន់យកពំនួតភ្លើងខាងលើ មកពួតគ្នា នឹងកំណាត់ឈើស្ងួតឯណោះ ដែលជាឈើអស់សម្ងួត នៅលើគោកឆ្ងាយអំពីទឹក តើធ្វើភ្លើងឲ្យកើតឡើង ធ្វើភ្លើងឲ្យឆេះឡើងបានដែរឬ ។ ព្រះករុណា ព្រះគោតមដ៏ចម្រើន សេចក្តីនោះព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះកំណាត់ឈើឯណោះ ជាឈើស្ងួតអស់សម្ងួត ទាំងឈើនោះក៏នៅលើគោក ឆ្ងាយអំពីទឹកផង ។ ម្នាលភារទ្វាជៈ រឿងនេះមានឧបមេយ្យដូចជាសមណៈឬព្រាហ្មណ៍ណានីមួយ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ដោយកាយផង

យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ សុប្បហីនោ ហោតិ សុប្បដិប្បស្សទ្ធោ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិប្បា កដុកា វេទនា វេទិយន្តិ ភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ នោ ចេបិ តេ ភោន្តោ សមណព្រាហ្មណា ឱបក្កមិកា ទុក្ខា តិប្បា កដុកា វេទនា វេទិយន្តិ ភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ ភារទ្វាជ តតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ ឥមា ខោ មំ ភារទ្វាជ តិស្សោ ឧបមា បដិភំសុ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

សេចក្តីប្រាថ្នាក្នុងកាម សេចក្តីស្នេហាក្នុងកាម សេចក្តីជ្រុលជ្រប់ក្នុងកាម សេចក្តីស្រេកឃ្លានក្នុងកាម សេចក្តីក្តៅក្រហាយក្នុងកាម ក្នុងកាមទាំងឡាយណា របស់សមណព្រហ្មណ៍ទាំងនោះ សេចក្តីប្រាថ្នាក្នុងកាមជាដើមនោះ ក៏សាបសូន្យស្រឡះ ស្ងប់រម្ងាប់ស្រឡះក្នុងចិត្តផង បើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទទួលនូវវេទនាជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាម សមណព្រាហ្មណ៍ទាំងនោះ ក៏គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងដ៏ប្រសើរពិត ឬបើទុកជាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនទទួលនូវវេទនាជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាមទេ សមណព្រាហ្មណ៍ទាំងនោះ ក៏គង់តែគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងដ៏ប្រសើរពិត យ៉ាងនោះឯង ។ ម្នាលភារទ្វាជៈ នេះជាសេចក្តីឧបមាទី ៣ មិនជាទីអស្ចារ្យប៉ុន្មាន ដែលតថាគតមិនធ្លាប់បានស្តាប់មកក្នុងកាលមុន ក៏ប្រាកដឡើងដល់តថាគត ។ ម្នាលភារទ្វាជៈ ឧបមាទាំង ៣ នេះឯង មិនជាទីអស្ចារ្យប៉ុន្មាន ដែលតថាគតមិនធ្លាប់បានស្តាប់មកក្នុងកាលមុន ក៏ប្រាកដឡើងដល់តថាគត ។

[១៦១] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ យន្នូនាហំ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហេយ្យំ អភិនិប្បីឡេយ្យំ អភិសន្តាបេយ្យន្តិ ។ សោ ខោ អហំ ភារទ្វាជ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហាមិ អភិនិប្បីឡេមិ អភិសន្តាបេមិ ។ តស្ស មយ្ហំ ភារទ្វាជ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ កច្ឆេហិ សេទា មុច្ចន្តិ ។ សេយ្យថាបិ ភារទ្វាជ ពលវា បុរិសោ ទុព្វលតរំ បុរិសំ សីសេ វា គហេត្វា ខន្ធេ វា គហេត្វា អភិនិគ្គណ្ហេយ្យ អភិនិប្បីឡេយ្យ អភិសន្តាបេយ្យ ឯវមេវ ខោ មេ ភារទ្វាជ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ

ព្រាហ្មណវគ្គ សគារវសូត្រ អំពីសេចក្តីព្យាយាមដ៏លំបាក

[១៦១] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញយកធ្មេញសង្កត់ធ្មេញ យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាបត្បុត ដុតកម្តៅចិត្តដោយចិត្ត ។ ម្នាលភារទ្វាជៈ តថាគតឯងក៏យកធ្មេញសង្កត់ធ្មេញ យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាបត្បុត ដុតកម្តៅចិត្តដោយចិត្ត ។ ម្នាលភារទ្វាជៈ កាលបើតថាគត យកធ្មេញសង្កត់ធ្មេញ យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាបត្បុត ដុតកម្តៅចិត្តដោយចិត្តទៅហើយ ញើសក៏ហូរចេញអំពីក្លៀក ។ ម្នាលភារទ្វាជៈ ដូចបុរសមានកម្លាំង ចាប់បុរសដែលខ្សោយ ត្រង់ក្បាលក្តី ត្រង់កក្តី សង្កត់សង្កិន គាបត្បុត ដុតកម្តៅ យ៉ាងណាមិញ ម្នាលភារទ្វាជៈ កាលបើតថាគត យកធ្មេញសង្កត់ធ្មេញ យកអណ្តាតទល់ពិតាន សង្កត់សង្កិន គាបត្បុត ដុតកម្តៅចិត្តដោយចិត្តទៅហើយ

កច្ឆេហិ សេទា មុច្ចន្តិ ។ អារទ្ធំ ខោ បន មេ ភារទ្វាជ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិ-តុន្នស្ស សតោ ។

[១៦២] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ យន្នូនាហំ អប្បាណកំ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ ភារទ្វាជ មុខតោ ច នាសតោ ច អស្សាស-បស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ ភារទ្វាជ មុខតោ ច នាសតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ កណ្ណសោតេហិ វាតានំ និក្ខមន្តានំ អធិ-មត្តោ សទ្ទោ ហោតិ ។ សេយ្យថាបិ នាម កម្មារគគ្គរិយា ធមមានាយ អធិមត្តោ សទ្ទោ ហោតិ ឯវមេវ ខោ មេ ភារទ្វាជ មុខតោ ច នាសតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ កណ្ណសោ-តេហិ វាតានំ និក្ខមន្តានំ អធិមត្តោ សទ្ទោ ហោតិ ។

ញើសក៏ហូរចេញអំពីក្លៀក យ៉ាងនោះឯង ។ ម្នាលភារទ្វាជៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែង មិនបានធូរថយទេ សតិរបស់តថាគតតម្កល់ខ្ជាប់មិនបានភ្លេច ឯកាយរបស់តថាគតដែលត្រូវសេចក្តីព្យាយាមគ្របសង្កត់ហើយ ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះឯង ក៏ប្រកបដោយសេចក្តីក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ។

[១៦២] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចម្រើននូវអប្បានកជ្ឈាន (ឈានសម្រេចដោយមិនមានខ្យល់ដង្ហើមចេញចូល) ។ ម្នាលភារទ្វាជៈ តថាគតក៏បិទខ្យល់ដង្ហើមចេញចូលអំពីមាត់ផង អំពីច្រមុះផង ។ ម្នាលភារទ្វាជៈ កាលបើតថាគតបិទខ្យល់ដង្ហើមចេញចូល អំពីមាត់និងច្រមុះហើយ ខ្យល់ដែលចេញអំពីរន្ធត្រចៀកក៏មានសំឡេងឮខ្លាំង ។ ដូចជាស្នប់របស់ជាងលោហៈកាលបើគេសប់ ក៏មានសំឡេងឮខ្លាំង យ៉ាងណាមិញ ម្នាលភារទ្វាជៈ កាលបើតថាគតបិទខ្យល់ដង្ហើមចេញចូលអំពីមាត់និងច្រមុះហើយ ខ្យល់ដែលចេញមកអំពីរន្ធត្រចៀក ក៏មានសំឡេងឮខ្លាំង យ៉ាងនោះឯង ។

អារទ្ធំ ខោ បន មេ ភារទ្វាជ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។

[១៦៣] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ យន្នូនាហំ អប្បានកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសប្បស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសប្បស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា មុទ្ធានំ ឱហនន្តិ ។ សេយ្យថាបិ ភារទ្វាជ ពលវា បុរិសោ តិណ្ហេន សិខរេន មុទ្ធានំ[១] អភិមត្ថេយ្យ ឯវមេវ ខោ មេ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសប្បស្សាសេសុ ឧបរុទ្ធេសុ

១ ម. មុទ្ធនឹ ។

ម្នាលភារទ្វាជៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែង មិនបានធូរថយទេ សតិរបស់តថាគតតម្កល់ខ្ជាប់មិនបានភ្លេច ឯកាយរបស់តថាគតដែលត្រូវសេចក្តីព្យាយាមគ្របសង្កត់ហើយ ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះឯង ក៏ប្រកបដោយសេចក្តីក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ។

[១៦៣] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចម្រើននូវអប្បានកជ្ឈាន ។ ម្នាលភារទ្វាជៈ តថាគតឯង ក៏បិទខ្យល់ដង្ហើមចេញចូល អំពីមាត់ផង អំពីច្រមុះផង អំពីរន្ធត្រចៀកផង ។ ម្នាលភារទ្វាជៈ កាលបើតថាគត បិទខ្យល់ដង្ហើមចេញចូល អំពីមាត់ ច្រមុះ និងរន្ធត្រចៀកហើយ ខ្យល់ខ្លាំងក៏ចាក់ដោតអំបែងក្បាល ។ ម្នាលភារទ្វាជៈ ដូចបុរសមានកម្លាំង ចាក់ដោតអំបែងក្បាលដោយដែកស្រួចដ៏មុត យ៉ាងណាមិញ ម្នាលភារទ្វាជៈ កាលបើតថាគតបិទខ្យល់ដង្ហើមចេញចូលអំពីមាត់ ច្រមុះ និងរន្ធត្រចៀកហើយ

អធិមត្តា វាតា មុទ្ធានំ ឩហនន្តិ ។ អារទ្ធំ ខោ បន មេ ភារទ្វាជ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។

[១៦៤] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ យន្នូនាហំ អប្បានកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា សីសេ សីសវេទនា ហោន្តិ ។ សេយ្យថាបិ ភារទ្វាជ ពលវា បុរិសោ ទឡ្ហេន វរត្តក្ខណ្ឌេន សីសេ សីសវេឋនំ ទទេយ្យ

ខ្យល់ខ្លាំងក៏ចាក់ដោតអំបែងក្បាល យ៉ាងនោះឯង ។ ម្នាលភារទ្វាជៈ សេចក្តីព្យាយាម របស់តថាគតតឹងតែង មិនបានធូរថយទេ សតិរបស់តថាគតតម្កល់ខ្ជាប់មិនបានភ្លេច ឯកាយរបស់តថាគតដែលត្រូវសេចក្តីព្យាយាមគ្របសង្កត់ហើយ ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះឯង ក៏ប្រកបដោយសេចក្តីក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ។

[១៦៤] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចម្រើននូវអប្បានកជ្ឈានតទៅទៀត ។ ម្នាលភារទ្វាជៈ តថាគតឯងក៏បិទនូវខ្យល់ដង្ហើមចេញចូល អំពីមាត់ផង អំពីច្រមុះផង អំពីរន្ធត្រចៀកផង ។ ម្នាលភារទ្វាជៈ កាលបើតថាគត បិទខ្យល់ដង្ហើមចេញចូល អំពីមាត់ អំពីច្រមុះ និងរន្ធត្រចៀកហើយ ក៏កើតមានទុក្ខវេទនាក្នុងក្បាលដ៏ក្រៃលែង ។ ម្នាលភារទ្វាជៈ ដូចបុរសមានកម្លាំងយកកំណាត់ព្រ័ត្រដ៏មាំមករុំព័ទ្ធក្បាល យ៉ាងណាមិញ

ឯវមេវ ខោ មេ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសប្បស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា សីសេ សីសវេទនា ហោតិ ។ អារទ្ធំ ខោ បន មេ ភារទ្វាជ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។

[១៦៥] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ យន្នូនាហំ អប្បានកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសប្បស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សា-សប្បស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា

ម្នាលភារទ្វាជៈ កាលបើតថាគត បិទខ្យល់ដង្ហើមចេញចូល អំពីមាត់ អំពីច្រមុះ និងរន្ធត្រចៀកហើយ ក៏កើតមានទុក្ខវេទនា ក្នុងក្បាលក្រៃលែង យ៉ាងនោះឯង ។ ម្នាលភារទ្វាជៈ សេចក្ដីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនបានធូរថយទេ សតិរបស់តថាគត តម្កល់ខ្ជាប់ មិនបានភ្លេច ឯកាយរបស់តថាគតដែលត្រូវសេចក្ដីព្យាយាមគ្របសង្កត់ហើយ ព្រោះសេចក្ដីព្យាយាមដ៏លំបាកនោះឯង ក៏ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ។

[១៦៥] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចម្រើននូវអប្បានកជ្ឈានតទៅទៀត ។ ម្នាលភារទ្វាជៈ តថាគតក៏បិទនូវខ្យល់ដង្ហើមចេញចូល អំពីមាត់ផង អំពីច្រមុះផង អំពីរន្ធត្រចៀកផង ។ ម្នាលភារទ្វាជៈ កាលបើតថាគតបិទខ្យល់ដង្ហើមចេញចូល អំពីមាត់ អំពីច្រមុះ និងរន្ធត្រចៀកហើយ ខ្យល់ខ្លាំង

កុច្ឆឹ បរិកន្តន្តិ ។ សេយ្យថាបិ ភារទ្វាជ ទក្ខោ
គោឃាតកោ វា គោឃាតកន្តេវាសី វា តិណ្ហេន
គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ
មេ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណ-
សោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ
អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ។ អារទ្ធំ ខោ បន
មេ ភារទ្វាជ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ
អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ
អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិ-
តុន្នស្ស សតោ ។

[១៦៦] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ
យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។
សោ ខោ អហំ ភារទ្វាជ មុខតោ ច នាសតោ ច
កណ្ណសោតតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។
តស្ស មយ្ហំ ភារទ្វាជ មុខតោ ច នាសតោ ច
កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ

ក៏វះអារនូវផ្ទៃ ។ ម្នាលភារទ្វាជៈ ដូចគោឃាតកៈ (អ្នកសម្លាប់គោ) ក្តី កូនសិស្សរបស់គោឃាតកៈក្តី ដែលឈ្លាសវៃវះអារនូវផ្ទៃដោយកាំបិតសម្រាប់អារគោដ៏មុត យ៉ាងណាមិញ ម្នាលភារទ្វាជៈ កាលបើតថាគតបិទខ្យល់ដង្ហើមចេញចូល អំពីមាត់ អំពីច្រមុះ និងរន្ធត្រចៀកហើយ ខ្យល់ខ្លាំងក៏វះអារនូវផ្ទៃយ៉ាងនោះឯង ។ ម្នាលភារទ្វាជៈ សេចក្តីព្យាយាមរបស់តថាគតតឹងតែងណាស់ មិនបានធូរថយទេ សតិរបស់តថាគតតម្កល់ខ្ជាប់មិនបានភ្លេច ឯកាយរបស់តថាគត ដែលត្រូវសេចក្តីព្យាយាមគ្របសង្កត់ហើយ ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះឯង ក៏ប្រកបដោយសេចក្តីក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ។

[១៦៦] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចម្រើននូវអប្បានកជ្ឈានតទៅទៀត ។ ម្នាលភារទ្វាជៈ តថាគតឯង ក៏បិទខ្យល់ដង្ហើមចេញចូល អំពីមាត់ផង អំពីច្រមុះផង អំពីរន្ធត្រចៀកផង ។ ម្នាលភារទ្វាជៈ កាលបើតថាគតបិទខ្យល់ដង្ហើមចេញចូល អំពីមាត់ អំពីច្រមុះ និងរន្ធត្រចៀកហើយ

អធិមត្តោ កាយស្មឹ ឌាហោ ហោតិ ។ សេយ្យថាបិ ភារទ្វាជ ពលវន្តោ បុរិសា ទុព្វលតរំ បុរិសំ នានាពាហាសុ គហេត្វា អង្គារកាសុយា សន្តាបេយ្យុំ[១] ឯវមេវ ខោ មេ ភារទ្វាជ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តោ កាយស្មឹ ឌាហោ ហោតិ ។ អារទ្ធំ ខោ បន មេ ភារទ្វាជ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។ អបិស្សុ មំ ភារទ្វាជ ទេវតា ទិស្វា ឯវមាហំសុ កាលកតោ សមណោ គោតមោតិ ។

១ ម. សន្តាបេយ្យុំ សម្បរិតាបេយ្យុន្តិ ទិស្សតិ ។

ក៏កើតមានសេចក្តីក្តៅក្រហាយក្នុងកាយដ៏ក្រៃលែង ។ ម្នាលភារទ្វាជៈ ដូចបុរសមានកម្លាំងចាប់បុរសដែលខ្សោយ ឲ្យដ៏ដើមដៃមួយម្នាង ហើយកម្តៅក្នុងរណ្តៅដ៏ពេញដោយរងើកភ្លើង យ៉ាងណាមិញ ម្នាលភារទ្វាជៈ កាលបើតថាគត បិទខ្យល់ដង្ហើមចេញចូល អំពីមាត់ អំពីច្រមុះ និងរន្ធត្រចៀកហើយ ក៏កើតមានសេចក្តីក្តៅក្រហាយក្នុងកាយដ៏ក្រៃលែង យ៉ាងនោះឯង ។ ម្នាលភារទ្វាជៈ សេចក្តីព្យាយាមរបស់តថាគត តឹងតែងណាស់ មិនបានធូរថយទេ សតិរបស់តថាគត តម្កល់ខ្ជាប់មិនបានភ្លេចឯកាយរបស់តថាគត ដែលត្រូវសេចក្តីព្យាយាមគ្របសង្កត់ហើយ ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះឯង ក៏ប្រកបដោយសេចក្តីក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ។ ម្នាលភារទ្វាជៈ ពួកទេវតាបានឃើញតថាគតហើយ ក៏ពោលយ៉ាងនេះថា ព្រះសមណគោតម ធ្វើមរណកាលទៅហើយ ។

ឯកច្ចា ទេវតា ឯវមាហំសុ ន កាលកតោ សមណោ គោតមោ អបិច កាលំ ករោតីតិ ។ ឯកច្ចា ទេវតា ឯវមាហំសុ ន កាលកតោ សមណោ គោតមោ នបិ កាលំ ករោតិ អរហំ សមណោ គោតមោ វិហារោ ត្វេវ សោ អរហតោ ឯវរូបោ ហោតីតិ ។

[១៦៧] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ យន្នូនាហំ សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជេយ្យន្តិ ។ អថខោ មំ ភារទ្វាជ តា ទេវតា ឧបសង្កមិត្វា ឯតទវោចុំ មា ខោ ត្វំ មារិស សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជិ សចេ ខោ ត្វំ មារិស សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជិស្សសិ តស្ស តេ មយំ ទិព្វំ ឱជំ លោមកូបេហិ អជ្ឈោហារិស្សាម តាយ ត្វំ យាបេស្សសីតិ ។ តស្ស មយ្ហំ ភារទ្វាជ

ឯទេវតាពួកខ្លះ ពោលយ៉ាងនេះថា ព្រះសមណគោតម មិនមែនធ្វើមរណកាលហើយទេ ប៉ុន្តែជិតនឹងធ្វើមរណកាលហើយ ។ ទេវតាពួកខ្លះពោលយ៉ាងនេះថា ព្រះសមណគោតម ធ្វើមរណកាលរួចហើយក៏មិនមែន ជិតនឹងធ្វើមរណកាលក៏មិនមែន ព្រះសមណគោតម ជាព្រះអរហន្តទ្រង់គង់សម្រាន្តនៅទេតើ ឯធម៌ជាគ្រឿងនៅរបស់ព្រះអរហន្ត មានសភាពយ៉ាងនោះឯង ។

[១៦៧] ម្នាលភារទ្វាជៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ។ ម្នាលភារទ្វាជៈ លំដាប់នោះ ទេវតាទាំងនោះចូលមករកតថាគតហើយពោលយាត់យ៉ាងនេះថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ព្រះអង្គកុំប្រតិបត្តិដើម្បីផ្តាច់បង់អាហារទាំងអស់ឡើយ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ បើព្រះអង្គនឹងប្រតិបត្តិដើម្បីផ្តាច់បង់អាហារទាំងអស់ហើយ យើងទាំងឡាយ នឹងបញ្ចូលនូវឱជារសទិព្វ តាមរណ្តៅនៃរោមព្រះអង្គ ព្រះអង្គនឹងបានញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយសារឱជារសនោះ ។ ម្នាលភារទ្វាជៈ តថាគតនោះ

ឯតទហោសិ អហំ ចេវ ខោ បន សព្វសោ ជទ្ធុកាំ[១] បដិជានេយ្យំ ឥមា ច ខោ មេ ទេវតា ធិព្វំ ឱជំ លោមកូបេហិ អជ្ឈោហារេយ្យុំ តាយ ចាហំ យាបេយ្យំ តំ មម អស្ស មុសាតិ ។ សោ ខោ អហំ ភារទ្វាជ តា ទេវតា បច្ចាចិក្ខាមិ អលន្តិ វទាមិ ។

[១៦៨] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ យន្នូនាហំ ថោកំ ថោកំ អាហារំ អាហារេយ្យំ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថយូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុកយូសន្តិ ។ សោ ខោ អហំ ភារទ្វាជ ថោកំ ថោកំ អាហារំ អាហារេសឹ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថយូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុកយូសំ ។ តស្ស មយ្ហំ ភារទ្វាជ ថោកំ ថោកំ អាហារំ អាហារយតោ បសតំ បសតំ យទិ វា មុគ្គយូសំ

១ ឱ. អជទ្ធុកន្តិ ទិស្សតិ ។

មានសេចក្ដីត្រិះរិះយ៉ាងនេះថា បើអាត្មាអញ ប្ដេជ្ញាខ្លួនថាជាអ្នកអត់អាហារទាំងអស់ផង ពួកទេវតានេះឯង គប្បីបញ្ចូលឱជារសទិព្វ តាមរណ្ដៅនៃរោមអាត្មាអញផង ឯអាត្មាអញគប្បីញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយឱជារសនោះផង អំពើទាំង ៣ នោះ ជាអំពើកុហករបស់អាត្មាអញ ។ ម្នាលភារទ្វាជៈ តថាគតនោះក៏ពោលហាមឃាត់ទេវតាទាំងនោះថា កុំឡើយ ។

[១៦៨] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញបរិភោគអាហារបន្តិច ៗ មួយទូកដៃ ៗ ទោះគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដី ។ ម្នាលភារទ្វាជៈ តថាគតក៏បរិភោគអាហារបន្តិច ៗ មួយទូកដៃ ៗ ទោះគ្រាប់សណ្ដែកបាយក្ដី គ្រាប់ពពាយជ្រុងក្ដី គ្រាប់សណ្ដែកកង់ក្ដី គ្រាប់សណ្ដែកទ្រើងក្ដី ។ ម្នាលភារទ្វាជៈ កាលបើតថាគតបរិភោគអាហារបន្តិច ៗ មួយទូកដៃ ៗ ទោះគ្រាប់សណ្ដែកបាយ

យទិ វា កុលត្ថុយូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុកយូសំ អតិមត្តកសិមានំ បត្តោ កាយោ ហោតិ ។ សេយ្យថាបិ នាម អសីតិក-បព្វានិ វា កាឡបព្វានិ វា ឯវមេវស្សុ មេ អង្គប្ប-ច្ចង្គានិ ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ឱដ្ឋបទំ ឯវមេវស្សុ មេ អានិសទំ ហោតិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម វដ្ដនាវឡី ឯវមេវស្សុ មេ បិដ្ឋិកណ្ដកោ ឧណ្ណតាវណតោ ហោតិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ជជ្ជរសាលាយ គោបាណសិយោ ឱលុគ្គវិលុគ្គា ភវន្តិ ឯវមេវស្សុ មេ ផាសុឡិយោ ឱលុគ្គវិលុគ្គា ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម គម្ភីរេ ឧទបានេ ឧទកតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ ឯវមេវស្សុ មេ អក្ខិកូបេសុ អក្ខិតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម តិត្ត-កាលាពុ អាមកច្ឆិន្នោ វាតាតបេន សំផុសិតោ ហោតិ

ឬគ្រាប់ពពាយជ្រុង ឬគ្រាប់សណ្ដែកកង់ ឬគ្រាប់សណ្ដែកទ្រើង កាយក៏ដល់នូវការស្គាំងស្គមក្រៃពេក ។ ដូចវល្លិលែនពែន ឬវល្លិយាវ យ៉ាងណាមិញ ព្រោះតែអាហារតិចនោះ អវយវៈតូចធំរបស់តថាគត ក៏យ៉ាងនោះឯង ។ ស្នាមជើងសត្វឱដ្ឋ យ៉ាងណាមិញ ព្រោះអាហារតិចនោះ ត្រគាករបស់តថាគត ក៏យ៉ាងនោះឯង ។ លួសដែលគេវេញយ៉ាងណាមិញ ព្រោះតែអាហារតិចនោះ ឆ្អឹងខ្នងរបស់តថាគត ក៏ឡើងរដិបរដុបយ៉ាងនោះឯង ។ បង្កង់សាលាដែលគ្រាំគ្រារគីមរគាម យ៉ាងណាមិញ ព្រោះតែអាហារតិចនោះ របៀបឆ្អឹងជំនីររបស់តថាគត ក៏រគីមរគាមយ៉ាងនោះឯង ។ ក្រពេញទឹកក្នុងអណ្ដូងទឹកដែលជ្រៅ ក៏ជ្រៅខ្វង់ចុះទៅប្រាកដយ៉ាងណាមិញ ព្រោះតែអាហារតិចនោះ ប្រស្រីភ្នែកក្នុងរណ្ដៅភ្នែករបស់តថាគត ក៏ជ្រៅខ្វង់ចុះទៅប្រាកដយ៉ាងនោះឯង ។ ផ្លែននោងព្រៃដែលគេកាត់កាលនៅខ្ចី លុះមានខ្យល់និងកម្ដៅថ្ងៃពាល់ត្រូវហើយ

សម្មិលាតោ ឯវមេវស្សុ មេ សីសច្ឆវិ សម្មិលាតា ហោតិ តាយេវប្បាហារតាយ ។ សោ ខោ អហំ ភារទ្វាជ ឧទរច្ឆវឹ បរិមសិស្សាមីតិ បិដ្ឋិកណ្ដកំយេវ បរិគ្គណ្ហាមិ បិដ្ឋិកណ្ដកំ បរិមសិស្សាមីតិ ឧទរច្ឆវឹយេវ បរិគ្គណ្ហាមិ យាវស្សុ មេ ភារទ្វាជ ឧទរច្ឆវិ បិដ្ឋិកណ្ដកំ អល្លីនា ហោតិ តាយេវប្បាហារតាយ ។ សោ ខោ អហំ ភារទ្វាជ វច្ចំ វា មុត្តំ វា ករិស្សាមីតិ តត្ថេវ អវកុជ្ជោ បបតាមិ តាយេវប្បាហារតាយ ។ សោ ខោ អហំ ភារទ្វាជ ឥមមេវ កាយំ អស្សាសេន្តោ បាណិនា គត្តានិ អនុមជ្ជាមិ ។ តស្ស មយ្ហំ ភារទ្វាជ បាណិនា គត្តានិ អនុមជ្ជតោ បូតិមូលានិ លោមានិ កាយស្មា បបតន្តិ តាយេវប្បាហារតាយ ។ អបិស្សុ មំ ភារទ្វាជ មនុស្សា ទិស្វា ឯវមាហំសុ កាឡោ សមណោ គោតមោតិ ។ ឯកច្ចេ មនុស្សា ឯវមាហំសុ ន កាឡោ សមណោ គោតមោ សាមោ សមណោ គោតមោតិ ។

ក៏ស្ថិតស្រពោន យ៉ាងណាមិញ ស្បែកក្បាល របស់តថាគត លុះអាហារតិចនោះពាល់ត្រូវហើយ ក៏ស្ថិតស្រពោនយ៉ាងនោះឯង ។ ម្នាលភារទ្វាជ: តថាគតគិតថា អាត្មាអញនឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវឆ្អឹងខ្នងទៅវិញ គិតថា អាត្មាអញនឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវស្បែកពោះទៅវិញ ម្នាលភារទ្វាជ: ស្បែកពោះតថាគត ជាប់គ្នានឹងឆ្អឹងខ្នងព្រោះតែអាហារតិចនោះឯង ។ ម្នាលភារទ្វាជ: តថាគតគិតថា អាត្មាអញនឹងបន្ទោបង់នូវវច្ចៈក្តី នូវទឹកមូត្រក្តី ក៏ដួលផ្កាប់មុខចុះក្នុងទីនោះព្រោះតែអាហារតិចនោះឯង ។ ម្នាលភារទ្វាជ: តថាគតថ្នាក់ថ្នមកាយនេះ ហើយបបោសអង្អែលខ្លួនដោយដៃ ។ ម្នាលភារទ្វាជ: កាលតថាគត បបោសអង្អែលខ្លួនដោយដៃ ឯរោមមានឫសស្អុយក៏ធ្លាក់ចុះអំពីកាយ ព្រោះតែអាហារតិចនោះឯង ។ ម្នាលភារទ្វាជ: មនុស្សទាំង-ឡាយបានឃើញតថាគតហើយក៏ពោលយ៉ាងនេះថា ព្រះសមណគោតមមានសម្បុរខ្មៅ ។ តែមនុស្សខ្លះពោលយ៉ាងនេះថា ព្រះសមណ-គោតមមិនមែនខ្មៅទេ ព្រះសមណគោតមមានសម្បុរសណ្តែកបាយ ។

ឯកច្ចេ មនុស្សា ឯវមាហំសុ ន ការេត្ថ សមណោ គោតមោ នបិ សាមោ មគ្គំរច្ឆរី សមណោ គោតមោតិ ។ យាវស្ស មេ ការណំ បរិសុទ្ធោ ធរិវណ្ណោ បរិយោធាតោ ឧបហតោ ហោតិ តាយេវប្បាហារតាយ ។

[១៦៩] តស្ស មយ្ហំ ការណំ ឯតទហោសិ យេ ខោ កេចិ អតីតមទ្ធានំ សមណា វា ព្រាហ្ម-ណា វា ឱបក្កមិកា ទុក្ខា តិប្បា កដុកា វេទនា វេទិយឹសុ ឯតាវបរមំ នយិតោ ភិយ្យោ យេបិ កេចិ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា ឱបក្កមិកា ទុក្ខា តិប្បា កដុកា វេទនា វេទិ-យិស្សន្តិ ឯតាវបរមំ នយិតោ ភិយ្យោ យេបិ កេចិ ឯតរហិ សមណា វា ព្រាហ្មណា វា ឱបក្កមិកា ទុក្ខា តិប្បា កដុកា វេទនា វេទិយន្តិ

មនុស្សខ្លះ ពោលយ៉ាងនេះថា ព្រះសមណគោតម មិនមែនខ្មៅ មិនមែនសម្បុរសណ្តែកបាយទេ ព្រះសមណគោតម មានសម្បុរប្រផេះទេតើ ។ ម្នាលភារទ្វាជៈ តាមពិត សម្បុរស្បែករបស់តថាគត សបរិសុទ្ធផូរផង់ តែអាប់អន់ទៅ ព្រោះតែមានអាហារតិចនោះឯង ។

[១៦៩] ម្នាលភារទ្វាជៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា សមណៈឬព្រាហ្មណ៍ណានីមួយ ក្នុងអតីតកាល បានរងនូវវេទនា ជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាម កំណត់ត្រឹមនេះ មិនហួសអំពីនេះឡើយ សមណៈឬព្រាហ្មណ៍ ណានីមួយ ក្នុងអនាគតកាល នឹងរងនូវវេទនា ជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាម កំណត់ត្រឹមនេះ មិនហួសអំពីនេះឡើយ សមណៈឬព្រាហ្មណ៍ ណានីមួយ ក្នុងកាលឥឡូវនេះ រងនូវវេទនា ជាទុក្ខ ក្លៀវក្លា ក្តៅក្រហាយ ដែលកើតអំពីសេចក្តីព្យាយាម

២៩៣



ឯតាវបរមំ នយិតោ ភិយ្យោ ។ ន ខោ បនាហំ ឥមាយ កដុកាយ ទុក្ករការិកាយ អធិគច្ឆាមិ ឧត្តរឹ មនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសំ សិយា នុ ខោ អញ្ញោ មគ្គោ ពោធិយាតិ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ អភិជានាមិ ខោ បនាហំ បិតុ សក្កស្ស កម្មន្តេ សីតាយ ជម្ពុឆាយាយ និសិន្នោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតា សិយា នុ ខោ ឯសោ មគ្គោ ពោធិយាតិ ។ តស្ស មយ្ហំ ភារទ្វាជ សតានុសារិវិញ្ញាណំ អហោសិ ឯសេវ មគ្គោ

កំណាត់ត្រឹមនេះ មិនហួសអំពីនេះឡើយ ។ ចំណែកតថាគត ក៏នៅតែមិនបានគុណវិសេសគឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ ដោយអំពើកម្រ ដ៏ក្តៅក្រហាយនេះឡើយ ទើបគិតថា ប្រហែលជាមានផ្លូវដទៃ ប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹងទេដឹង ។ ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះឃើញយ៉ាងនេះថា អាត្មាអញធ្លាប់អង្គុយនៅក្នុងម្លប់ដើមព្រីងដែលត្រជាក់ ក្នុងការងាររបស់សក្យៈជាបិតា ក៏បានស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានសម្រេចបឋមជ្ឈានប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខកើតអំពីសេចក្តីស្ងាត់នោះ ក៏សម្រាន្តនៅដោយឥរិយាបថទាំង ៤ ប្រហែលជាផ្លូវនុ៎ះផង ប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹងទេដឹង ។ ម្នាលភារទ្វាជៈ តថាគតនោះមានវិញ្ញាណ រឭកតាមនូវសតិថា ផ្លូវនុ៎ះឯង ទើបជាផ្លូវ

ពោជិយាតិ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ កិន្នុ ខោ អហំ តស្ស សុខស្ស ភាយាមិ យន្តំ សុខំ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហីតិ ។ តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ ន ខោ អហំ តស្ស សុខស្ស ភាយាមិ យន្តំ សុខំ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហីតិ ។

[១៧០] តស្ស មយ្ហំ ភារទ្វាជ ឯតទហោសិ ន ខោ តំ សុករំ សុខំ អធិគន្តុំ ឯវំ អធិមត្តកសិមានំ បត្តកាយេន យន្នូនាហំ ឱឡារិកំ អាហារំ អាហារេយ្យំ ឱទនំ កុម្មាសន្តិ ។ សោ ខោ អហំ ភារទ្វាជ ឱឡារិកំ អាហារំ អាហារេសឹ ឱទនំ កុម្មាសំ ។ តេន ខោ បន មំ ភារទ្វាជ សមយេន បញ្ច ភិក្ខូ បច្ចុបដ្ឋិតា ហោន្តិ យំ ខោ សមណោ គោតមោ ធម្មំ អធិគមិស្សតិ តន្នោ អារោចេស្សតីតិ ។ យតោ ខោ អហំ ភារទ្វាជ

ប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹងពិត ។ ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា សេចក្តីសុខណា ក្រៅអំពីកាមទាំងឡាយ ក្រៅអំពីអកុសលធម៌ទាំងឡាយ អាត្មាអញ ខ្លាចសេចក្តីសុខនោះដែរឬហ្ន៎ ។ ម្នាលភារទ្វាជៈ តថាគតមានសេចក្តីត្រិះរិះឃើញ យ៉ាងនេះថា សេចក្តីសុខណា ក្រៅអំពីកាមទាំងឡាយ ក្រៅអំពីអកុសលធម៌ទាំងឡាយ អាត្មាអញ មិនខ្លាចសេចក្តីសុខនោះឡើយ ។

[១៧០] ម្នាលភារទ្វាជៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលដែលមានកាយដល់ នូវការស្គាំងស្គមក្រៃពេកយ៉ាងនេះ មិនងាយនឹងបានសេចក្តីសុខនោះឡើយ បើដូច្នោះ គួរតែអាត្មាអញ បរិភោគអាហារជាឱឡារិក គឺបាយនិងនំឲ្យពេញលេញ ។ ម្នាលភារទ្វាជៈ តថាគតឯង ក៏បានបរិភោគអាហារឱឡារិក គឺបាយនិងនំ ។ ម្នាលភារទ្វាជៈ សម័យនោះឯង ភិក្ខុ ៥ រូប តាមមកបម្រើតថាគតដោយគិតថា ព្រះសមណគោតមនឹងត្រាស់ដឹងធម៌ណា មុខជានឹងប្រាប់ធម៌នោះដល់យើងទាំងឡាយ ។ ម្នាលភារទ្វាជៈ កាលណាបើតថាគត

ឱឡារិកំ អាហារំ អាហារេសិំ ឱទនំ កុម្មាសំ អថ មេ តេ បញ្ច ភិក្ខូ និព្វិជ្ជ បក្កមឹសុ ពាហុល្លិកោ សមណោ គោតមោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយាតិ ។

[១៧១] សោ ខោ អហំ ភារទ្វាជ ឱឡារិកំ អាហារំ អាហារិត្វា ពលំ គហេត្វា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហាសិំ វិតក្ក-វិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហាសិំ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហាសិំ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេសិំ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ

បានបរិភោគអាហារឱឡារិកគឺបាយនិងនំហើយ កាលនោះភិក្ខុទាំង ៥ រូបនោះនឿយណាយចាកតថាគត ក៏នាំគ្នាចៀសចេញទៅដោយគិតថា ព្រះសមណគោតម ជាអ្នកល្មោភ សាបសូន្យចាកសេចក្តីព្យាយាម វិលមកដើម្បីសេចក្តីល្មោភវិញហើយ ។

[១៧១] ម្នាលភារទ្វាជៈ លុះតថាគតនោះបរិភោគអាហារឱឡារិក មានកម្លាំងហើយ ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បាន សម្រេចបឋមជ្ឈាន សម្រាន្តនៅដោយឥរិយាបថទាំង ៤ តថាគត បានសម្រេចទុតិយជ្ឈាន ជាធម្មជាតកើតក្នុងសន្តានចិត្ត ប្រកបដោយ សេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិន មានវិចារៈ មានតែបីតិនិងសុខ កើតអំពីសមាធិគឺបឋមជ្ឈាន ព្រោះ រម្ងាប់នូវវិតក្កៈនិងវិចារៈ ក៏សម្រាន្តនៅដោយឥរិយាបថទាំង ៤ តថាគត មានចិត្តនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មាន ស្មារតីដឹងខ្លួនផង បានទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈ ទាំងឡាយ សរសើរនូវបុគ្គលនោះថា បុគ្គលដែលបាននូវតតិយជ្ឈាន មានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជា សុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានសម្រេចនូវតតិយជ្ឈាននោះ

វិហាសី សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។

[១៧២] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្ស-តិញ្ញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយំ ខោ មេ ភារទ្វាជ រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិ-គតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

សម្រាន្តនៅដោយឥរិយាបថទាំង ៤ តថាគតលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ហើយក្នុងកាលមុន ក៏បានសម្រេចចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មានតែសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

[១៧២] កាលបើចិត្តតម្កល់ខ្ជាប់ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង ដល់នូវសេចក្ដីមិនញាប់ញ័រ ទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតនោះបង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតនោះ រលឹកឃើញនូវបុព្វេនិវាសជាច្រើនប្រការ គឺរលឹកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាសជាច្រើនប្រការព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ។ ម្នាលភារទ្វាជៈ បឋមវិជ្ជានេះឯង តថាគតបានក្នុងវេលាបឋមយាមនៃរាត្រី ឯអវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដែលមិនប្រមាទ មានព្យាយាមជាគ្រឿងដុតបង់នូវកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វានតាមពិត ។

ព្រាហ្មណវគ្គស្ស សគារវសុត្តេ ចុតូបបាតញ្ញាណំ

[១៧៣] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបា-តញ្ញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សា-មិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាមិ អយំ ខោ មេ ភារទ្វាជ រត្តិយា មជ្ឈិមេ យាមេ ទុតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

ព្រាហ្មណវគ្គ សគារវសូត្រ ចុតូបបាតញ្ញាណ

[១៧៣] កាលបើចិត្តតាំងខ្ជាប់ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង ដល់នូវសេចក្តីមិនញាប់ញ័រ ទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតនោះក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ (ប្រាជ្ញាដឹងនូវចុតិនិងបដិសន្ធិ) របស់សត្វទាំងឡាយ ។ តថាគតនោះមានចក្ខុជាទិព្វដ៏បរិសុទ្ធកន្លងបង់នូវចក្ខុ ជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតឡើង ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ បេ ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលប្រព្រឹត្តទៅសមគួរតាមកម្ម ម្នាលភារទ្វាជៈ វិជ្ជាទី ២ នេះឯង តថាគតបានក្នុងមជ្ឈិមយាមនៃរាត្រី ឯអវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង ដល់តថាគតដែលមិនប្រមាទ មានព្យាយាមជាគ្រឿងដុតបង់កិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វានតាមពិត ។

[១៧៤] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញា-ណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថា-ភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ។ តស្ស មយ្ហំ[១] ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ

១ ម. មេ ។

[១៧៤] កាលបើចិត្តតាំងខ្ជាប់ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្មជាចិត្តនឹងធឹង ដល់នូវសេចក្តីមិនញាប់ញ័រ ទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតនោះក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ[១] ។ តថាគតនោះ បានដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាទីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិជាដំណើរទៅកាន់ទីរលត់អាសវៈ ។ កាលបើតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចស្រឡះចាកកាមាសវៈផង ចិត្តក៏រួចស្រឡះចាកភវាសវៈផង ចិត្តក៏រួចស្រឡះ ចាកអវិជ្ជាសវៈផង

១ ប្រាជ្ញាដឹងច្បាស់នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ ធម៌នោះមានទុក្ខសច្ចជាដើម ។

វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។ អយំ ខោ មេ ភារទ្វាជ រត្តិយា បច្ឆិមេ យាមេ តតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោតិ ។

[១៧៨] ឯវំ វុត្តេ សង្គារវោ មាណវោ ភគវន្តំ ឯតទវោច អដ្ឋិត វត ភោតោ គោតមស្ស បធានំ អហោសិ សប្បុរិស វត ភោតោ គោតមស្ស បធានំ អហោសិ យថាតំ អរហតោ សម្មាសម្ពុទ្ធស្ស កឹ នុ ខោ ភោ គោតម អត្ថិ ទេវាតិ ។ ឋានសោ ខោ បេតំ[១] ភារទ្វាជ វិទិតំ យទិទំ អត្ថិ ទេវាតិ ។

---

ឱ. ឋានសោ មេ តន្តិ ទិស្សតិ ។

កាលបើចិត្តរួចស្រឡះហើយ សេចក្តីដឹងថា ចិត្តរួចស្រឡះដូច្នេះក៏កើតមាន តថាគតដឹងច្បាស់ថា កំណើតរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលភារទ្វាជៈ វិជ្ជាទី ៣ នេះឯង តថាគតបានហើយក្នុងបច្ឆិមយាមនៃរាត្រី ឯអវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង ដល់តថាគត ដែលជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតបង់នូវកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន តាមពិត ។

[១៧៥] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សគារវមាណព ពោលពាក្យនេះនឹងព្រះមានព្រះភាគថា ឱហ្ន៎ ព្រះគោតមដ៏ចម្រើន មានសេចក្តីព្យាយាមមិនបានឈប់ ឱហ្ន៎ ព្រះគោតមដ៏ចម្រើន ជាអរហន្តសម្មាសម្ពុទ្ធ មានសេចក្តីព្យាយាមជារបស់សប្បុរសបពិត្រព្រះគោតមដ៏ចម្រើន ទេវតាមានមែនឬទេ ។ ម្នាលភារទ្វាជៈ ពាក្យណាថា ទេវតាមានដូច្នេះ ពាក្យនុ៎ះតថាគតដឹងច្បាស់តាមហេតុពិត ។

កិន្នុ ខោ ភោ គោតម អត្ថិ ទេវាតិ បុដ្ឋោ សមានោ ឋានសោ បេតំ[១] ភារទ្វាជ វិទិតំ យទិទំ អត្ថិ ទេវាតិ វទេសិ ននុ[២] ភោ គោតម ឯវំ សន្តេ តុច្ឆា មុសា ហោតីតិ ។ អត្ថិ ទេវាតិ ភារទ្វាជ បុដ្ឋោ សមានោ អត្ថិ ទេវាតិ យោ វទេយ្យ ឋានសោ វិទិតា មេ ទេវាតិ យោ វទេយ្យ ។ អថខ្វេត្ថ វិញ្ញូបុរិសេន ឯកំសេន និដ្ឋំ គន្តុំ[៣] វា យទិទំ អត្ថិ ទេវាតិ ។ កិស្ស បន មេ ភវំ គោតមោ អាទិកេនេវ ន ព្យាកាសីតិ ។ ឧច្ចេន សម្មតំ ខោ ឯតំ ភារទ្វាជ លោកស្មឹ យទិទំ អត្ថិ ទេវាតិ ។

១ ឱ. ឋានសោ មេ តន្តិ ទិស្សតិ ។ ២ ម. ននុ ខោតិ ទិស្សតិ ។ ៣ ឱ. គន្តព្វំ ។

បពិត្រព្រះគោតមដ៏ចម្រើន កាលបើខ្ញុំព្រះអង្គសួរថា ទេវតាមានមែនឬទេ ហេតុអ្វីក៏ព្រះអង្គឆ្លើយថា ម្នាលភារទ្វាជៈ ពាក្យណាថា ទេវតាមានដូច្នេះ ពាក្យនុ៎ះតថាគតដឹងច្បាស់តាមហេតុពិត បពិត្រព្រះគោតមដ៏ចម្រើន កាលបើមានហេតុយ៉ាងនេះហើយ ពាក្យរបស់ព្រះអង្គជាពាក្យកុហកទទេ ។ ម្នាលភារទ្វាជៈ បុគ្គលណាកាលដែលគេសួរថា ទេវតាមានមែនឬទេដូច្នេះ គប្បីពោលថា ទេវតាមានមែនដូច្នេះក្តី មួយទៀតបុគ្គលណាពោលថា ទេវតា យើងដឹងតាមហេតុពិត ទេវតាយើងដឹងច្បាស់ហើយដូច្នេះក្តី ។ ពាក្យណាថា ទេវតាមានដូច្នេះ មានតែវិញ្ញូបុរស ទើបអាចដល់នូវសេចក្តីចូលចិត្តតាមពិត ក្នុងពាក្យនុ៎ះឯង ។ ចុះព្រោះហេតុអ្វី បានជាព្រះគោតមដ៏ចម្រើន មិនដោះស្រាយតាមបទខាងដើមដល់ខ្ញុំព្រះអង្គ ។ ម្នាលភារទ្វាជៈ ព្រោះថាពាក្យណាថា ទេវតាមានដូច្នេះ ពាក្យនុ៎ះគេសន្មត ដោយសព្ទដ៏ខ្ពស់ ក្នុងលោក ។

ព្រាហ្មណវគ្គស្ស សគារវសុត្តេ តិសរណគមនំ

[១៧៦] ឯវំ វុត្តេ សគារវោ មាណវោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច

[១៧៦] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សគារវមាណព ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ប្រៀបដូចបុគ្គល ផ្ងារឡើងនូវរបស់ដែលគេផ្កាប់ទុក ឬបើកឡើងនូវរបស់ដែលគេបិទបាំង ឬប្រាប់ផ្លូវដល់បុគ្គលវង្វេងផ្លូវ ពុំនោះសោត ដូចគេទ្រោលនូវប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុ រមែងមើលឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ឯធម៌ដែលព្រះគោតមដ៏ចម្រើន បានសំដែងហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះឯង ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើន ទាំងព្រះធម៌

ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

សគារវសុត្តំ ទសមំ និដ្ឋិតំ ។

ព្រាហ្មណវគ្គោ បញ្ចមោ ។

តស្ស វគ្គស្ស ឧទ្ទានំ

ព្រហ្មាយុ សេលស្ស លាយនោ
ឃោដមុខោ ច ព្រាហ្មណោ
ឯសុការី ធនញ្ជានី
វាសេដ្ឋោ សុភគារវោ ។

មជ្ឈិមបណ្ណាសកំ សមត្តំ ។

ទាំងព្រះភិក្ខុសង្ឃ ថាជាទីពឹងទីរឭក សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវព្រះរត្នត្រ័យជាទីពឹង ទីរលឹកស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

ចប់ សគារវសូត្រ ទី ១០ ។

ចប់ ព្រាហ្មណវគ្គ ទី ៥ ។

## ឧទ្ទាននៃវគ្គនោះ ដូច្នេះគឺ

រឿងព្រហ្មាយុព្រាហ្មណ៍ ១ សេលព្រាហ្មណ៍ ១ អស្សលាយនមាណព ១ ឃោដមុខព្រាហ្មណ៍ ១ ចង្កីព្រាហ្មណ៍ ១ ឯសុការីព្រាហ្មណ៍ ១ ធនញ្ជានីព្រាហ្មណ៍ ១ វាសេដ្ឋមាណព ១ សុភមាណព ១ សគារវមាណព ១ ។

ចប់ មជ្ឈិមបណ្ណាសកៈ ។

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

# មជ្ឈិមបណ្ណាសកំ

# ឆដ្ឋោ ភាគោ

# ព្រាហ្មណវគ្គោ

## បឋមំ ព្រហ្មាយុសុត្តំ


| | | អង្កេ |
|---|---|---|
| ព្រាហ្មណវគ្គស្ស ព្រហ្មាយុសុត្តេ | *ឧត្តរាមន្តនំ*........................................ | ២ |
| | *ឧត្តរស្ស ភគវន្តូបសង្កមនំ*.................. | ៥ |
| | *ភគវន្តានុពន្ធនំ*.................................... | ៧ |
| | *មហាបុរិសលក្ខណានិ*........................ | ៨ |
| | *ព្រហ្មាយុស្ស ឧទានំ*.......................... | ១៩ |
| | *អញ្ញាតរាមន្តនំ*.................................... | ២១ |
| | *ភគវន្តូបសង្កមនំ*................................ | ២៣ |
| | *ភគវតោ បរិវិតក្កនំ*............................ | ២៧ |
| | *ភគវន្តំ បញ្ហាបុច្ឆនំ*.......................... | ២៨ |
| | *អនុបុព្វីកថាកថនំ*.............................. | ៣១ |

# សុត្តន្តបិដក មជ្ឈិមនិកាយ

# មជ្ឈិមបណ្ណាសកៈ

# ឆដ្ឋភាគ

# ព្រាហ្មណវគ្គ

# ព្រហ្មាយុសូត្រ ទី ១

លេខទំព័រ


ព្រាហ្មណវគ្គ ព្រហ្មាយុសូត្រ *ការហៅរកឧត្តរមាណព*................................ ២

*ឧត្តរមាណពចូលទៅគាល់ព្រះមានព្រះភាគ* ៥

*ការដើរដាប់តាមព្រះមានព្រះភាគ*................ ៧

*ព្រះមហាបុរិសលក្ខណ*................................ ៨

*ឧទានរបស់ព្រហ្មាយុព្រាហ្មណ៍*..................... ១៩

*ការហៅមាណពម្នាក់*.................................... ២១

*ការចូលទៅគាល់ព្រះមានព្រះភាគ*............... ២៣

*ការត្រិះរិះរបស់ព្រះមានព្រះភាគ*.................. ២៧

*ការសួរប្រស្នាចំពោះព្រះមានព្រះភាគ*........... ២៨

*ទ្រង់សំដែងអនុបុព្វីកថា*................................ ៣១

# មាតិកាបត្តានិ

អង្កេ

| | | | |
|---|---|---|---|
| ព្រាហ្មណវគ្គស្ស | ព្រហ្មាយុសុត្តេ | *ព្រហ្មាយុស្ស និវេសនូបសង្កមនំ..........* | *៣៣* |
| | | *ព្រហ្មាយុស្ស គតិព្យាករណំ................* | *៣៤* |

## ទុតិយំ សេលសុត្តំ

| | | | |
|---|---|---|---|
| ព្រាហ្មណវគ្គស្ស | សេលសុត្តេ | *ភគវន្តូបសង្កមនំ .................................* | *៣៧* |
| | | *ភគវតោ អធិវាសនា............................* | *៣៩* |
| | | *ទុល្លភឃោសោ....................................* | *៤១* |
| | | *សេលស្ស ភគវន្តូបសង្កមនំ.................* | *៤៣* |
| | | *ភគវតោ បរិវិតក្កនំ..............................* | *៤៥* |
| | | *ភគវន្តាភិត្ថុតិ........................................* | *៤៦* |
| | | *កេណិយស្សមូបសង្កមនំ .....................* | *៥១* |
| | | *សេលស្ស ភគវន្តូបសង្កមនំ................* | *៥៣* |
| | | *ភគវន្តប្បសំសា ...................................* | *៥៤* |

## តតិយំ អស្សលាយនសុត្តំ

| | | | |
|---|---|---|---|
| ព្រាហ្មណវគ្គស្ស | អស្សលាយនសុត្តេ | *អស្សលាយនូបសង្កមនំ ......................* | *៥៧* |
| | | *ភគវន្តូបសង្កមនំ...................................* | *៥៩* |

# សន្ទឹកចង្អុលច្រាប់មាតិកា

លេខទំព័រ

ព្រាហ្មណវគ្គ ព្រហ្មាយុសូត្រ *ទ្រង់ចូលទៅកាន់ផ្ទះរបស់ព្រហ្មាយុព្រាហ្មណ៍* ................................ ៣៣

*ការព្យាករគតិរបស់ព្រហ្មាយុព្រាហ្មណ៍*..... ៣៤

## សេលសូត្រ ទី ២

ព្រាហ្មណវគ្គ សេលសូត្រ *ការចូលទៅគាល់ព្រះមានព្រះភាគ* ........... ៣៧

*ការទទួលនិមន្តន៍នៃព្រះមានព្រះភាគ*....... ៣៩

*សូរសំឡេងដែលរកបានដោយក្រ* ............ ៤១

*សេលព្រាហ្មណ៍ចូលទៅគាល់ព្រះមានព្រះភាគ* .................................................. ៤៣

*ព្រះតម្រិះរបស់ព្រះមានព្រះភាគ* ............. ៤៥

*ការពោលសរសើរព្រះមានព្រះភាគ*.......... ៤៦

*ទ្រង់ចូលទៅកាន់អាស្រមរបស់កេណិយជដិល* ៥១

*សេលភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ*.. ៥៣

*ការពោលសរសើរព្រះមានព្រះភាគ*.......... ៥៤

## អស្សលាយនសូត្រ ទី ៣

ព្រាហ្មណវគ្គ អស្សលាយនសូត្រ *ការចូលទៅរកអស្សលាយនមាណព* ..... ៥៧

*ការចូលទៅគាល់ព្រះមានព្រះភាគ* ........... ៥៩

# មាតិកាបត្តានិ


អង្កេ

ព្រាហ្មណវគ្គស្ស អស្សលាយនសុត្តេ *អកុសលកម្មបថា* ............................ ៦១

*មេត្តចិត្តភាវនា* .................................. ៦៥

*សិនាទានូបមា*.................................... ៦៧

*អគ្យាភិនិព្វត្តូបមា*............................... ៦៨

*ព្រាហ្មណកញ្ញាសំវាសូបមា*................. ៧១

*វលវាសម្បយោជនូបមា*....................... ៧៣

*ភូតបុព្វកថា*...................................... ៧៥


## ចតុត្ថំ ឃោដមុខសុត្តំ


ព្រាហ្មណវគ្គស្ស ឃោដមុខសុត្តេ *ចត្តារោ បុគ្គលា*................................. ៨៥

*ទ្វេ បរិសា*......................................... ៨៩

*បឋមបុគ្គលោ* .................................... ៩១

*ទុតិយបុគ្គលោ* .................................. ៩៥

*តតិយបុគ្គលោ* .................................. "

*ចតុត្ថបុគ្គលោ* ................................... ៩៧

*សិក្ខាសាជីវសមាបន្នតា*....................... ៩៩

# សង្ខឹកចង្អុលប្រាប់មាតិកា

លេខទំព័រ

ព្រាហ្មណវគ្គ អស្សលាយនសូត្រ *អកុសលកម្មបថ*................................ ៦១

*ការចម្រើនមេត្តាចិត្ត*.............................. ៦៥

*ឧបមាដោយការកាន់យកនូវគ្រឿងលំអិត* ៦៧

*ឧបមាដោយការបង្កាត់ភ្លើង*.................. ៦៨

*ឧបមាដោយការនៅរួមជាមួយនឹងព្រាហ្មណ-*

*កញ្ញា*.................................................. ៧១

*ឧបមាដោយការបង្កាត់សេះនឹងបាលា* . ៧៣

*ទ្រង់ដំណាលរឿងព្រេង*...................... ៧៥

# ឃោដមុខសូត្រ ទី ៤

ព្រាហ្មណវគ្គ ឃោដមុខសូត្រ *បុគ្គល ៤ ពួក*..................................... ៨៥

*បរិស័ទ ២ ពួក*.................................. ៨៩

*បុគ្គលទីមួយ*....................................... ៩១

*បុគ្គលទីពីរ*......................................... ៩៥

*បុគ្គលទីបី*.......................................... "

*បុគ្គលទីបួន*........................................ ៩៧

*ការបរិបូរដោយសិក្ខានិងសាជីវៈ* .......... ៩៩

# មាតិកាបត្តានិ


| | | អង្កេ |
|---|---|---|
| ព្រាហ្មណវគ្គស្ស ឃោដមុខសុត្តេ | ឥន្ទ្រិយសំវរោ ...................................... | ១០៣ |
| | ចតុរូបដ្ឋានំ ........................................ | ១០៥ |
| | បុព្វេនិវាសានុស្សតិញ្ញាណំ.................. | ១០៦ |
| | ចុតូបបាតញ្ញាណំ................................ | ១០៧ |
| | អាសវក្ខយញ្ញាណំ .............................. | ១០៩ |
| | ឃោដមុខស្ស សរណគមនំ ................ | ១១១ |
| | សង្ឃសាលាការាបនំ............................ | ១១២ |


## បញ្ចមំ ចង្កីសុត្តំ


| | | |
|---|---|---|
| ព្រាហ្មណវគ្គស្ស ចង្កីសុត្តេ | ពុទ្ធគុណប្បសំសា.............................. | ១១៥ |
| | ចង្កិប្បសំសា ....................................... | ១១៩ |
| | ភគវន្តវណ្ណកថា ................................. | ១២១ |
| | ភគវន្តអប្បសាទនំ.............................. | ១២៧ |
| | កាបទិកប្បដិបុច្ឆា ............................... | ១២៩ |
| | សច្ចានុបត្តិព្យាករណំ .......................... | ១៣៣ |
| | សច្ចានុរក្ខណព្យាករណំ....................... | ១៤១ |
| | ពហុការធម្មព្យាករណំ......................... | ១៤៣ |
| | តិសរណគមនំ .................................... | ១៤៧ |

# សង្ខឹកាចង្អុលប្រាប់មាតិកា

លេខទំព័រ


ព្រាហ្មណវគ្គ ឃោដមុខសូត្រ *ការសង្រួមឥន្ទ្រិយ....................................* ១០៣

*រូបជ្ឈានបួន.............................................* ១០៥

*បុព្វេនិវាសានុស្សតិញ្ញាណ........................* ១០៦

*ចុតូបបាតញ្ញាណ.....................................* ១០៧

*អាសវក្ខយញ្ញាណ...................................* ១០៩

*ឃោដមុខព្រាហ្មណ៍ដល់នូវសរណៈ.........* ១១១

*ឲ្យឃោដមុខព្រាហ្មណ៍ធ្វើសាលាសម្រាប់សង្ឃ* ១១២


## ចង្កីសូត្រ ទី ៥


ព្រាហ្មណវគ្គ ចង្កីសូត្រ *សេចក្តីសរសើរពុទ្ធគុណ...........................* ១១៥

*សេចក្តីសរសើរចង្កីព្រាហ្មណ៍ ..................* ១១៩

*ពោលសរសើរព្រះមានព្រះភាគ .............* ១២១

*ព្រះមានព្រះភាគទ្រង់ឃាត់កាបទិកមាណព* ១២៧

*ទ្រង់សួរតបទៅកាបទិកមាណព ..............* ១២៩

*ទ្រង់ព្យាករនូវការរក្សាសច្ចៈ......................* ១៣៣

*ទ្រង់ព្យាករនូវការកើតឡើងនៃសច្ចៈ .........* ១៤១

*ទ្រង់ព្យាករនូវធម៌មានឧបការៈច្រើន .........* ១៤៣

*កាបទិកមាណពដល់នូវត្រៃសរណៈ.........* ១៤៧

# មាតិកាបត្តានិ

## ឆដ្ឋំ ឯសុការីសុត្តំ


អង្កេ

ព្រាហ្មណវគ្គស្ស ឯសុការីសុត្តេ *បារិចរិយកថា*........................................ ១៤៩

*សទ្ធនកថា*............................................. ១៥៥

*កុសលាវាធកភាវោ*................................. ១៥៩


## សត្តមំ ធនញ្ជានិសុត្តំ


ព្រាហ្មណវគ្គស្ស ធនញ្ជានិសុត្តេ *ធនញ្ជានិប្បវុត្តិបុច្ឆនំ* ............................ ១៧១

*ធនញ្ជានិឧបសង្កមនំ* ........................... ១៧៣

*អធម្មចរិយវិសមចរិយា* ........................ ១៧៥

*ធនញ្ជានិប្បដិបុច្ឆា*............................... ១៨១

*ពាឡ្ហទុក្ខាវោចនំ*................................. ១៩១

*ធនញ្ជានិប្បដិបុច្ឆា* .............................. ១៩៧

*អប្បមញ្ញាភាវនា*.................................. ១៩៩

*ភគវន្តូបសង្កមនំ*.................................. ២០១

# សង្ខឹកចង្អុលច្រាប់មាតិកា

# ឯសុការីសូត្រ ទី ៦

លេខទំព័រ

ព្រាហ្មណវគ្គ ឯសុការីសូត្រ *ទ្រង់សំដែងនូវការបម្រើ......................... ១៤៩*

*សំដែងអំពីទ្រព្យសម្រាប់ខ្លួន................ ១៥៥*

*ភាពនៃបុគ្គលត្រេកអរនឹងកុសលធម៌.... ១៥៩*

# ធនញ្ជានិសូត្រ ទី ៧

ព្រាហ្មណវគ្គ ធនញ្ជានិសូត្រ *ការសួរដំណឹងធនញ្ជានិព្រាហ្មណ៍ ....... ១៧១*

*ការចូលទៅរកធនញ្ជានិព្រាហ្មណ៍ ....... ១៧៣*

*ការប្រព្រឹត្តខុសធម៌និងការប្រព្រឹត្តមិនស្មើ ១៧៥*

*ការសួរតបទៅធនញ្ជានិព្រាហ្មណ៍........ ១៨១*

*ការប្រាប់នូវសេចក្ដីទុក្ខជាទម្ងន់............. ១៩១*

*ការសួរតបទៅធនញ្ជានិព្រាហ្មណ៍........ ១៩៧*

*អប្បមញ្ញាភាវនា.................................. ១៩៩*

*ការចូលទៅគាល់ព្រះមានព្រះភាគ....... ២០១*

# មាតិកាបត្តានិ

## អដ្ឋមំ វាសេដ្ឋសុត្តំ

| | | អង្កេ |
|---|---|---|
| ព្រាហ្មណវគ្គស្ស វាសេដ្ឋសុត្តេ | ភគវន្តូបសង្កមនំ ................................ | ២០៥ |
| | ព្រាហ្មណប្បញ្ហា ................................ | ២០៦ |
| | ព្រាហ្មណព្យាករណំ ........................... | ២០៨ |

## នវមំ សុភសុត្តំ

| | | |
|---|---|---|
| ព្រាហ្មណវគ្គស្ស សុភសុត្តេ | ចតុកម្មដ្ឋានំ ....................................... | ២២៧ |
| | បញ្ចធម្មប្បញ្ញត្តិ ................................ | ២៣១ |
| | ជច្ចន្ធូបមា ............................................ | ២៣៧ |
| | សុភមាណវប្បដិបុច្ឆា .......................... | ២៤១ |
| | កាមគុណកថា .................................... | ២៤២ |
| | ឈានកថា .......................................... | ២៤៥ |
| | សុភមាណវប្បដិបុច្ឆា........................... | ២៤៦ |
| | សុភមាណវវិសជ្ជនា ............................ | ២៤៨ |
| | មគ្គប្បដិបុច្ឆា........................................ | ២៥១ |
| | អប្បមញ្ញាកថា ................................... | ២៥៣ |
| | ជាណុស្សោណិស្ស សុភទស្សនំ.......... | ២៥៧ |

# សង្ខេបរឿងចង្អុលប្រាប់មាតិកា

## វាសេដ្ឋសូត្រ ទី ៨

លេខទំព័រ

ព្រាហ្មណវគ្គ វាសេដ្ឋសូត្រ *ការចូលទៅគាល់ព្រះដ៏មានព្រះភាគ* ............ ២០៥
*បញ្ហារបស់ព្រាហ្មណ៍* .................................. ២០៦
*ការព្យាករនូវពាក្យថាព្រាហ្មណ៍* .................. ២០៨

## សុភសូត្រ ទី ៩

ព្រាហ្មណវគ្គ សុភសូត្រ *ហេតុជាទីតាំងនៃការងារ ២ យ៉ាង* .................. ២២៧
*ការបញ្ញត្តធម៌ ៥ យ៉ាង* ................................ ២៣១
*ឧបមាដោយបុរសខ្វាក់ពីកំណើត* .................. ២៣៧
*ការសួរតបទៅសុភមាណព* ............................ ២៤១
*សំដែងអំពីកាមគុណ* .................................... ២៤២
*សំដែងអំពីឈាន* ........................................... ២៤៥
*ការសួរតបទៅសុភមាណព* ............................ ២៤៦
*ការដោះស្រាយរបស់សុភមាណព* ................. ២៤៨
*ការសួររកផ្លូវ* .................................................. ២៥១
*សំដែងអំពីអប្បមញ្ញា* .................................... ២៥៣
*ជាណុស្សោណិព្រាហ្មណ៍ជួបនឹងសុភមាណព* ២៥៧

# មាតិកាបត្តានិ

## ឧសមំ សគារវសុត្តំ

អង្កេ

ព្រាហ្មណវគ្គស្ស សគារវសុត្តេ សគារវូបសង្កមនំ................................ ២៦១
សមណព្រាហ្មណានំ វេមត្ត-
ព្យាករណំ.......................................... ២៦៣
ភូតបុព្វកថា........................................ ២៦៥
អាឡារូបសង្កមនំ ................................ ២៦៧
ឧទ្ទកូបសង្កមនំ.................................... ២៦៩
បឋមូបមា........................................... ២៧៥
ទុតិយូបមា.......................................... ២៧៧
តតិយូបមា.......................................... ២៧៩
ទុក្ខប្បធានំ .......................................... ២៨១
អប្បានកជ្ឈានំ..................................... ២៨៣
ថោកាហារាហរណំ ............................. ២៨៩
ចតុរូបជ្ឈានំ........................................ ២៩២
ចុតូបបាតញ្ញាណំ................................. ២៩៧
កតវន្តប្បសំសា ................................... ២៩៩
តិសរណគមនំ .................................... ៣០១

# សន្ទឹកចង្អុលប្រាប់មាតិកា
# សគារវសូត្រ ទី ១០

លេខទំព័រ


| | | |
|---|---|---|
| ព្រាហ្មណវគ្គ សគារវសូត្រ | ការចូលទៅរកសគារវមាណព............. | ២៦១ |
| | ការទ្រង់ព្យាករនូវសេចក្តីផ្សេងគ្នានៃពួកសមណៈនិងព្រាហ្មណ៍........................ | ២៦៣ |
| | សំដែងអំពីរឿងធ្លាប់មានមក............... | ២៦៥ |
| | ទ្រង់ចូលទៅរកអាឡារតាបស.............. | ២៦៧ |
| | ទ្រង់ចូលទៅរកឧទ្ទកតាបស ............... | ២៦៩ |
| | ឧបមា ទី ១ ...................................... | ២៧៥ |
| | ឧបមា ទី ២ ..................................... | ២៧៧ |
| | ឧបមា ទី ៣ .................................... | ២៧៩ |
| | សេចក្តីព្យាយាមដ៏លំបាក.................... | ២៨១ |
| | អប្បានកជ្ឈាន.................................... | ២៨៣ |
| | ការសោយអាហារតិច.......................... | ២៨៩ |
| | រូបជ្ឈាន ៤......................................... | ២៩២ |
| | ចុតូបបាតញ្ញាណ................................ | ២៩៧ |
| | ការសរសើរព្រះមានព្រះភាគ.............. | ២៩៩ |
| | ការដល់នូវត្រៃសរណៈ........................ | ៣០១ |

